# បញ្ញា

# ប្រវត្តិពុទ្ធានុពុទ្ធ

## ប្រវត្តិព្រះពុទ្ធនិងពុទ្ធសាវ័ក ជំនួយដល់ការសិក្សាធម្មវិន័យ



ចម្លងដោយ

**បណ្ណាគារ ត្រៃរតន៍**

លេខ ១៣៦ អ៊ី០ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស. ២៥៤៥ គ.ស. ២០០១

www.elibraryofcambodia.org

អំណោយពី លោក ខៀវ ឃុន សំរ៉ង់ ជាអ្នកប្រគល់ជូន ដើម្បីទុកដាក់ក្នុង elibrary of Cambodia កក្កដា 2015

# បញ្ញា

# ប្រវត្តិពុទ្ធានុពុទ្ធ

## ប្រវត្តិព្រះពុទ្ធនិងពុទ្ធសាវ័ក
## ជំនួយដល់ការសិក្សាធម្មវិន័យ

ថ្នាក់ទោ-ឯក


ប្រមូលរៀបរៀងដោយ

សែម-សូរ

សញ្ញាប័ត្រពុទ្ធិកឧត្តមសិក្សាបឋមភូមិ ១៩៦៣
បរិញ្ញាប័ត្រអក្សរសាស្ត្រ ១៩៦៩



លេខ១៣៦អឺ០ វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ព.ស ២៥៤៥ គ.ស២០០១



www.elibraryofcambodia.org

# បញ្ហា
# ប្រវត្តិពុទ្ធានុពុទ្ធ

---

## ភាគទី ១

## បុព្វប្រវត្តិ

ខ្ញុំព្រះករុណា សូមនមស្ការគុណកែវទាំង ៣ គឺ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដោយសេចក្តីគោរព

តទៅខ្ញុំព្រះករុណា ខ្ញុំបាទ សូមលើកយកនូវប្រវត្តិរបស់ព្រះសម្មាសម្ពុទ្ធជាព្រះបរមគ្រូនៃមនុស្ស និងទេវតា ព្រមទាំងប្រវត្តិរបស់ព្រះអរហន្តជាពុទ្ធសាវ័ក ដែលបានជួយបំពេញពុទ្ធសកម្មយ៉ាងច្រើន មកបរិយាយជាលំដាប់លំដោយតរៀងទៅ ។

សំនួរ - ពុទ្ធប្រវត្តិ គឺអ្វី ?

ចម្លើយ - ពុទ្ធប្រវត្តិ គឺរឿងរ៉ាវផ្សេងៗ របស់ព្រះសម្មាសម្ពុទ្ធ ដែលជាអ្នកត្រាស់ដឹងធម៌ទាំងពួង ដោយគ្មានទើសទាក់ត្រង់កន្លែងណាឡើយ ។

ស- ចុះអនុពុទ្ធប្រវត្តិ គឺអ្វីដែរ ?

ច- អនុពុទ្ធប្រវត្តិ គឺប្រវត្តិរបស់សាវ័កនៃព្រះសម្មាសម្ពុទ្ធនេះឯង ។

www.elibraryofcambodia.org

ស. ព្រះពុទ្ធ និង ព្រះអនុពុទ្ធ មានការទាក់ទងគ្នាយ៉ាងណា ? ចូរពន្យល់ !

ឆ. ព្រះពុទ្ធ និងអនុពុទ្ធ មានការទាក់ទងគ្នាយ៉ាងជិតស្និទ្ធណាស់ ព្រោះថាកាលព្រះពុទ្ធទ្រង់បានត្រាស់ដឹងហើយ ព្រះអង្គមានព្រះបំណងធំបំផុត គឺការយោងប្រោសសត្វលោកនេះឯង កាលទ្រង់យោងសំដែងធម៌វិន័យនេះ មានពួកជនក្នុងត្រកូលផ្សេងៗ ចូលមកស្តាប់ធម៌ហើយបានយល់ចេះដឹងស្គាល់នូវព្រះពុទ្ធោវាទទាំងនោះហើយ ជនខ្លះក៏នាំគ្នាចូលមកបួសហើយបានសម្រេចមគ្គផលតាមឧបនិស្ស័យរបស់ខ្លួន បានជាព្រះអរហន្តសាវ័ករបស់ព្រះសម្មាសម្ពុទ្ធនេះឯង ។

ព្រះសម្មាសម្ពុទ្ធ ដែលទ្រង់បានត្រាស់ដឹងធម៌គ្រប់យ៉ាងហើយ តែបើគ្មានជនណាស្តាប់ ជឿ និងទទួលប្រតិបត្តិតាម ព្រះអង្គក៏គ្មានសកម្មភាពទៅកើតដែរ បានសេចក្តីថា ការត្រាស់ដឹងធម៌របស់ព្រះអង្គជាការឥតប្រយោជន៍ ។ ចំណែកខាងពួកសាវ័កវិញ កាលបើគ្មានអង្គព្រះសម្មាសម្ពុទ្ធ ជាអ្នកដឹកនាំពន្យល់ឱ្យប្រព្រឹត្តប្រតិបត្តិទេ ក៏មិនអាចរកផ្លូវត្រូវស្វែងរកការយល់ចេះដឹងធម៌ទាំងពួងតាមព្រះអង្គបានឡើយ ។ ការទាក់ទងរវាងព្រះពុទ្ធ និង អនុពុទ្ធ មានបែបយ៉ាងនេះឯង ។

www.elibraryofcambodia.org

ស. ពាក្យថា ពោធិសត្វ និងពុទ្ធង្កុរ ដូចគ្នា ឬផ្សេងគ្នា ? ពាក្យទាំងពីរនេះមានន័យយ៉ាងណា ? ចូរពន្យល់ !

ច. ពាក្យថា ពោធិសត្វ និងពុទ្ធង្កុរ បើនិយាយពីន័យគឺដូចគ្នា បានសេចក្តីថា ពោធិសត្វ : គឺសត្វដែលកសាងបារមី ដើម្បីបានត្រាស់ជាព្រះពុទ្ធ ។ ឯពុទ្ធង្កុរក៏ដូច្នោះដែរ គឺជនដែលជាពន្លកដែលត្រូវបានកើត-ត្រាស់ដឹងជាព្រះពុទ្ធ ។ ដូច្នេះពាក្យទាំងពីរនេះ សម្រាប់ហៅចំពោះជនតែម្នាក់ ដែលបានបំពេញបារមី ដើម្បីបានត្រាស់ជាព្រះពុទ្ធនេះឯង ។

ស. ចុះពាក្យថា ពុទ្ធភូមិ បានដល់អ្វី ? មានប៉ុន្មានយ៉ាង? អ្វីខ្លះ ?

ច. ពុទ្ធភូមិ គឺកន្លែង ឬស្ថានដែលព្រះពោធិសត្វរាល់អង្គទ្រង់យោនយកកំណើត សាងបារមី ដើម្បីបានត្រាស់ជាព្រះពុទ្ធ ។ ពុទ្ធភូមិនេះមាន ៣ យ៉ាង គឺ :

១. **បញ្ញាធិក**.. ការសាងបារមីដោយយកប្រាជ្ញាជាធំ ។

២. **សទ្ធាធិក**.. ការសាងបារមីដោយយកជំនឿជាធំ ។

៣. **វិរិយាធិក**.. ការសាងបារមីដោយយកព្យាយាមជាធំ ។

គួរកត់ចំណាំថា ព្រះពុទ្ធបរមគ្រូនៃយើងទ្រង់សាងបារមី

www.elibraryofcambodia.org

ក្នុងបញ្ញាធិកមានរយៈពេល អសង្ខេយ្យ និង ១ សែនកប្ប ទើបបានត្រាស់ជាព្រះពុទ្ធ ។ ចំណែកភូមិដទៃទៀត មានរយៈវេលាវែងជាងនេះ ។

ស- ចុះ បារមី បានដល់អ្វី ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

ច- បារមី បានដល់គុណធម៌ជាគ្រឿងនាំសត្វឱ្យដល់នូវត្រើយនៃសេចក្ដីសម្រេច ឬ ដល់ត្រើយព្រះនិព្វាន ។ បារមីមាន ៣០ គឺ ១- ទាន, ២- សីល, ៣- នេក្ខម្ម, ៤- បញ្ញា, ៥- វីរិយ, ៦- ខន្តី, ៧- សច្ច, ៨- អធិដ្ឋាន, ៩- មេត្តា, ១០- ឧបេក្ខា ។ ក្នុងបារមីមួយៗ នេះចែកជា ៣ ដូចគ្នាទាំង ១០ ដូចជាទានចែកជា ៣ គឺ ទានបារមី ១, ទានឧបបារមី ១, ទានបរមត្ថបារមី ១ រួមទាំងអស់ត្រូវជា ៣០ បើរាប់តែឈ្មោះមាន ១០ ។

ស- ចុះពាក្យថា **មហាបរិច្ចាគ** បានដល់អ្វី ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

ច- ពាក្យថា **មហាបរិច្ចាគ** មានន័យថាការលះបង់ ឬការចំណាយដ៏ធំ ។ មហាបរិច្ចាគមាន ៥ យ៉ាងគឺ :

**១- អង្គបរិច្ចាគ.-** ការលះបង់អវៈយវៈជាអង្គកាយរបស់ខ្លួនឱ្យទៅជាទាន ។

**២- ធនបរិច្ចាគ.-** ការលះបង់ទ្រព្យសម្បត្តិឱ្យទៅជា

www.elibraryofcambodia.org

ទាន ។

៣. **បុត្តបរិច្ចាគៈ** ការលះបង់កូនប្រុសស្រីឱ្យទៅជាទាន ។

៤. **ធារបរិច្ចាគៈ** ការលះបង់ប្រពន្ធឱ្យទៅជាទាន ។

៥. **ជីវិតបរិច្ចាគៈ** ការលះបង់ជីវិតឱ្យទៅជាទាន ។

ស. ព្រះពោធិសត្វ បំពេញតែបារមី ៣០ មហាបរិច្ចាគ ៥ នេះទេ ឬមានបំពេញអ្វីផ្សេងទៀតដែរ ? បើមានតើឈ្មោះអ្វី មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

ច. មាន គឺទ្រង់បំពេញចរិយា ៣ ទៀត

១. **លោកត្ថចរិយា** ការប្រព្រឹត្តធ្វើប្រយោជន៍ដើម្បីលោក ។

២. **ញាតត្ថចរិយា** ការប្រព្រឹត្តធ្វើប្រយោជន៍ ដើម្បីពពួកញាតិ ។

៣. **ពុទ្ធត្ថចរិយា** ការប្រព្រឹត្តធ្វើប្រយោជន៍ ដើម្បីបានត្រាស់ដឹងជាព្រះពុទ្ធ ហើយយាងប្រោសសត្វ ។

ស. ក្នុងដំណើរសាងបារមីធម៌ ដើម្បីបានត្រាស់ជាព្រះពុទ្ធនេះ តើព្រះពោធិសត្វនៃយើងទ្រង់បានទូវព្យាករណ៍ ក្នុងសំណាក់ព្រះពុទ្ធអង្គណា កាលនោះព្រះអង្គយកកំណើតជាអ្វី ? បានធ្វើអ្វី

www.elibraryofcambodia.org

ព្យាករណ៍នោះថាយ៉ាងណា ?

ច. ព្រះពោធិសត្វនៃយើង, កាលចាប់ផ្ដើមសាងបារមីនោះ ទ្រង់បានជួបនិងបាននូវព្យាករណ៍អំពីសំណាក់ នៃព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះនាមទីបង្ករ ជាដំបូងបង្អស់ ។ កាលនោះ ព្រះពោធិសត្វនៃយើង ទ្រង់យកកំណើតក្នុងត្រកូលព្រាហ្មណ៍ ១ ឈ្មោះថា : សុមេធបណ្ឌិត ក្នុងនគរអមរវតី ជាត្រកូល ១ ដ៏ស្ដុកស្ដម្ភណាស់ ហើយសុមេធ បានរៀនចេះចប់ត្រៃវេទ ។ ពេលមួយសុមេធបណ្ឌិត កើតចិត្តសង្វេគ បានលះបង់ទ្រព្យសម្បត្តិចេញទៅសាងផ្នួសជាតាបសនៅហេមពាន្ត ហើយបានសម្រេចសមាបត្តិ ៨ និង អភិញ្ញា ៦ ក្នុងរវាង ៧ ថ្ងៃ ។

កាលនោះ ព្រះពុទ្ធទ្រង់ព្រះនាមទីបង្ករទ្រង់កើតឡើងក្នុងលោក គង់នៅសុទស្សនមហាវិហារ ក្នុងនគរអមរវតីនោះ ។ ថ្ងៃមួយ សុមេធតាបសបាននិមន្តចេញពីហេមពាន្ត ចូលទៅនគរអមរវតី ក៏បានឃើញមហាជនកំពុងនាំគ្នាធ្វើផ្លូវថ្វាយព្រះពុទ្ធទីបង្ករ និងសាវ័ក ដែលនឹងយាងចូលទៅក្នុងទីក្រុង ។ តាបសបានសាកសួររឿងហេតុសព្វគ្រប់ ក៏បានសុំទីថ្លុក ១ ដើម្បីធ្វើឱ្យបានល្អថ្វាយព្រះពុទ្ធ និងព្រះអរហន្តជាមួយគេដែរ ។ កាលតាបសកំពុងធ្វើ ព្រះសម្ពុទ្ធទីបង្ករ និងសាវ័កបាននិមន្តមកដល់ ។ ទីដែល

www.elibraryofcambodia.org

តាបសកំពុងធ្វើនោះ មិនទាន់បានហើយ។ ដោយគ្មានអ្វីនឹងថ្វាយព្រះសាស្តាយាងឆ្លងភក់ តាបសក៏ប្រះក្រាបខ្លួនសឹងសណ្តូកកាត់ទីថ្លុក រួចនិមន្តព្រះពុទ្ធ និងសាវ័កឱ្យយាងជាន់លើខ្លួន ឆ្លងថ្លុកនោះ ។ ព្រះសម្ពុទ្ធទីបង្ករ និងសាវ័ក ២ ម៉ឺនអង្គបានយាងជាន់លើខ្លួនតាបសឆ្លងរួច ទ្រង់បែរមកព្យាករណ៍ថា "សុមេធតាបសនេះពិតជានឹងបានត្រាស់ជាព្រះពុទ្ធ ១ អង្គនាម សមណគោតមក្នុងភទ្ទកប្បខាងមុខជាមិនខាន ក្នុងកាលអំណើះទៅ ៤ អសង្ខេយ្យ កម្រៃ ១ សែនកប្បទៀត" ។

សុមេធតាបសឮដូច្នោះ មានចិត្តត្រេកអរណាស់ ក៏ពិចារណារកឃើញនូវពុទ្ធការកធម៌ទាំង ៣០ ដោយចិត្តជ្រះថ្លាយ៉ាងខ្លាំង ។ ព្រះពុទ្ធទីបង្ករ និងសាវ័កបានបូជាផ្កាចំពោះសុមេធតាបស រួចយាងប្រទក្សិណ ហើយក៏យាងផុតទៅ ។ ពេលនោះព្រហ្មមហាព្រហ្មពីពាន់ត្រេកអរញាប់ញ័រ ថ្វាយពរសព្ទសាធុការយ៉ាងខ្លាំង ឯមហាជនក្នុងនគរ និងទេវតានានា ក៏បានថ្វាយផ្កាកម្រង និងសព្ទសាធុការពរចំពោះសុមេធតាបសគ្រប់គ្នា ដើម្បីប្រតិស្ឋអធិដ្ឋានសុំឱ្យសុមេធតាបស បានត្រាស់ជាព្រះពុទ្ធទៅអនាគតកាល ។

ស- តពីនោះមក តើព្រះពោធិសត្វនៃយើងទ្រង់បានជួប

www.elibraryofcambodia.org

នឹងព្រះសម្ពុទ្ធអង្គណាខ្លះ ? បានព្យាករណ៍ដែរឬទេ ?

ចៈ តពីព្រះពុទ្ធនាមទីបង្ករ ព្រះពោធិសត្វទ្រង់បានជួប នឹងព្រះពុទ្ធ ២៣ អង្គទៀតគឺ : កោណ្ឌញ្ញៈ១, សុមង្គល១, សុមន១, រេវត១, សោភិត១, អនោមទស្សី១, បទុម១, នារទ១, បទុមុត្តរ១, សុមេធ១, សុជាត១, បិយទស្សី១, អត្ថទស្សី១, ធម្មទស្សី១, សិទ្ធត្ថ១, តិស្ស១, បុស្ស១, វិបស្សី១, សិខី១, វេស្សភូ១, កកុសន្ធ១, កោនាគមន១, កស្សប១ ។ ក្នុងពុទ្ធកាលព្រះសម្ពុទ្ធទាំង ២៣ តមកទៀតនេះ ព្រះពោធិសត្វសុទ្ធតែបាននូវព្យាករណ៍ថា នឹងបានត្រាស់ជាព្រះពុទ្ធដូចគ្នាទាំងអស់ ។

សៈ ដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធ តើអ្នកប្រាថ្នាជាព្រះពុទ្ធនោះ ត្រូវប្រកបដោយអ្វី ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

ចៈ ដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធ បុគ្គលអ្នកសាងអភិនីហារជាដំបូង ត្រូវប្រកបដោយធម្មសមោធាន ៨ ប្រការគឺ :

**១- មនុស្សត្តំ**.- ភាពជាមនុស្ស[១] ។

**២- លិង្គសម្បត្តិ**.- ដល់ព្រមដោយភេទ គឺភេទប្រុស[២]

---

១- សត្វតិរច្ឆាន មាននាគ ជាដើម ឬអមនុស្ស មានទេវតាជាដើម ប្រាថ្នាពុទ្ធភូមិ ពុំបានសម្រេចឡើយ ។

២- ស្ត្រីភេទ ឬភេទខ្ទើយ ក៏ប្រាថ្នាពុទ្ធភូមិ ពុំបានសម្រេចដែរ ។

www.elibraryofcambodia.org

៣. **ហេតុ..** ប្រកបព្រមដោយហេតុ គឺមានឧបនិស្ស័យគួរនឹងបានសម្រេចព្រះអរហត្តផល ។

៤. **សត្ថារទស្សនំ..** បានជួបនឹងព្រះសាស្តាសម្មាសម្ពុទ្ធ[៣] ។

៥. **បព្វជ្ជា..** បានបួសក្នុងព្រះពុទ្ធសាសនា ឬបួសក្រៅព្រះពុទ្ធសាសនាជាតាបសបូសី ។

៦. **គុណសម្បត្តិ..** ដល់ព្រមដោយគុណធម៌មានឈានជាដើម ។

៧. **អធិការោ..** មានការកសាងដ៏ខ្ពង់ខ្ពស់ មានជីវិតបរិច្ចាគជាដើម ។

៨. **ឆន្ទតា..** មានការពេញចិត្តនឹងប្រាថ្នានូវប្រាជ្ញាសម្មាសម្ពោធិញ្ញាណ ។

ស. ចុះក្នុងពុទ្ធកាលនៃព្រះសម្មាសម្ពុទ្ធនាម កស្សប ព្រះពោធិសត្វនៃយើង ទ្រង់យោនយកកំណើតជាអ្វី ? បានធ្វើអ្វីខ្លះ ? បានព្យាករណ៍យ៉ាងណា ?

---

៣. បើព្រះពុទ្ធបរិនិព្វានហើយ ប្រាថ្នានូវពុទ្ធភូមិនឹងចេតិយ ឬគល់ពោធិព្រឹក្ស ក៏ពុំបានសម្រេចដែរ ។

www.elibraryofcambodia.org

ច. ព្រះពោធិសត្វនៃយើង ទ្រង់យកកំណើតកើតជាជោតិបាលមាណព ជាអ្នកចេះចាំត្រៃវេទយ៉ាងស្ទាត់ជំនាញ ។ ពេលមួយជោតិបាលមាណព បានចូលទៅគាល់ព្រះសាស្តានាមកស្សប ជាមួយឃដិការជាសម្លាញ់ បានស្តាប់ធម្មកថា ហើយក៏បួសក្នុងសំណាក់ព្រះសាស្តាអង្គនោះ បានរៀនព្រះត្រៃបិដកចេះចាំហើយមានវត្តិប្រតិបត្តិយ៉ាងល្អ ។ ព្រះពុទ្ធទ្រង់នាមកស្សបៈ ទ្រង់ធ្វើព្យាករណ៍ថា "ភិក្ខុនេះនឹងបានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ នាមសមណគោតមមិនខានឡើយ" ។

ស. ចុះកាលជោតិបាលភិក្ខុបានធ្វើមរណកាលទៅ តើទៅកើតជាអ្វីទៀត ?

ច. កាលជោតិបាលភិក្ខុ ធ្វើមរណកាលទៅ បានទៅកើតក្នុងភពតូច ធំជាច្រើនជាតិ លុះដល់ជាតិទី ២ ជាមនុស្សជាតិ មុនពេលបានត្រាស់ដឹងជាព្រះពុទ្ធនេះ ព្រះពោធិសត្វនៃយើងទ្រង់យកកំណើតជារាជបុត្រនៃព្រះបាទស្រីសញ្ជ័យ និងព្រះនាងសុបារសុប្បតី នៅនគរជេតុត្តរ មាននាមថា "វេស្សន្តរ" ។ កាលបានសោយរាជ្យហើយ ព្រះវេស្សន្តរ ធ្វើទានបារមីយ៉ាងខ្លាំងក្លា រួចក៏បានទៅបួសជាតាបសនៅគីរីវង្កត បានបរិច្ចាគជាលីក្រស្នា រាជបុត្រាបុត្រី និងព្រះនាងមទ្រីឱ្យទៅជាទានថែមទៀត ។ ដោយ

www.elibraryofcambodia.org

តេជៈទានបារមីនេះ អាចបណ្ដាលឱ្យក្រឡាមហាប្រឹថពីរកម្រើក ញាប់ញ័រខ្លាំង ដើម្បីថ្វាយសព្ទសាធុការពរចំពោះព្រះអង្គ ។

ស- ចុះកាលព្រះវេស្សន្តរសោយទិវង្គតទៅ បានកើតនៅស្ថានណាទៀត ? មានព្រះនាមថាដូចម្ដេច ? ព្រះជន្មប៉ុន្មាន ?

ច- កាលព្រះវេស្សន្តរ សោយទិវង្គតទៅ បានទៅកើតនៅស្ថានតុសិត ឈ្មោះថា "សន្តុសិតទេវបុត្ត" មានព្រះជន្មាយុ ៤ ពាន់ឆ្នាំទិព្វ (ត្រូវជា ៥៧ កោដិ ៦ លានឆ្នាំមនុស្សលោក) ។

☆

☆ ☆

www.elibraryofcambodia.org

# ភាគទី ២

## ប្រវត្តិនៃព្រះរាជវង្សព្រះពោធិសត្វ និងលក្ខណៈ នៃជនជាតិក្នុងជម្ពូទ្វីប ក្នុងបុរាណសម័យ

ស. ក្នុងជាតិដែលបានត្រាស់ដឹងជាព្រះពុទ្ធអង្គនោះ តើព្រះពោធិសត្វទ្រង់កើតនៅទីណា ? ក្នុងវង្សណា ? ឈ្មោះអ្វី ?

ច. ព្រះពោធិសត្វ ទ្រង់យកព្រះកំណើតនៅក្នុង ជម្ពូទ្វីប គឺ ប្រទេសនេប៉ាល់សព្វថ្ងៃនេះឯង នៅក្នុងសាក្យវង្សខាងព្រះបិតា និងកោលិយវង្សខាងព្រះមាតា ។

ស. ជម្ពូទ្វីប បានដល់ទីណាខ្លះ ? សព្វថ្ងៃនៅណា ?

ច. ជម្ពូទ្វីប បានដល់ប្រទេសនេប៉ាល់ និងប្រទេសឥណ្ឌាភាគខាងជើងនោះឯង ។

ស. ជម្ពូទ្វីបនេះ មានចែកជាប៉ុន្មានចំណែកដែរ ? អ្វីខ្លះ? ចូរពន្យល់មកមើល !

ច. មានចែកជា ២ ចំណែកគឺ ចំណែកខាងក្នុងហៅថា មជ្ឈិមជនបទ, ចំណែកខាងក្រៅហៅថា បច្ចន្តជនបទ ឬ បច្ចន្តប្បទេស ។ នៅក្នុងគម្ពីរវិន័យបិដកមហាវគ្គត្រង់ធម្មក្ខន្ធកៈ ប្រាប់កំណត់ព្រំដែន នៃមជ្ឈិមជនបទនោះដូចតទៅ :

www.elibraryofcambodia.org

១- ទិសបូព៌ា	រាប់ពីមហាសាលនគរចូលមក

២- ទិសអគ្នេយ៍	រាប់ពីស្ទឹងសលវតីចូលមក

៣- ទិសទក្សិណ	រាប់ពីស្ទឹងសេតកណ្ណិកនិគមមក

៤- ទិសបស្ចិម	រាប់ពីថូនគ្រាមចូលមក

៥- ទិសឧត្តរ	រាប់ពីភ្នំឧសីរទ្ធជៈចូលមក

ដែនដីដែលនៅខាងក្នុងព្រំខ័ណ្ឌសីមានេះហៅថា មជ្ឈិម-បទេស ឬ មជ្ឈិមជនបទ ។ ក្នុងមជ្ឈិមប្រទេសនេះ មានអាណា-ចក្រ ឬ រដ្ឋធំៗ ឬហៅថា មហាជនបទចំនួន ១៦ ដែលមាននៅក្នុងគម្ពីរអង្គុត្តរនិកាយតកនិបាត ត្រង់ឧបោសថសូត្រ មានឈ្មោះដូចតទៅ :

១- អង្គរដ្ឋ (ដែនអង្គៈ) រាជធានីឈ្មោះ ចម្បា

២- មគធរដ្ឋ រាជធានីឈ្មោះ រាជគ្រឹះ

៣- កាសិរដ្ឋ រាជធានីឈ្មោះ ពារាណសី

៤- កោសលរដ្ឋ រាជធានីឈ្មោះ សាវត្ថី

៥- វជ្ជីរដ្ឋ រាជធានីឈ្មោះ វេសាលី

៦- មល្លរដ្ឋ រាជធានីឈ្មោះ កុសាវតី

( មល្លរដ្ឋនេះក្រោយមកចែកជា ២ ក្រុងគឺ កុសិនារា និងបាវា)

៧- ចេតីរដ្ឋ រាជធានីឈ្មោះ សោត្ថិវតី

www.elibraryofcambodia.org

៨- វង្សរដ្ឋ រាជធានីឈ្មោះ កោសម្ពី

៩- កុរុរដ្ឋ រាជធានីឈ្មោះ ឥន្ទបត្ថ

១០- បញ្ចាលរដ្ឋ រាជធានីឈ្មោះ កម្ពិល:

១១- មច្ឆរដ្ឋ រាជធានីឈ្មោះ សាគល:

១២- សុរសេន រាជធានីឈ្មោះ មថុរា

១៣- អស្សករដ្ឋ រាជធានីឈ្មោះ ពោតលិ

១៤- អវន្តីរដ្ឋ រាជធានីឈ្មោះ ឧជ្ជេនី

១៥- គន្ធាររដ្ឋ រាជធានីឈ្មោះ តក្កសិលា

១៦- កម្ពោជរដ្ឋ រាជធានីឈ្មោះ ទ្វារក

រដ្ឋទាំង ១៦ នេះជារដ្ឋធំៗ មានឥទ្ធានុភាពច្រើន ។ ដទៃពីនេះមានរដ្ឋតូចៗ ឬមានឋាន:ត្រឹមតែជាជនបទប៉ុណ្ណោះចំនួន ៥ ទៀតគឺ :

១៧- សក្កជនបទ រាជធានីឈ្មោះ កបិលពស្តុ

១៨- កោលិយរដ្ឋ រាជធានីឈ្មោះ រាមគ្រាមនិងទេវទហ

១៩- ភគ្គរដ្ឋ រាជធានីឈ្មោះ សុំសុមារគីរ:

២០- វិទេហ: រាជធានីឈ្មោះ មិថិលា

២១- អង្គុត្តរាប: រាជធានីឈ្មោះ អាបណ:

រដ្ឋ ឬ ជនបទទាំង ៥ នេះ ជាដែនដីតូចៗ នៅចំណុះរដ្ឋ

www.elibraryofcambodia.org

ឯទៀត ហើយរដ្ឋខ្លះ[illegible]ទាជ្យ រដ្ឋខ្លះគ្រាន់តែមានត្រកូលធំៗ គ្រប់គ្រង[illegible] ។

នៅសម័យនោះ មានរដ្ឋ ២ ធំៗ ដែលមានឥទ្ធានុភាពខ្លាំងគឺ :

១. មគធរដ្ឋ ព្រះរាជានាមព្រះបាទពិម្ពិសារ, អជាតសត្រូវ

២. កោសលរដ្ឋ ព្រះរាជានាមព្រះបាទបសេនទិ, វិឌូឌុកៈ

រដ្ឋទាំងពីរនេះ កាលពីដើមមានឫទ្ធានុភាពស្មើគ្នា លុះក្រោយមកមគធរដ្ឋ មានជ័យជំនះលើកោសលរដ្ឋវិញ ។

ស. មនុស្សក្នុងជម្ពូទ្វីប គេចែកជាប៉ុន្មានប្រភេទដែរ ? អ្វីខ្លះ ? ប្រភេទនីមួយៗ មានមុខងារផ្សេងគ្នា ឬ ដូចគ្នា ?

ច. គេចែកជាវណ្ណៈមាន ៤ ផ្សេងគ្នាគឺ :

**១. វណ្ណៈព្រាហ្មណ៍.** ជាជនជាតិខ្ពង់ខ្ពស់ដែលគេជឿថាកើតពីព្រះឱស្ឋព្រហ្ម ។ វណ្ណៈនេះមានមុខងារខាងការបង្ហាត់បង្រៀន និងធ្វើពិធីផ្សេងៗ ក្នុងសាសនាព្រាហ្មណ៍ ហើយអាចសិក្សាគម្ពីរវេទនាជាដើមបាន ។

**២. វណ្ណៈក្សត្រ.** ជាជនជាតិដែលគេជឿថា កើតពីព្រះហស្តព្រហ្ម ។ វណ្ណៈនេះ មានភារៈមុខងារខាងការគ្រប់គ្រង

www.elibraryofcambodia.org

ប្រទេស និងរៀនសូត្រវិជ្ជាយុទ្ធសាស្ត្រសម្រាប់ការពារប្រទេស ។

៣. **វណ្ណៈវេស្សៈ**.. ជាជនជាតិដែលគេជឿថា កើតពីពោះព្រហ្ម. វណ្ណៈនេះ មានមុខងារខាងការធ្វើជំនួញ.ធ្វើស្រែចំការ ។

៤. **វណ្ណៈសូទ្រៈ**.. ជាជនជាតិដែលគេជឿថា កើតពីជើងព្រហ្ម ។ វណ្ណៈនេះមានមុខការខាងធ្វើការស៊ីឈ្នួលគេដោយកម្លាំងកាយ ។

ស. ព្រះសម្មាសម្ពុទ្ធទ្រង់សម្ភពក្នុងវណ្ណៈណា ? វង្សត្រកូលឈ្មោះអ្វី ? នៅទីណា?

ច. ព្រះសម្មាសម្ពុទ្ធទ្រង់សម្ភពក្នុងវណ្ណៈក្សត្រ សាក្យវង្សនៅ សក្កជនបទ ។

ស. សក្យវង្ស និងដែនសក្កៈនេះនៅឯណា ? មានប្រវត្តិនិយាយដូចម្តេចខ្លះ ? ចូរ និទានរៀបរាប់ដោយមានគ្រឿងអាង !

ច. ដែនសក្ក ជាដែនដី ១ ចំណែកក្នុងជម្ពូទ្វីប.មជ្ឈិមប្រទេសនៅពីខាងត្បូង ជិតភ្នំហេមពាន្ត (សព្វថ្ងៃនៅក្នុងប្រទេសនេប៉ាល់) ជានិវាសនដ្ឋាននៃពួកសាក្យវង្សនេះឯង ។ ក្នុងគម្ពីរបាលីយើងតែងឮជាញឹកញយ នូវព្រះបន្ទូលរបស់ព្រះពុទ្ធជាម្ចាស់ដែលតែងតែត្រាស់ថា "ខត្តិយោ ជាតិយា ភោតមោ ភោរគ្គន

www.elibraryofcambodia.org

សាក្យបុត្តោ សាក្យ កុលា បព្វជិតោ.- តថាគតជាក្សត្រដោយជាតិ ជាគោតមដោយគោត្រ ... ជាសាក្យបុត្រដោយត្រកូលចេញពីសាក្យត្រកូលហើយបួស" ។

ដូច្នេះយើងឃើញថា ព្រះអង្គជាក្សត្រប្រសូត្រនៅក្នុងសាក្យវង្ស ហើយជាគោតមគោត្រទៀត ។ សាក្យវង្សនេះនៅក្នុងដែនសក្ក ឬ សាក្យនេះឯង ។ តាមសេចក្តីក្នុងគម្ពីរ សុមង្គលា-វិលាសិនី ដែលជាគម្ពីរខាងពួកទក្ខិណនិកាយ និពន្ធដោយព្រះពុទ្ធឃោសាចារ្យ ដំណាលថា មហាក្សត្រដែលជាដើមសន្តតិវង្សនាមព្រះបាទ "មហាសម្មតៈ" (សោយរាជ្យក្នុងទីដទៃ មិនមានឈ្មោះប្រាកដ គឺមិនមែននៅក្នុងដែនសក្ករបស់សាក្យវង្សនេះទេ) ។ មហាក្សត្រ ដែលសោយរាជ្យតសន្តតិវង្សត១មកមានរាយព្រះនាមដូចតទៅ :

| | | |
|---|---|---|
| ព្រះមហាសម្មតៈ | មានឱរសនាម | រោជ. |
| ព្រះរោជ. | មានឱរសនាម | វររោជ |
| ព្រះវររោជ | មានឱរសនាម | កល្យាណៈ |
| ព្រះកល្យាណ | មានឱរសនាម | វរកល្យាណៈ |
| ព្រះវរកល្យាណ | មានឱរសនាម | មន្ធាតា |
| ព្រះមន្ធាតា | មានឱរសនាម | វរមន្ធាតា |

www.elibraryofcambodia.org

| | | |
|---|---|---|
| ព្រះវរមន្ធាតា | មានឱរសនាម | ឧបោសថ |
| ព្រះឧបោសថ | មានឱរសនាម | ចរៈ |
| ព្រះចរៈ | មានឱរសនាម | ឧបចរៈ |
| ព្រះឧបចរៈ | មានឱរសនាម | មហាទេវ |

តពីព្រះបាទមហាទេវៈមក មានមហាក្សត្រសោយរាជ្យចំនួន ទៅ ៨៤០០០ ព្រះអង្គ ទើបដល់ព្រះបាទ ឱក្កាករាជ ។

ព្រះបាទឱក្កាករាជនេះ ជាបឋមក្សត្រនៃសាក្យវង្ស ព្រះអង្គមានព្រះជាយា ៥ ព្រះអង្គគឺ : ភត្តា ១, ចិត្តា ១, ជន្តុ ១, ជាលិនី១ និងវិសាខា១ ។ ព្រះនាងភត្តាជាជាយាធំ (អគ្គមហេសី) មានរាជបុត្រ ៤ ព្រះអង្គគឺ ឱក្កាកមុខ១, ករកណ្ឌ១, ហត្ថិនិក១, សិនិបុរៈ១ និងរាជធីតា ៥ អង្គគឺ បិយា១,សុប្បិយា១, អានន្ទា១, វិជិតា១, វិជិតក្កសេនា១ ។ ព្រះនាងបិយា ជារាជធីតាច្បងលើរាជបុត្រ រាជធីតាឯទៀតៗ ។ កាលព្រះនាងភត្តាជាអគ្គមហេសីសោយព្រះវិលាល័យទៅ ព្រះរាជាទ្រង់លើកខត្តិយានី១ អង្គដែលមានរូបឆោមល្អជាអគ្គមហេសី ។ ខត្តិយានីអង្គនេះ មានព្រះរាជបុត្រ១ អង្គនាម ជន្តុ ។ កាលព្រះជន្តុបាន ៥ ថ្ងៃ ព្រះមាតាបាននាំយកទៅថ្វាយបង្គំព្រះបាទ ឱក្កាករាជ ជាបិតាៗទ្រង់សព្វព្រះទ័យណាស់ ក៏ទ្រង់ប្រទានពរថា "ឱ្យព្រះនាងសុំពរអ្វី១តាមប្រាថ្នា"

www.elibraryofcambodia.org

ព្រះនាងក៏សុំរាជសម្បត្តិថ្វាយព្រះរាជបុត្រ ។ ដំបូងព្រះរាជាមិនព្រមទេ តែដោយព្រះនាងទទូចអង្វរច្រើនដងពេក ព្រះរាជាក៏ព្រមតាមសំណូមពរនាង រួចត្រាស់ហៅបុត្រាបុត្រីទាំង ៩ អង្គមកថ្វាយរឿងហេតុទាំងនោះដោយសព្វគ្រប់ រួចទ្រង់ប្រទានសេះដំរី និងពលជាច្រើនដល់រាជបុត្រាបុត្រីទាំង ៩ អង្គ ហើយឱ្យយាងចេញពីព្រះនគរទៅរកសាងនគរថ្មីសិន ទំរាំអស់ពីព្រះអង្គទៅ សឹមវិលត្រឡប់មកវិញ ។

តាមសេចក្ដីដំណាលថា កាលក្សត្រាក្សត្រីទាំង ៩ អង្គយាងចេញទៅ មានប្រជាជនជាច្រើននាក់បានតាមទៅដែរ ។ កាលយាងកាត់ព្រៃហេមពាន្តឆ្ងាយទៅៗ ក៏បានទៅដល់ទី ១ មានដើម សក្កៈ ដុះច្រើន ក៏បានជួបនឹងតាបស ១ អង្គនាម កបិលដែលជាតួអង្គព្រះពោធិសត្វ ហើយយាងចេញសាងផ្នួសគង់នៅទីព្រៃសក្កៈនោះ ។ កាលជ្រាបថា ក្សត្រាក្សត្រី ៩ អង្គ យាងរកទីសាងព្រះនគរដូច្នោះ ព្រះកបិលតាបសក៏បានថ្វាយអាស្រមបទដល់ក្សត្រាក្សត្រី ដើម្បីសាងព្រះនគរ ព្រោះលោកយល់ថា ទីនេះជាទីជយភូមិល្អ ដោយមានឃើញសត្វធំ ដេញសត្វតូចមកដល់ទីនោះ សត្វធំក៏អស់អំណាចទៅវិញ ។ ក្សត្រាក្សត្រីទ្រង់ទទួលយកហើយ ក៏សាងព្រះនគរជាលំនៅស្ថាន នៅត្រង់អាស្រមបទ

www.elibraryofcambodia.org

តាបសនោះហើយដាក់នាមថា "កបិលវត្ថុបុរី", ប្រែថា ក្រុងជាទ្រព្យរបស់កបិលតាបស, តមកក៏ក្លាយជាក្រុងកបិលពស្តុ ។

លុះក្សត្រាក្សត្រីទាំង ៩ អង្គ បានសាងព្រះនគរនៅត្រង់អាស្រមបទកបិលតាបសនោះរួច ក្សត្រ ៤ អង្គក៏រៀបអភិសេកជាមួយក្សត្រី ៤ អង្គតាមលំដាប់ ១ គ្នា ដោយលើកព្រះនាងបិយា ជាបងបង្អស់ទុកជាព្រះមាតា ។ កាលអភិសេករួចហើយក៏តាំងព្រះរាជវង្សនេះថា សក្កវង្ស ឬ សាក្យវង្ស ដើម្បីឱ្យស្របតាមស្ថានទីដែលទ្រង់បានសាងព្រះនគរនៅត្រង់ ព្រៃនៃដើមសក្កៈនោះឯង ។ តមកពាក្យថា សក្កៈ នេះ ក៏បានជាឈ្មោះនៃដែន (រដ្ឋ) ផង ជាឈ្មោះនៃរាជវង្សផង ។ សាក្យវង្ស និងសក្កៈជនបទ កើតតាំងពីត្រឹមក្សត្រាក្សត្រីទាំង ៩ អង្គ ជារាជបុត្រាបុត្រីនៃព្រះបាទ ឱក្កាករាជ នោះឯង ។

តាមសេចក្តីដំណាលថា ពេលក្រោយមកព្រះនាង បិយា ដែលជារៀមច្បង កើតរោគឃ្លង់ពេញព្រះកាយ ។ ព្រះអនុជបានធ្វើអាស្រមបទ១ នៅក្នុងព្រៃ ដើម្បីថ្វាយឱ្យព្រះនាងគង់នៅតែ១ព្រះអង្គឯង កុំឱ្យឆ្លងរោគឃ្លង់ទៅជនឯទៀត ១ ។ កាលណោះមានព្រះរាជា ១ ព្រះអង្គសោយរាជ្យនៅនគរពារាណសី នាមព្រះបាទ រាមៈ ក៏ទ្រង់កើតរោគឃ្លង់ដែរ ។ ព្រះអង្គបានដាក់រាជ្យ

www.elibraryofcambodia.org

ថ្វាយទៅព្រះរាជឱរសច្បង ហើយយាងទៅគង់ក្នុងព្រៃតែ១ អង្គដែរ ។ ទ្រង់សោយតែផ្លែឈើ និងមើមឈើ លុះសោយយូរៗ ទៅ ក៏ប៉ះលើផ្លែឈើរម្ងាប់រោគឃ្លង់ ទ្រង់ជាសះស្បើយ ហើយ យាងទៅទៀត បានជួបព្រះនាងបិយា នៅត្រង់អាស្រមព្រះនាង។ កាលជ្រាបថា ព្រះនាងជាខត្តិយានីដែរ ព្រះរាម ក៏ជួយព្យាបាល រោគឃ្លង់ព្រះនាងទាល់តែបានជាសះស្បើយ ហើយនៅរួមរក្សជា គូស្វាមីភរិយាតាមប្រពៃណី ។ តមកទ្រង់យាងចេញពីនោះតាម ស្នាមជើងខ្លា រហូតទៅដល់ដែននៃព្រៃ រកោលៈ ក៏បានកសាង ទីក្រុងនៅទីនោះ ហើយថ្វាយនាមក្រុងថ្មីថា រកោលនគរ តាំង ព្រះរាជវង្សថ្មីមួយទៀត ដោយយកដើមកោលៈ ជាតំណាង ហើយប្រសិទ្ធិនាមព្រះវង្សថ្មីនេះថា កោលិយវង្សទីក្រុងនោះ មាន ឈ្មោះថា រាមគ្រាម គឺយកនាមថា ព្រះនាមព្រះបាទ រាមៈ ។ កោលិយវង្សនេះតមក បានចែកជា ២ វង្សទៅទៀតគឺ កោលិយៈ ខាងទេវទហៈ ១, កោលិយខាងរាមគ្រាម ១ ។ ក្រុងទាំងពីរជា រាជធានីដូចគ្នា ។ ឯទេវទហៈ ក៏មាន ២ គឺ ទេវទហៈខាងសាក្យ វង្ស ១, ទេវទហៈខាងកោលិយវង្ស១ ។ ព្រះនាងសិរិមហាមាយា ជាពុទ្ធមាតាក្តី ព្រះនាងយសោធរាពិម្ពាជា អគ្គមហេសីនៃព្រះ សិទ្ធត្ថក្តី គឺជាក្សត្រីនៃក្រុងទេវទហៈខាងសាក្យវង្ស មិនមែន

www.elibraryofcambodia.org

ទេវទហៈខាងកោលិយវង្សទេ ។

ស. ចុះដែនសក្កនេះចែកចេញជាប៉ុន្មាននគរ ? ប៉ុន្មាននិគម ? ប៉ុន្មានគ្រាមតទៅទៀត ចូរពន្យល់ !

ច. ដែនសក្កដែលយើងបានឃើញប្រវត្តិជាមួយសាក្យវង្សនិងកោលិយវង្សរួចហើយនោះ ចែកចេញជា ៣ នគរគឺ : កបិលព័ស្តុ១, វិធញ្ញា១, សាលាវតី១, មាននិគម ៤ គឺ ទេវទហនិគម១, មេទឡុនិគម១, ខោមទុស្សនិគម១ និងសក្ករ និគម១ មានគ្រាម១ គឺ សារគ្រាម ។ នគរចែកជានិគម ( នគរ = ខេត្ត ), និគម ( ស្រុក ) ចែកជាគ្រាម (តំបន់) បន្តែគ្រាមខ្លះបានរីកចំរើនឡើងយូរទៅ ក៏ក្លាយជាទីប្រជុំធំ បានជារាជធានី ដូចរាមគ្រាមជាតំបន់ទេ តែក្លាយជារាជធានីនៃកោលិយវង្ស តែនៅហៅថាគ្រាមដដែល ។ ដូច្នេះ ទេវទហៈខាងសាក្យវង្ស គ្រាដើមប្រហែលជាគ្រាមដែរ តែក្រោយមកក៏ក្លាយជារាជធានីនៃពួកសាក្យវង្សខាងទេវទហៈ ជាគូនឹងសាក្យវង្ស ខាងកបិលពស្តុទៅវិញ ។

ស. ព្រះពុទ្ធជាម្ចាស់ ទ្រង់ប្រសូត្រពីក្នុងវង្សណា ? ចូររាប់តាមលំដាប់ !

ប. ទ្រង់ប្រសូត្រពីសាក្យវង្សខាងកបិលព័ស្តុ និងសាក្យវង្សខាងទេវទហៈ ។ សាក្យវង្សដែលមានព្រះក្សត្រាក្សត្រីទាំង ៨

www.elibraryofcambodia.org

អង្គ បានផ្សំផ្គុំទៅនឹងកោលិយវង្ស ដែលមានព្រះបាទ រាម និងព្រះនាងបិយាជាអ្នកបង្កើតថា : យើងមិនបានដឹងថាមានការទាក់ទងគ្នាយ៉ាងណាឡើយ យើងដឹងតែសាក្យវង្សខាងទេវទហៈ ប៉ុណ្ណោះ វង្សទាំងពីរនេះនៅជាប់គ្នា មានស្ទឹងរោហិណីតាំងនៅកណ្ដាល ហើយអ្នកដែនទាំងពីរ បានអាស្រ័យនឹងយកទឹកស្ទឹងនេះទៅប្រើប្រាស់ធ្វើស្រែចំការរៀងៗខ្លួន ។ នៅមុនពុទ្ធកាលត្រឹម ២ ជួរមនុស្ស វង្សទាំងពីរនេះ មានលំដាប់ដូចតទៅ :

| ខាងនគរកបិលពស្តុ | ខាងនគរទេវទហៈ |
|---|---|
| ព្រះបាទជ័យសេន | ព្រះបាទអញ្ជនៈ |
| មាន | មានប្អូនស្រី |
| ឱរសនាម សីហហនុ | នាម កញ្ចនា |
| ធីតានាម យសោធរា | |

កាលព្រះបាទជយសេន សោយទិវង្គតទៅ ព្រះសីហហនុឡើងសោយរាជ្យតសន្តតិវង្ស ហើយបានយកព្រះនាង កញ្ចនា ជាកនិដ្ឋាភគិនី (ប្អូនស្រី) របស់ព្រះបាទអញ្ជនៈនៅនគរ ទេវទហៈ មកអភិសេកជាអគ្គមហេសី. ឯព្រះបាទអញ្ជនៈ នៅនគរទេវទហៈ ក៏បានយកព្រះនាង យសោធរា ជាកនិដ្ឋាភគិនី នៃព្រះបាទ សីហហនុ មកអភិសេកជាមហេសីដែរ ។ ដូច្នេះ ក្សត្រទាំងពីរអង្គ

www.elibraryofcambodia.org

គឺ ព្រះសីហហនុ និងអញ្ជនៈ បានប្អូនស្រីគ្នា យកធ្វើជាមហេសីទៅវិញទៅមក ។

ព្រះបាទសីហហនុ និងព្រះនាង កាញ្ចនា មានឱរស ៥ អង្គគឺ : សុទ្ធោទនៈ១, សុក្កោទន១, អមិតោ្តទន១, ធោតោទន១, ខណិតោទន១, មានរាជធីតា ២ អង្គគឺ បមិតា១, អមិតា១ ។

ព្រះបាទអញ្ជនៈ និងព្រះនាងយសោធរា មានឱរស ២ គឺ សុប្បពុទ្ធ១[1] , ទណ្ឌបាណិ ១ និងរាជធីតា ២ សិរិមហាមាយា១, បជាបតិ១ ។

ស. សាក្យវង្សនេះ មានលក្ខណៈពិសេសយ៉ាងណា ?

ច. សាក្យវង្សនេះ មានលក្ខណៈពិសេសត្រង់ចេះរក្សាឈាមដោយការប្រកាន់មានៈយ៉ាងរឹងត្អឹងណាស់ ឥតមានទៅយកក្សត្រី ឬ ក្សត្រាក្នុងត្រកូលណាមកធ្វើជាប្តីប្រពន្ធឡើយ គឺយកតែក្សត្រជនក្នុងសាក្យវង្សដូចគ្នា ធ្វើជាប្តីប្រពន្ធតែប៉ុណ្ណោះ ។

តាមសេចក្តីដំណាលថា សាក្យវង្សខាង កបិលព័ស្តុ នៅខាងត្រើយនៃស្ទឹងរោហិណីម្ខាង និងសាក្យវង្សខាងទេវទហៈ

១. សុប្បពុទ្ធនេះ ជាបិតានាងយសោធរាពិម្ពា ជាអគ្គមហេសីនៃព្រះសិទ្ធត្ថ ។ កាលសិទ្ធត្ថបានត្រាស់ហើយ សុប្បពុទ្ធនឹង ខឹងថា ព្រះអង្គចោលនាងពិម្ពា ក៏ប្រទូស្តរាយព្រះពុទ្ធ ត្រូវព្រះធរណីស្រូបទៅ ។

www.elibraryofcambodia.org

នៅខាងត្រើយស្ទឹងរោហិណីនេះម្ខាង, ហើយវង្សនៃនគរទាំងពីរយកទឹកស្ទឹងប្រើប្រាស់ជាមួយគ្នា ។ កាលណាក្សត្រាក្សត្រី នៅក្នុងវង្សទាំងពីរពេញកម្លោះក្រមុំហើយ ពេលគេចុះទៅងូតទឹកនៅក្នុងស្ទឹងរោហិណី គេតែងលបពង្រត់គ្នាកាន់ត្រកូលទៅវៀងគ្នាជានិច្ច ព្រោះគេទុកពិធីពង្រត់គ្នានេះជាមង្គល ១ ដ៏ពិសេសរបស់គេ ។

ស- ចុះពួកសាក្យវង្ស នៅក្នុងនគរទាំងពីរនេះ ជាមហាក្សត្រ និងជាប្រទេសឯករាជ្យ ឬ ជាក្សត្រនៅក្នុងចំណុះប្រទេសណាដែរ ?

ឆ- ពិតមែនតែក្សត្រក្នុងវង្សទាំងពីរ ជាអ្នកប្រកាន់ឈាមជ័រពូជត្រកូលយ៉ាងនេះក៏ដោយ ក៏ប៉ុន្តែជាប្រទេសមួយ ដែលនៅចំណុះដែនកោសលជាដែនមួយដ៏ធំដែរ មិនមែនជាប្រទេសឯករាជ្យឡើយ ។

ស- នគរកបិលព័ស្តុនេះ មានឈ្មោះយ៉ាងនេះជាប់រហូតតាំងពីដើមមក ឬ មានឈ្មោះយ៉ាងណាផ្សេងដែរ ? បើមានតើក្នុងសម័យណា ?

ឆ- មិនមែនមានឈ្មោះថា កបិលព័ស្តុយ៉ាងនេះរហូតមកទល់សម័យពុទ្ធកាលទេ គឺ កាលរាជបុត្រាបុត្រីព្រះបាទ ឱក្កាករាជ

www.elibraryofcambodia.org

បានតាំងសាងព្រះនគរមក បានដាក់ឈ្មោះថា កបិលពស្តុ ដូច្នេះ ហើយមានក្សត្រសោយរាជ្យនៅក្នុងរាជធានីតែមួយនេះ អស់ពេលជាច្រើន ឆ្នាំរហូតទល់ព្រះបាទ សិទិរាជ ១ ក៏ផ្លាស់នាមនគរ និងរាជធានីថា "វេទិកត្តរ" វិញ ចាប់ពីសម័យនោះមក នគរ ជេតុត្តរ ក៏បានរីកធំឡើង មានប្រទេសចំណុះជាច្រើន (ដូចមាន នៅក្នុងមហាវេស្សន្តរជាតក បាននិទានរៀបរាប់ស្រាប់) តមក មានព្រះបាទស្រីសញ្ជ័យ, ព្រះបាទ [illegible]ន្តរ, ព្រះបាទជាលី, ព្រះបាទសិ[illegible]ៈ, ព្រះបាទសីហសរាជ រួចតមកពោះព្រះ មហាក្សត្រសោយរាជ្យចំនួន ១៦.១០០ អង្គ ទើបមកដល់ព្រះបាទ ជយសេន ព្រះបាទសីហហនុ ជារាជបុត្រព្រះបាទជយសេន បាន ផ្លាស់នាមនគរជេតុត្តរថា "កបិពស្តុ" វិញ ប៉ុន្តែដល់សម័យ នេះនគរកបិលពស្តុ ប្រែក្លាយទៅជាប្រទេសតូច នៅក្រោម អំណាចនៃដែនកោសលទៅវិញ ។

www.elibraryofcambodia.org

ភាគទី ៣

# ព្រះបដិសន្ធិ

## និង ការប្រសូត្រនៃព្រះសិទ្ធត្ថកុមារ

ស- កំណើតព្រះវេស្សន្តរនៅក្នុងស្ថានតុសិត ឈ្មោះសន្តុសិតទេវបុត្តនោះ ជាកំណើតយ៉ាងណា ? ព្រោះហេតុអ្វី ?

ច- កំណើតព្រះវេស្សន្តរ នៅស្ថានតុសិតនោះ ជាកំណើតអស្ចារ្យ សោយតែផលល្អ ហើយជាកំណើតប្រកបដោយសុខុមាលភាព ដើម្បីរង់ចាំពេលវេលា នឹងចុះមកយកបដិសន្ធិក្នុងមនុស្សលោក នឹងបានត្រាស់ជាព្រះពុទ្ធតែម្តង ។ តាមធម្មតាកំណើតនៅស្ថាននេះ ជាកំណើតដ៏ទៀងទាត់របស់ព្រះពោធិសត្វរាល់ព្រះអង្គ នៅពេលមុននឹងបានត្រាស់ជាព្រះពុទ្ធអង្គ ។

ស- កាលសន្តុសិតទេវបុត្តជិតផុតអាយុក្នុងស្ថានតុសិតនោះហើយ តើមានកើតហេតុយ៉ាងណា ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? អ្នកណាទៅអារាធនាព្រះអង្គឱ្យមកយកបដិសន្ធិ ឬទ្រង់យាងមកដោយព្រះអង្គឯង ?

ច- កាលសន្តុសិតទេវបុត្តហៀបនឹងអស់ព្រះជន្ម នៅស្ថានតុសិតនោះហើយ មានកើតកោលាហល គឺការជ្រួលជ្រើម ៥ យ៉ាងគឺ :

www.elibraryofcambodia.org

១. **កប្បកោលាហល..** ការជ្រួលជ្រើបថា នៅ ១ សែនឆ្នាំទៀត ភ្លើងនឹងឆេះកប្ប មនុស្សត្រូវនាំគ្នាធ្វើបុណ្យឱ្យទានរក្សាសីល ។

២. **ពុទ្ធកោលាហល..** ការជ្រួលជ្រើមថា នៅ ១ សែនឆ្នាំទៀត ព្រះពុទ្ធនឹងកើតក្នុងលោក ។

៣. **ចក្កវត្តិកោលាហល..** ការជ្រួលជ្រើមថា នៅ ១ សែនឆ្នាំទៀត ស្ដេចចក្កពត្តិ នឹងកើតឡើងក្នុងលោក ។

៤. **មង្គលកោលាហល..** ការជ្រួលជ្រើមថា នៅ ១ សែនឆ្នាំទៀត ព្រះពុទ្ធនឹងសម្ដែងមង្គលសូត្រ ៣៨ ប្រការ ដល់មនុស្ស និងទេវតា ។

៥. **មោនេយ្យកោលាហល..** ការជ្រួលជ្រើមថា នៅ ១ សែនឆ្នាំទៀត ព្រះពុទ្ធនឹងសំដែង មោនេយ្យបដិបត្តិ ។

សុទ្ធវាសមហាព្រហ្ម ជាអ្នកហោះប្រកាសប្រាប់នូវកោលាហលទាំង ៥ នេះដល់ទេវតា និងព្រហ្មទាំងឡាយទាំង ១ ហ្មឺនលោកធាតុ ទេវតា និងព្រហ្មទាំងឡាយឮហើយ ក៏ទៅអារាធនា អញ្ជើញសន្តុសិតទេវបុត្រឱ្យច្យុតចុះទៅយកកំណើតក្នុងមនុស្សលោក ដើម្បីនឹងបានត្រាស់ជាព្រះពុទ្ធ ដោយពាក្យថា :

**កាលោយន្តេ មហាវីរ ឧប្បជ្ជ មាតុកុច្ឆិយំ**

www.elibraryofcambodia.org

សនេទកំ គារយន្តោ ពុទ្ធស្ស អមតំ មធំ

បពិត្រព្រះមហាបុរសអ្នកមានព្យាយាម កាលនេះជាកាលគួរដល់ព្រះអង្គហើយ សូម ព្រះអង្គច្យុតចុះទៅយកព្រះបដិសន្ធិក្នុងផ្ទៃនៃព្រះមាតា ដើម្បីបានត្រាស់ហើយចម្លងមនុស្ស និងទេវតា ឱ្យបានដល់នូវស្ថានបរមសុខ ។

ស- ចុះកាលពួកទេវតា និងព្រហ្ម បានអារាធនាដូច្នោះហើយ តើសន្តុសិតទេវបុត្តចុះមកភ្លាម ឬបានគិតរំពឹងមើលយ៉ាងណាដែរ ?

ច- មិនមែនយាងចុះមកភ្លាមទេ ទ្រង់ប្រមើលមើលនូវហេតុ ៥ យ៉ាងហៅថា បញ្ចវិលោកនៈគឺ :

**១- កាល** ពេលដែលមនុស្សមានអាយុច្រើនផុតត្រឹម ១ សែនឆ្នាំ និងតិចផុតត្រឹម ១ រយឆ្នាំ ទើបព្រះពុទ្ធយកកំណើត ។

**២- បទេស** ព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់ពុំដែលយកកំណើតក្នុងបច្ចន្តបទេសទេ ទ្រង់កើតតែក្នុងមជ្ឈិមប្រទេសតែប៉ុណ្ណោះ ។

**៣- ត្រកូល** ព្រះពុទ្ធតែងយកកំណើតក្នុងត្រកូល ២ គឺត្រកូលក្សត្រ និងត្រកូលព្រាហ្មណ៍ ឯត្រកូលក្រៅពីនេះ ទ្រង់ពុំដែលកើតទេ ។

www.elibraryofcambodia.org

៤- ទ្វីប ព្រះពុទ្ធតែងយកកំណើតតែក្នុងជម្ពូទ្វីបមួយប៉ុណ្ណោះ ។ ទ្វីប ៣ ទៀតគឺ បុព្វវិទេហទ្វីប, ឧត្តរកុរុទ្វីប និងអមរគោយានទ្វីប ព្រះពុទ្ធគ្រប់អង្គពុំដែលកើតទេ ។

៥- ព្រះពុទ្ធតែងយកកំណើតក្នុងផ្ទៃនៃមាតាណា ដែលមានអភិនីហារកសាងមកអស់ ១ សែនកប្ប ដើម្បីបានជាពុទ្ធមាតា ។

ស- កាលទ្រង់ប្រមើលនូវហេតុទាំង ៥ នេះរួចតើសន្តុសិតទេវបុត្ត មានបុព្វនិមិត្ត ដូចម្ដេចខ្លះ ?

ច- មានកើតបុព្វនិមិត្ត ៥ ប្រការគឺ :

១- បុប្ផាទិព្វ ដែលទ្រង់តាក់តែងកាយស្រូវស្រពោនស្វិត

២- សំពត់ទិព្វ មានពណ៌សៅហ្មង

៣- ញើស ហូរចេញពីក្លៀក

៤- ព្រះកាយទ្រង់ចាស់ជរាទ្រុឌទ្រោម

៥- ទ្រង់អផ្សុកព្រះទ័យ មិនចង់ស្ថិតនៅក្នុងស្ថានទិព្វ ។

ស- ព្រះពោធិសត្វ ទ្រង់ចុះចាប់បដិសន្ធិនៅក្នុងផ្ទៃនៃព្រះមាតាណា? នៅទីណា? នៅថ្ងៃ-ខែឆ្នាំណា ? ពេលវេលាណា ?

ច- ទ្រង់ចុះចាប់បដិសន្ធិក្នុងផ្ទៃនៃព្រះនាងសិរិមហាមាយា ជាអគ្គមហេសីនៃព្រះបាទសិរីសុទ្ធោទនៈ មហាក្សត្រនៅ

www.elibraryofcambodia.org

ដែនសក្កៈ ក្រុងកបិលពស្តុ ក្នុងសាក្យត្រកូលដែនជម្ពូទ្វីប. មជ្ឈិមប្រទេស នៅថ្ងៃព្រហស្បត៍ ពេញបូរមី ខែ អាសាធ ឆ្នាំរកា ពេលទៀបភ្លឺ ។

ស. តាមធម្មតា ពេលដែលសត្វចុះចាប់បដិសន្ធិ មាតាតែងមានសុបិននិមិត្តប្លែកៗ ចុះកាលព្រះពោធិសត្វចុះចាប់បដិសន្ធិនោះ តើព្រះនាងសិរិមហាមាយា ជាព្រះមាតាមានសុបិនិមិត្តដែរ ឬ គ្មាន បើមានតើសុបិននិមិត្តយ៉ាងណា ?

ច. មានទេ គឺព្រះនាងសិរិមហាមាយាទ្រង់សុបិនថា "ស្តេចនៃទេពតាក្នុងទិសទាំង ៤ គឺព្រះបាទកុវេរវណ្ណ១. ធតរដ្ឋ១. វិរូឡហ្ក១. វិរូបក្ខ១ បានមកលើកយកព្រះនាងទាំងព្រះសយនាទៅកាន់ភ្នំហេមពាន្ត ដាក់លើមនោសិលាទំហំ ៦០ យោជន៍ឰដ៍ក្រោមដើមរាំងធំ ១ កំពស់ ១០០ យោជន៍ រួចមានទេវធីតាមកសុំយាងព្រះនាងទៅស្រង់ទឹកក្នុងអនោតត្តស្រះ ។ នៅជិតស្រះមានភ្នំប្រាក់ ១ មានវិមានមាស ១ នៅលើភ្នំប្រាក់ ។ កាលស្រង់ហើយ ព្រះនាងយាងទៅផ្ទុំក្នុងវិមានមាស លើភ្នំប្រាក់បែរព្រះសិរទៅទិសខាងកើត ។ មានដំរីស ១ ចុះមកពីភ្នំមាស ១ ដែលនៅជិតភ្នំប្រាក់ ហើយកាន់ផ្កាឈូកបន្ទឹសម្លេងដូចត្រៀល ឡើងទៅលើភ្នំប្រាក់រួចចូលទៅក្នុងវិមានមាស ដើរប្រទក្សិណព្រះនាង ៣

www.elibraryofcambodia.org

ផ្ទុំរួចហាក់ដូចជាចូលទៅក្នុងឧទរព្រះនាងខាងស្តាំ ។ គឺពេលនេះហើយដែលព្រះពោធិសត្វនៃយើងទ្រង់ចាប់បដិសន្ធិ ។

ស- កាលមុនពេលព្រះពោធិសត្វចុះចាប់បដិសន្ធិក្នុងផ្ទៃនៃព្រះនាង តើព្រះសិរីមហាមាយា បានធ្វើអ្វីខ្លះ ?

ច- ព្រះនាងសិរីមហាមាយា ទ្រង់ក្រសាលមហោស្រពអស់ពេល ៧ ថ្ងៃជាមួយអ្នក នគរមុនថ្ងៃពេញបូរមី លុះដល់ថ្ងៃពេញបូរមី ព្រះនាងបានបរិច្ចាគទ្រព្យចំនួនមួយសែនកហាបណៈឱ្យជាទាន រួចក៏សមាទានឧបោសថសីលស្រេច ទើបចូលផ្ទុំ ។

ស- នៅពេលដែលព្រះពោធិសត្វ ទ្រង់យាងចុះចាប់បដិសន្ធិ តើមានហេតុភេទណាទាក់ទងដល់មនុស្ស ធម្មជាតិនិងព្រៃភពនេះដែរឬទេ ?

ច- មាន គឺមានហេតុចម្លែកនៅក្នុងមនុស្សលោក ធម្មជាតិ និងលោកទាំងមូល ចំនួន ៣២ បែបគឺ : ១- ប្រឹថពីកម្រើកមានពន្លឺពេញលោកធាតុ, ២- លោកន្តរមហានរក ដែលងងឹតក៏មានពន្លឺឡើង, ៣- មនុស្សខ្វាក់ បែរជាមើលឃើញ, មនុស្សថ្លង់បែរជាឮ, មនុស្សគបែរជានិយាយបាន, មនុស្សគមបែរជាត្រង់, មនុស្សខ្វិនដើររួច, ៤- មនុស្សសត្វ ដែលត្រូវជាប់គុកច្រវាក់ខ្នោះ ត្រូវរួចចេញបាន, ៥- ភ្លើងក្នុងនរកទាំងឡាយ

www.elibraryofcambodia.org

មានអវិចីជាដើម បែរជារលត់, ៦. សេចក្តីស្រេកឃ្លានរបស់ពួកប្រេតក៏បាត់បង់, ៧. បង្អួច ទ្វារដែលបិទជិតត្រូវរបើកចេញ, ៨. សំពៅនិងទូកបានទៅដល់កំពង់តាមប្រាថ្នា, ៩. សត្វតិរច្ឆានទាំងឡាយ មិនភ័យតក់ស្លុត, ១០. រោគរបស់មនុស្សសត្វក៏បានរម្ងាប់, ១១. សត្វដែលមានពៀរនិងគ្នា បែរជាមានមេត្តាដល់គ្នានិងគ្នា, ១២. មនុស្សសត្វនិយាយសំដីជាទីស្រឡាញ់ចូលចិត្តដល់គ្នានិងគ្នា, ១៣. ពពួកសេះទាំងឡាយបន្លឺសម្លេងរកគ្នា, ១៤. ពពួកដំរីបានបន្លឺសម្លេងគឹកកងរកគ្នា, ១៥. តូរ្យតន្ត្រីបានបន្លឺសម្លេងដោយខ្លួនឯង, ១៦. គ្រឿងអាភរណៈរបស់មនុស្សមានពន្លឺ ហើយប៉ះគ្នាចេញជាសម្លេងប្រាកដឡើង, ១៧. ទិសទាំងឡាយភ្លឺច្រាលឡើង, ១៨. គ្មានខ្យល់ព្យុះបក់បោក, ១៩. មានខ្យល់តិចៗ ល្ហមហើយត្រជាក់ដល់មនុស្ស, ២០. មហាមេឃបង្អុរភ្លៀង, ២១. ទឹកទំលាយផែនដីផុសផុលឡើង, ២២. ហ្វូងសត្វស្លាបឥតហើរទៅក្នុងអាកាស, ២៣. ខ្សែទឹកក្នុងស្ទឹងនៅនឹងថ្កល់ដូចទឹកស្រះ, ២៤. ទឹកប្រៃក្នុងសមុទ្របែរជាផ្អែម, ២៥. ផ្កាឈូកមានពណ៌ ៥ ដុះរីកក្នុងសមុទ្រស្ទឹង និងផ្ទៃផែនដី, ២៦. ផ្ការីកទាំងអស់, ២៧. រុក្ខជាតិវល្លិទាំងឡាយ កើតមានផ្កាឈូកចេញតាមដើម, មែក, ទង, ២៨. ឈូកទាំងឡាយទំលាយផែនថ្មផុស

www.elibraryofcambodia.org

ឡើងមកមួយកន្លែងមានផ្កា ៧១ គ្រប់ផែនថ្ម, ២៩- មានផ្កាឈូកដុះសំយុងចេញពីអាកាស, ៣០- វុក្ខជាតិទាំងនាមានផ្លែផ្កាក្នុងពេលនោះ, ៣១- ភ្លៀងផ្កាទិព្វមានផ្កាមន្ទាបុស្សជាដើមក៏ធ្លាក់ចុះមក, ៣២- តូរ្យតន្ត្រីក៏បន្លឺសម្លេងឯអាកាស ទង់ជ័យទិព្វក៏កើតឡើងដូចគ្នាពេញទាំង ១ម៉ឺនលោកធាតុ ហើយមានពណ៌និងពន្លឺអស្ចារ្យ ។ ហេតុដ៏ចម្លែកអស្ចារ្យនេះ ហៅថាបុព្វនិមិត្ត ។

ស- នាងសិរិមហាមាយា កាលតើនឡើងហើយ តើធ្វើយ៉ាងណាដែរ ?

ច- កាលព្រះនាងតើនឡើងហើយ ក៏ទូលព្រះស្វាមីដោយសព្វគ្រប់ ព្រះស្វាមីបានហៅព្រាហ្មណ៍មកទាយសុបិននិមិត្តថ្វាយព្រះនាង ។

ស- ព្រាហ្មណ៍ប៉ុន្មាននាក់ ដែលទាយសុបិន្តនិមិត្តថ្វាយព្រះនាង ? ទាយថាយ៉ាងណា ?

ច- មាន ៦៤ នាក់ ។ ទាំង ៦៤ នោះបានទាយថា ព្រះនាងនឹងមានបុត្រ បើបុត្រនោះនៅជាឃរាវាស នឹងបានជាស្តេចចក្រ, បើយាងចេញបួស នឹងបានត្រាស់ជាព្រះពុទ្ធ ។

ស- ព្រះពោធិសត្វទ្រង់គង់ក្នុងគភ៌ដោយអាការៈយ៉ាងណា ? អស់វេលាប៉ុន្មាន ? មានអ្នកណាថែរក្សាខ្លួន ?

www.elibraryofcambodia.org

ច- ទ្រង់គង់តែនព្រះភ្នែន បែរភក្ត្រទៅរកឧទរព្រះមាតា បែរខ្នងទៅខាងខ្នងព្រះមាតា អស់វេលា ១០ ខែ មានមហារាជទាំង ៤ នៅថែរក្សា ។

ស- ព្រះពោធិសត្វ ទ្រង់ប្រសូត្រនៅទីណា ? ព្រោះហេតុអ្វី ? នៅថ្ងៃខែឆ្នាំណា ? ពេលថ្មើរម៉ាន ?

ច- ប្រសូត្រនៅសួន លុម្ពិនី ជាឧទ្យានដែលនៅត្រង់ចន្លោះនគរទាំងពីរ គឺកបិលព័ស្តុ និងទេវទហៈ ។ ទីប្រសូត្រនេះសព្វថ្ងៃហៅថា តំបន់ដាប៉ារិយ៉ា ជាទីរហោស្ថានគ្មានមនុស្សនៅឡើយ ។ តាមសេចក្តីដំណាលក្នុងគម្ពីរពុទ្ធសាសនាថា បានជាទ្រង់ប្រសូត្រនៅទីឧទ្យាន ដែលមិនមែនជាព្រះរាជវាំង ឬជាមជ្ឈមណ្ឌល មានប្រសូតិគ្រឹះដូច្នោះ ព្រោះនៅពេលនោះព្រះនាងសិរិមហាមាយា ទ្រង់យាងទៅសួរសុខទុក្ខព្រះមាតាបិតាលុះទ្រង់ដល់ទៅទីនោះ ទ្រង់ក៏ប្រឈួនព្រះឧទរ ហើយយាងចូលទៅក្រោមដើមសាលព្រឹក្ស ព្រះនាងក៏ប្រសូត្ររាជបុត្រមក ។ តែតាមធម្មតារបស់លទ្ធិព្រាហ្មណ៍ កាលណាស្ត្រីមានគភ៌គ្រប់ខែហើយ តែងតែទៅប្រសូត្រនៅខាងផ្ទះមាតាបិតារបស់ខ្លួនជាដរាប មិនដែលប្រសូត្រនៅនឹងផ្ទះរបស់ខ្លួន ឬនៅផ្ទះមាតាបិតាក្មេកទេ ។

www.elibraryofcambodia.org

គោលទាំងពីរខាងលើនេះ សមរម្យគួរឱ្យជឿហើយ តែយើងគួរពិចារណាថា បើព្រះនាងចង់យាងទៅសួរសុខទុក្ខ ឬយាងទៅដើម្បីប្រសូត្រនៅឯព្រះដំណាក់នៃព្រះមាតាបិតា ម្ដេចក៏មិនយាងទៅមុនពេលនេះ ? ព្រោះព្រះនាងជាអគ្គមហេសី នៃព្រះមហាក្សត្រផង ហើយមានព្រាហ្មណ៍ហោរាដែលចេះក្បួនតម្រាយ៉ាងជំនាញៗផង ក៏គង់ជ្រាបថាព្រះគភ៌មានរយៈពេលប៉ុន្មានថ្ងៃដែរ ម្ដេចក៏ទាល់តែព្រះគភ៌គ្រប់ ១០ ខែគត់ ទើបព្រះនាង យាងទៅ ។ យ៉ាងនេះគោលអាងទាំងពីរខាងលើពុំទាន់សមរម្យត្រឹមត្រូវនៅឡើយទេ តែយើងអាចសន្និដ្ឋានបានយ៉ាងនេះទៅវិញថា "ព្រះសិទ្ធត្ថកុមារពោធិសត្វ ជាអនាគតនៃព្រះពុទ្ធវង្សនោះជាមនុស្សអស្ចារ្យ ត្រូវតែមានសភាព និងលក្ខណៈទាំងអស់ប្លែកពីមនុស្សឯទៀតៗបែបនេះ ។ ដូច្នេះបានជាពេលព្រះនាងសិរិមហាមាយាទ្រង់ជ្រាបថា នាងនឹងប្រសូត្របុត្រនោះព្រះនាងទ្រង់ឈរ ព្រះហស្តស្ដាំ មានបំណងនឹងទាញមែកសាលព្រឹក្សដែលព្រះនាងចូលទៅពីក្រោមនោះ មែកសាលព្រឹក្សក៏ទោរទន់មកថ្វាយព្រះនាងទាញ ព្រះនាងទ្រង់ទាញហើយទ្រង់ប្រសូត្រព្រះរាជបុត្រមកដោយស្រួល ។ ព្រះពោធិសត្វទ្រង់ប្រសូត្រនៅសួនលុម្ពិនីនៅថ្ងៃសុក្រ ពេញបូរមី ខែពិសាខ ឆ្នាំ ច ពេលថ្ងៃជិតត្រង់ ប្រកប

www.elibraryofcambodia.org

ដោយសេចក្ដីសុខក្សេមក្សាន្ដ ។

ស- នៅពេលព្រះពោធិសត្វប្រសូត្រនោះ ទ្រង់មានអាការៈ និងលក្ខណៈប្លែកយ៉ាងណា ? មានហេតុភេទអ្វីចំឡែកកើតឡើង ?

ច- នៅពេលដែលព្រះកុមារទ្រង់ប្រសូត្រនោះ មានសភាពប្លែក ៣ ប្រការគឺ :

១- ព្រះមាតាទ្រង់ឈរទាញមែកសាលព្រឹក្ស.

២- ពេលប្រសូត្រមក មានសុទ្ធាវាសមហាព្រហ្មទាំង ៤ បានយកបណ្ដាញមាសមកទទួលព្រះពោធិសត្វ.

- មហារាជទាំង ៤ បានទទួលព្រះរាជកុមារពីមហាព្រហ្ម.

- ពួកស្រីស្នំ ទទួលយកព្រះកុមារពីមហារាជទៅទៀត ។

៣- ព្រះកុមារទ្រង់យាងចុះពីដៃស្រីស្នំ ហើយយាងទៅដោយព្រះបាទបាន ៧ ជំហាន ទើបលើកព្រះហស្ដស្ដាំឡើង រួចបន្លឺព្រះវាចាថា "អគ្គោ ហមស្មិ លោកស្ស សេដ្ឋោហមស្មិ លោកស្ស ជេដ្ឋោ លោកស្ស អយមន្តិមា ជាតិ នត្ថិ ទានិ បុនព្ភវោ = ខ្លួនយើងជាកំពូលនៃលោក ជាបុគ្គលប្រសើរវិសេសជាងគេនៅក្នុងលោក, ជាចម្បងជាងគេទាំងអស់ក្នុងលោក ជាតិនេះជាកំណើតទីបំផុតនៃយើងតទៅយើងលែងកើតទៀត

www.elibraryofcambodia.org

ហើយ" ។

- មានមហាព្រហ្មយកស្វេតច្ឆត្រមកបាំងថ្វាយ.

- សុយាមទេវរាជយកផ្លិតរោមមកបក់ថ្វាយ

- ទេវបុត្រ ១ អង្គកាន់កែវ ៧ ប្រការ

- ទេវបុត្រ ១ អង្គកាន់ស្បែកជើងមាស

- ទេវបុត្រ ១ អង្គកាន់គ្រឿងសំរាប់រាជ្យទាំង ៥ គឺ ម្កុដ១. ព្រះខ័ន១ ស្វេតច្ឆត្រ១ សុពណ៌១ វាលវិជនី១ ឈរអម.

- មានទឹកក្តៅត្រជាក់ហូរធ្លាក់មកពីអាកាស លាងមន្ទិលព្រះគភ៌ ។

- មានកើតហេតុចម្លែកអស្ចារ្យ ដូចជាការកម្រើកផែនប្រឹថពីជាដើម ដូចគ្នានឹងពេលទ្រង់ចុះចាប់បដិសន្ធិដែរ ។

ស- ព្រះពោធិសត្វទ្រង់ប្រសូត្រភ្លាមក៏ចេះយាង ចេះមានព្រះវាចាដូចមនុស្សចាស់ តែក្នុងជាតិ១ នេះ ឬមានក្នុងជាតិណាដែរ ?

ច- មាននៅពីជាតិមុនគឺ កាលទ្រង់កើតជាមហោសថ (សាងបញ្ញាបារមី) ពេលប្រសូត្រមកភ្លាមព្រះឥន្ទបានយកឱសថទិព្វមកដាក់ក្នុងព្រះហស្តនៃព្រះកុមារ១ ក្តាប់ឱសថនោះជាប់ ហើយលើកឡើង បន្លឺព្រះវាចាថា "ម៉ែ ! នេះគឺថ្នាំ " ។ សេដ្ឋីសិរិ

www.elibraryofcambodia.org

វឡ្សក៏ជាបិតា កើតរោគឈឺក្បាល ៧ ឆ្នាំហើយ ។ ពុំអាចព្យាបាលឱ្យជាបាននោះ ក៏យកថ្នាំរបស់បុត្រខ្លួនជុះនឹងទឹកហើយផឹក បានជាសះស្បើយភ្លាម ។ ដូច្នេះបានជាដាក់ឈ្មោះបុត្រថា "មហោសថ" ។

កាលទ្រង់យកកំណើតជាវេស្សន្តរ ពេលប្រសូត្រហើយ ក៏បន្លឺវាចាសួរព្រះមាតាថា "ទ្រព្យក្នុងផ្ទះយើងមានដែរឬទេ ? ខ្ញុំនឹងឱ្យទាន" ។

ដូច្នេះ ក្នុងកំណើតជាព្រះពោធិសត្វ កាលទ្រង់ប្រសូត្រភ្លាម ហើយចេះនិយាយដូច្នេះ មាន ៣ ព្រះជាតិ រាប់ទាំងជាតិទីបំផុតនេះឯង ។

ស- ក្នុងថ្ងៃដែលព្រះពោធិសត្វប្រសូត្រនោះ មានអ្វីកើតដែរ ? ហៅថាអ្វី ? មានប៉ុន្មាន ? មានការទាក់ទងនឹងព្រះពោធិសត្វនៅពេលក្រោយយ៉ាងណា ?

ច- មាន ៧ គឺ មនុស្ស ៤ នាក់ :

១- នាងពិម្ពាយសោធរា ជារាជធីតាព្រះបាទសុប្បពុទ្ធ នៅនគរទេវទហៈ ជាជីដូនមួយនឹងព្រះពោធិសត្វ ហើយក្រោយមកក៏បានជាអគ្គមហេសីនៃព្រះពោធិសត្វ ។

២- ព្រះអានន្ទ ជាបុត្រនៃព្រះសុក្កោទនៈ ជាជីដូនមួយនឹង

www.elibraryofcambodia.org

ព្រះអង្គដែរ ហើយពេលក្រោយមក ព្រះអានន្ទនេះ បានជាពុទ្ធុប្បដ្ឋាក ដែលបំរើព្រះពុទ្ធរហូតទល់ព្រះនិព្វាន ហើយចេះចាំព្រះពុទ្ធវចនៈទាំងអស់ គ្មានសល់ចន្លោះឡើយ ។

៣. នាយឆន្នអាមាត្យ ជាកូនអាមាត្យនៅក្នុងរាជវាំងកបិលព័ស្តុ ។ ក្រោយមកឆន្នានោះបានជាអាមាត្យយ៉ាងទំនុកទុកព្រះទ័យនៃព្រះពោធិសត្វ មិនសូវចេះខ្លាចញញើតព្រះពោធិសត្វឡើយ ហើយព្រះពោធិសត្វ ក៏មិនដែលយកទោសពៃរ៍អ្វីដែរ ។ ឆន្នអាមាត្យ ហ៊ាននិយាយទូលទាស់ពីរឿងផ្សេងៗ ហើយបើខ្លួនយល់ឃើញយ៉ាងណា ក៏ហ៊ាននិយាយទាស់តាមយោបល់របស់ខ្លួនភ្លាម ។ ឆន្នអាមាត្យនេះ មានការស្និទ្ធស្នាលនឹងព្រះពោធិសត្វណាស់ ។ កាលព្រះអង្គយាងចេញទៅសាងព្រះផ្នួស ហើយឱ្យឆន្នអាមាត្យទៅនាំសេះកណ្ឋកៈ មកថ្វាយព្រះអង្គ ឆន្នអាមាត្យភ្ញាក់ឡើងហើយនិយាយរអ៊ូរទាំមាត់កប្រើនថា "មិនដឹងជាទ្រង់យាងទៅណាទាំងកណ្ដាលរាត្រី ពេលកំពុងងុយដេកយ៉ាងនេះទេ" ។ ប៉ុន្តែទោះជាយ៉ាងណាក៏នៅតែធ្វើការ ហើយព្រះពោធិសត្វក៏ជ្រាបនិស្ស័យចិត្តគាត់ច្បាស់ ។ ពេលទ្រង់សាងព្រះផ្នួសហើយ ព្រះពោធិសត្វទ្រង់ដោះគ្រឿងអលង្ការវេចឱ្យឆន្នអាមាត្យស្ពាយត្រឡប់ទៅនគរវិញ ឆន្នអាមាត្យប្រកែកផងយំសោកបោក

www.elibraryofcambodia.org

ខ្លួនផងថា ខ្ញាចព្រះបាទសុទ្ធោទនយកទោស ថ្ងៃក្រោយខ្លួននឹងទៅជាមនុស្សគ្មានទីពឹង ព្រោះអស់ពីព្រះអង្គជាម្ចាស់ជីវិតទៅហើយ, ប៉ុន្តែដោយព្រះសិទ្ធត្ថទ្រង់បង្ខំពេក ឆន្នអាមាត្យ ក៏នាំសេះស្តាយបង្វិចត្រឡប់ទៅនគរវិញទាំងក្រៀមក្រម " ។

កាលព្រះសាស្តា បានត្រាស់ហើយ ឆន្នអាមាត្យ ក៏បួសជាភិក្ខុក្នុងសំណាក់ព្រះអង្គ តែពុំខ្លាចព្រះអង្គ និងសាវ័កធំៗឡើយ ពេលណាខឹង ក៏ជេរសាវ័កទាំងនោះថា "កាលអញនាំព្រះសិទ្ធត្ថមកបួស គ្មានឃើញអ្នកណាសោះ មានតែអញម្នាក់ដែលបានហែហមព្រះអង្គមក ឥឡូវស្រាប់តែមានមោគ្គល្លាន, សារីបុត្ត, អានន្ទ ... ពោរពាស ... " ។ ព្រះសាស្តាទ្រង់ជ្រាបអធ្យាស្រ័យថា ឆន្ននេះអាងលើព្រះអង្គខ្លាំងណាស់ ហើយកាលព្រះអង្គគង់ព្រះជន្មនៅ នឹងមិនបានសម្រេចមគ្គផលអ្វីឡើយ ទាល់តែអស់ពីព្រះអង្គទៅទើបបានសម្រេច ។ ព្រះសាស្តាទ្រង់តែងបន្ទោសឱ្យភិក្ខុឆន្នជានិច្ច ហើយទ្រង់ផ្តាំនឹងព្រះអានន្ទថា " កាលអស់ពីព្រះអង្គហើយ ឱ្យអានន្ទធ្វើទោសព្រហ្មទណ្ឌ គឺកុំឱ្យអ្នកណានិយាយរកភិក្ខុឆន្ននេះឱ្យសោះ ។ លុះព្រះសាស្តាបរិនិព្វានទៅ អានន្ទបានដាក់ទោសព្រហ្មទណ្ឌដល់ឆន្នភិក្ខុ តាមព្រះ[illegible] ឆន្នភិក្ខុនឹកសង្វេគក្នុងចិត្ត ក៏ប្រឹងប្រព្រឹត្តធម៌រហូតបានសម្រេចអរហត្តផល។

www.elibraryofcambodia.org

៤. កាឡុទាយីអាមាត្យ ជាកូនអាមាត្យនៅក្នុងព្រះរាជវាំងដែរ ហើយក្រោយមក ក៏បានជាអាមាត្យតពូជត្រកូលក្នុងព្រះរាជវាំង។ កាឡុទាយីនេះ ជាអាមាត្យទី១ ដែលព្រះបាទសិរីសុទ្ធោទនៈបញ្ជូនឱ្យទៅនិមន្តព្រះសាស្ដា ដែលគង់នៅឯក្រុងរាជគ្រឹះ ដើម្បីឱ្យយាងមកក្រុងកបិលព័ស្តុជាលើកដំបូង ។ កាឡុទាយីអាមាត្យនាំបរិវារ១ពាន់នាក់ទៅដល់ជួបព្រះសាស្ដា ហើយក៏ភ្លេចបណ្ដាំអស់ រួចបួសជាមួយបរិវារទាំង១ពាន់នាក់ទៀត លុះបួសហើយទើបនឹកឃើញព្រះបណ្ដាំ ហើយចូលទៅនិមន្តឱ្យយាងទៅកាន់ក្រុងកបិលព័ស្តុតាមព្រះបន្ទូលផ្ដាំផ្ញើ ។

៥. ជនទៃពីនេះមានសេះ១ គឺសេះរាជានេយ្យឈ្មោះកណ្ឋកៈប្រវែងខ្លួន ១៨ ហត្ថ ដែលបានជាជំនិះយាងពេញព្រះទ័យនៃព្រះពោធិសត្វ ។ កាលព្រះអង្គយាងទៅសាងព្រះផ្នួស ទ្រង់គង់លើសេះនេះទៅហើយកាលទ្រង់សាងផ្នួសរួច ឆន្នអាមាត្យដឹកសេះនេះត្រឡប់វិញ គ្រាន់តែផុតកន្ទុយភ្នែកសេះកណ្ឋកៈក៏បែកទ្រូងស្លាប់ ដោយចិត្តអាល័យព្រះជាម្ចាស់ពេក ហើយបានទៅកើតជាកណ្ឋកៈនៅ[illegible] ។

៦. មានដើមពោធិព្រឹក្ស១ដើម ក៏ដុះនៅថ្ងៃដំណាលនឹងព្រះអង្គប្រសូត្រដែរ គឺដុះនៅត្រង់គយាសិសប្រទេសឱរុវេលនិគម

www.elibraryofcambodia.org

ក្នុងដែនមគធៈ ។ ពោធិនេះក្រោយមកបានជាទីត្រាស់ដឹងនៃព្រះសាស្តា មានកំពស់ ៥០ ហត្ថ ។

៧- មានកំណប់ទ្រព្យ ៤ ទៀតគឺ :

ក- សង្ខនិធិ មានសំណុំមាត់ជុំវិញ ១ គាវុធ

ខ- ឯលនិធិ មានសំណុំមាត់ជុំវិញ កន្លះយោជន៍

គ- ឧបលនិធិ មានសំណុំមាត់ជុំវិញ ៣ គាវុធ

ឃ- បុណ្ឌរីកនិធិ មានសំណុំមាត់ជុំវិញ ១ យោជន៍

កំណប់ទ្រព្យទាំង ៤ នេះ មានជម្រៅទៅដល់ទីបំផុតផែនដីដូចគ្នា ។

មនុស្ស- សត្វ- រុក្ខជាតិ និងកំណប់ទ្រព្យដែលកើតពេលជំណាលគ្នា នឹងព្រះពោធិសត្វប្រសូត្រនោះ មាន ៧ ហៅថា សហជាតវត្ថុៗ ទាំងនេះសុទ្ធតែមានការទាក់ទងនឹងព្រះពោធិសត្វទាំងអស់ ។

www.elibraryofcambodia.org

# ភាគទី ៤

## ព្រះលក្ខណៈរូបនិងកុមារវ័យ នៃព្រះសិទ្ធត្ថពោធិសត្វ

ស. ព្រះពោធិសត្វទ្រង់ប្រសូត្ររួច ទ្រង់យាងទៅ ៧ ជំហាននោះអាចទុកជានិមិត្តរូបយ៉ាងណាដែរ ?

ច. អាចទុកជានិមិត្តរូបនៃការប្រកាសផ្សាយព្រះពុទ្ធសាសនាក្នុងជនបទទាំង ៧ គឺ កាសីនិងកោសល១ មគធ និងអង្គៈ១ សក្ក១ វជ្ជី១ មល្ល១ វង្ស១ កុរុ១ និងជនបទតូចៗ ក្រៅពីនេះដែលត្រូវនៅចំណុះជនបទមានទាំង ៧ នោះ ។

ស. កាលប្រសូត្រហើយ តើគេថ្វាយនាមថាដូចម្តេច ? ព្រោះអ្វី ?

ច. គេថ្វាយនាមថា សិទ្ធត្ថកុមារ ប្រែថា អ្នកសម្រេចប្រយោជន៍គ្រប់ប្រការ ។

ស. ចុះព្រះសិទ្ធត្ថកុមារ មានព្រះលក្ខណៈរូបដូចជនឯទៀតដែរ ឬប្លែកគ្នា បើប្លែកគ្នា តើប្លែកយ៉ាងណាខ្លះ ?

ច. ព្រះសិទ្ធត្ថកុមារ មានព្រះលក្ខណៈរូប ពុំដូចជនឯទៀតៗ ឡើយ គឺទ្រង់ប្រកបដោយព្រះលក្ខណៈរូប ៣២ ប្រការ អនុព្យញ្ជនៈ ៨០ និងមង្គល ១០៨ ប្រការគឺ :

www.elibraryofcambodia.org

## ព្រះលក្ខណៈរូប ៣២ ប្រការ

១. មានផ្ទៃព្រះបាទទាំងគូរាបស្មើ. ២. លើផ្ទៃព្រះបាទមានរូបចក្រមានកង់និងផ្តុំព្រមទាំងកាំមួយពាន់ ហើយមានចន្លោះៗ ស្មើគ្នា. ៣. មានកែងវែង គឺ ១ ភាគ ៤ ជាតួកែង ។ ៤. ម្រាមព្រះហស្ត និងម្រាមព្រះបាទវែងៗ គឺម្រាមព្រះហស្តទាំង ៤ ស្មើគ្នា ឯម្រាមព្រះបាទទាំង៥ វែងស្មើគ្នា ហើយម្រាមទាំងអស់រៀវល្អដូចម្សៅដ៏ល្អិត ដែលគេលុញលាយប្រេង. ៥. ផ្ទៃព្រះហស្ត និងផ្ទៃព្រះបាទទន់ល្មន់ដូចសំឡី. ៦. ព្រះហស្ត និងផ្ទៃព្រះបាទប្រទាក់ដោយក្រឡាល្អិតៗ ដូចសំណាញ់. ៧. កព្រះបាទអណ្តែកឡើងហាក់ដូចជាមិនជាប់និងព្រះបាទ. ៨. មានស្មងវែងមូលស្រដៀងនឹងស្មងសត្វទ្រាយ. ៩. ទ្រង់អាចឈរហើយស្ទាបជង្គង់ដោយព្រះហស្តទាំងពីរបាន ដោយមិនបាច់ឱន. ១០. មានព្រះអង្គជាតិស្ថិតនៅស្រោម ដូចអង្គជាតិគោឈ្មោល ឬដំរី. ១១. មានពណ៌សម្បុរថ្ងៃ (សុវណ្ណ) ភ្លឺរលោងដូចពណ៌មាស. ១២. សម្បុរថ្ងៃល្អិតផូរផង់រលើងរលោងស្រិល ធូលីមិនអាចជាប់បាន. ១៣. មានរោមតែមួយ ១ ក្នុងរណ្តៅមួយៗគ្រប់រណ្តៅ. ១៤. មានរោមខៀវស្រស់ដូចផ្កាអញ្ចន ចុងឡើងវិលព័ទ្ធពេននៅខាងស្តាំ. ១៥. ព្រះកាយត្រង់ដូចកាយព្រហ្ម. ១៦. មានសាច់ ៥

www.elibraryofcambodia.org

កន្លែងគឺ ខ្នងព្រះហស្តទាំងពីរ, ខ្នងព្រះបាទទាំងពីរ និងកពេញបរិបូណ៌ល្អឥតឃើញសរសៃឡើយ. ១៧- ឲ្យព្រះកាយដែលគួរខ្ពស់, វែង, ស្តម, ធាត់, មូល, សំប៉ែតក៏ខ្ពស់, វែង, ស្តម, ធាត់, មូល, សំប៉ែតឥតថ្កង ។ ១៨- ចង្អូរខ្នងពេញស្មើឥតផត ខ្នងឡើយ. ១៩- មានទ្រង់ទ្រាយព្រះកាយដូចបរិមណ្ឌលដើមជ្រៃ គឺដើមជ្រៃមានដើមនិងមែកប្រវែងគ្នាមិនលើសមិនខ្វះ. ២០- ព្រះកមូលសម. ២១- មានសរសៃប្រសាទ៧ ពាន់ល្អិតប្រជុំត្រង់កសម្រាប់ទទួលនាំអាហារទៅផ្សព្វផ្សាយក្នុងព្រះកាយឥតទើសទាក់ សូម្បីអាហារ ១ គ្រាប់តូចប៉ុនគ្រាប់ល្ងក៏ដោយ. ២២- មានព្រះចង្កាពេញបរិបូណ៌ប្រហែលនឹងវង់ព្រះខែនៃថ្ងៃ១២ កើត។ ២៣- មានព្រះទន្ត៤០ គត់ គឺលើ ២០ ក្រោម ២០ ។ ២៤- ព្រះទន្តទាំង ៤០ រាបស្មើល្អ ។ ២៥- ព្រះទន្តទាំង ៤០ ជិតស្និទ្ធល្អ. ២៦- ព្រះចង្កូមកែវទាំង៤ សស្អាត ភ្លឺជាងពន្លឺផ្កាយព្រឹក. ២៧- មានព្រះអណ្តាតល្មម ប្លែកពីអណ្តាតមនុស្សទាំងពួង. ២៨- ព្រះសូរសៀងក្រាងក្រអៅដូចសំឡេងរាជសីហ៍ ហើយពិរោះដូចសំឡេងករវីក. ២៩- ព្រះនេត្រត្រង់កន្លែងខៀវក៏ខៀវស្រស់ដូចផ្កាត្រកៀត, ត្រង់កន្លែងលឿងក៏លឿងដូចផ្កាកណ្ណិកា, ត្រង់កន្លែងក្រហមក៏ក្រហមដូចផ្កាច្បារ, ត្រង់កន្លែងដែលស ក៏សត្រចះដូចផ្កាយព្រឹក, ត្រង់

www.elibraryofcambodia.org

កន្លែងដែលគួរខ្មៅ ក៏ខ្មៅដូចផ្លែផ្តាំ ។ ៣០. ដួងព្រះនេត្រថ្វាយង់ដូចភ្នែកកូនគោដែលទើបនឹងកើត ។ ៣១. ព្រះកេសរុះត្រង់ចន្លោះចិញ្ចើមសទន់ដូចសំឡី ។ ៣២. ព្រះសិរមូលល្អដូចពពុះទឹក ឬដូចវត្ថុដែលគេក្រឡឹង ។

## អនុព្យញ្ជនៈ ៨០ គឺ :

១. ម្រាមព្រះហស្ត និងម្រាមព្រះបាទមានពណ៌លឿង, ២. ម្រាមព្រះហស្ត និងម្រាមព្រះបាទមូលល្អ, ៤. ក្រចកទាំង២០ មានពណ៌ក្រហម, ៥. ក្រចកទាំង២០ ងស្មើតឡើង, ៦. ក្រចកមានពណ៌រលោងរលើប, ៧. កព្រះហស្ត និងកព្រះបាទត្រូតនៅក្នុងសាច់, ៨. ព្រះបាទស្មើគ្នា, ៩. ព្រះដំណើរល្អយាងយាសដូចដំណើរដំរី, ១០. ព្រះដំណើរល្អដូចជាដំណើរនៃរាជសីហ៍, ១១. ព្រះដំណើរល្អដូចជាដំណើរនៃហង្ស, ១២. ព្រះដំណើរដូចជាដំណើរនៃគោឧសភរាជ, ១៣. បើទ្រង់ឈរហើយត្រូវយាងទៅ តែងតែលើកព្រះបាទខាងស្តាំបោះទៅមុនជាដរាប, ១៤.ព្រះមណ្ឌលជង្គង់មូលល្អ, ១៥. មានព្យញ្ជនៈជាបុរសពេញគ្រប់គ្រាន់ គឺមិនមានកិរិយាដូចស្ត្រីឡើយ, ១៦. ផ្ចិតមិនខូងមិនផត គឺមូលស្មើល្អ . ១៧. ពោះមានសណ្ឋានជ្រៅ, ១៨. ពោះមានសណ្ឋាន

www.elibraryofcambodia.org

ខ្ទេរិលទៅខាងស្តាំ ( ទក្ខិណាវដ្ត ) , ១៩. ភ្លៅទាំងគូមូលល្អ. ២០. ព្រះហស្តទាំងគូល្អ. ២១. ព្រះអវៈយវៈ ធំតូចទាំងអស់មានលក្ខណៈល្អតាមចំណែក១. ២២. សាច់ដែលគួរក្រាសក៏ក្រាស. ២៣. សាច់មិនយា ឬជ្រួញជ្រីវ. ២៤. កាយគ្មានប្រជ្រុយឬអាចម៍រុយ. ២៥. ព្រះកាយាវយវៈសមគ្នាតាមលំដាប់លំដោយលើក្រោម ២៦. ព្រះកាយបរិសុទ្ធ គ្មានមន្ទិល. ២៧. មានព្រះកម្លាំងច្រើន. ២៨. មានច្រមុះខ្ពស់សម. ២៩. សណ្ឋានច្រមុះល្អ , ៣០. បបូរព្រះឱសលើក្រោមមិនបានចូលចេញលើសគ្នា. ៣១. ព្រះទន្តឥតគ្រៀងសៅហ្មង. ៣២. ព្រះទន្តសម្បុរស័ង្ខ. ៣៣. ព្រះទន្តរលីងស្អាត. ៣៤. ព្រះឥន្ទ្រីយ៍ទាំង ៥ បរិសុទ្ធល្អ. ៣៥. ព្រះចង្កូមទាំង ៤មូលពេញលេញ. ៣៦. វង់ព្រះភក្ត្រមានទម្រង់មូលទ្រវែងសមល្អ. ៣៧. ថ្ពាល់ទាំងគូល្អភ្លឺថ្លាស្មើគ្នា. ៣៨. អព្ភាញព្រះហស្តមានស្នាមជ្រៅ. ៣៩. អព្ភាញព្រះហស្តមានស្នាមវែង. ៤០. អព្ភាញព្រះហស្តមានស្នាមត្រង់. ៤១. អព្ភាញព្រះហស្តមានស្នាមក្រហមរុងរឿង. ៤២. រស្មីព្រះកាយមានពន្លឺជាបរិមណ្ឌល. ៤៣. ថ្ពាល់ទាំងគូពេញកំពុងណែនល្អ. ៤៤. ត្របកព្រះនេត្រទូលាយវែងសម. ៤៥. ព្រះនេត្រប្រកបដោយប្រសាទទាំង៥. ៤៦. ចុងសរសៃព្រះរោមទាំងឡាយមិនបានវៀច. ៤៧. អណ្តាត

www.elibraryofcambodia.org

មានទម្រង់ល្អ. ៤៨- អណ្ដាតទន់មិនរឹង. ៤៩-ដោះទាំងគូមានទម្រង់វែងដូចជាត្របកបទុមជាតិ. ៥០- វង្សព្រះកមានទម្រង់មូល. ៥១- សរសៃទាំងពួងស្ដួតឥតជ្រួញ. ៥២- ជួរសរសៃទាំងឡាយត្រួតនៅក្នុងសាច់ទាំងអស់. ៥៣- ព្រះសិរមានទម្រង់ដូចឆ័ត្រកែវ. ៥៤- បរិមណ្ឌលថ្ងាសទូលាយវែងល្មម. ៥៥- ថ្ងាសមានទម្រង់ដ៏ល្អ. ៥៦-ចិញ្ចើមមានទម្រង់ដ៏ល្អដូចដងធ្នូ. ៥៧- ព្រះរោមចិញ្ចើមមានសរសៃដ៏ល្អិត. ៥៨- សរសៃព្រះរោមចិញ្ចើមដុះហើយដួលរាបទៅដោយលំដាប់. ៥៩- ព្រះចិញ្ចើមធំល្មម. ៦០- ព្រះចិញ្ចើមវែងផុតចុងព្រះនេត្រ. ៦១- សម្បុរថ្ងៃល្អិតធ្វារពេញព្រះកាយ. ៦២- ព្រះកាយរុងរឿងទៅដោយសិរី. ៦៣- ព្រះសិរីរកាយតែងភ្លឺថ្លាមិនស្អាប់សៅហ្មង. ៦៤- ព្រះសិរីរកាយស្រស់ថ្លាដូចផ្កាឈូក. ៦៥- ព្រះសិរីរកាយមានសម្ផស្សទន់ភ្លន់. ៦៦-ក្លិនព្រះកាយក្រអូបឈ្ងុយដូចក្លិនផ្កា. ៦៧- ព្រះរោមមានសរសៃស្មើគ្នាទាំងអស់. ៦៨-ព្រះរោមមានសរសៃល្អិតធ្វារ. ៦៩- ព្រះដង្ហើមចេញចូលល្អិត. ៧០- ព្រះឱស្ឋមានទម្រង់ល្អហាក់ដូចជាទ្រង់ព្រះញញឹមជានិច្ច. ៧១- ក្លិនព្រះឱស្ឋក្រអូបដូចក្លិនឧប្បល. ៧២-ព្រះកេសាខ្មៅរលោងស្រិល. ៧៣- ព្រះកេសាមានក្លិនដូចជាក្លិននៃផ្កាកោមល. ៧៥- ព្រះកេសាមានទម្រង់មូល ព័ទ្ធព្រះកេស.

www.elibraryofcambodia.org

៧៦. ព្រះកេសាខ្មៅស្និទ្ធ, ៧៧. សរសៃព្រះកេសាធ្មារល្អិត, ៧៨. សរសៃព្រះកេសាស្លូត, ៧៩. សរសៃព្រះកេសាវិលព័ទ្ធព្រះកេសានៅខាងស្តាំ, ៨០. មានព្រះរស្មីភ្លឺចិញ្ចាចលើព្រះសិរ ។

## ទ្រង់ប្រកបដោយមង្គល ១០៨ គឺ

ត្រង់ផ្ទៃព្រះបាទទាំងគូប្រកបដោយកងចក្រមួយម្ខាង នៅត្រង់កណ្តាលផ្ទៃព្រះបាទ ។ កងចក្រមានកាំ១ពាន់មានកង់និងដុំ។ ខាងក្រៅកងចក្រមានរូបមង្គល ១០៨ យ៉ាងគឺ : ១. រូបលំពែង, ២. រូបកញ្ចក់ឆ្លុះ, ៣. រូបផ្កានូនស្រី, ៤. រូបខ្សែសយ, ៥. រូបសង្វារ, ៦. រូបថាសមាស, ៧. រូបជើងតាំង, ៨. រូបមច្ឆាទាំងគូ, ៩. រូបប្រាសាទ, ១០. រូបកង្វេរ, ១១. រូបសសរខឿន, ១២. រូបស្វេតឆត្រ, ១៣. រូបព្រះខ័ន, ១៤. រូបផ្លិតស្លឹកត្នោត, ១៥. រូបផ្លិតកន្ទុយក្ងោក, ១៦. រូបផ្លិតរោមម្រឹគ, ១៧. រូបមកុដ, ១៨. រូបបាត្រ, ១៩. រូបកម្រងផ្កាម្លិះ, ២០. រូបផ្កាឧប្បលខៀវ, ២១. រូបផ្កាឧប្បលស, ២២. រូបផ្កាឧប្បលក្រហម, ២៣. រូបផ្កាឈូកក្រហម, ២៤. រូបផ្កាឈូកស, ២៥. រូបថ្នាំងមានទឹកពេញ, ២៦. រូបសមានទឹកពេញ, ២៧. រូបមហាសមុទ្រទាំង៤, ២៨. រូបភ្នំចក្រវាឡ, ២៩. រូបព្រៃហេមពាន្ត, ៣០. រូបភ្នំព្រះសុមេរុ,

www.elibraryofcambodia.org

៣១. រូបព្រះចន្ទ, ៣២. រូបព្រះអាទិត្យ, ៣៣.រូបពួកផ្កានក្ខត្តឫក្ស ៣៤. រូបមហាទ្វីបទាំងបួន, ៣៥. រូបទ្វីបតូចៗទាំងពាន់, ៣៦.រូបព្រះបរមចក្រពត្តិរាជនិងបរិវារ, ៣៧. រូបស័ង្ខទក្ខិណាវ័ដ្ដ, ៣៨. រូបត្រីមាស, ៣៩. រូបចក្រទាំងគូ, ៤០. រូបស្ទឹងទាំងប្រាំពីរ, ៤១. រូបស្រះធំទាំង៧, ៤២. រូបភ្នំបរិភណ្ឌទាំង៧, ៤៣. រូបស្តេចគ្រុឌ, ៤៤. រូបក្រពើ, ៤៥. រូបទង់ជ័យសំពត់ទាំងផ្ទត់, ៤៦. រូបរតនបល្ល័ង្គ, ៤៧. រូបកៅអី, ៤៨. រូបភ្នំកៃលាស, ៤៩. រូបរាជសីហ៍, ៥០. រូបស្តេចខ្លា, ៥១. រូបដំរីឯរាវ័ណ្ណ, ៥២. រូបស្តេចវរាហក, ៥៣. រូបវាសុកីនាគរាជ, ៥៤. រូបស្តេចហង្ស, ៥៥.រូបមានព្រៃ, ៥៦. រូបគោឧសភរាជ, ៥៧. រូបស្តេចដំរីឧបោសថ, ៥៨. រូបស្តេចដំរីឆទ្ទន្ត (ដំរីមានភ្លុក), ៥៩. រូបមករមាស, ៦០. រូបមហាព្រហ្មមុខ៤, ៦១. រូបផ្ទះមាស, ៦២. រូបអណ្តើកមាស, ៦៣. រូប[illegible]គោព្រមទាំងកូន, ៦៤. រូបកិន្នរឈ្មោល, ៦៥. រូបកិន្នរញី, ៦៦. រូបសត្វករវិក, ៦៧. រូបសត្វក្រៀល, ៦៨. រូបសត្វក្ងោក, ៦៩. រូបសត្វចាក្រពាក, ៧០.រូបស្តេចគ្របីត ៧១. រូបកាមាវចរសួគ៌ទាំង៦ជាន់, ៧២. រូបសោឡសមហាព្រហ្មទាំង១៦ ជាន់ ។ រូបទាំងនេះស្ថិតនៅជុំវិញកងចក្រត្រង់កណ្តាលព្រះបាទឆ្វេងស្តាំដូចគ្នា ។

www.elibraryofcambodia.org

ស. កាលព្រះសិទ្ធត្ថកុមារប្រសូត្រហើយ តើព្រះបិតាបាន ធ្វើពិធីអ្វីថ្វាយដែរ ? នៅប៉ុន្មានថ្ងៃក្រោយពីការប្រសូត្រនោះ ?

ច. ព្រះបិតាបានធ្វើពិធីមួយ ដើម្បីអញ្ជើញព្រាហ្មណ៍មក ទាយព្រះលក្ខណៈថ្វាយព្រះសិទ្ធត្ថកុមារ ក្រោយពេលប្រសូត្រ ហើយ ៥ ថ្ងៃ ។

ស. តើមានព្រាហ្មណ៍ប៉ុន្មាននាក់ ដែលបានទាយលក្ខណៈ ថ្វាយព្រះកុមារ ? ឈ្មោះអ្វីខ្លះ ? ព្រាហ្មណ៍ណាទាយថាយ៉ាង ណាខ្លះ ?

ច. មានព្រាហ្មណ៍ ៨ នាក់គឺ ឈ្មោះរាមព្រាហ្មណ៍១, លក្ខណៈព្រាហ្មណ៍១, យញ្ញព្រាហ្មណ៍១, ធនព្រាហ្មណ៍១, ភោជព្រាហ្មណ៍១, សុទត្តព្រាហ្មណ៍១, សុយាមព្រាហ្មណ៍១, កោណ្ឌញ្ញព្រាហ្មណ៍១[1] ។

ព្រាហ្មណ៍ទាំង ៨ នាក់នេះ, ៧ នាក់ខាងដើម បានទាយ តាមជំណើរ ២ យ៉ាងគឺថា "បើនៅខាងឃរាវាសរហូត នឹងបាន

---

(១). ថាព្រះសុទ្ធោទនៈ យកព្រាហ្មណ៍ចេះហោរាសាស្ត្រចំនួន ១០៨ នាក់ មក ប្រជុំគ្នា ហើយជ្រើសរើសសម្រិតសម្រាំងយកតែព្រាហ្មណ៍ ៨ នាក់ដែលចេះ ជាងគេឱ្យទាយលក្ខណៈថ្វាយព្រះរាជបុត្រ ។

www.elibraryofcambodia.org

ជាស្តេចបរមចក្រពត្តិ បើយាងចេញទៅបួសនឹងបានត្រាស់ជាព្រះសព្វញ្ញុពុទ្ធ" ឯកោណ្ឌញ្ញព្រាហ្មណ៍ដែលមានវ័យក្មេងជាងគេបានទាយថ្វាយតែម្យ៉ាងថា "ព្រះសិទ្ធត្ថកុមារមុខជានឹងយាងចេញទៅបួស ហើយនឹងបានត្រាស់ជាព្រះពុទ្ធយ៉ាងពិតប្រាកដ" ។ តាមរឿងដំណាលថា ព្រាហ្មណ៍ ៧ នាក់ខាងដើមមានវ័យចាស់ជរាក៏ស្លាប់អស់ តែបានផ្តាំកូនរបស់ខ្លួន ឱ្យចេញបួសតាមព្រះសិទ្ធត្ថគ្រប់គ្នា ។ ឯកោណ្ឌញ្ញព្រាហ្មណ៍ បានរស់នៅហើយចេញបួសជាមួយកូនព្រាហ្មណ៍ ៤ នាក់ទៀតមានឈ្មោះថា "បញ្ចវគ្គិយភិក្ខុ" ហើយកាលព្រះពុទ្ធបានត្រាស់ថ្មីៗ ក៏បានសំដែងធម្មចក្រប្រោសបញ្ចវគ្គិយភិក្ខុ ក៏បានសម្រេចមគ្គផលដែលក្នុងចំណោមនោះ ព្រះកោណ្ឌញ្ញត្ថេរ បានជា រត្តិញ្ញូ គឺជាអ្នកដឹងស្គាល់ច្បាស់នូវយាមនៃរាត្រីកាល ។

ស- នៅពេលប្រសូត្រហើយថ្មីៗ ព្រះកុមារមានគុណវិសេសយ៉ាងណាខ្លះ ? មានហេតុភេទដូចម្តេច ?

ច- មានហេតុអស្ចារ្យយ៉ាងនេះ គឺថ្ងៃ១ព្រះកាឡទេវិលតាបស ជាជីតូនរបស់ព្រះបាទសិរីសុទ្ធោទនៈ បាននិមន្តចូលទៅកាន់ព្រះដំណាក់ដើម្បីសុំជួប សុំឃើញព្រះកុមារ។ ព្រះសុទ្ធោទនៈ

www.elibraryofcambodia.org

បានឱ្យគេនាំព្រះកុមារមកថ្វាយបង្គំព្រះតាបស តែព្រះបាទរបស់ព្រះកុមារបែរជាទៅប្រតិស្ឋានលើជតាតាបសទៅវិញ ។ ឃើញដូច្នោះ តាបសក៏ធ្វើនមស្ការហើយសើចរួចយំ ។ ព្រះសុទ្ធោទនៈឃើញដូច្នោះក៏ថ្វាយបង្គំព្រះរាជបុត្រ រួចសួរព្រះតាបស ១ ទូលថា អាត្មាសើច ព្រោះការសប្បាយនឹងព្រះកុមារ ដែលនឹងបានត្រាស់ជាព្រះពុទ្ធ អាត្មាយំ ព្រោះនឹកថា ខ្លួនចាស់ណាស់ហើយមុខជាស្លាប់ខានជួបព្រះកុមារ ដែលនឹងបានត្រាស់ជាព្រះពុទ្ធទៅអនាគតកាលនោះជាមិនខាន ។ រួចព្រះកាឡទេវិលតាបសបានទាយព្រះលក្ខណៈព្រះកុមារថា "ពិតជានឹងបានត្រាស់ជាព្រះពុទ្ធមិនខានឡើយ" ។ កាលនិមន្តត្រឡប់ទៅវិញ ក៏ប្រាប់ក្មួយម្នាក់ឈ្មោះនាឡកមាណពឱ្យចេញបួស ដើម្បីរង់ចាំការបានត្រាស់នៃព្រះសិទ្ធត្ថ ។ នាឡកចេញបួស ហើយកាលព្រះពុទ្ធបានត្រាស់ឡើង ក៏បានជួបនឹងព្រះអង្គ១ បានសំដែងមោនេយ្យបដិបត្តិឱ្យស្តាប់ ក៏បានសម្រេចអរហត្តផល ។ ព្រះកាឡទេវិលតាបសកាលស្លាប់ទៅ បានទៅកើតក្នុងស្ថានព្រហ្មលោក ។

មានរឿងដំណាលម្យ៉ាងទៀតថា កាលព្រះសិទ្ធត្ថកុមារបានព្រះជន្មថ្ងៃ ទ្រង់បានសម្រេចបឋមជ្ឈាន នៅពេលដែលព្រះបិតាចេញច្រត់ព្រះនង្គ័ល ហើយទុកព្រះកុមារឱ្យផ្ទំក្រោមដើម

www.elibraryofcambodia.org

ព្រីងធំ ។ ព្រះបិតាកាលឃើញព្រះរាជបុត្រគង់ពែនភ្នែនស្ងប់ស្ងាត់ តាំងសមាធិដូច្នោះ ក៏ថ្វាយបង្គំម្តងទៀតជាលើកទីពីរ ។

ស- ព្រះសិទ្ធត្ថកុមារ ជារាជបុត្រទោលឬមានបងប្អូនដែរ ?

ច- ព្រះអង្គគ្មានបងប្អូនរួមឧទរមាតាជាមួយទេ ព្រោះពេលព្រះអង្គប្រសូត្រហើយបាន ៧ថ្ងៃ ព្រះនាងសិរិមហាមាយាជាព្រះមាតាទ្រង់សោយព្រះទិវង្គតទៅ ។ ទ្រង់មានតែព្រះអនុជរួមបិតាជាមួយពីរព្រះអង្គគឺ នន្ទកុមារ និងនាងរូបនន្ទា ។

ស- ព្រះនាងសិរិមហាមាយាសោយទិវង្គតព្រោះអ្វី ? ទ្រង់បានទៅកើតនៅទីណា ? អ្នកណានៅថែរក្សាព្រះសិទ្ធត្ថកុមារ ?

ច- ទ្រង់ទៅកើតនៅស្ថានតុសិត ។ ព្រះនាងឥតមានជម្ងឺអ្វីទេ តែធម្មតារបស់ពុទ្ធមាតាកាលប្រសូត្រព្រះរាជបុត្រហើយតែងនឹងសោយទិវង្គត ស្លាប់យ៉ាងនេះជាធម្មតាដូចជាដើមចេក ឬដើមអំពៅ កាលមានត្រយូង, មានផ្កាផ្លែហើយក៏តែងតែងាប់ ឥតដែលមានត្រយូង ផ្កា-ផ្លែ ជាលើកទីពីរទៀតទេ ម្យ៉ាងទៀតព្រះពុទ្ធមាតាដែលប្រសូត្រព្រះពោធិសត្វហើយ បើនៅមានព្រះជន្មតទៅទៀត ហើយបើព្រះស្វាមីបានទៅរួមសំវាស ព្រះស្វាមីនេះ

www.elibraryofcambodia.org

នឹងត្រូវបែកព្រះសិរជា ៧ ភាគមិនខាន ព្រោះទ្វារយោនីនៃពុទ្ធមាតា ដែលប្រសូត្រព្រះកុមារហើយ ជាទ្វារយោនីដ៏ល្អបរិសុទ្ធ ឥតមានបុត្រណាប្រសូត្រជាលើកទីពីរទេ ប្រសិនបើមានបុត្រណាប្រសូត្រអំពីព្រះនាង បុត្រនោះក៏នឹងត្រូវបែកព្រះសិរសា ៧ ភាគដែរ ។ នេះជាធម្មតារបស់ព្រះពុទ្ធ និងពុទ្ធមាតាគ្រប់ព្រះអង្គទាំងអស់ ។

កាលព្រះនាងសិរីមហាមាយាទិវង្គតទៅ ព្រះនាងគោតមីទទួលចិញ្ចឹមព្រះកុមារ ហើយព្រះនាងនេះជាមហេសីទី២ របស់ព្រះសុទ្ធោទនៈមានបុត្រ១ គឺនន្ទកុមារ និងបុត្រី១ គឺនាងរូបនន្ទាជាម្ដាយមីង (មាតុច្ឆា) របស់ព្រះសិទ្ធត្ថកុមារ ។ ព្រះនន្ទកុមារមានព្រះជន្មប្អូនព្រះសិទ្ធត្ថ តែ ២-៣ ថ្ងៃប៉ុណ្ណោះ ព្រោះព្រះបាទសុទ្ធោទនៈ បានយកព្រះនាងបជាបតិគោតមីតាំងពីដំណាលគ្នានិងព្រះនាងសិរីមហាមាយាឯណោះ គ្រាន់តែមិនបានតាំងក្នុងទីជាមហេសី ព្រោះមានព្រះនាងសិរីមហាមាយាជាមហេសីរួចទៅហើយ ។

ស- ព្រះសិទ្ធត្ថកុមារ ជាទីស្រឡាញ់រាប់អានរបស់ញាតិទេ ? គេបានបេ្តជ្ញាយ៉ាងណា ?

ច- ព្រះអង្គជាទីស្រឡាញ់នៃញាតិណាស់ ព្រះញាតិខាង

www.elibraryofcambodia.org

មាតា ៨០ ពាន់ ខាងបិតា ៨០ ពាន់ សុទ្ធតែបានប្ដេជ្ញាថា បើព្រះសិទ្ធត្ថបានជាស្ដេចក្ដី ជាព្រះពុទ្ធក្ដី នឹងថ្វាយបុត្រមួយអង្គ១ម្នាក់ ។

ស. គេបានធ្វើអ្វីថ្វាយព្រះអង្គខ្លះ ?

ច. កាលទ្រង់មានព្រះជន្ម ៧ ឆ្នាំ វិស្សុកម្មទេវបុត្របាននិម្មិតស្រះបោក្ខរណីប្រកបដោយកែវ ៧ ប្រការថ្វាយ ។ កាលទ្រង់ព្រះជន្ម ១៦ ឆ្នាំ ព្រះបិតាបានឱ្យជាងធ្វើប្រាសាទ ៣ ថ្វាយគឺ ចន្ទប្រាសាទ១ មាន ៩ ជាន់សម្រាប់គង់នៅហេមរដូវ, កោកនទប្រាសាទ១ មាន ៥ ជាន់សម្រាប់គង់នៅគិម្ហរដូវ, កោញ្ចប្រាសាទ១មាន៣ជាន់សម្រាប់គង់នៅវស្សានរដូវ ។

ស. កាលនៅពីយុវវ័យ តើព្រះសិទ្ធត្ថបានទៅរៀនសិល្បសាស្ត្រដែរ ? ទ្រង់ចេះសិល្បសាស្ត្រយ៉ាងណាខ្លះ ?

ច. បានរៀនជាមួយអាចារ្យពិស្វាមិត្រដែរ, ទ្រង់ចេះសិល្បសាស្ត្រច្រើនៗ ដូចយ៉ាងកាលព្រះបាទសុទ្ធោទនៈត្រាសបញ្ជាឱ្យព្រះញាតិយករាជធីតាមកថ្វាយ ពួកញាតិប្រកែកថា ព្រះសិទ្ធត្ថមិនចេះសិល្បសាស្ត្រអ្វី ព្រះអង្គក៏សំដែងឫទ្ធិ គឺលើកធ្នូដ៏មានកំលាំង ១ពាន់ ហើយបានឡើងលាន់កក្រើកធរណី ។ ពួកសាក្យរាជក៏ខ្លាចព្រះសិទ្ធត្ថខ្លាំងណាស់ ។

www.elibraryofcambodia.org

# ការឡើងសោយរាជ្យសម្បត្តិ

ស- ព្រះសិទ្ធត្ថកុមារ ទ្រង់ឡើងសោយរាជ្យសម្បត្តិនៅថ្ងៃ ខែ ឆ្នាំណា ? មានមហេសីព្រះនាមអ្វី ? ក្នុងព្រះជន្មប៉ុន្មាន ?

ច- ទ្រង់ឡើងសោយរាជ្យសម្បត្តិនៅ ថ្ងៃសៅរ៍ ពេញបូរមី ខែ អាសាឍ ឆ្នាំ ឆ្លូវ ដោយមានព្រះនាងពិម្ពាយសោធរា ជារាជធីតានៃព្រះបាទសុប្បពុទ្ធនៅនគរទេវទហៈ ជាព្រះអគ្គមហេសី ក្នុងព្រះជន្ម ១៦ វស្សា ។

www.elibraryofcambodia.org

# ភាគទី ៥

## ការចេញសាងព្រះផ្នួស
## និងការធ្វើទុក្ករកិរិយា នៃព្រះពោធិសត្វ

ស- តាំងពីពេលព្រះសិទ្ធត្ថកុមារប្រសូត្ររហូតទល់ពេលបានសោយរាជសម្បត្តិនេះ តើព្រះបាទសុទ្ធោទនៈ មានការចាប់អារម្មណ៍ចំពោះព្រះរាជបុត្រយ៉ាងណា ? ទ្រង់ធ្វើយ៉ាងណា ? ព្រោះហេតុអ្វី ?

ច- ព្រះសុទ្ធោទនៈជាបិតា មានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះព្រះរាជបុត្រតែ១ ដែលជាទីស្រឡាញ់ពេញព្រះទ័យ ខ្លាចក្រែងតែព្រះរាជបុត្រយាងចេញទៅបួស។ ការចាប់អារម្មណ៍នេះ ព្រោះព្រាហ្មណ៍ហោរាក្តី កាឡទេវិលតាបសក្តី សុទ្ធតែព្យាករថ្វាយថា "ព្រះសិទ្ធត្ថកុមារពិតជាចេញទៅបួស ព្រោះឃើញទេវទូតទាំង៤ ហើយកាលបួសរួចនឹងបានត្រាស់ជាព្រះពុទ្ធមិនខាន" ។ គឺដោយបានដឹងជាមុននេះហើយ ដែលជាហេតុនាំឱ្យព្រះសុទ្ធោទនៈទ្រង់ប្រយ័ត្នខ្លាំងណាស់ គឺហាមផ្តាច់មិនឱ្យមានមនុស្សចាស់, ឈឺ, ស្លាប់ មកជិតឱ្យព្រះរាជបុត្រឃើញឡើយ ។ មិនតែប៉ុណ្ណោះសោត ព្រះអង្គប្រឹងធ្វើយ៉ាងណា ដើម្បីឱ្យព្រះរាជបុត្រនៅគ្រងរាជសម្បត្តិជាមហាក្សត្រ និងបានជាស្តេចចក្រក្នុង

www.elibraryofcambodia.org

លោកនេះឯង ។ ការប្រឹងនេះ គឺដោយបានពូទំនាយរបស់ហោរាផង ដោយការយល់ និងចំណង់របស់ព្រះអង្គផង ។

ស. ព្រះសិទ្ធត្ថមុននឹងយាងចេញទៅសាងផ្នួស ទ្រង់បានឃើញអ្វី ? ដោយហេតុយ៉ាងណា ? នៅទីណា ?

ច. ទ្រង់ទតឃើញទេវទូតទាំង ៤ ដែលមកនិម្មិតធ្វើជាមនុស្សចាស់ម្តង ។ ៤ ខែទៀតទ្រង់ទតឃើញមនុស្សឈឺម្តង ។ ៤ ខែកន្លងមកទៀតទ្រង់ទតឃើញមនុស្សស្លាប់ម្តង ។ ៤ ខែទៀតទ្រង់ទតឃើញអ្នកបួសម្តងទៀតនៅក្នុងឱទ្យាន ពេលដែលទ្រង់យាងទៅក្រសាល ។

ស. ព្រះសិទ្ធត្ថទ្រង់យាងទៅសាងព្រះផ្នួស ព្រោះតែឃើញទេវទូតទាំងនោះតែម្យ៉ាង ឬព្រោះហេតុផ្សេងដែរ ?

ច. តាមពិតមិនមែនត្រឹមតែទេវទូត ដែលសុទ្ធាវាសទេវតាមកនិម្មិតថ្វាយនោះទេ ក៏ប៉ុន្តែដោយអភិនីហារបារមីដ៏ចាស់ក្លាផង ដោយព្រះពុទ្ធិញាណរបស់ព្រះអង្គផង ឯទេវទូតគ្រាន់តែជានិមិត្តរូប ឬជាហេតុ[illegible]ព្រះអង្គធុញទ្រាន់នឹងឃរាវាសតែប៉ុណ្ណោះ ពោលគឺកាលព្រះអង្គទតឃើញទេវទូតទាំង៣ ខាងដើមទ្រង់មានព្រះទ័យភ័យខ្លាចញាប់ញ័រខ្លាំងហោស ហើយមានការធុញទ្រាន់ជិនណាយនឹងកាមសុខផង លុះដល់ទ្រង់ទតឃើញទេវ

www.elibraryofcambodia.org

ទូតទី ៤ គឺភេទអ្នកបួស ទ្រង់ក៏ជ្រះថ្លានឹងភេទនេះយ៉ាងខ្លាំង ហើយក៏មានព្រះទ័យចង់យាងសាងផ្នួស ឥតមានអ្វីមកឃាត់ឃាំងគ្មានឡើយ ។

ស- ព្រះសិទ្ធត្ថទ្រង់យាងចេញសាងព្រះផ្នួសថ្ងៃ ខែ ឆ្នាំណា ? វេលាថ្មើរណា ? ដោយសារអ្វី ? ជាមួយអ្នកណា ? ទ្រង់សោយរាជ្យបានប៉ុន្មានឆ្នាំហើយ ? ក្នុងព្រះជន្មប៉ុន្មាន ? ទ្រង់មានរាជបុត្រាបុត្រីឬទេ ?

ច- ទ្រង់យាងចេញសាងផ្នួស នៅថ្ងៃព្រហស្បតិ៍ ពេញបូរមី ខែអាសាឍ ឆ្នាំថោះ វេលាអធ្រាត្រ ដោយសារព្រះទីនាំងសេះ ឈ្មោះកណ្ឋកៈ មានឆន្នអាមាត្យជូនព្រះដំណើរផង ក្រោយពីពេលទ្រង់សោយរាជ្យបាន ១៣ ឆ្នាំ ក្នុងជន្មាយុ ២៩ ឆ្នាំ ។ តាមសេចក្ដីដំណាលថា នៅពេលថ្ងៃទ្រង់យាងទៅប្រពាតឧទ្យាន លុះត្រឡប់មកវិញ ទ្រង់ឮនាងកីសាគោតមីខត្តិយកញ្ញា ទូលថាព្រះនាងពិម្ពាប្រសូត្រព្រះរាជបុត្រហើយ ព្រះសិទ្ធត្ថទ្រង់ដោះកែវមុក្តាថ្វាយព្រះនាងនោះ ហើយទ្រង់ឡើងលើប្រាសាទស្រង់សោយ រួចផ្ទុំយ៉ាងស្កប់ស្កល់ផុតបឋមយាម ។ តើនឡើងក្នុងមជ្ឈិមយាម ទ្រង់ព្រះវិតក្កថា "រាជបុត្រនេះជាចំណងធំណាស់" ហើយទ្រង់ ទតទៅឃើញស្ត្រីរបាំដេក

www.elibraryofcambodia.org

ប្រគរគ្នាដោយអាការប្លែកៗ ជាហេតុនាំឱ្យព្រះអង្គនឹកភ្នកក្នុងព្រះទ័យថា ទីនេះពោរពេញទៅដោយសាកសព ហើយទ្រង់ដាស់ឆន្នរាមាត្យឱ្យទៅដឹកសេះកណ្ឋកៈមក ឯព្រះអង្គទ្រង់យាងចូលទៅក្នុងបន្ទប់នាងពិម្ពា ដោយមានប្រាថ្នានឹងបីពរថើបព្រះរាជបុត្រ តែព្រះនាងពិម្ពាដាក់រាជបុត្រឱ្យផ្ទំក្បែរព្រះនាង ព្រះមហាបុរសទ្រង់ខ្លាចព្រះនាងពិម្ពាភ្ញាក់ ទ្រង់ក៏យាងចុះពីប្រាសាទដោយព្រះចិន្តាថា "ព្រោះក្រោយសឹមជួបភក្ត្របុត្រវិញ" ។

ស. កាលព្រះអង្គគង់លើខ្នងអស្សតរយាងចេញទៅ តើទ្រង់បាននឹកគិត ឬងាកមកទតព្រះនគរវិញទេ ? ទីនោះមានឈ្មោះអ្វីដែរ ?

ច. ព្រះសិទ្ធត្ថរាជទ្រង់យាងគង់លើខ្នងសេះ ហើយជិះចេញទៅដល់ខាងក្រៅព្រាសាទ ទ្រង់ក៏ងាកទតអកព្រះរាជវាំងវិញ ទើបបានជាគេហៅទីនោះឈ្មោះថា "កុនិវត្តនចេតិយ"។

ស. កាលចេញពីដំណាក់ទៅ តើបានជួបនិងអ្នកណាឬទេ ? ទ្រង់មានព្រះបន្ទូលយ៉ាងណាខ្លះដែរ ?

ច. កាលចេញទៅផុតព្រះដំណាក់ ទ្រង់ជួបនឹងទេវបុត្រមារមកឃាត់ព្រះអង្គថា "នែព្រះសិទ្ធត្ថ ! កុំចេញទៅបួសអីព្រោះនៅតែ ៧ ថ្ងៃទៀត ទ្រង់នឹងបានសម្បត្តិចក្រហើយ" ព្រះ

www.elibraryofcambodia.org

សិទ្ធត្ថឆ្លើយតបថា "នែមារចិត្តបាប! យើងដឹងហើយ តែយើងមិនអាឡោះអាល័យឡើយ ។ មារចៀសចេញទៅព្រះអង្គក៏ទ្រង់មានព្រះបន្ទូលថា "រាហុរលោ • អន្ទាក់អញត្រូវរាហុចាប់ហើយ ។

ស. តើគួរឱ្យជឿបានថាទេវបុត្រមានមកឃាត់ព្រះអង្គដែរឬយ៉ាងណា ? បើគ្មានទេ តើហេតុនេះមានលក្ខណៈយ៉ាងណាទៅវិញ ?

ច. បើតាមការពិចារណារបស់យើងទៅ ឃើញថាគ្មានទេវបុត្តមារមកឃាត់ទេ ព្រោះការដែលព្រះអង្គចេញបួសនេះគ្មានបញ្ហាអ្វីទាក់ទងរំខានដល់ទេវបុត្តឡើយ ក៏ប៉ុន្តែតាមពិតដែលថាមានមារមកឃាត់ព្រះអង្គនៅពេលនោះ គឺគំនិតអាក្រក់ ឬការស្តាយបន្តិចបន្តួច កើតចេញពីសន្តានព្រះទ័យរបស់ព្រះអង្គផ្ទាល់នោះឯង អកធ្វើឱ្យព្រះបំណងដ៏មុតមាំរបស់ព្រះអង្គឱ្យមានការរារែកខ្លះៗនោះឯង ។ គំនិតអាក្រក់, ការខ្វល់ស្តាយខ្លះៗនេះហើយដែលលោកទុកជាមារ ឬជាចិត្តបាប ។

ស. ទ្រង់បរសេះកាត់នគរណាខ្លះ ? មានចម្ងាយផ្លូវប៉ុន្មាន ហើយយាងទៅទ្រង់ព្រះផ្នួសនៅទីណា ?

ច. ទ្រង់បរសេះកាត់នគរបីគឺ កបិលព័ស្តុ១, សាវត្ថី១, វេសាលី១ ចម្ងាយផ្លូវ ៣០ យោជន៍ ឆ្លងទៅគង់ត្រើយខាងនាយ

www.elibraryofcambodia.org

នៃស្ដឹងអនោមា ។

ស. ព្រះរាជឱរសព្រះអង្គដែលប្រសូត្រនៅថ្ងៃព្រះអង្គចេញសាងព្រះផ្នួសនោះ តើមាននាមដូចម្ដេច ? អ្នកណាថ្វាយនាមនេះ ? មានរឿងដំណាលយ៉ាងណាដែរ ?

ច. មាននាមថា រាហុល ។ តាមសេចក្ដីដំណាលថា ពេលឆន្នអាមាត្យត្រឡប់ពីជូនដំណើរព្រះមហាបុរស ដែលយាងទៅសាងព្រះផ្នួសនោះ ក៏បានទូលរឿងហេតុដោយសព្វគ្រប់ ហើយក្រោយពីការស្ដីបន្ទោស នឹងតាមការសោយសោកស្ដាយព្រះអង្គរួចហើយ ព្រះបាទសុទ្ធោទនៈ ទ្រង់សួរឆន្នអាមាត្យថា "ព្រះសិទ្ធត្ថមានផ្ដាំពាក្យណាដល់ខ្ញុំព្រះអង្គទេ" ? ហើយផ្ដាំឱ្យថ្វាយនាមព្រះរាជបុត្រថាអ្វីដែរ ? ឆន្នអាមាត្យទូលថា ឥតផ្ដាំអ្វីទេ តែពេលដែលទ្រង់យាងចេញផុតទៅពីព្រះរាជវាំង ទ្រង់មានព្រះបន្ទូលតែម្នាក់ឯងថា "រាហុល រាហុល" ប៉ុណ្ណោះ ព្រះបាទសុទ្ធោទនៈ ទ្រង់ចាប់ព្រះទ័យនឹងវាចានេះ ក៏ថ្វាយនាមព្រះនត្តាថា "រាហុល" នេះឯង ។

ស. កាលទ្រង់ឱ្យឆន្នអាមាត្យ ដឹកសេះត្រឡប់មកវិញហើយ តើព្រះសិទ្ធត្ថរាជទ្រង់ធ្វើយ៉ាងណាទៀត ? មានអ្នកណាទៅជួយឧបត្ថម្ភក្នុងពិធីសាងព្រះផ្នួសនោះដែរ ?

www.elibraryofcambodia.org

ច. ទ្រង់គង់លើផ្នែកខ្សាច់ក្បែរមាត់ស្ទឹងអនោមា ហើយមានព្រះទ័យនឹងកាត់ព្រះកេសាពេលនោះ ព្រះខ័នទិព្វក៏ធ្លាក់មកថ្វាយព្រះអង្គ ។ ទ្រង់កាត់ព្រះកេសាដោយព្រះអង្គឯងឱ្យសល់វែងតែពីរធ្នាប់ប៉ុណ្ណោះ ។ លុះកាត់រួចហើយ ទ្រង់អធិដ្ឋានព្រះមោលីរួចបោះទៅក្នុងអាកាស ។ គ្រានោះព្រះឥន្ទបានយកប្រអប់កែវមកទ្រព្រះកេសារួចយកទៅបញ្ចុះក្នុង ចូឡាមណិចេតិយនៅស្ថានតាវត្តិង្ស ។ ឯព្រះកេសាព្រះអង្គទ្រង់កាត់តែម្តងនេះប៉ុណ្ណោះ រហូតបរិនិព្វាន ឥតមានកាត់ទៀតទេ ហើយព្រះកេសាប្រវែងពីរធ្នាប់នោះ នៅតែដដែលដោយវិលព័ទ្ធព្រះកេសានៅខាងស្តាំយ៉ាងល្អ ។ លុះកាត់ព្រះកេសារួចហើយ ឃដិការមហាព្រហ្មបានយកបរិក្ខារ ៨ មុខមកថ្វាយគឺ ស្បង់១, ចីពរ១, សង្ឃដី១, បាត្រ១, កាំបិតកោរ១, បំពង់ម្ជុល១, វត្ថពន្ធចង្កេះ១, តម្រងទឹក១ ។ ឯសំពត់ដែលទ្រង់ស្លៀកនោះ មហាព្រហ្មបានយកទៅបញ្ចុះនៅទុស្សចេតិយ ដែលមានកំពស់ ១២ យោជន៍នាព្រហ្មលោក ។

ស. តាមទំនាយរបស់ព្រាហ្មណ៍ក្តី តាមសំដីរបស់មារដែលឃាត់ព្រះអង្គក្តី ថាព្រះអង្គបើនៅជាឃរាវាស នឹងបានជាស្តេចបរមចក្រពត្តិ បើយាងទៅបួសនឹងបានជាព្រះពុទ្ធ, ថានៅ៧

www.elibraryofcambodia.org

ថ្ងៃទៀត ទ្រង់នឹងបានជាស្ដេចចក្រ ។ ចូរឆ្លើយបង្ហាញហេតុផលទៅមើល តើពុទ្ធានុភាពនៃស្ដេចបរមចក្រ និងពុទ្ធានុភាព ខាងណាមានគុណវិសេសជាង ព្រោះហេតុអ្វី ?

ច- សម្បត្តិទាំងពីរនេះ ព្រះអង្គនឹងបានសម្បត្តិណា១មិនខាន គឺបើមិនយាងទៅបួស ក៏ត្រូវតែបានជាស្ដេចចក្រ បើយាងទៅបួសនឹងបានជាពុទ្ធអង្គ ក៏ប៉ុន្តែឋានៈស្ដេចចក្រ និងឋានៈព្រះពុទ្ធផ្សេងគ្នា ហើយធ្វើផលឱ្យសត្វលោកក៏ផ្សេងគ្នាដែរ គឺស្ដេចចក្រធ្វើប្រយោជន៍បានចំពោះតែមនុស្ស ហើយឱ្យបានតែសម្បត្តិមនុស្ស និងសម្បត្តិសួគ៌តែប៉ុណ្ណោះ ឯព្រះពុទ្ធអង្គវិញទ្រង់បានធ្វើប្រយោជន៍ទូទៅចំពោះមនុស្សសត្វ ទេពតា ឥន្ទ្រព្រហ្ម ហើយអាចដឹកនាំទូទ្នានសត្វលោកឱ្យបាននិព្វានសម្បត្តិ ដែលជាស្ថានបរមសុខទៀត ។ ត្រង់នេះហើយដែលជាគោលបំណងនៃព្រះពុទ្ធអង្គដែលទ្រង់បានបំពេញចរិយា ៣ គឺ លោកត្ថចរិយា ញាតត្ថចរិយា និងពុទ្ធត្ថចរិយា ។ ដូច្នេះបានជាព្រះអង្គកាលយាងចេញទៅពីព្រះរាជវាំងបន្តិច ហើយមានព្រះទ័យនឹកដល់សម្បត្តិបរមចក្រនោះ ក៏មានព្រះទ័យមួយមកកំចាត់បង់ចេញវិញ ហើយយាងទៅទ្រង់ព្រះផ្នួសទាល់តែបាន ។ ដូច្នេះការយាងសាងផ្នួស ហើយបានត្រាស់ជាព្រះពុទ្ធ នឹងមានប្រយោជន៍វិសេសជាងបានជាស្ដេចចក្រពត្តិ ។

www.elibraryofcambodia.org

ស. ពេលទ្រង់ព្រះផ្នួសហើយថ្មីៗ តើព្រះអង្គបានធ្វើយ៉ាងណាខ្លះ? អ្នកណាដែលបានជួបនឹងព្រះអង្គជាដំបូង? បាននិយាយយ៉ាងណាខ្លះនឹងព្រះអង្គដែរ ?

ច. ទ្រង់យាងទៅគង់នៅអនុបិយម្ពវ័ន ក្នុងដែនមគធៈ ហើយទ្រង់មិនសោយអាហារចំនួន ៧ ថ្ងៃ ដោយសេចក្ដីសុខវិវេក រាយក្នុងបព្វជ្ជា លុះថ្ងៃព្រហស្បតិ៍ ៨ រោជ ខែ អាសាឍជាថ្ងៃទី ៨ ទើបស្ដេចចូលទៅបិណ្ឌបាតក្នុងនគររាជគ្រឹះ ។ ពួករាជបុរសបាន ឃើញព្រះមហាបុរសមានព្រះអាការចម្លែក ក៏ទៅទូលព្រះបាទពិម្ពិសារ ។ បើកព្រះបង្អួចទតមើលឃើញប្លែក ក៏ចាត់ឱ្យរាជបុរសតាមឃ្លាំមើល ។ ព្រះមហាបុរសកាលបានភត្តល្មមហើយ ក៏និមន្តទៅគង់ក្នុងញកភ្នំបណ្ឌវៈ ហើយប្រារព្ធឆាន់ចង្ហាន់ ។ រាជបុរសលបមើលឃើញអាការៈប្លែក ក៏មកទូលព្រះបាទពិម្ពិសាវិញតាមដំណើររឿង ។ ពេលនោះព្រះបាទពិម្ពិសាក៏យាងទៅភ្នំបណ្ឌវៈដោយព្រះអង្គឯង ហើយបានជួបនឹងព្រះមហាបុរសទ្រង់សាកសួររឿងហេតុសព្វគ្រប់ ព្រះរាជាទ្រង់សុំឱ្យព្រះពោធិសត្វសោយរាជ្យពាក់កណ្ដាល តែព្រះពោធិសត្វមិនទទួលដោយបានទូលដំណើរសព្វគ្រប់ ។ ព្រះបាទពិម្ពិសារទូលទូលព្រះពោធិសត្វថា បើព្រះអង្គបានត្រាស់ហើយ សូមទ្រង់មកប្រោសខ្ញុំព្រះករុណាជាញោម

www.elibraryofcambodia.org

មុនគេ ។ ព្រះពោធិសត្វក៏ទ្រង់ទទួលព្រមហើយព្រះរាជាក៏យាង ទៅព្រះរាជវាំងវិញ ។

ច. ព្រះពោធិសត្វទ្រង់យាងទៅកន្លែងណាទៀត ? ទ្រង់ដែលទៅរៀនជាមួយគ្រូអាចារ្យណាដែរ ? ឬព្រះអង្គស្វែងរកធម៌១ព្រះអង្គឯង ?

ឆ. ទ្រង់ចេញពីភ្នំបណ្ឌវៈឆ្ពោះទៅអាស្រមបទ អាឡារតាបស ហើយទ្រង់សិក្សា និងចំរើនបានសមាបត្តិ ៧ រួចនិមន្តទៅកាន់សំណាក់ ឧទកតាបស ហើយខំចំរើនបានសមាបត្តិ ៨ រួចក៏ទ្រង់សួររកឫសគល់នៃធម៌វិសេស១នឹងតាបស ២ ទាល់ឆ្លើយមិនរួច ព្រះពោធិសត្វទ្រង់សន្និដ្ឋានថា "ផ្លូវនេះមិនមែនជាផ្លូវត្រាស់ដឹងទេ" ទើបទ្រង់យាងចេញពីទីនោះឆ្ពោះទៅកាន់ឧរុវេលនិគម ក្នុងដែនមគធៈជដែល ហើយតាំងស្នឹងស្នាធ៌ ដើម្បីស្វែងរកសម្ពោធិញ្ញាណតែ១ ព្រះអង្គឯងនៅទីនោះ ។

ស. នៅឧរុវេលនិគម ព្រះពោធិសត្វទ្រង់ធ្វើយ៉ាងណាខ្លះ? អស់រយៈវេលាប៉ុន្មាន ? មានអ្នកណានៅជាមួយដែរ ?

ច. ទ្រង់តាំងសេចក្ដីព្យាយាមដ៏ធំ (មហាបធាន) ដើម្បីស្វែងរកសម្ពោធិញ្ញាណ ដោយការរិះរករំពឹងគិតពិចារណាតាមព្រះបញ្ញាញាណរបស់ព្រះអង្គផ្ទាល់ ចំពោះហេតុផលផ្សេង១

www.elibraryofcambodia.org

លុះទ្រង់ធ្វើយ៉ាងនេះហើយមិនបានឃើញធម៌អ្វីមួយនោះ ទ្រង់បានតាំងព្យាយាមរិតតែខ្លាំង ហើយតឹងតែងណាស់ទៅទៀត ដោយទ្រង់ព្យាយាមបន្ថយព្រះភត្តាហារបន្តិចម្តងៗ រហូតទល់ឈប់សោយអ្វីទាំងអស់ ។ គឺនៅពេលនោះហើយដែលព្រះអង្គមានព្រះសរីរកាយស្គមស្គាំងនៅសល់តែស្បែកដណ្តប់ឆ្អឹង ហើយទ្រង់ដួលផ្ទុំលើព្រះធរណីស្តូកស្តឹង ។ ត្រង់នេះហើយដែលយើងធ្លាប់ដឹងមកថា "ទ្រង់ធ្វើទុក្ករកិរិយា" គឺការបំពេញព្យាយាមដ៏តឹងតែងកម្រអ្នកណាធ្វើបានដូចព្រះអង្គ ។ នៅពេលដែលព្រះអង្គដួលនោះ មានសេចក្តីដំណាលថា : ព្រះឥន្ទបានយកពិណមានខ្សែ៣ ទៅដេញថ្វាយព្រះពោធិសត្វស្តាប់. ព្រះឥន្ទបានរិតខ្សែ១ធូរពេក ដេញឥតពិរោះ ក៏រិតខ្សែ១យ៉ាងតឹង ហើយដេញទៀត ក៏ឥតពិរោះ ទើបរិតខ្សែ១ ចុងក្រោយយ៉ាងល្មមមិនធូរមិនតឹង ក៏អាចសម្លេងពិរោះ ។ ព្រះពោធិសត្វស្តាប់ហើយក៏ពិចារណាថា : អាត្មាអញបានធ្វើព្យាយាមតឹងពេក បានជាមិនបានត្រាស់ដូចខ្សែពិណដែលរិតតឹងពេក ក៏គ្មានសម្លេងពិរោះសោះ ទើបព្រះអង្គទ្រង់ត្រឡប់មកឆាន់ចង្ហាន់វិញ ញុំាងព្រះសរីរកាយឱ្យមានសម្ផស្សសម្រស់ដូចដើម ។

ពេលដែលព្រះពោធិសត្វធ្វើមហាបធាន និងធ្វើទុក្ករកិរិយា

www.elibraryofcambodia.org

អស់រយៈវេលា ៦ ឆ្នាំនោះ មានភិក្ខុ ៥ អង្គគឺ ភទ្ទិយៈ១. វប្បៈ១. មហានាម១. អស្សជិ១ (ទាំង ៤ អង្គនេះជាកូនព្រាហ្មណ៍ ៤នាក់ ដែលទាយលក្ខណៈព្រះសិទ្ធត្ថកុមារ) និងព្រះកោណ្ឌញ្ញ១ (ជាអ្នកទាយលក្ខណៈព្រះពោធិសត្វដោយផ្ទាល់) ដែលបានចេញបួសហើយតាមទៅនៅបំរើព្រះអង្គនៅឧរុវេលនិគមហៅថា បញ្ចវគ្គិយភិក្ខុ ។ ប៉ុន្តែកាលភិក្ខុទាំង ៥ អង្គ បានឃើញព្រះពោធិសត្វត្រឡប់ឆាន់អាហារវិញនោះ ក៏នាំគ្នាចេញចោលព្រះអង្គ ទៅគង់នៅព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី រដ្ឋកាសី ចម្ងាយផ្លូវ ១៨ យោជន៍ដោយយល់ឃើញថាព្រះសិទ្ធត្ថប្រើងរត់រាហារហើយ នៅតែមិនបានត្រាស់ ចុះទម្រាំត្រឡប់ឆាន់អាហារវិញដូច្នេះ មុខជាលែងបានត្រាស់ដឹងអ្វីហើយ ។

ស. ពេលដែលព្រះអង្គដួលលើព្រះធរណីនោះ មានដំណាលថា ព្រះឥន្ទយកពិណមានខ្សែ៣ មកដេញថ្វាយ ទើបព្រះពោធិសត្វមានស្មារតីពិចារណា រកហេតុផលខុសត្រូវបាន ។ តើរឿងនេះពិតឬទេ ? បើពិតតើនឹងចាត់ថា ព្រះពោធិសត្វជាអ្នកមានបញ្ញាច្រើនជាងមនុស្សសាមញ្ញបានដែរ ?

ច. រឿងនេះ គឺជាការប្រៀបធៀបឱ្យងាយស្តាប់តែប៉ុណ្ណោះ តែតាមពិតពុំដូច្នោះឡើយ គឺពេលព្រះអង្គអស់ព្រះកាយ

www.elibraryofcambodia.org

ពលខ្លាំង ដេកដួលស្តូកស្តឹងលើព្រះធរណីនោះ ព្រះអង្គនៅតែមានស្មារតី, មានវិចារណញ្ញាណគ្រប់គ្រាន់នៅឡើយ ហើយព្រះអង្គក៏ពិចារណាដោយហេតុ ៣ យ៉ាងគឺ :

ទី ១. ទ្រង់ពិចារណាថា បើទ្រង់ប្រព្រឹត្តធូរពេក ទ្រង់ក៏ពុំបានត្រាស់ដឹងនូវធម៌ណា១ដែរ ដូចជាខ្សែពិណដែលគេរិតធូរពេកក៏គ្មានសម្លេងពីរោះ ។

ទី ២. ទ្រង់ពិចារណា បើទ្រង់ប្រព្រឹត្តតឹងពេកក៏នាំឱ្យអន្តរាយមិនអាចរកធម៌ណា១ឃើញដែរ ដូចខ្សែពិណដែលគេរិតតឹងពេកក៏គ្មានសម្លេងពិរោះនោះឯង ។

ទី ៣. ទ្រង់ពិចារណាថា បើផ្លូវធូរពេកក៏មិនបានត្រាស់ តឹងពេកក៏មិនបានត្រាស់ មានតែផ្លូវកណ្តាលមួយប៉ុណ្ណោះទើបបានត្រាស់ ដូចខ្សែពិណដែលគេរិតល្មម មិនតឹងពេកធូរពេកក៏មានសម្លេងពិរោះ ដូច្នេះគួរព្រះអង្គដើរតាមផ្លូវកណ្តាលវិញ ។

លុះពិចារណាយ៉ាងនេះហើយ ទ្រង់ក៏ត្រឡប់សោយអាហារតាមវិធីដ៏ល្មម ។ ផ្លូវតឹងពេកហៅថា អត្តកិលមថានុ-យោគ គឺការប្រព្រឹត្តធ្វើកាយឱ្យលំបាកលំបិន, ផ្លូវកណ្តាលគឺមជ្ឈិមាបដិបទា គឺការប្រតិបត្តិយ៉ាងសមគួរ ជាកណ្តាលមិនតឹងមិនធូរ ។ រឿងនេះមានផលយ៉ាងវិសេសនៅពេលទ្រង់បានត្រាស់

www.elibraryofcambodia.org

ជាព្រះសម្ពុទ្ធ ហើយបានយកការភិសោធន៍នោះទៅសំដែងប្រាប់បញ្ចវគ្គិយភិក្ខុ ។

ដូច្នេះ គ្មានព្រះឥន្ទឯណាមកដេញពិណថ្វាយព្រះអង្គទេ. បើដូច្នោះមែន ព្រះអង្គបែរជាអ្នកគ្មានប្រាជ្ញាស្មារតី គ្មានវិចារណ-ញ្ញាណទៅវិញ ហើយការត្រាស់ដឹងរបស់ព្រះអង្គទៅជាការត្រាស់ដឹង ដោយមានគេដឹកនាំទៅវិញដែរ គឺព្រះអង្គមិនមែនជាសម្មាសម្ពុទ្ធឡើយ ផ្ទុយទៅវិញ ការពិចារណាឃើញដោយការយកខ្សែពិណមកធ្វើជាគ្រឿងប្រៀបធៀបនោះ គឺជាវិចារណ-ញ្ញាណ ដែលផុះចេញពីដួងហឫទ័យរបស់ព្រះអង្គផ្ទាល់តែម្តង ។

ស- ការធ្វើទុក្ករកិរិយារបស់ព្រះអង្គ មានផលប្រយោជន៍ខ្លះដែរ ឬគ្មានប្រយោជន៍ទេ បានជាព្រះអង្គលះបង់ទៅវិញ ?

ច- គ្មានប្រយោជន៍សោះទេ នៅពេលដែលព្រះអង្គមិនទាន់បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ តែមានប្រយោជន៍សំខាន់នៅពេលដែលត្រាស់ដឹងរួចហើយ គឺមានប្រយោជន៍ក្នុងការប្រៀនប្រដៅសត្វលោកទូទៅ ដែលប្រឹងស្វែងរកធម៌ដោយការធ្វើខ្លួនឱ្យលំបាកវេទនាឧទាហរណ៍ ពេលដែលទ្រង់សំដែងធម្មចក្កប្បវត្តនសូត្រ ប្រោសបញ្ចវគ្គិយភិក្ខុ ទ្រង់បានលើកយកអត្តកិលម-ថានុយោគនេះ មកបង្ហាញហេតុផលដល់បញ្ចវគ្គិយភិក្ខុឱ្យឃើញ

www.elibraryofcambodia.org

ច្បាស់ថា ការស្វែងរកផ្លូវត្រាស់ដឹងដោយខ្លួនឱ្យលំបាក មានការអត់អាហារជាដើមនោះ ជាផ្លូវខុស ។ ដូច្នេះបានជាគថាគតលះបង់វិធីនោះចោល ហើយស្វែងរកការត្រាស់ដឹងដោយផ្លូវកណ្ដាល ក៏បានរកឃើញធម៌ពិតមែន ។

ស- តាំងពីព្រះពោធិសត្វ ទ្រង់យាងចេញសាងព្រះផ្នួសរហូតទល់ពេលនេះ តើព្រះអង្គទ្រង់ដែលយាងទៅកាន់ក្រុងកបិលពស្តុឬទេ ? តើព្រះបិតា, នាងពិម្ពា និងញាតិវង្សដែលជួប ឬដឹងដំណឹងយ៉ាងណាខ្លះដែរ ?

ច- ប្រាំមួយឆ្នាំកន្លងផុតទៅ ព្រះអង្គពុំដែលយាងទៅកាន់ក្រុងកបិលពស្តុសោះទេ ទាំងព្រះបិតា ឬក៏ញាតិវង្ស ក៏ពុំមាននរណាដែលតាមទៅសាកសួរយ៉ាងណាៗ នោះឡើយ ព្រោះមនុស្សជំនាន់នោះ មានការយល់ថា មនុស្សដែលកាត់កោរសក់ដូចព្រះពោធិសត្វនោះ ជាអពមង្គលដ៏ធំមួយ បើទោះជាត្រឡប់មកវិញក្នុងពេលដែលមិនទាន់បានត្រាស់ដឹង ដើម្បីមកកាន់រាជសម្បត្តិវិញ ក៏គ្មានអ្នកណាគេរាប់រកឡើយ ក៏ប៉ុន្តែព្រះបិតាក្ដី នាងពិម្ពាក្ដី នៅតែអាឡោះអាល័យព្រះអង្គជានិច្ច ហើយតែងដឹងដំណឹងយ៉ាងច្បាស់ថាព្រះអង្គទ្រង់ធ្វើអ្វីៗទាំងអស់ទៀតផង ជាពិសេសគឺទ្រង់នៅតែជឿថា ព្រះសិទ្ធត្ថបើមិនទាន់បានត្រាស់ដឹង

www.elibraryofcambodia.org

ទេ នឹងមិនទិវង្គតឡើយ តួយ៉ាងដូចកាលព្រះអង្គអត់ចង្ហាន់ហើយដួលលើព្រះធរណី មានទេវតាជាពួកមារបានទៅទូលព្រះសុទ្ធោ. ទនៈថា ព្រះសិទ្ធត្ថដួលស្លាប់ហើយ តែព្រះរាជាពុំជឿឡើយ ។ ចំណែកខាងនាងពិម្ពាវិញ នាងនៅតែមានភក្តីភាពយ៉ាងរឹងប៉ឹងហើយស្មោះត្រង់នឹងព្រះអតីតភស្តាជាដរាប តួយ៉ាងដូចកាលបានឮថា ព្រះសិទ្ធត្ថទ្រង់ផ្ទុំលើផ្ទាំងថ្មក្តី សោយទឹកក្នុងថ្លុកក្តី អត់រាហារក្តី នាងក៏ឈប់ផ្ទុំលើសិរីយសយនា. សោយទឹកសៅហ្មង. មិនសោយអាហារតាមព្រះភស្តាដែរ ។ មានពួកសាក្យរាជខ្លះមានព្រះទ័យប្រតិព័ទ្ធព្រះនាង ហើយចង់បាននាងជាទេពី ក៏ព្រះនាងមិនព្រមជាដាច់ខាត ស៊ូនៅមេម៉ាយយ៉ាងអភ័ព្វជាមួយបុត្រពន្លកជានិច្ច ។ ដោយសរុបមកព្រះពោធិសត្វ នឹងញាតិវង្សបានដឹងសុខទុក្ខគ្នាទៅវិញទៅមកយ៉ាងច្បាស់ គ្រាន់តែមិនបានជួបគ្នាតែប៉ុណ្ណោះ ។

www.elibraryofcambodia.org

# ភាគទី ៦

## ហេតុអស្ចារ្យ

## នៅមុនពេលត្រាស់ដឹង

ស- ព្រះពោធិសត្វទ្រង់ធ្វើទុក្ករកិរិយាអស់រយៈពេលប៉ុន្មានឆ្នាំមកហើយ តាំងពីពេលបានយាងចេញសាងព្រះផ្នួសមកទល់ នឹងពេលនេះ ?

ច- ព្រះពោធិសត្វទ្រង់ធ្វើទុក្ករកិរិយាអស់ ៦ ឆ្នាំមកហើយ បើគិតតាំងពីពេលព្រះអង្គទ្រង់យាងចេញសាងព្រះផ្នួស មកទល់នឹងពេលនេះ គឺពេលមុនថ្ងៃពេញបូរមី ខែពិសាខនេះ ។

ស- នៅពេលមុនថ្ងៃពេញបូរមី ខែពិសាខនេះ តើព្រះពោធិសត្វគង់ក្នុងឧរុវេលនិគមនោះដដែល ឬទ្រង់យាងទៅទីណាដែរ ?

ច- ទ្រង់គង់នៅតែក្នុងទីនោះដដែល ឥតយាងទៅទីណាឆ្ងាយឡើយ ។

ស- ថ្ងៃណាជាថ្ងៃមុនពេលត្រាស់ដឹងនៃព្រះពុទ្ធជាម្ចាស់? ទ្រង់មានហេតុភេទយ៉ាងណាកើតឡើងដល់ព្រះអង្គដែរឬទេ ?

ច- ថ្ងៃ ១៤ កើត ខែពិសាខ ឆ្នាំរកា រហូតទល់ពាក់កណ្តាលអាធ្រាត្រ( បន្ទាប់ពីថ្ងៃ១៤ កើតទៅ) ជាថ្ងៃមុនពេលត្រាស់

www.elibraryofcambodia.org

ដឹងជាព្រះសម្ពុទ្ធនៃអង្គព្រះសិទ្ធត្ថពោធិសត្វ ។ នៅពេលទៀបភ្លឺ គឺដើមថ្ងៃ ១៥ កើត ខែពិសាខ ព្រះអង្គទ្រង់សុបិនចម្លែកអស្ចារ្យ ជាហេតុនាំឱ្យព្រះអង្គយល់ និងកំណត់ទុកក្នុងព្រះទ័យថា : ព្រះអង្គពិតជានឹងបានត្រាស់ដឹងជាមិនខាន ។

ស. សុបិនចម្លែកនោះយ៉ាងណាខ្លះ ? ទ្រង់រកអ្នកណាទាយឱ្យឬទេ ? ហើយមានសេចក្តីសន្និដ្ឋានយ៉ាងណាទៅវិញ ?

ច. សុបិននោះមាន ៥ ប្រការយ៉ាងនេះគឺ :

១. ទ្រង់ឃើញថា ព្រះអង្គផ្ទុំផ្ងារមានមហាប្រឹថពីជាក្រឡាបន្ទំ, មានភ្នំហេមពានជាខ្នើយ, ហើយព្រះហស្តឆ្វេងសណ្តូកទៅក្នុងមហាសមុទ្រទិសខាងកើត ព្រះហស្តស្តាំសណ្តូកចុះក្នុងមហាសមុទ្រទិសខាងលិច ព្រះបាទទាំងគូសណ្តូកចុះក្នុងមហាសមុទ្រទិសខាងត្បូង ទ្រង់ផ្ទុំបើកព្រះនេត្រ ហើយឃើញពន្លឺរហូតដល់ភវគ្គព្រហ្ម ។

២. ទ្រង់ទតឃើញស្មៅចិញ្ចៀនដុះចេញពីផ្ចិត ហើយលូតឡើងទៅលើរហូតអាកាសវេហាស៍ ។

៣. ទ្រង់ទតឃើញពួកដង្កូវមានក្បាលខ្មៅខ្លួនស វារឡើងពីចុងព្រះបាទរហូតទល់ជង្គង់ ។

៤. ទ្រង់ទតឃើញសត្វបក្សី៤ ពួកមានពណ៌សម្បុរផ្សេងៗ

www.elibraryofcambodia.org

ហើរមកពីទិសទាំង៤ មកក្រាបទៀបព្រះបាទព្រះអង្គ ហើយក៏មានសម្បុរសដូចគ្នាទាំងអស់ទៅវិញ ។

៥. ទ្រង់ឃើញថា ទ្រង់យាងចង្ក្រមលើភ្នំលាមកដ៏ធំ តែព្រះបាទមិនប្រឡាក់លាមកនោះឡើយ ។

កាលទ្រង់តើនឡើងហើយទ្រង់ជ្រាបថា ព្រះអង្គនឹងបានត្រាស់ ទ្រង់ក៏ទាយសុបិននិមិត្តនោះដោយព្រះអង្គឯងថា :

- ការផ្ទុំលើផែនដី គឺការបាននូវសម្មាសម្ពោធិញ្ញាណ,

- ភ្នំហេមពាន្តជាខ្នើយ គឺការបាននូវខ្នើយ សព្វញ្ញុត-ញ្ញាណ ។

- ការសណ្ដូកព្រះហស្ត និងព្រះបាទក្នុងមហាសមុទ្រ ជាបុព្វនិមិត្តនៃការសំដែងធម្មចក្រ ដល់មនុស្ស និងទេពតា ។

- ការផ្ទុំផ្ងារលើផែនដី ជាបុព្វនិមិត្តនៃកិរិយាធ្វើសត្វដែលមានមុខផ្កាប់ឱ្យផ្ងាឡើង ។

- ការឃើញនូវពន្លឺភ្លឺដល់ភវគ្គព្រហ្ម ជាបុព្វនិមិត្តនៃអនាវរណញ្ញាណ ។

- ការឃើញតិណជាតិដុះអំពីផ្ចិត ជាបុព្វនិមិត្តនៃការសំដែងនូវអដ្ឋង្គិកមគ្គ ។

- ការឃើញថា ដង្កូវវារឡើងជាបុព្វនិមិត្តនៃបរិស័ទទាំង៤

www.elibraryofcambodia.org

ដែលដល់នូវព្រៃសរណគម៍ស្មើជីវិត ។

. ការឃើញសត្វបក្សី៤ ពួកប្រែក្លាយខ្លួនជាបុព្វនិមិត្តនៃត្រកូលទាំង៤ ចេញបួស ហើយប្រព្រឹត្តតាមធម៌វិន័យរបស់ព្រះអង្គ ។

. ការយាងចង្ក្រមលើភ្នំលាមក ជាបុព្វនិមិត្តនៃចតុប្បច្ច័យជាលាភសក្ការៈ ដែលកើតឡើងដល់ព្រះអង្គ តែព្រះទ័យមិនជាប់ជំពាក់ក្នុងលាភសក្ការៈនោះឡើយ ។

## ពុទ្ធបូជា

ស. នៅព្រឹកនៃថ្ងៃ ១៥ កើត ខែពិសាខនោះ ព្រះពោធិសត្វ ទ្រង់យាងទៅណាទៀត ? ទ្រង់បានទទួលអ្វីពីអ្នកណាដែរ ?

ច. ព្រឹកនោះ ព្រះពោធិសត្វទ្រង់ជម្រះព្រះកាយហើយ ក៏រៀបចំព្រះអង្គរួចនិមន្តទៅគង់នៅក្រោមដើមព្រះជ្រៃ១ ជិតឧរុវេលនិគមនោះឯង ដើម្បីរង់ចាំពេលនឹងត្រាច់ទៅបិណ្ឌបាត្រ ។ នៅទីនោះព្រះអង្គក៏បានទទួលមធុបាយាសអំពីនាងសុជាតា ជាធីតានៃសេនកុដុម្ពីក៏ដែលមានលំនៅ នៅភូមិមួយជិតឧរុវេលនិគមនោះឯង ។

ស. នាងសុជាតាបានថ្វាយមធុយាសដល់ព្រះបរមពោធិ

www.elibraryofcambodia.org

សត្វនោះ គឺជាការថ្វាយតាមធម្មតារៀងរាល់ថ្ងៃ ឬទើបនឹងថ្វាយថ្ងៃនេះទេ ?

ប- ក្នុងរឿងនេះ យើងអាចឆ្លើយតាមប្រភពពីរយ៉ាងគឺ :

ទី១- មានសេចក្ដីដំណាលថា "កាលនាងសុជាតានៅក្រមុំ នាងបានធ្វើការបន់ស្រន់បួងសួងប្រាថ្នានូវហេតុពីរយ៉ាងគឺ :

ក- នាងប្រាថ្នាសុំឱ្យបានស្វាមី មានជាតិត្រកូលស្មើគ្នា ហើយមានចិត្តប្រកបដោយធម៌ទៀតផង ។

ខ- នាងប្រាថ្នាសុំឱ្យបានកូនប្រុសជាដំបូង ហើយឱ្យកូនប្រុសនោះស្ដាប់បង្គាប់មាតាបិតា និងជាកូនប្រកបដោយធម៌ ។ បើនាងបានដូច្នោះមែន នាងនឹងធ្វើពលិកម្មណាមួយមានតម្លៃ១សែនថ្វាយដល់ទេពតារក្សាដើមព្រះជ្រៃដែលនៅជិតភូមិ ។

សេចក្ដីដំណាលទាំងពីរនេះ បានដូចបំណងមែន លុះដល់ពេលមុនថ្ងៃពេញបូរមី ខែពិសាខនោះ នាងបានឱ្យនាយគង្វាលគោនាំមេគោមួយពាន់ក្បាលទៅលែង ឱ្យស៊ីក្នុងព្រៃឈើឯម ហើយដល់ពេលល្ងាចនាងឱ្យយកភាជនៈ ៥០០ ទៅត្រងទឹកដោះមេគោ ៥០០ ហើយយកទៅឱ្យមេគោ ៥០០ ទៀតផឹក ។ នាងឱ្យធ្វើយ៉ាងនេះរហូតទល់សល់មេគោ ៨ ក្បាល ក៏ឱ្យគេរិតយកទឹកដោះពីមេគោទាំង ៨ មកដើម្បីធ្វើមធុយាសយាស គឺនំផ្អែមដូច

www.elibraryofcambodia.org

ទឹកឃ្មុំ ។ កាលយកភាជន៍ទៅជិតដោះមេគោ ទឹកដោះក៏ហូរចេញមកដោយខ្លួនឯង ។ នាងសុជាតាឃើញដូច្នោះ ក៏ចាត់ចែងធ្វើដោយដៃខ្លួនផ្ទាល់ ពួកចតុលោបាល, មហាព្រហ្ម, ព្រះឥន្ទ និងទេវតានានាបានមកជួយរក្សាចង្ក្រាន ជួយចាំងឆ័ត្រ, ជួយថែរក្សាភ្លើង និងជួយនាំឱជារសមកដាក់ក្នុងមធុបាយាសនោះ នៅពេលដែលនាងសុជាតាបានចំអិនមធុបាយាស ។ នាងសុជាតាឃើញហេតុអស្ចារ្យប្លែកដូច្នោះ ក៏ប្រាប់ទាសីម្នាក់ឈ្មោះនាងបុណ្ណាឱ្យទៅបោសសំអាតគល់ព្រះជ្រៃជាមុន ។ នាងបុណ្ណាបានដើរទៅជិតដើមជ្រៃ ក៏បានឃើញព្រះពោធិសត្វដែលកំពុងគង់ពីខាងក្រោមដើមជ្រៃពីខាងកើត បែរព្រះភក្ត្រទៅកើតទតលោកធាតុមានរស្មីដូចពណ៌មាសផ្សាយពីព្រះកាយ ក៏ស្មានថាជាទេវតាចុះមករង់ចាំទទួលមធុបាយាសលាបំណន់របស់នាងសុជាតា នាងក៏រត់ត្រឡប់ទៅប្រាប់នាងសុជាតាថា ទេវតាចុះមករង់ចាំឯគល់ព្រះជ្រៃឯណោះ សូមនាងប្រញាប់ឡើង ។ នាងសុជាតាបានយកភាជន៍មាសតម្លៃ១ សែនមកដាក់មធុបាយាស រួចតាក់តែងខ្លួនហើយក៏ទូលដើរសំដៅដើមព្រះជ្រៃភ្លាម ។

ដូច្នេះក្នុងរឿងទី១នេះ នាងសុជាតាពុំស្គាល់ព្រះបរមពោធិសត្វទេ គឺនាងស្មានព្រះបរមពោធិសត្វថា ជាទេវតាទេវិញ

www.elibraryofcambodia.org

ទី២- មានសេចក្ដីដំណាលថា នាងសុជាតាស្គាល់ព្រះបរម ពោធិសត្វយ៉ាងជាក់ច្បាស់ណាស់ គឺឱរុវេលនិគមនោះជាស្រុក ទេសរបស់នាង ព្រៃដែលព្រះពោធិសត្វគង់តាំងធម៌ និងផ្ទះនាង នៅជិតល្មម ហើយព្រះពោធិសត្វធ្លាប់យាងទៅភូមិនាង ដើម្បី បិណ្ឌបាត្រស្ទើរតែរាល់ថ្ងៃ ឯនាងក៏ធ្លាប់ប្រគេនភត្ត, ធ្លាប់គោរព ព្រះពោធិសត្វថាជាអ្នកបួស មានគុណធម៌នេះក្នុងព្រះអង្គដែរ ។ លុះដល់ថ្ងៃមុនថ្ងៃពេញបូរមីនោះ នាងក៏គិតថា ព្រះសិទ្ធត្ថជា សាមណៈ ទ្រង់គង់ធ្វើធម៌នៅជិតភូមិស្ថាននាងជាយូរហើយ ។ ធ្លាប់និមន្តមកបិណ្ឌបាត្រនៅផ្ទះនាងជាញឹកញាប់ណាស់ បិតានាង ក្ដី ប្ដីនាងក្ដី ក៏មានសេចក្ដីស្រឡាញ់រាប់អាន និងគោរពព្រះសិទ្ធត្ថ ដូចជានាងដែរ តែ ៦ ឆ្នាំមកហើយ នាងពុំដែលបានភោជនាហារ អ្វីប្រគេនព្រះសិទ្ធត្ថឱ្យបានឆ្ងាញ់ម្ដងសោះ ដូច្នេះនៅថ្ងៃពេញបូរមី ខែពិសាខនេះ គួររៀបធ្វើមធុបាយាសប្រគេនព្រះសិទ្ធត្ថឱ្យបាន ឆ្ងាញ់ម្ដង រួចនាងក៏ចាត់ចែងដូចនិយាយមកខាងដើម ដើម្បីយក ទៅថ្វាយព្រះពោធិសត្វ នៅក្រោមព្រះជ្រៃជាទីដែលទ្រង់តែងតែ គង់នៅរៀងរាល់ព្រឹក មុនពេលចេញទ្រង់បិណ្ឌបាត្រ ។

ដូច្នេះក្នុងរឿងទី២ នេះបញ្ជាក់ឱ្យឃើញថា នាងសុជាតា ស្គាល់ព្រះពោធិសត្វដោយជាក់ច្បាស់ ហើយនាងប្រគេនមធុបា-

www.elibraryofcambodia.org

យាសនោះជាការសម្តែងសេចក្តីគោរព ចំពោះគុណធម៌របស់ព្រះអង្គប៉ុណ្ណោះ តែឥតបានបែរបន់អ្វីឡើយ ឯនាងបុណ្ណាគឺជាប្អូននាងសុជាតា មិនមែនជាអ្នកបំរើទេ ។ រឿងទាំងពីរនេះ សូមឱ្យអ្នកសិក្សាពិចារណាផងទៀតចុះ ។

ស. ព្រះពោធិសត្វទទួលភត្តពីនាងសុជាតានោះ ដោយអាការៈយ៉ាង ទ្រង់សោយភ្លាម ឬយកទៅសោយទីណា ? ទ្រង់ធ្វើយ៉ាងណាខ្លះ ?

ច. កាលនាងសុជាតាលើកភាជន៍មធុបាយាសប្រគេនព្រះអង្គទ្រង់បែររកបាត្រ ដែលឃដីការមហាព្រហ្មប្រគេនក៏មិនឃើញ នាងសុជាតាដឹងហេតុដូច្នោះ ក៏ប្រគេនទាំងភាជន៍ទាំងមធុបាយាសនោះទៅព្រះអង្គ ។ ទទួលហើយ ទ្រង់មិនទាន់សោយភ្លាមដែរ ទ្រង់កាន់ភាជន៍មធុបាយាសនោះ យាងទៅកាន់ឆ្នេរស្ទឹងនេរញ្ជរ ហើយដាក់ភាជន៍មធុបាយាសលើឆ្នេរស្ទឹង រួចទ្រង់យាងចុះស្រង់ទឹក ហើយទើបឡើងមកសោយមធុបាយាស តែមុននឹងសោយ ទ្រង់ពូតជាពំនូត១ ប៉ុនគ្រាប់ត្នោតបាន ៤៩ ពំនូត រួចទើបសោយ ។ ទ្រង់សោយអស់ទាំង ៤៩ ពំនូត រួចក៏ចុះយកភាជន៍នោះចុះទៅក្នុងស្ទឹង ដើម្បីលាងព្រះហស្តហើយផ្សងថា "បើអាត្មាអញបានត្រាស់ដឹងមែន សូមឱ្យភាជន៍មាសនេះ

www.elibraryofcambodia.org

អណ្តែតច្រាសទឹកទៅ" ផ្សេងរួចក៏បោះភាជន៍ទៅក្នុងទឹកស្ទឹង ភាជន៍មាសបានអណ្តែតឡើងបញ្ច្រាសទឹកទៅបាន ៨ ហត្ថ ទើបលិចចុះ ។ ព្រះអង្គរិតតែជ្រាបច្បាស់ថា ទ្រង់នឹងបានត្រាស់យ៉ាងពិតប្រាកដ ។

ស- ភាជន៍មាសលិចចុះទៅទីណា ?

ច- ភាជន៍លិចចុះទៅដល់ភពកាឡនាគ ហើយទង្គិចនឹងភាជន៍មាស៣ របស់ព្រះពុទ្ធអង្គ៣ ព្រះអង្គពីមុនក្នុងភទ្ទកប្បនេះ រួចក៏ស៊កសៀតចូលខាងក្រោមភាជន៍ទាំង៣ នោះឮសូរក្រឹកៗ ។

ស- មានអ្នកណាបានដឹងឮខ្លះ ? ហើយបានធ្វើយ៉ាងណាដែរ ?

ច- មានស្តេចកាឡនាគ (នាគខ្មៅ) បានឮភាជន៍ទង្គិចគ្នាក៏ភ្ញាក់ ហើយពោលថា : ពីម្សិលមិញព្រះពុទ្ធត្រាស់មួយអង្គ ថ្ងៃនេះមានព្រះពុទ្ធត្រាស់មួយអង្គទៀត ។ និយាយរួចក៏ពោលសរសើរពុទ្ធគុណដោយប្រការផ្សេងៗ ។

ស- ពុទ្ធបរិស័ទយើងខ្លះ កាលណាធ្វើបុណ្យពុទ្ធាភិសេក តែងធ្វើពិធីថ្វាយចង្ហាន់ព្រះនៅពេលយប់ ដោយមានជំនឿថា ព្រះអង្គទាល់តែឆាន់ចង្ហាន់នាងសុជាតា ទើបបានត្រាស់ ។ តាមរឿងពិត តើព្រះអង្គបានត្រាស់ព្រោះតែទ្រង់បានឆាន់ចង្ហាន់នាង

www.elibraryofcambodia.org

សុជាតា ឬយ៉ាងណា ? ព្រោះហេតុអ្វី ?

ច. ព្រះអង្គបានត្រាស់ដឹង មិនមែនដោយសារបានឆាន់ចង្ហាន់មធុបាយាសរបស់នាងសុជាតានោះទេ គឺបានត្រាស់ដោយពុទ្ធការកធម៌ និងការខំប្រឹងស្វែងស្វាធ៌របស់ព្រះអង្គតែប៉ុណ្ណោះ ប៉ុន្តែពុទ្ធបរិស័ទយើងខ្លះមានជំនឿភាន់ច្រឡំយ៉ាងខ្លាំងថា ព្រះអង្គបានត្រាស់ដោយការឆាន់មធុបាយាសរបស់នាងសុជាតា ។ តាមពិត ការថ្វាយចង្ហាន់ដល់ព្រះអង្គនៅពេលយប់នៃពិធីបុណ្យពុទ្ធាភិសេកដូច្នេះជាកំហុសមួយធំណាស់ ឯការយល់ជឿ និងប្រកាន់ថាព្រះអង្គបានត្រាស់ ដោយសារការឆាន់ចង្ហាន់នាងសុជាតាដូច្នោះក៏ត្រូវមានកំហុសទោសធ្ងន់ដែរ ។ បើធ្វើចង្ហាន់ថ្វាយក៏គួរធ្វើថ្វាយវេលាព្រឹក ហើយដង្វាយនោះ គ្រាន់តែធ្វើឡើងដើម្បីទុកជាទីរលឹកដល់ថ្ងៃនៃការបានត្រាស់ដឹង របស់ព្រះពុទ្ធអង្គតែប៉ុណ្ណោះបានហើយ ព្រោះនាងសុជាតាជាស្ត្រីម្នាក់ ដែលបានជួបបានថ្វាយចង្ហាន់ដល់ព្រះបរមពោធិសត្វ នៅថ្ងៃដែលព្រះអង្គបានត្រាស់ដឹងគ្មានអ្នកណាមានភ័ព្វដូចនាងឡើយ ។ ម្យ៉ាងទៀត យើងមិនមែនបដិសេធចង្ហាន់សុជាតាថា គ្មានប្រយោជន៍នោះឡើយ គឺមានប្រយោជន៍ខ្លាំងណាស់ ព្រោះជាចង្ហាន់មានរសជាតិ ហើយកាលព្រះអង្គឆាន់អស់ហើយ ក៏អាក់ខានឆាន់៤៩ ថ្ងៃនៅពេលត្រាស់

www.elibraryofcambodia.org

ដឹងថ្មីៗ ក៏ដោយមានឱជារសនៃចង្ហាន់នោះមកជួយឧបត្ថម្ភព្រះកាយព្រះអង្គ តែមិនមែនបានត្រាស់ដោយសារតែចង្ហាន់របស់នាងនោះឡើយ គឺដោយបារមីរបស់ព្រះអង្គទៅវិញ ។

ស- កាលព្រះពោធិសត្វទ្រង់សោយមធុបាយាស និងបណ្តែតភាជន៍មាសរួចហើយ តើព្រះអង្គយាងទៅគង់នៅទីណា? បានជួបនឹងអ្នកណាដែរ ?

ច- ទ្រង់ប្រថាប់សំរាកព្រះកាយនៅក្នុងសាលវ័ន ក្បែរស្ទឹងនេរញ្ជរា លុះដល់ពេលរសៀល ទើបទ្រង់យាងទៅកាន់ដើមពោធិព្រឹក្ស ។ នៅតាមផ្លូវទ្រង់បានជួបនឹងសោត្ថិយព្រាហ្មណ៍ ដែលកំពុងច្រូតស្មៅសំរាប់ប្រក់ ។ តាមធម្មតា ព្រាហ្មណ៍កាលកំពុងធ្វើអ្វី ហើយបានជួបនឹងអ្នកបួស ក៏តែងឱ្យវត្ថុនោះ ។ ដូច្នេះបានជាសោត្ថិយព្រាហ្មណ៍ បានថ្វាយស្មៅសម្រាប់ប្រក (ស្លា ឬស្បូវ) ៨ ក្តាប់ដល់ព្រះពោធិសត្វ ដើម្បីសំដែងសេចក្តីគួរសម ។ ព្រះពោធិសត្វទទួលយកស្មៅនោះហើយ ក៏យាងសំដៅទៅគល់ពោធិព្រឹក្ស រួចយកស្មៅដែលព្រាហ្មណ៍ថ្វាយទៅក្រាលហើយគង់ពីលើ ។

ស- ដើមពោធិព្រឹក្សនោះនៅឯណា ? ដុះពីកាលណា ? មានអាយុ និងកំពស់ប៉ុន្មានដែរ ? ព្រះអង្គទ្រង់គង់ពីខាងណា

www.elibraryofcambodia.org

ហើយទ្រង់ធ្វើយ៉ាងណាទៀត ? មានហេតុភេទដូចម្តេចខ្លះ ? ចូររៀបរាប់ត្រង់កន្លែងនេះឱ្យសព្វគ្រប់តាមការចេះដឹង !

ច. ដើមពោធិព្រឹក្សនោះ នៅឧរុវេលនិគមយាសិសប្រទេស បានដុះនៅថ្ងៃដំណាលគ្នានឹងព្រះពោធិសត្វទ្រង់ប្រសូត្រ មានអាយុ ៣៥ ឆ្នាំហើយមានកំពស់ ៥០ ហត្ថ ។ កាលព្រះបរមពោធិសត្វយាងទៅដល់ ទ្រង់គង់នៅពីខាងត្បូង, រួចគង់ពីខាងលិច, រួចគង់ពីខាងជើង ហើយបែរព្រះភក្ត្រទៅកាន់គល់ពោធិព្រឹក្ស ក៏ប៉ុន្តែទីទាំងប៉ុន្មាននោះ ហាក់ដូចជារេបីរដុបរកុបរគើលព្រមទាំងមានការញាប់ញ័រហាក់ដូចជាទូលព្រះអង្គថា "ទីនេះមិនមែនជាទីកើតរតនបល្លង្កទេ" ។ ព្រះអង្គទ្រង់យាងទៅគង់ពីខាងកើត រួចទ្រង់បែរព្រះភក្ត្រទៅរកគល់ពោធិព្រឹក្ស ក៏មានសភាពស្រួល ហាក់ដូចជាទូលថា ទីនេះជាទីកើតរតនបល្លង្ក ។ ព្រះអង្គទ្រង់ក្រាលស្មៅដែលព្រាហ្មណ៍ថ្វាយហើយគង់ពីលើ ។ ខណៈនោះរតនបល្លង្កក៏ផុសឡើង មានកំពស់ ១៤ ហត្ថទ្រព្រះអង្គពីក្រោមដើមពោធិព្រឹក្សភ្លាម ។

កាលរតនបល្លង្កផុសឡើងហើយ ព្រះពោធិសត្វទ្រង់គង់ដោយព្រះភ្នែនពីលើ រួចទ្រង់អធិដ្ឋានដោយអង្គ ៤ ថា "បើអាត្មាអញមិនបានត្រាស់ដឹងទេ ស្បែក, សរសៃ, សាច់, ឈាមរបស់

www.elibraryofcambodia.org

អាត្មាអញ ចូររីងស្ងួតទៅចុះ អញនឹងមិនក្រោកចោលរតនបល្លង្ក នេះឡើយ ។ ទ្រង់អធិដ្ឋានហើយទ្រង់បែរខ្នងទៅរកគល់ពោធិ-[illegible]ភក្ត្រទៅកាន់បូព៌ាទិសវិញម្តង ។ សូមបញ្ជាក់ថា [illegible]ដែលទ្រង់យាងពីសាលវ័នមក ពួកទេពតាទាំង [illegible]នធ្វើសក្ការបូជាដោយកម្រងផ្កាទិព្វផ្សេងៗ [illegible]ច្រើន [illegible]សាធុការពរដល់ព្រះអង្គយ៉ាងគឹកកង ឯ [illegible] វល្លិជាតិ, រុក្ខជាតិនានា ក៏បញ្ចេញផ្ការយោនរយាន ដើម្បីបូជាព្រះពោធិសត្វជាម្ចាស់ដែរ ។ លុះបានគង់លើរតន-បល្លង្កហើយ ព្រះឥន្ទបានផ្លុំស័ង្ខថ្វាយ,គន្ធព្វទេវបុត្រប្រគំពិណថ្វាយ, សុយាមទេវបុត្រយកចាមរទិព្វមកបក់ថ្វាយ, សហម្បតីព្រហ្មយកស្វេតច្ឆត្រមកបាំងថ្វាយ, កាឡនាគរាជបាននាំពួកកញ្ញាមករាំថ្វាយ, ឯទេវតាជាច្រើនអនេកបានបូជាកម្រងផ្កា និងសព្ទ-សាធុការពរដល់ព្រះអង្គយ៉ាងណែនណាន់តាន់តាប់ ។

ស- រតនបល្ល័ង្កដែលទ្រង់គង់នោះ កើតពីស្មៅដែលព្រាហ្មណ៍ថ្វាយ ឬកើតពីអ្វី ? ហើយបល្ល័ង្កនោះជាបល្ល័ង្កពិត ឬយ៉ាងណាដែរ ?

ច- មិនមែនកើតពីស្មៅនោះទេ តែកើតពីបុញ្ញានុភាព និងបារមីរបស់ព្រះអង្គ ដែលទ្រង់បានធ្វើសន្សំមកហើយអស់ច្រើន

www.elibraryofcambodia.org

អសង្ខេយ្យនោះឯង ។ម្យ៉ាងទៀតបល្ល័ង្កនោះមិនមែនជាកែវពិតទេ ប៉ុន្តែជាភ្នែនមួយដ៏សំខាន់ ដែលព្រះអង្គពែនហើយទ្រង់បានអធិដ្ឋានប្តេជ្ញាថា បើព្រះអង្គមិនបានត្រាស់ដឹងទេ ព្រះអង្គស៊ូក្ស័យសង្ខារ ព្រះអង្គមិនក្រោកចេញឡើយ ។

## ការផ្ចាញ់មារ

ស- នៅពេលដែលព្រះពោធិសត្វ ទ្រង់គង់លើរតនបល្ល័ង្កនារសៀលថ្ងៃនោះ តើមានជនណាក្រៅពីទេវតា មកជួបនឹងព្រះអង្គដែរ ?

ច- ក្រៅពីទេវតាដែលបានធ្វើសក្ការបូជា មានទេវបុត្រមារបានកេណ្ឌទ័ពមក ដើម្បីជ្រែកដណ្តើមរតនបល្ល័ង្កអំពីព្រះមហាបុរស ។

ស- មានកេណ្ឌទ័ពមកចំនួនប៉ុន្មាន ? មកនៅទីណា ? មានអាវុធៈ និងធ្វើយ៉ាងណាខ្លះ ?

ច- ទ័ពមារមានច្រើនជាអនេក គឺខាងមុខកម្រាស ១២ យោជន៍ ខាងឆ្វេង-ស្តាំ មានកម្រាស ១២ យោជន៍ដូចគ្នា ។ ទ័ពទាំងនេះបានស្រែកឮខ្ទរខ្ទារទៅចម្ងាយមួយសែនយោជន៍ ។ មេទ័ពជាទេវបុត្រមារជិះលើដំរីគិរីមេខលា កំពស់ ១៥០ យោជន៍

www.elibraryofcambodia.org

និម្មិតដៃមួយពាន់សុទ្ធតែកាន់អាវុធ ឯសេនាក៏និម្មិតកាយមានពណ៌ខៀវលឿងជាដើម, ខ្លះធ្វើជាយក្ស, ជាម្រឹគ មានកំពស់ ១ គាវុធខ្លះ, ២ គាវុធខ្លះ, ៣ គាវុធខ្លះ, ១យោជន៍ខ្លះ ហើយនាំគ្នាដើរចូលសំដៅទៅដើមពោធិរកព្រះពោធិសត្វជាម្ចាស់ ត្រង់ខាងក្រោយ, ខាងឆ្វេង-ស្តាំ ។ ព្រះពោធិសត្វទ្រង់គង់តែមួយព្រះអង្គឯងនៅលើរតនបល្ល័ង្ក ឯពួកទេវតាបានរត់ចោលព្រះអង្គទៅកាន់ទងទៃៗរស់ ។ ទេវបុត្រមារបានបណ្តាលឱ្យកើតជាខ្យល់ភ្លៀងធំ, ភ្លៀងថ្មភ្នំ, ភ្លៀងគ្រឿងប្រហារ, ភ្លៀងរងើកភ្លើង, ភ្លៀងផេះក្តៅ, ភ្លៀងដីខ្សាច់, ភ្លៀងភក់ បាចសាចមកលើព្រះអង្គ តែមិនអាចត្រូវព្រះពោធិសត្វបានឡើយ ។ ធ្វើយ៉ាងណាមិនកើត ក្រុងមារបានបរដំរី ដៃកាន់អាវុធ ១ ពាន់ចូលទៅស្រែកថា "នែសិទ្ធត្ថ ! ចូរដើរចេញពីបល្ល័ង្កនេះ ព្រោះជារបស់យើង" ។ ព្រះពោធិសត្វបាននឹកដល់បារមីទាំង ៣០ ប្រការដែលព្រះអង្គបានបំពេញរស់ជាច្រើនអសង្ខេយ្យកប្ប ទ្រង់គ្មានខ្លាចសោះ ហើយបានតបទៅនឹងមារថា "ម្នាលមារ ! បល្ល័ង្កនេះមិនមែនកើតសម្រាប់អ្នកទេ គឺកើតសម្រាប់យើងដែលជាអ្នកបំពេញបារមី ៣០, មហាបរិច្ចាគ៥, ចរិយា ៣ ទេតើ ។ មារឮដូច្នោះរិតតែក្រោធខ្លាំងឡើង ហើយបានចោលអាវុធ, លើកកំពូលភ្នំបោះសំដៅព្រះអង្គ តែវត្ថុទាំង

www.elibraryofcambodia.org

នោះក្លាយជាកម្រងផ្កាថ្វាយព្រះអង្គទៅវិញ ។

ព្រះសិទ្ធត្ថទ្រង់ព្រះចិន្តាថា "នៅថ្ងៃត្រាស់ដឹង បល្ល័ង្ករតន៍តែងកើតដល់ព្រះពោធិសត្វរាល់ព្រះអង្គជាដរាប ឯបល្ល័ង្កនេះក៏កើតដល់អាត្មាអញ ហើយសម្រាប់តែអាត្មាដែរ" រួចទ្រង់សួរទៅមារថា "បើបល្ល័ង្កនេះជារបស់អ្នក តើអ្នកមានអ្នកឯណាជាសាក្សី ? មារតបថា "ពលសេនាទាំងអស់ជាសាក្សីរបស់យើង ចុះសិទ្ធត្ថឯងមានអ្នកណាជាសាក្សីដែរ ? ព្រះពោធិសត្វទ្រង់ត្រាស់ថា "សាក្សីរបស់អ្នកសុទ្ធតែជាអ្នកមានចិត្តចេតនា ឯសាក្សីរបស់យើងគឺ មហាប្រឹថពីនេះឯង" ។ គ្រានោះព្រះមហាប្រឹថពីក៏លាន់កញ្ជ្រើកឡើង រួចជាអនុទូលថាជាសាក្សីមែន ។ គ្រាបរួចនោះព្រះបរមពោធិសត្វទ្រង់ទឹកដល់ដីរបច្ច័យនាគេន្ទ្រ ដែលព្រះអង្គបានប្រទានដល់អ្នកស្រុកកលិង្គរាស្ត្រ កាលទ្រង់សោយព្រះជាតិជាព្រះវេស្សន្តរ ។ គ្រានោះដីរីនាឡាគិរីក៏លុតជង្គង់ ទ្រោមក្បាលចុះ ឯក្រុងមារឃើញដូច្នោះក៏លើកដៃសរសើរថា"

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
សទេវកស្មឹ លោកស្មឹ នត្ថិ តេ បដិបុគ្គលោ
តុវំ ពុទ្ធោ តុវំ សត្ថា តុវំ មារាភិភូ មុនិ
តុវំ អនុសយេ ឆេត្វា តិណ្ណោ តារេសិ មំ បជំ

www.elibraryofcambodia.org

"បពិត្រព្រះមហាបុរស[illegible]ព្យាយាម ខ្ញុំព្រះអង្គសូមនមស្ការចំពោះព្រះអង្គជា[illegible] ហើយដែលគ្មានបុគ្គលណាប្រៀបបាន នៅក្នុងលោកនេះ និងទេវលោក, [illegible] ជាអ្នកត្រាស់ដឹង ជាសាស្តាចារ្យ ជាអ្នកប្រាជ្ញអាចគ្រប[illegible] ពួកមារបាន ព្រះអង្គទ្រង់កាត់ផ្តាច់នូវគ្រឿងត្រាំគឺកិលេស ហើយអាចនាំពួកសត្វឱ្យឆ្លងផុតពីភព ៣ ដាក់ដល់ស្ថានបរមសុខ ជាអវសាន" ។ កាលពោលយ៉ាងនេះហើយ ពួកមារក៏នាំគ្នាចេញបាត់អស់ទៅនៅពេលល្ងាចថ្ងៃជិតលិច ។ ពួកទេពតាឃើញដូច្នោះក៏ហោះត្រឡប់មកកាន់ពោធិព្រឹក្សវិញ ហើយធ្វើសក្ការៈបូជាព្រះបរមពោធិសត្វដោយយកម្រងមាលា និងសព្វសាធុការពរដ៏ច្រើនអនេក ។ ព្រះមហាប្រឹថពីក្តី វុក្ខជាតិក្តី បានសំដែងកាយវិការរបស់ខ្លួនបូជាព្រះបរមពោធិសត្វ ដោយអាការផ្សេងៗ យ៉ាងច្រើន ។

ស. កាលព្រះពោធិសត្វយាងចេញសាងបព្វជ្ជា មានមារមកឃាត់ព្រះអង្គដែរ ក៏ប៉ុន្តែមារនោះ គឺជាព្រះទ័យស្តាយស្រណោះរបស់ព្រះអង្គបន្តិចបន្តួច ចំពោះភេទគ្រហស្ថនោះឯងទេវិញ ចុះពួកមារដែលមកចង់ដណ្តើមរតនបល្ល័ង្កនេះ តើជាមារពិតប្រាកដ ឬជាមារយ៉ាងណា ? ចូរដោះស្រាយឱ្យល្អមស្តាប់បាន

www.elibraryofcambodia.org

ទៅមើល !

ច. មារមកដណ្តើមរតនបល្ល័ង្ក ធ្វើទុក្ខបុកម្នេញព្រះពោធិសត្វ នៅពេលមុនទ្រង់បានត្រាស់នេះ បើតាមការពិចារណាទៅក៏មិនមែនជាមារមានជារូប ឬទេវបុត្តមារនោះដែរ គឺជាកិលេសមារ. ជាព្រះទ័យសាំញ៉ាំមិនទាន់ផុតអាល័យពីធម៌របស់បុថុជ្ជននោះឯង ។ ព្រះទ័យរបស់ព្រះអង្គជាបុថុជ្ជននេះហើយ ដែលកំពុងប្រឆាំងតយុទ្ធគ្នាយ៉ាងខ្លាំង ហើយស្មុគស្មាញជាទីបំផុត នៅក្នុងបេះដូងព្រះអង្គ ដែលលោកប្រៀបបានទៅនឹងខ្យល់ព្យុះសង្ឃរា ឬភ្លៀងគ្រប់យ៉ាងដ៏ធំ ៗ បោកបក់មកនឹងព្រះទ័យរបស់ព្រះអង្គក៏ប៉ុន្តែព្រះទ័យករុណា. សេចក្តីព្យាយាម. បុញ្ញាភិនិហាររបស់ព្រះអង្គ បាននាំព្រះទ័យព្រះអង្គឱ្យកាត់ផ្តាច់នូវកិលេសមារ ដោយឥតអាឡោះអាល័យ ហើយផ្តោតព្រះទ័យចុចចំតែគោលដៅមួយ គឺតស៊ូដើម្បីបាននូវសម្មាសម្ពោធិញ្ញាណនេះឯង ។ គឺនៅត្រង់សេចក្តីមេត្តាករុណា និងការលះបង់ដោយឥតអាល័យនេះហើយ ដែលយើងធ្លាប់ដឹងថា "នាងគង្គឹងព្រះធរណីច្បូតសក់បញ្ចេញទឹកឱ្យជន់លិចពួកពលមារអស់" ។

ប្រសិនបើពួកពលមារលើកទ័ពមកដូច្នោះមែន ប្រហែល រុក្ខជាតិ. ភូមិស្ថានអ្នកស្រុកនៅទីនោះទាំងប៉ុន្មានត្រូវវិនាសអស់

www.elibraryofcambodia.org

ដោយសារទ័ពមារដ៏ច្រើនញាំញី ឬត្រូវនឹងអាវុធរបស់មារទៅហើយ ក៏ប៉ុន្តែដោយមារនោះជាកិលេសមារ ដែលមាននៅតែក្នុងព្រះទ័យ, ក្នុងតួរអង្គព្រះពោធិសត្វតែប៉ុណ្ណោះ បានជាគ្មានអ្នកស្រុកអ្នកភូមិណាដឹង ឯធម្មជាតិក៏នៅតង់វង់បញ្ចេញឥទ្ធានុភាពរបស់ខ្លួនបូជាព្រះអង្គវិញ ។

ដូច្នេះការដែលព្រះអង្គ បានធ្វើចម្បាំងឈ្នះមារនោះ គឺឈ្នះកិលេសមារ ពោលគឺ រាគៈ តណ្ហា នោះឯងទេវិញទេ ។

www.elibraryofcambodia.org

# ភាគទី ៥

## ការបានត្រាស់ដឹងនៃព្រះសម្ពុទ្ធ

ស. កាលព្រះបរមពោធិសត្វ ទ្រង់ឈ្នះមារហើយ តើព្រះអង្គទ្រង់ក្រោកចាក ឬទ្រង់គង់នៅលើរតនបល្ល័ង្កនោះដដែល ? ហើយទ្រង់បានធ្វើយ៉ាងណាខ្លះ ?

ច. ឥតក្រោកទៅទីណាទេ, កាលទ្រង់បានរម្ងាប់បន្ទាបកិលេសមារហើយ ទ្រង់ប្រឹងស្មឹងស្មាធ៍ពិចារណារកធម៌លើរតន-បល្ល័ង្កទៅទៀត ក៏ប៉ុន្តែទ្រង់រកពុំបានឃើញ ទ្រង់ក៏ចាប់ផ្តើមពិចារណាតាមវិធីបដិលោម និងអនុលោមចុះឡើងយ៉ាងនេះថា :

"កាលមុនដែលអញមកអង្គុយលើរតនបល្ល័ង្កនេះ អញអង្គុយបែរមុខទៅទិសខាងមុខរកគល់ពោធិព្រឹក្ស មុននេះអញអង្គុយខាងត្បូងគល់ពោធិព្រឹក្ស, មុននេះទៀតអញអង្គុយខាងលិចខាងជើងគល់ពោធិព្រឹក្ស មុននេះទៅទៀតអញមកពីសាលវ័ន ពីស្ទឹងនេរញ្ជរា, មុននេះទៅទៀតអញឆាន់ចង្ហាន់អស់ ៤៩ ដុំ រួចផ្សងភាជន៍មាសក្នុងទឹក ... ។ ទ្រង់ពិចារណាច្រាសឡើង រហូតដល់ពេលទ្រង់ទទួលចង្ហាន់នាងសុជាតាឡើងទៅខាងលើ ខាងដើមរហូតទល់កាលពេលព្រះអង្គ ទ្រង់យាងពេញសាងព្រះផ្នួស. ទ្រង់ពិចារណាច្រាសឡើងទៅទៀត រហូតទ្រង់ជ្រាបដឹងថា ព្រះ

www.elibraryofcambodia.org

ព្រះអង្គជារាជបុត្រ, ជាក្សត្រវង្សណា មាននាទីជាអ្វី ទ្រង់បាន ប្រសូត្រពីពេលណា ? មាតាបិតាឈ្មោះអ្វី ៗ ហើយពិចារណា ឡើងលើពីពេលនោះទៅទៀត ក៏គិតលែងឃើញ ទាល់ត្រឹមទ្រង់ ដឹងថាទ្រង់ជាជាតិ, ជាបុត្រជាអ្នកត្រកូលណា ៗ ប៉ុណ្ណោះ ទ្រង់ក៏ ពិចារណាបណ្តោយចុះស្រប មកជាលំដាប់រហូតដល់ពេលដែល ទ្រង់គង់លើរតនបល្ល័ង្កវិញដដែល តែទ្រង់ពុំបានឃើញអ្វីទេ ។ កាលពិចារណាស្ទុតមកដល់នេះហើយ នៅទុញទាល់ត្រឹមនេះ ក៏ ទ្រង់ពិចារណាភាវរកទៅដើមវិញ រហូតទល់ពេលទ្រង់ប្រសូត្រ ។ ការពិចារណាសារចុះសារឡើងយ៉ាងនេះ ហៅថា ការពិចារណា តាមបដិលោមវិធី និងអនុលោមវិធី ហើយការពិចារណាបែបនេះ ទ្រង់ទើបនឹងរកឃើញក្នុងពេល ដែលទ្រង់គង់លើរតនបល្ល័ង្កតែ ប៉ុណ្ណោះ ពេលមុនៗ នេះទ្រង់ពុំដែលនឹកឃើញយ៉ាងនេះទេ ។

កាលព្រះអង្គពិចារណាជាអនុលោម បដិលោមហើយនេះ ព្រះបញ្ញាញាណព្រះអង្គកាន់តែភ្លឺឡើងៗ ជា[illegible] ទ្រង់ពិចារណាច្រាសឡើងម្តងទៀត [illegible] ទ្រង់[illegible]ឃើញជាដំបូងថា កាលមុនជាតិ[illegible] [illegible]ទេវបុត្ត. កាលមុននេះអា[illegible] នៅជេតុត្តនគរ ...។ កាលមានញាណនេះហើយទ្រង់ក៏ពិចារណា

www.elibraryofcambodia.org

រកឃើញនូវព្រះជាតិជាច្រើន ហៅថាអនេកជាតិ ។ នៅក្នុងបឋមយាមនៃរាត្រីកាល ១៥ កើត ខែពិសាខនេះ ទ្រង់បាននូវបុព្វេនិវាសានុស្សតិញ្ញាណ គឺការដឹងដោយការរលឹកឃើញនូវទីកន្លែងដែលទ្រង់យោនយកមកពីមុនទាំងអស់ ព្រមទាំងសភាព, គោត្រ, ត្រកូល, សេចក្តីសុខទុក្ខ, អាយុសង្ខារ, ចំណីអាហារ និងហេតុផ្សេងៗ ក្នុងជាតិនោះៗ ។

កាលព្រះបរមមហាបុរស បាននូវបុព្វេនិវាសានុស្សតិញ្ញាណ ក្នុងបឋមយាមហើយ ដល់មជ្ឈិមយាមទ្រង់ពិចារណានូវនិស្ស័យរបស់សត្វដទៃក្រៅពីព្រះអង្គទៀត ហើយទ្រង់ក៏បានឃើញនូវអំពើ, ការកើតស្លាប់របស់មនុស្សផ្សេងៗ តទៀត ព្រះអង្គក៏បាននូវញាណទី ២ គឺ ចុតូបបាតញ្ញាណ ៈ ការដឹងនូវការច្យុត និងការកើត ព្រមទាំងកម្មផលរបស់សត្វលោកដោយឥតទើសទាក់ ។

កាលទ្រង់បានដឹងស្គាល់នូវការកើត និងការស្លាប់របស់មនុស្សសត្វហើយ បច្ឆិមយាមក៏ចូលមកដល់ ហើយទ្រង់គង់ពិចារណារកនូវហេតុ នៃការកើតស្លាប់ និងហេតុនៃការរំលត់នូវការកើតការស្លាប់នោះតទៅទៀត ដោយទ្រង់ទាញនូវបដិច្ចសមុប្បាទធម៌មកពិចារណាថា ៖

www.elibraryofcambodia.org

"សេចក្តីសោក - ខ្សឹកខ្សួល - ទុក្ខព្រួយ - ចង្អៀតចង្អល់ក្តួចចិត្ត កើតមានព្រោះជរា និងមរណៈដែលមានជាតិជាបច្ច័យ, តណ្ហាកើតពីវេទនា, វេទនាកើតពីសម្ផស្ស, សម្ផស្សកើតពីអាយតនទាំង ៦, អាយតនទាំង៦ កើតពីនាមនិងរូប, នាមនិងរូបកើតពីវិញ្ញាណ, វិញ្ញាណកើតពីសង្ខារ, ឯសង្ខារកើតមកពីអវិជ្ជា។ ដូច្នេះអវិជ្ជា គឺការល្ងិតល្ងង់សូន្យសុង ជាប្រភពដំបូងនាំឱ្យមានការកើតស្លាប់ទុក្ខព្រួយនោះឯង ។ បើអវិជ្ជារលត់ សង្ខារ, វិញ្ញាណ, នាមរូប, អាយតនទាំង៦, សម្ផស្ស, វេទនា, តណ្ហា, ឧបាទាន, ភព, ជាតិ, ជរា និងមរណៈ ក៏រលត់ទៅឯង១ ហើយទុក្ខសោកខ្សឹកខ្សួល ការចង្អៀតចង្អល់ក្តួចចិត្តសព្វយ៉ាង ក៏រលត់ទៅទាំងអស់ដែរ ។ គឺនៅត្រង់ការរលត់អស់នេះហើយ ដែលសត្វលោកនឹងដល់នូវស្ថានព្រះនិព្វានជាស្ថានបរមសុខ ពោលគឺសេចក្តីសុខតែមួយ ឥតប្រែក្រឡាសមកកាន់សេចក្តីទុក្ខវិញដូចស្ថានឯទៀត១ ។

ពេលជិតផុតបច្ឆិមយាមទៅហើយ ព្រះពោធិសត្វក៏បានពិចារណា នូវបដិច្ចសមុប្បាទធម៌ដោយវិធីច្រាសបណ្តោយចុះឡើង ហើយក៏ទ្រង់បាននូវញាណទី៣ ហៅ អាសវក្ខយញ្ញាណ ពោលគឺការដឹងនូវហេតុ នៃការកើតនិងរលត់នៃអាសវក្ខ (គ្រឿង

www.elibraryofcambodia.org

សៅហ្មង), ព្រះធរណីក៏កម្រើករំពើកអស់វារៈ ១២ ដង ជានិមិត្តរូបនៃការបូជានូវការបានត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ របស់ព្រះសិទ្ធត្ថគោតមជាបរមសម្មាសម្ពុទ្ធ ។ ធម្មជាតិ ទេពតានានា បានបញ្ចេញកម្រងផ្កា, បានលើកទង់ជ័យឡើងថ្វាយនូវសេចក្តីត្រេកអររបស់ខ្លួន ចំពោះការបានត្រាស់ដឹងរបស់ព្រះសិទ្ធត្ថជាព្រះពុទ្ធអង្គពេញលក្ខណៈ ។ ព្រះពុទ្ធបរមគ្រូកាលបាននូវសម្មាសម្ពោធិញ្ញាណហើយ ទ្រង់បានបន្លឺគាថាជាដំបូងថា :

**អនេកជាតិ សំសារំ សន្ធាវិសំ អនិព្វិសំ**
**គហការំ គវេសន្តោ ទុក្ខា ជាតិ បុនប្បុនំ**
**គហការ ទិដ្ឋោសិ បុន គេហំ នកាហសិ**
**សព្វា តេ ផាសុកា គហកូដំ វិសំខតំ**
**វិសំខារគតំ ចិត្តំ តណ្ហានំ ខយមជ្ឈគា ។**

កាលពីអង្គអញតថាគត អន្ទោលក្នុងវាលវដ្ដសង្សារ
ច្រើនអសង្ខេយ្យកោដិកប្បា តែងបានទុក្ខារាល់ជាតិភព ។
ឥឡូវតណ្ហាគឺជាងផ្ទះ តថាគតយល់ច្បាស់ក្នុងចិត្តស៊ប់
បានដឹងបានឃើញដោយសព្វគ្រប់ អ្នកលែងប់សង់ផ្ទះបានទៀតហើយ ។
ឆ្អឹងជំនីនិងដំបូលអ្នក ត្រូវអញបំបាក់ឥតសល់ឡើយ
ចិត្តតថាគតបានដល់ត្រើយ ឥតតណ្ហាឡើយគឺនិព្វាន ។

www.elibraryofcambodia.org

ស. ញាណទាំង៣ គឺបុព្វេនិវាសានុស្សតិញ្ញាណ១ ចុតូបបាតញ្ញាណ១ អាសវក្ខយញ្ញាណ១ ជាចំណេះកើតមកពីការពិចារណារបស់ព្រះអង្គ តើនឹងហៅថាអ្វីផ្សេងទៀតបានទេ ?

ច. នឹងហៅថាវិជ្ជាក៏បាន ព្រោះថាការចេះដោយការពិចារណា គឺបុព្វេនិវាសានុស្សតិវិជ្ជា, ចុតូបបាតវិជ្ជា និងអាសវក្ខយវិជ្ជា ដែលយើងធ្លាប់ដឹងថា ព្រះអង្គមានវិជ្ជា៣ នោះឯង ។

ស. ព្រះសម្មាសម្ពុទ្ធ មានវិជ្ជាដែលកើតពីព្រះអង្គឯងតែ ៣ នេះទេ ឬមានផ្សេងទៀត ?

ច. មាន៥ ទៀតគឺ វិបស្សនាវិជ្ជា១, មនោមយិទ្ធិវិជ្ជា១, ឥទ្ធិវិជ្ជា១, ទិព្វសោតវិជ្ជា១, ចេតោបរិញ្ញាវិជ្ជា១, រួមទាំងវិជ្ជា៣ ខាងលើ ត្រូវជាវិជ្ជា៨ ។

ស. ព្រះសិទ្ធត្ថជាបរមគ្រូ ទ្រង់បានត្រាស់ជាព្រះពុទ្ធនៅទីណា ? នៅថ្ងៃខែឆ្នាំណា ? ក្រោយពីពេលទ្រង់ព្រះផ្នួសបានប៉ុន្មានឆ្នាំ ? ក្នុងព្រះជន្មប៉ុន្មាន ? មានអ្នកណាបានជួបប្រទះខ្លះ? ហើយតើធម៌ណាខ្លះដែលព្រះអង្គបានដឹង ទើបអាចសន្និដ្ឋានថាព្រះអង្គបានត្រាស់ដឹងមែន ?

ច. ទ្រង់បានត្រាស់នៅក្រោមដើមពោធិព្រឹក្ស ដែលដុះដំណាលគ្នានឹងថ្ងៃដែលព្រះអង្គទ្រង់ប្រសូត្រ នៅគយាសីស

www.elibraryofcambodia.org

ប្រទេស ឬឧរុវេលនិគម នៅថ្ងៃពុធ ពេញបូរមី ខែពិសាខឆ្នាំរកា (បានត្រាស់ដឹងដោយសព្វគ្រប់ នៅដើមថ្ងៃព្រហស្បត៍ ១រោជ ខែពិសាខ ព្រោះរាត្រីថ្ងៃពុធ ពេញបូរមី ខែពិសាខ នោះទ្រង់ទើបនឹងបានញាណពីរ ក្នុងបឋមយាម និងមជ្ឈិមយាម ដល់បច្ឆិមយាមផុតពីអាធ្រាត ចូលក្នុងថ្ងៃព្រហស្បត៍ទើបបានញាណទី៣ទៀត) ក្រោយពីទ្រង់បានសាងព្រះផ្នួសបាន ៦ ឆ្នាំ ក្នុងព្រះជន្ម ៣៥ ព្រះវស្សា ។ ពេលទ្រង់បានត្រាស់នោះគ្មានមនុស្សទៅបានឃើញទេ មានតែទេពតាប៉ុណ្ណោះ ដែលបានទៅធ្វើសក្ការបូជានមស្ការព្រះអង្គ ។

ដោយហេតុថា ព្រះអង្គជ្រាបនូវហេតុនិងផល នៃសមុទ-យធម៌ និងនិរោធធម៌ ពោលគឺហេតុដែលនាំឱ្យកើតទុក្ខសោករោគភ័យ និងហេតុនៃការរលត់ទុក្ខសោកជាដើមនោះ ដោយព្រះពុទ្ធញ្ញាណយ៉ាងពិតប្រាកដ ព្រមទាំងទ្រង់រកឃើញឃើញក្នុងការប្រតិបត្តិ ដើម្បីរំលត់ទុក្ខគឺការដើរតាមផ្លូវមានអង្គ ៨ ប្រការគឺ :

សម្មាទិដ្ឋិ = ការយល់ឃើញត្រូវ.

សម្មាសង្កប្បៈ = ការត្រិះរិះត្រូវ.

សម្មាវាចា = សំដីត្រូវ.

សម្មាកម្មន្តៈ = ការងារត្រូវ.

www.elibraryofcambodia.org

សម្មាអាជីវោ = ការចិញ្ចឹមជីវិតត្រូវ.

សម្មាវាយាមោ = ព្យាយាមត្រូវ.

សម្មាសតិ = ការរលឹកឃើញត្រូវ.

សម្មាសមាធិ = ការដំកល់ចិត្តត្រូវ ។

ទ្រង់យល់ថា ផ្លូវប្រកបដោយអង្គ ៨ ប្រការនេះហើយ ដែលនាំសត្វឱ្យផុតទុក្ខ ពោលគឺអាចដើរទៅកាន់ស្ថានព្រះនិព្វានបាន ។ អាស្រ័យហេតុនេះហើយទើបសន្និដ្ឋានបានថា ព្រះអង្គជាអ្នកត្រាស់ដឹង ។ ការប្រឹងប្រែងបំពេញទុក្ករកម្មក្តី ការលះរាជសម្បត្តិ និងមាតាបិតាក្តី ការបំពេញបារមីអស់ច្រើនអសង្ខេយ្យក្តី ក៏ដើម្បីឃើញនូវធម៌ប៉ុណ្ណោះ ហើយធម៌នេះព្រះអង្គទ្រង់ទើបនឹងបានឃើញ នៅពេលដែលទ្រង់គង់លើរតនបល្ល័ង្ក នៅព្រឹកនៃថ្ងៃ ១រោជនោះឯង ពីដើមមកព្រះអង្គពុំបានដឹងយ៉ាងនេះទេ ។ កាលទ្រង់មានញាណញេយ្យយ៉ាងនេះហើយ ទើបទ្រង់ជ្រាបថា សកម្មភាពរបស់ព្រះអង្គ ដែលបានធ្វើមកទាំងប៉ុន្មានមានលក្ខណៈត្រូវខ្លះ ខុសខ្លះ ឯពួកសត្វទាំងអស់ត្រូវកិលេសតណ្ហារុំព័ទ្ធជិត ដូចសត្វជាប់ក្នុងសំឡាញ់មកពីមិនដឹងហេតុផលយ៉ាងណា ដើម្បីរំដោះខ្លួនឱ្យរួចបាននោះឯង ។

✧ ✧ ✧

www.elibraryofcambodia.org

# ភាគទី ៨

## ព្រះពុទ្ធសកម្មភាព
## នៅពេលត្រាស់ដឹងហើយថ្មីៗ

ស. កាលព្រះពុទ្ធបរមគ្រូត្រាស់ដឹងនូវញេយ្យធម៌ហើយ តើទ្រង់យាងទៅពន្យល់សត្វលោកភ្លាម ឬទ្រង់ធ្វើយ៉ាងណាខ្លះ ? មានអ្នកណាខ្លះដែលជួបនឹងព្រះអង្គ ?

ច. ទ្រង់ពុំទាន់យាងទៅព្រោសសត្វ ឬទៅសំដែងធម៌ ដែលព្រះអង្គទើបនឹងរកឃើញនោះទេ គឺទ្រង់ធ្វើសកម្មភាពផ្សេងៗ អស់ ៤៩ ថ្ងៃមានរយៈកាលដូចតទៅនេះ :

ក្នុងសប្តាហ៍ទី ១ គឺចាប់ពីថ្ងៃព្រហស្បតិ៍ ១រោជ ខែពិសាខ ទៅទល់ថ្ងៃព្រហស្បតិ៍ ៨ រោជ ទ្រង់គង់នៅលើរតនបល្ល័ង្កក្រោមដើមពោធិព្រឹក្ស ជាទីដែលទ្រង់បានត្រាស់នោះ [illegible]ដែល ដើម្បីពិចារណាធម៌ដែលទ្រង់បានត្រាស់ដឹងហើយ ។

ក្នុងសប្តាហ៍ទី ២ ចាប់ពីថ្ងៃព្រហស្ប៍ ៨រោជទៅ, ពេលព្រឹក ទ្រង់ធ្វើយមកបា្បដិហារ្យដោះសេចក្តីសង្ស័យរបស់ទេពតា ហើយទ្រង់ចុះទៅគង់នៅខាងទិសឦសាន្ត នៃរតនបល្ល័ង្ក រួចទតរតនបល្ល័ង្កដោយព្រះនេត្រមិនប៉ព្រិចសោះ អ[illegible] ទល់ថ្ងៃព្រហស្បតិ៍ ១៥ រោជ ខែពិសាខ ។ ទីនេះ[illegible]

www.elibraryofcambodia.org

ស្សកចេតិយ ។

សប្តាហ៍ទី ៣ ចាប់ពីព្រឹកនៃថ្ងៃព្រហស្បត៍ ១៥ រោជ ខែពិសាខ ទៅទល់ព្រឹកនៃថ្ងៃព្រះហស្បត៍ ៧កើត ខែជេស្ឋ ទ្រង់យាងចង្រ្កមលើផ្ទះកែវហៅថា រតនចេតិយ ដែលព្រះឥន្ទបាននិម្មិតថ្វាយនៅចន្លោះរតនបល្ល័ង្ក និងអនិមិស្សកចេតិយ អស់ ៧ ថ្ងៃទៀត ។

សប្តាហ៍ទី ៤ ចាប់ពីព្រឹកនៃថ្ងៃព្រហស្បត៍ ៧កើត ខែជេស្ឋ ទៅទ្រង់គង់នៅក្នុងផ្ទះកែវដែលទេពតានិម្មិតថ្វាយ នៅខាងទិសពាយព្យ នៃគល់ពោធិព្រឹក្សអស់ ៧ ថ្ងៃទៀត ។ ផ្ទះកែវនេះតាមពិត មិនមែនជាផ្ទះទេ តែជាវិការៈនៃព្រះសទ្ធម្មទាំងឡាយ គឺសតិបដ្ឋាន ៤ ជាទីលាន, ឥទ្ធិបាទ៤ ជាសសរ ព្រះវិនយបិដកជាជញ្ជាំង, សម្មប្បធាន៤ ជាក្រប, សមាបត្តិ៨ ជារតនិងផ្ទៃ, ព្រះសុត្តន្តបិតកជាគ្រឿងដំបូល, ព្រះអភិធម្មបិដកជាប្រដាប់ប្រក ។

ក្នុងសប្តាហ៍ទី ៥ ចាប់ពីថ្ងៃព្រហស្ប ១៤កើត ខែជេស្ឋ ទៅ ទ្រង់យាងទៅគង់នៅក្រោមដើមអជបាលនិគ្រោធ(ដើមជ្រៃដែលពួកអ្នកគង្វាលចៀម ពពែតែងជ្រកអាស្រ័យនៅ) អស់៧ ថ្ងៃ ដើម្បីពិចារណាព្រះសទ្ធម្ម នឹងមនុស្សដែលទ្រង់គួរប្រោសបាន ៦ ពួក ។ តមកធីតានៃមារគឺនាងតណ្ហា, អរតី, រាគា បានមកលួង

www.elibraryofcambodia.org

លោមព្រះអង្គដោយអាការផ្សេង ១ តែមិនបានសម្រេចក៏ត្រឡប់ទៅស្ថានរបស់ខ្លួនវិញ ។

នៅសប្តាហ៍ទី ៦ ចាប់ពីថ្ងៃព្រហស្បត៍ ២រោជ ខែជេស្ឋទៅ ទ្រង់យាងទៅគង់នៅក្បែរស្រះមុច្ចលិន្ទ ។ នៅទីនោះបាននាគរាជឈ្មោះមុច្ចលិន្ទ បានចេញមកនិម្មិតកាយដ៏ធំពែនខ្លួនធ្វើជាបល្ល័ង្ក ហើយបើកពពារធ្វើជាឆ័ត្រថ្វាយព្រះសាស្តា ដើម្បីបិទបាំងភ្លៀងខ្យល់ ដែលបង្អុរនឹងបក់មក ។ ទ្រង់គង់អស់ ៧ ថ្ងៃទៀត ។

ក្នុងសប្តាហ៍ទី ៧ ចាប់ពីថ្ងៃព្រហស្បត៍ ១៣រោជ ខែជេស្ឋទៅដល់ថ្ងៃ ៥ កើត ខែអាសាឍ ទ្រង់យាងទៅគង់នៅក្រោមដើមកែស១ដើម អស់ ៧ថ្ងៃទៀត នៅថ្ងៃទាំង ៤៩ រាប់តាំងពីពេលបានត្រាស់មក ទ្រង់ពុំបានសោយចង្ហាន់ទេ គឺសោយតែវិមុត្តិសុខរហូត ។ លុះដល់ចុងនៃសប្តាហ៍ទី ៧ នេះ ទើបព្រះឥន្ទយកផ្លែស្រម៉ទិព្វមកថ្វាយព្រះអង្គ ១ ទ្រង់ទទួលមកសោយ ។ បន្ទាប់មកមានពាណិជពីរនាក់បងប្អូននិងគ្នា បងឈ្មោះ **តបុស្ស:** ប្អូនឈ្មោះ **ភល្លិត** បាននាំឈ្នួញរទេះ ៥០០ គ្រឿងដើម្បីនាំទំនិញទៅលក់ឯ **ឧក្កលាជនបទ** លុះដល់ជងព្រៃជិតដើមកែស មានទេពតាជាសាច់ញាតិពីអតីតជាតិ បានប្រាប់ពាណិជទាំងពីរថា ព្រះពុទ្ធនឹងបានត្រាស់ថ្មី ១ ឥឡូវគង់នៅក្រោមដើមកែសចូរអ្នកទៅថ្វាយ

www.elibraryofcambodia.org

បង្គំ ថ្វាយសត្តូវផ្សេងៗ ចុះ ។ ពាណិជបានចូលទៅថ្វាយបង្គំ ហើយបានថ្វាយសត្តូវ ព្រមទាំងសូមដល់សរណគមន៍ពីរ ថ្វាយខ្លួនជាសាវ័កយកព្រះពុទ្ធព្រះធម៌ជាទីពឹងទីរលឹកស្មើជីវិត ។ ពាណិជទាំងពីរនេះហើយជាឧបាសក ដែលយកព្រះពុទ្ធ ព្រះធម៌ជាសរណគមន៍មុនគេបង្អស់ក្នុងលោក ។ លុះពាណិជថ្វាយបង្គំលាហើយសុំនូវវត្ថុទុកជាទីរលឹកអំពីព្រះអង្គៗ ក៏យកព្រះហស្តអង្អែលព្រះសិរ រួចជាប់ព្រះកេសា ៨ សរសៃនឹងព្រះហស្ត ទ្រង់ក៏ប្រទានព្រះកេសាទៅពាណិជទាំងពីរ ។ បានខ្ចប់ព្រះកេសា ហើយយកទៅបញ្ចុះនៅ សិង្គុត្តរចេតិយ ។

សូមបញ្ជាក់ថា សិង្គុត្តរចេតិយនោះ ស្ថិតនៅក្នុងប្រទេសភូមាសព្វថ្ងៃនេះ ហើយគេបានបញ្ចុះពុទ្ធបរិក្ខាររបស់ព្រះពុទ្ធ៤ អង្គហើយគឺ ធម្មចក្ររបស់ព្រះពុទ្ធនាម កកុសន្ធ ១, វត្ថពន្ធរបស់ព្រះកោនាគមន១, សាដករបស់ព្រះពុទ្ធនាម កស្សប១ និងព្រះកេសធាតុរបស់ព្រះសិទ្ធត្ថគោតម ៨ សរសៃ ។ នៅពេលដែលពាណិជទាំងពីរធ្វើបុណ្យបញ្ចុះព្រះកេសធាតុនោះ ព្រះបាទឧបលាបរាជ ទ្រង់បានជួយឧត្ថម្ភផង ឯព្រះកេសធាតុក៏ធ្វើបាដិហារ្យយ៉ាងខ្លាំង ជាហេតុនាំឱ្យមនុស្សទេពតាជ្រះថ្លាដ៏ច្រើន ។

ស. កាលទ្រង់សោយចង្ហាន់របស់ពាណិជហើយ តើព្រះ

www.elibraryofcambodia.org

ពុទ្ធជាម្ចាស់ទ្រង់យាងទៅណាទៀត ? ហើយបានធ្វើជាយ៉ាងណា ?

ច- ទ្រង់យាងទៅគង់ក្រោមដើមអជបាលនិគ្រោធវិញ ។ នៅទីនោះព្រះអង្គទ្រង់គង់ពិចារណាធម៌ ដែលព្រះអង្គបានរកឃើញហើយ ។ ទ្រង់ព្រះតម្រិះក្នុងព្រះទ័យថា "ធម៌ដែលអង្គអញតថាគតបានរកឃើញ ហើយមានកិលេស, មានគ្រឿងសៅហ្មងនៅក្នុងចិត្តមិនងាយនឹងដឹងបានទេ ដូច្នោះបើតថាគតយកធម៌ដែលមានន័យជ្រៅទៅសំដែងឱ្យសត្វលោកទាំងនោះស្តាប់ ក៏ជាការឥតប្រយោជន៍ដែរ" ។ អាស្រ័យហេតុនេះហើយ ទើបព្រះអង្គមានព្រះទ័យរួញរាក្នុងការសម្តែងធម៌ ដើម្បីដឹកនាំសត្វលោកឱ្យប្រតិបត្តិតាម និងបានសម្រេចប្រយោជន៍ រួចខ្លួនពីវដ្តសង្សារនេះបាន ។

ស- ព្រះទ័យរារែកនេះ បាននាំឱ្យអ្នកណាដឹង ? តើព្រះអង្គមិនសំដែងធម៌រហូត ឬមួយទ្រង់សំដែងដែរ ? ការសំដែងនោះដោយទឹកព្រះទ័យព្រះអង្គ ឬដោយអ្នកណាអារាធនា ?

ច- តាមសេចក្តីដំណាលថា រឿងនេះជ្រាបដល់ទៅសហម្បតិមហាព្រហ្ម ក៏ចុះមកអារាធនាព្រះអង្គ ឱ្យសំដែងធម៌ដែលទ្រង់បានឃើញហើយ ដើម្បីជាប្រយោជន៍ដល់សត្វលោក ប៉ុន្តែ

www.elibraryofcambodia.org

តាមការពិចារណា របស់យើងទៅឃើញថា ព្រះអង្គព្រះពុទ្ធជាអគ្គបុគ្គល, ជាបរមគ្រូក្នុងលោក ហើយការស្វែងរកធម៌របស់ព្រះអង្គ ដើម្បីនឹងយកព្រះធម៌នោះ មកពន្យល់ណែនាំសត្វលោកឱ្យយល់ដឹងឃើញ ហើយនឹងរកមធ្យោបាយផ្សេងៗ ដើម្បីដើរចេញពីវដ្ដសង្សារនេះឯង បានសេចក្ដីថា ការរកបាននូវធម៌ថ្លៃរបស់ព្រះពុទ្ធអង្គៗ នឹងមិនលាក់ទុកតែ១ ព្រះអង្គឯងទេ ព្រះអង្គពិតជាចែករំលែកព្រះធម៌នោះ ដល់សត្វលោកជាមិនខាន ។ កាលបើគេនិយាយថា ព្រះអង្គរកធម៌ឃើញហើយៗ ទ្រង់តាំងព្រះទ័យថាមិនព្រមសំដែង ដោយទ្រង់ព្រងើយកន្តើយ ទាល់តែសហម្បតីមហាព្រហ្មមកអារាធនា ទើបព្រះអង្គសំដែងនោះ ជាការមិនពិត, មិនសមហេតុផលឡើយ ការនិយាយដូច្នេះហាក់ដូចជាសហម្បតីព្រហ្មនោះដឹងសុខទុក្ខ នឹងអាការចិត្តរបស់សត្វលោកជាងព្រះអង្គទៅទៀត ឯព្រះអង្គជាព្រះសព្វញ្ញូ បែរជាមិនដឹងអ្វីស្មើនឹងសហម្បតីព្រហ្មទៅវិញ ។

ដូច្នេះ ការនឹកគិតពិចារណារបស់ព្រះពុទ្ធអង្គថា ធម៌ដែលព្រះអង្គបានត្រាស់នោះ មានន័យជ្រៅឆ្ងាយណាស់ សត្វដែលមានរាគាទិកិលេស មិនងាយនឹងបានឃើញបានយល់ នោះវាមានយ៉ាងនេះពិតមែន ដូចមនុស្សម្នាក់ដែលរៀនសូត្របានវិជ្ជាជ័ខ្ពង់

www.elibraryofcambodia.org

ខ្ពស់ណាមួយ ក៏តែងគិតថាអ្នកដទៃដែលមានបញ្ញាទន់ខ្សោយ មិនងាយនឹងយល់ចេះដឹងវិជ្ជាដែលខ្លួនបានចេះនោះឡើយ ម្លោះហើយក៏នឹកគិតធុញទ្រាន់នឹងវិជ្ជានោះ ទៅបង្រៀនអ្នកដទៃទៅវិញ ។ ឯព្រះពុទ្ធកាលគង់នៅក្រោមដើមអជបាលនិគ្រោធនោះហើយជញ្ជឹងគិតមួយភ្លែត ក៏មានព្រះចិន្តាស្លុងទៅយ៉ាងនោះមែនតែកាលទ្រង់ព្រះចិន្តាតទៅទៀត ក៏មានព្រះតំរិះ១ ថាត្រូវតែសំដែងធម៌ ដែលព្រះអង្គរកឃើញហើយ ដើម្បីជាប្រយោជន៍ដល់សត្វលោក ទោះបានតិចក្តី ត្រូវតែសំដែង ។ ព្រះទ័យករុណាមេត្តានេះហើយ ដែលហៅថាព្រហ្ម ពោលគឺការកំណត់ដោយព្រះអង្គឯង ថានឹងសំដែងធម៌ដល់សត្វលោកដែលជាការចាំបាច់ហើយដែលយើងធ្លាប់ដឹងថា ព្រហ្មអារាធនា តែតាមពិតគ្មានព្រហ្មឯណាមកអារាធនាទេ គឺទឹកព្រះទ័យអាណិតអាសូរចំពោះសត្វលោកនោះឯង ជាតួសហម្បតីព្រហ្ម ។

ស- កាលទ្រង់ផ្តើមព្រះទ័យនឹងសំដែងធម៌នោះ ព្រះអង្គទ្រង់ចាត់នូវសត្វលោកជា ៤ ពួកជា "បរិស័ទ ៤ ជំពូកដូចផ្កាឈូកក្នុងផលថាន" ។ តើបុគ្គលជាបរិស័ទទាំង ៤ ជំពូកនេះ មានលក្ខណៈខុសគ្នាយ៉ាងណាខ្លះ ?

ច- កាលទ្រង់តាំងព្រះទ័យនឹងសំដែងធម៌ ក៏ដោយសារ

www.elibraryofcambodia.org

ព្រះអង្គទ្រង់យកបុគ្គល ៤ ជំពូកមកប្រៀបប្រដូចនឹងផ្កាឈូក ៤ ផ្នែកដែលមានលក្ខណៈខុសគ្នាយ៉ាងនេះគឺ :

ឧគ្ឃដិតញ្ញូ.- ជនដែលមានបញ្ញាបារមីចាស់ក្លា កាលណាស្តាប់រសនៃព្រះធម៌នោះភ្លាម ប្រៀបដូចផ្កាឈូកដែលផុះផុតពីទឹក កាលណាមានពន្លឺព្រះអាទិត្យក៏រីកភ្លាម ។

វិបច្ចិតញ្ញូ.- ជនដែលមានបញ្ញាបារមីពុំទាន់ចាស់ក្លាខ្លាំង កាលបើបានស្តាប់ធម៌ហើយ លុះតែព្រះធម៌នោះមានន័យពិស្តារវែងឆ្ងាយ ទើបចាក់ធ្លុះយល់បាន ដូចផ្កាឈូកដែលផុះផុតពីទឹកហើយ តែពុំទាន់ដល់កាលវេលានឹងរីកក្នុងថ្ងៃនេះ ។

នេយ្យបរិស័ធ.- ជនដែលមានបញ្ញាបារមី ពុំទាន់រឹងប៉ឹងនៅឡើយ លុះតែទ្រង់ទេសនាទូន្មានជាញឹកញយទៅ ទើបចេះដឹងយល់បាន ដូចផ្កាឈូកដែលនៅប៉ប្រះទឹក លុះតែផុះផុតពីទឹកហើយ ត្រូវពន្លឺព្រះអាទិត្យជាច្រើនដងទើបរីកបាន ។

បទបរមបរិស័ធ.- ជនដែលជាអ្នកគ្មានបារមីសោះ គឺមិនព្រមស្តាប់មិនព្រមប្រតិបត្តិតាម ការទូន្មានដឹកនាំរបស់ព្រះអង្គ ដូចផ្កាឈូកទើបនឹងប៉ិចពកនៅក្នុងទឹក វាតែងតែត្រូវចំណីជាផរាប ។

កាលទ្រង់នឹកឃើញយ៉ាងនេះហើយ ទ្រង់ក៏តាំងព្រះទ័យ

www.elibraryofcambodia.org

ថា នឹងសំដែងធម៌ដើម្បីទូន្មានសត្វលោក តាមគួរដល់ឧបនិស្ស័យ របស់សត្វលោកនីមួយៗ ដែលបានកសាងពីអតីតជាតិមក ។

www.elibraryofcambodia.org

# ភាគទី ៩

## បឋមទេសនា

### ធម្មចក្កប្បវត្តនសូត្រ
### និងការដឹកនាំសាវកជាដំបូង

ស. កាលព្រះសម្មាសម្ពុទ្ធទ្រង់ប្រារព្ធ នឹងសំដែងព្រះធម៌ប្រោសសត្វហើយ តើព្រះអង្គទ្រង់នឹកដល់ជនណាមុនគេ ? ដោយហេតុអ្វី ? ហើយតើបានទៅប្រោសជននោះឬទេ ?

ច. ព្រះសាស្ដាទ្រង់នឹកឃើញអាឡារតាបសកាលាមគោត្រ ដែលព្រះអង្គធ្លាប់ទៅរៀនយកសមាបត្តិ៧ កាលទ្រង់ទើបនឹងបួសហើយថ្មីៗ ប៉ុន្តែទ្រង់ក៏ជ្រាបថា តាបសនេះធ្វើមរណកាលទៅ៧ ថ្ងៃទៅហើយ ។ តមកទ្រង់នឹកឃើញដល់ ឧទកតាបសរាមបុត្រ ដែលព្រះអង្គធ្លាប់ទៅរៀនយកនេវសញ្ញាយតនសមាបត្តិ បន្ទាប់ពីរៀនសមាបត្តិ៧ មក ប៉ុន្តែព្រះសាស្ដាទ្រង់បានជ្រាបថា ឧទកតាបសនេះ ក៏បានធ្វើមរណកាលពីពេលព្រលប់ម្សិលមិញនេះទៅហើយ ។

ស. បន្ទាប់មក តើព្រះសាស្ដាទ្រង់នឹកឃើញដល់ជនណា ? នៅឯណា ? ព្រោះហេតុអ្វី ?

ច. តមកព្រះសាស្ដាទ្រង់នឹកឃើញទៅបញ្ចវគ្គិយបូសី

www.elibraryofcambodia.org

ដែលធ្លាប់នៅបំរើព្រះអង្គ កាលទ្រង់ធ្វើទុក្ករកិរិយា ប៉ុន្តែបញ្ចវគ្គិ-យឫសីទាំងនេះនៅឯវជ្ជកាសី ក្នុងព្រៃឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសីឯណោះ ។ ជនទាំង៥ រូបនេះ ជាមនុស្សមានគុណបំណាច់លើព្រះអង្គផង ជាមនុស្សដែលមានឧបនិស្ស័យចាស់ក្លា ធ្លាប់មានចិត្តអប់រំក្នុងធម៌ខ្លះហើយផង ។

ស. ព្រះសាស្ដាទ្រង់យាងទៅប្រោសឥសីទាំង ៥ រូបនោះឬទេ ? ពីទីត្រាស់ដឹងទៅឥសិបតនមិគទាយវ័ន មានចម្ងាយប៉ុន្មាន ? ទ្រង់សំដែងធម៌អ្វីប្រោសជនទាំងនោះ នៅខែ ឆ្នាំណា? ចូរពន្យល់ឱ្យស្ដាប់បាន !

ច. ទ្រង់យាងទៅប្រោសបញ្ចវគ្គិយឫសី ដោយទ្រង់ធ្វើព្រះដំណើរចេញ ពីគយាសីសប្រទេស ជាទីត្រាស់ដឹង ឆ្ពោះទៅវជ្ជកាសិចម្ងាយផ្លូវ ១៨ យោជន៍ (ប្រហែល ១៥០ គ.ម) ទៅទិសខាងលិច ។

នៅតាមផ្លូវ ព្រះសាស្ដាបានជួបនឹងឧបកាជីវក១ បានសួរព្រះសាស្ដាថា "... លោកបួសក្នុងសំណាក់លោកណា ? ព្រះសាស្ដាបានត្រាស់ថា" សព្វាភិភូ សព្វវិទូហមស្មិ សព្វេសុ ធម្មេសុ អនូបលិត្តោ សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ សយំ អភិសញ្ញាយ កមុទ្ទិសេយ្យំ = តថាគតជាអ្នកបានគ្របសង្កត់

www.elibraryofcambodia.org

កិលេសបានអស់ ជាអ្នកចេះដឹងយល់នូវហេតុផលសព្វ មិនជាប់ជំពាក់ក្នុងធម៌ ហើយលះធម៌(ខ្មៅ) ទាំងពួងបានហើយ ។ បានរួចស្រឡះ ព្រោះអស់តណ្ហា ឥតមានគ្រូអាចារ្យណាទេ ព្រោះជាផាសព្វញ្ញុពុទ្ធទៅហើយ" ។ ឧបការឮហើយក៏ងក់ក្បាល ដើរចេញទៅ ។

ព្រះសាស្ដាទ្រង់ធ្វើព្រះដំណើរទៅទៀត តែនៅតាមផ្លូវ ១៨ យោជន៍នោះ មិនឮថា បានជួបនឹងជនណាឡើយ លុះទៅដល់ឥសិបតនមិគទាយវ័នហើយ ក៏បានជួបនឹងបញ្ចវគ្គិយឫសី ។ ពួកឫសីទាំងនោះ កាលឃើញព្រះសាស្ដាហើយក៏និយាយគ្នាថា "ពួកយើងកុំនាំគ្នាក្រោកទទួលព្រះគោតម" ។ កាលបើព្រះសាស្ដាយាងចូលទៅជិត ពួកនោះបានហៅចំពោះព្រះសាស្ដាថា "គោតម" ។ ព្រះសាស្ដាទ្រង់ត្រាស់ឃាត់ ២-៣ ដង ហើយទ្រង់ត្រាស់ថា តថាគត បានស្វែងរកការត្រាស់ដឹង ដោយខ្លួនឯងឃើញហើយ អ្នកទាំងឡាយចូរចាំស្ដាប់ចុះ តថាគតនឹងសំដែងឱ្យអ្នករាល់គ្នាស្ដាប់យល់ និងចេះដឹងឥឡូវនេះហើយ ។ ពួកបញ្ចវគ្គិយឫសីក៏នាំគ្នាព្រមស្ដាប់ ហើយព្រះសាស្ដាទ្រង់ចាប់ផ្ដើមសំដែងធម្មចកប្បវត្តនសូត្រ ប្រោសបញ្ចវគ្គិយឫសីទាំងនោះ នៅថ្ងៃពេញបូរមី ខែអាសាឍ ឆ្នាំ រកា (កុក្កុដេសព្វញ្ញុ ពុទ្ធោ តត្ថ ចក្កំ បវត្តយិ) ដោយ

www.elibraryofcambodia.org

មានគោលសំខាន់ពីរប្រការគឺ :

១- កាមសុខល្លិកានុយោគ.- បព្វជិតមិនត្រូវប្រព្រឹត្តធ្វើខ្លួនឱ្យជាប់ជំពាក់ដោយកាម គឺចំណង់ និង [illegible]

២- អត្តកិលមថានុយោគ.- បព្វជិតមិនត្រូវប្រព្រឹត្តធ្វើខ្លួនឱ្យលំបាកលំបិន ក្នុងករណីដែលគេត្រូវ [illegible]

ធម៌ទាំងពីរប្រការនេះជាធម៌ថោកទាប [illegible] អ្នកស្រុក ហើយជាធម៌របស់បុថុជ្ជន មិនមែន [illegible] ឡើយ ។ ធម៌នេះតថាគត ធ្លាប់សេពគប់ ធ្លាប់ប្រព្រឹត្តមករួចហើយ តែមិនបានផលប្រយោជន៍អ្វីទាល់តែសោះ មានតែផ្លូវមួយទេគឺ :

- មជ្ឈិមាបដិបទា.- បព្វជិតត្រូវប្រព្រឹត្តប្រតិបត្តិយ៉ាងណា ? គឺត្រូវដើរតាមផ្លូវប្រកបដោយអង្គ ៨ ប្រការ (អដ្ឋង្គិកមគ្គ) ប៉ុណ្ណោះ ទើបជាធម៌នាំឱ្យកើតបញ្ញាចក្ខុ ... នាំឱ្យរលត់ទុក្ខបាន។

លុះព្រះសាស្តាបានបង្ហាញនូវការប្រព្រឹត្តទាំង ៣ បែបនេះហើយ ព្រះអង្គក៏សំដែងអរិយសច្ចទាំង៤ គឺទុក្ខសច្ច១, សមុទយសច្ច១, និរោធសច្ច១, មគ្គសច្ច១ ព្រមទាំងញាណ ៣ គឺសច្ចញ្ញាណ១, កិច្ចញ្ញាណ១, កតញ្ញាណ១ ឱ្យប្រព្រឹត្តទៅក្នុងសច្ចធម៌ទាំង ៤ ។ ពួកទេពតាបានបន្លឺសំឡេងត១គ្នា រហូតដល់ព្រហ្ម

www.elibraryofcambodia.org

លោក ឯលោកធាតុទាំង១ មិនក៏កំរើកញាប់ញ័រ ។ លុះចប់ធម្ម-ចក្កប្បវត្តនសូត្រហើយ ព្រះកោណ្ឌញ្ញក៏បានធម្មចក្ខុថា "យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មំ = វដ្ដ (ការវិលចុះឡើង) ទាំង ៣ គឺ កម្ម, កិលេសនិងវិបាក ណា១ ដែលមានការកើតឡើង តាមធម្មតា វដ្ដទាំង ៣ នោះតែងតែរលត់ទៅវិញជាធម្មតា ។ ការយល់បែបនេះ នាំឱ្យព្រះកោណ្ឌញ្ញៈបានសម្រេចសោតាបត្តិផល ជាបឋមសាវ័ករបស់ព្រះសមណគោតមសម្មាសម្ពុទ្ធ ។ ទ្រង់បន្លឺព្រះវាចារថា "អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ ឱហ្ន កោណ្ឌញ្ញបានចេះដឹងហើយៗ "។ ព្រះកោណ្ឌញ្ញៈក៏បាននាមថា "អញ្ញាកោណ្ឌញ្ញៈ តមក " ។

គ្រានោះ ព្រះអញ្ញាកោណ្ឌញ្ញ បានសូមផ្នួសក្នុងសំណាក់ព្រះសាស្តាៗ ទ្រង់អនុញ្ញាតជាឯហិភិក្ខុឧបសម្បទា ។

ស- ចុះឫសី ៤ រូបទៀតបានសម្រេចធម៌អ្វីដែរ ? ព្រះសាស្តាទ្រង់ធ្វើយ៉ាងណាទៀត ?

ច- នៅរាត្រីនៃថ្ងៃពេញបូរមី ខែអាសាឍនោះ ឫសី៤ រូបទៀតមិនទាន់បានសម្រេចទេ ព្រះសាស្តាទ្រង់លើកយកធម្មចក្កនេះមកសំដែងឱ្យឫសីវប្បៈក្នុងថ្ងៃ ១ រោជ, ដល់ភទ្ទិយក្នុងថ្ងៃ២ រោជ ដល់មហានាមក្នុងថ្ងៃ៣រោជ និងដល់អស្សជិក្នុងថ្ងៃ៤រោជ។

www.elibraryofcambodia.org

កាលសំដែងចប់មួយពេល១ ឬសីនីមួយ១ ក៏បានសម្រេចសោតាបត្តិផល ហើយចូលសូមឧបសម្បទាជាឯហិភិក្ខុម្តងមួយ១ដូចគ្នា។ តមកព្រះសាស្តាទ្រង់លើកយកអនត្តលក្ខណសូត្រ គឺធម៌ដែលសំដែងថា អ្វីក៏មិនមែនជារបស់ខ្លួនទាំងអស់ មកសំដែងឱ្យបញ្ចវគ្គិយភិក្ខុទាំងអស់ស្តាប់ដោយបរិយាយថា "រូប, វេទនា, សញ្ញា, សង្ខារ និងវិញ្ញាណ, សុទ្ធតែមិនមែនជារបស់ខ្លួនទាំងអស់ជាដើម ។ បញ្ចវគ្គិយភិក្ខុ កាលស្តាប់អនត្តលក្ខណសូត្រចប់ហើយ ក៏បានសម្រេចអរហត្តផលទាំងអស់អង្គ ឯព្រះអញ្ញាកោណ្ឌញ្ញៈ ក៏បានជាឯតទគ្គ (អ្នកជំនាញការ) ខាងរត្តិញ្ញូ គឺជាអ្នកស្គាល់យាមទាំង ៣ នៃរាត្រីកាលដោយច្បាស់លាស់ ។

## ១- ប្រវត្តិព្រះអញ្ញាកោណ្ឌញ្ញត្ថេរ

( រត្តិញ្ញូ )

ព្រះអញ្ញាកោណ្ឌញ្ញៈ កើតក្នុងត្រកូលព្រាហ្មណ៍មហាសាល ក្នុងស្រុកទោណវត្ថុ ជិតនគរកបិលព័ស្តុ ។ កាលពីយុវវ័យ លោកបានរៀនចេះចប់គម្ពីរត្រៃវេទ ព្រមទាំងតម្រាទាយមហាបុរិសលក្ខណៈ ។

កាលព្រះបាទសិរីសុទ្ធោទនៈ ជ្រើសរើសព្រាហ្មណ៍ ដើម្បី

www.elibraryofcambodia.org

ទាយព្រះលក្ខណនៃព្រះពោធិសត្វ ដែលទើបនឹងប្រសូត្រថ្មី ១ នោះ ព្រះអង្គបានរើសយកតែព្រាហ្មណ៍ ៨ រូបដែលចេះជាងគេ ចេញពីព្រាហ្មណ៍ចំនួន ១០៨ ដើម្បីទាយព្រះលក្ខណៈថ្វាយព្រះរាជបុត្រ ។ កោណ្ឌញ្ញព្រាហ្មណ៍ ចូលក្នុងចំនួន ៨ នាក់ដែរ ហើយមានវ័យក្មេងជាងគេ ។ ក្នុងចំណោមព្រាហ្មណ៍ទាំង ៨ ដែលព្រះបាទសិរីសុទ្ធោទន ជ្រើសរើសយកមកនោះ ព្រាហ្មណ៍ ៧ នាក់ខាងដើម សុទ្ធតែទាយដោយគតិ ២ យ៉ាងថា "បើព្រះកុមារនៅជាយរាវាសនឹងបានជាស្តេចចក្រ. បើទ្រង់យាងចេញសាងព្រះផ្នួស នឹងបានត្រាស់ជាព្រះពុទ្ធ ។ ចំណែកខាងកោណ្ឌញ្ញព្រាហ្មណ៍ដែលមានវ័យក្មេងជាងគេ បានទាយដោយគតិម្យ៉ាងថា ព្រះកុមារពិតជានឹងបានត្រាស់ជាព្រះពុទ្ធមិនខាន" ។

កាលព្រះពោធិសត្វយាងចេញសាងព្រះផ្នួសហើយ ព្រាហ្មណ៍ ៧ នាក់ខាងដើមស្លាប់អស់ទៅ នៅតែកោណ្ឌញ្ញ-ព្រាហ្មណ៍មួយ ហើយកោណ្ឌញ្ញៈ ក៏បានបបួលកូនព្រាហ្មណ៍អ្នកទាយលក្ខណៈថ្វាយព្រះពោធិសត្វបាន ៤ នាក់រួមជា ៥ នាក់នឹងខ្លួន ហើយនាំគ្នាចេញបួសជាឫសី ចូលទៅនៅគាល់បំរើព្រះពោធិសត្វ ដើម្បីរង់ចាំការត្រាស់ដឹងនៃព្រះអង្គនៅឯគយាសិសប្រទេសក្នុងដែនមគធៈ ។ លុះព្រះពោធិសត្វធ្វើទុក្ករកិរិយាអស់

www.elibraryofcambodia.org

ពេល ៦ ឆ្នាំ ដោយបន្ថយអាហារហើយក៏នៅតែមិនបានត្រាស់ជាព្រះពុទ្ធទៀត ព្រះអង្គក៏ត្រឡប់សោយអាហារវិញ។ ឃើញដូច្នោះ ពួកបញ្ចវគ្គិយបូសី បានគិតគ្នាថា អម្បាលយ៉ាងព្រះសិទ្ធត្ថ[illegible] អាហារទៅហើយ នៅតែមិនបានត្រាស់ ចុះទំរាំព្រះអង្គ[illegible] សោយអាហារវិញ តើអាចនឹងរកការត្រាស់ដឹងបានឬទេ ? គិតគ្នាហើយ ក៏នាំគ្នាលាព្រះពោធិសត្វ ធ្វើដំណើរទៅនៅឯព្រៃឥសិ-បតនមិគទាវ័ន ជិតក្រុងពារាណសី ដែនកាសី ខាង[illegible]ពោធិគ-យាចំនួន ១៨ យោជន៍អស់ទៅ ។

នៅពេលដែលព្រះពោធិសត្វបានត្រាស់ជាព្រះសម្មាសម្ពុទ្ធហើយព្រះអង្គក៏យាងទៅសំដែងធម្មចក្កប្បវត្តនសូត្រ ប្រោសបញ្ចវគ្គិយបូសី នៅថ្ងៃពេញបូរមី ខែអាសាឍ ឆ្នាំរកា (ក្រោយពេលត្រាស់ដឹង ២ ខែ) ។ កាលចប់ធម៌ក្នុងរាត្រីនោះ ព្រះកោណ្ឌញ្ញៈបានធម្មចក្ខុភ្លឺស្វាងក្នុងធម៌ ហើយបានសម្រេចសោតាបត្តិផល ។ ព្រះសាស្តាជ្រាប ក៏បន្លឺព្រះវាចាថា "អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ ឱហ្ន ! កោណ្ឌញ្ញបានដឹងហើយ ! ដូច្នេះបានជាលោកបាននាមថា អញ្ញា-កោណ្ឌញ្ញៈ ជាប់តមក ។

ព្រះអញ្ញាកោណ្ឌញ្ញៈ បានសុំឧបសម្បទាជាឯហិភិក្ខុ ហើយបាន

www.elibraryofcambodia.org

ស្តាប់អនត្តលក្ខណសូត្រ ក៏បានសម្រេចអរហត្តផល មានឯកទត្ត ជារត្តិញ្ញូ គឺមហាសាវ័កទី១ បានសម្រេចធម៌មុនគេ ហើយស្គាល់យល់ច្បាស់នូវរាត្រីកាល ។

ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ មានព្រះជន្មចាស់ជាងព្រះសាស្តាច្រើនណាស់ ហើយជាសាវ័កដំបូងបង្អស់របស់ព្រះសមណ-គោតម ។ កាលលោកបានសម្រេចព្រះអរហត្តផលហើយ លោកបាននិមន្តទៅទោណវត្ថុ ជិតក្រុងកបិលពស្តុជាជាតិភូមិ ហើយបានដឹកនាំបុណ្ណមាណព ជាក្មួយឱ្យបួសហើយនាំមកកាន់សំណាក់ព្រះសាស្តា ។

កាលលោកមានព្រះជន្មចាស់ហើយ ក៏និមន្តទៅគង់នៅក្នុងហេមពាន្ត ជិតឆទ្ទន្តស្រះអស់ ១២ ឆ្នាំ ក៏បរិនិព្វានទៅ មុនពុទ្ធបរិនិព្វាន ។

## ២. ប្រវត្តិព្រះវប្បត្ថេរ

ព្រះថេរអង្គនេះ ជាបុត្រព្រាហ្មណ៍អ្នកទាយលក្ខណៈថ្វាយព្រះពោធិសត្វ ។ កាលកោណ្ឌញ្ញព្រាហ្មណ៍បានបបួលវប្បៈក៏ស្ម័គ្រចិត្តជ្រះជ្រះថ្លាទៅបួសជាមួយ កោណ្ឌញ្ញតាមបណ្តាំបិតា ដើម្បីរង់ចាំការត្រាស់ដឹងនៃព្រះសិទ្ធត្ថពោធិសត្វ ។

www.elibraryofcambodia.org

វប្បៈជាសមាជិក១ ក្នុងចំណោមឫសីទាំង ៥ ដែលបាន ទៅបួសបំរើព្រះពោធិសត្វ ។ នៅពេលដែលព្រះពោធិសត្វបាន ត្រាស់ដឹងហើយៗ និមន្តទៅសំដែងធម៌ប្រោសវប្បៈ ក៏បាន សម្រេចសោតាបត្តិផលបន្ទាប់ពីព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ហើយបាន ឧបសម្បទាជាឯហិភិក្ខុ ។ លុះព្រះសាស្តាទ្រង់ប្រទានអនត្ត-លក្ខណៈសូត្រចប់ វប្បៈក៏បានសម្រេចអរហត្តផលជាមួយភិក្ខុ ៤ រូបទៀតក្នុងចំណោមបញ្ចវគ្គិយ ។

ព្រះវប្បត្ថេរ បានជាជំនួយដល់ព្រះបរមសាស្តាចារ្យ ក្នុង ការប្រកាសផ្សាយព្រះពុទ្ធសាសនា ក្នុងបឋមពោធិកាល ។ លុះ ទ្រង់មានព្រះជន្មចាស់ជរាហើយ លោកក៏បរិនិព្វានទៅ ។

## ៣. ប្រវត្តិព្រះភទ្ទិយត្ថេរ

ព្រះភទ្ទិយត្ថេរ ជាបុត្រព្រាហ្មណ៍អ្នកទាយលក្ខណៈថ្វាយ ព្រះសាស្តាដែរ ហើយជាសមាជិក១ រូបក្នុងចំណោមបញ្ចវគ្គិយ ភិក្ខុ ។ ( ប្រវត្តិប្រហែលគ្នានឹងព្រះវប្បត្ថេរ ) ។

## ៤. ប្រវត្តិព្រះមហានាមត្ថេរ

ព្រះថេរអង្គនេះ ក៏ជាបុត្រព្រាហ្មណ៍អ្នកទាយលក្ខណៈ ថ្វាយព្រះសាស្តាដែរ ហើយជាសមាជិក១ រូបក្នុងចំណោមបញ្ចវគ្គិយភិក្ខុ ( ប្រវត្តិប្រហែលគ្នានឹងព្រះវប្បត្ថេរ ) ។

www.elibraryofcambodia.org

## ៥. ប្រវត្តិព្រះអស្សជិត្ថេរ

ព្រះថេរអង្គនេះ ជាបុត្រព្រាហ្មណ៍អ្នកទាយលក្ខណៈថ្វាយព្រះសាស្តា ហើយជាសមាជិក១ រូបក្នុងចំណោមបញ្ចវគ្គិយភិក្ខុ ។

កាលលោកបានសម្រេចអរហត្តផលហើយ បាននិមន្តទៅកាន់ក្រុងរាជគ្រឹះ ដើម្បីប្រកាសផ្សាយព្រះពុទ្ធសាសនា ។ ពេល១ លោកនិមន្តបិណ្ឌបាត្រក្នុងក្រុងរាជគ្រឹះ បានជួបនឹងឧបតិស្សមាណព បានសំដែងធម៌១យ៉ាងខ្លីឱ្យមាណពនោះស្តាប់ មាណពក៏បានសម្រេចធម្មចក្ខុ ហើយតាមព្រះថេរទៅកាន់សំណាក់ព្រះសាស្តា រួចសូមបព្វជ្ជាឧបសម្បទាជាមួយនឹងសម្លាញ់ឈ្មោះកោលិតមាណព ព្រមទាំងបរិវារ ២៥០ នាក់ ។ ឧបតិស្សមាណពមាននាមថា សារីបុត្ត (អគ្គសាវកស្តាំ) ឯកោលិត នាមថាមោគ្គល្លាន (អគ្គសាវកឆ្វេង) ។ សេចក្តីដំណាលថា ព្រះសារីបុត្តមានការគោរពព្រះអស្សជិត្ថេរជាគ្រូណាស់ សូម្បីតែដឹងថាព្រះអស្សជិត្ថេរគង់នៅទីណា ក៏លោកសឹងយកព្រះកេសទៅរកទិសនោះដែរ

ព្រះអស្សជិត្ថេរ កាលមានព្រះជន្មចាស់ជរាហើយ ក៏បរិនិព្វានតាមការគួរ ។

ស. កាលព្រះសាស្តាប្រោសបញ្ចវគ្គិយភិក្ខុរួចហើយ តើព្រះអង្គគង់ចាំវស្សានៅទីណា ? មានព្រះអរហន្តប៉ុន្មានអង្គ ?

www.elibraryofcambodia.org

ច. ចំណែកខាងព្រះសាស្ដាបរមគ្រូ កាលសំដែងធម្មចក្កប្បវត្តនសូត្រ និងអនត្តលក្ខណៈសូត្រ ប្រោសបញ្ចវគ្គិយឱ្យតាំងនៅក្នុងអរហត្តផលហើយ ក៏គង់ចាំព្រះវស្សានៅក្នុងព្រៃឥសិបតនមិគទាយ ក្នុងវស្សាទី១ នោះឯងជាមួយព្រះអរហន្ត ៥ អង្គ ។ ក្នុងពេលនោះមានព្រះអរហន្តទាំងអស់ ៦ អង្គក្នុងលោកហើយ។

ស. កាលព្រះសាស្ដាទ្រង់ប្រោសបញ្ចវគ្គិយភិក្ខុរួចហើយ តើព្រះអង្គបានប្រោសជនណាទៀត ? នៅទីណា ? ចូរនិយាយប្រវត្តិជននោះផង !

ច. ព្រះអង្គបានប្រោសយសកុលបុត្តជាកូនសេដ្ឋី នៅក្រុងពារាណសីទៀត ។ កាលព្រះយសកុលបុត្តបានបួសក្នុងសំណាក់ព្រះសាស្ដាហើយ សេដ្ឋីប្ដីប្រពន្ធជាឪពុកម្ដាយយសកុលបុត្តបានតាមទៅរកបុត្រ ក៏បានឃើញនៅក្នុងព្រៃឥសិបតនមិគទាយ ដោយបានឃើញស្បែកជើងនៅត្រង់ទ្វារចូល ។ កាលបានជួបនឹងព្រះសាស្ដាហើយ ព្រះអង្គទ្រង់សំដែងអនុបុព្វិកថាប្រទានឱ្យស្ដាប់ សេដ្ឋីប្រពន្ធស្ដាប់ហើយ ក៏បានសម្រេចសោតាបត្តិផល រួចក៏និមន្តព្រះសាស្ដាឱ្យទៅទទួលភត្តឯផ្ទះ ។

ព្រឹកឡើង ព្រះសាស្ដាទ្រង់យាងទៅទទួលភត្ត ឯផ្ទះសេដ្ឋីមាតាបិតាព្រះយសជាមួយព្រះយសត្ថេរ ។ សេដ្ឋី - សេដ្ឋីនី និង

www.elibraryofcambodia.org

ភរិយាព្រះយសត្ថេរ បានប្រគេនចង្ហាន់ដល់ព្រះសាស្តា ហើយបាន នូវព្រះត្រៃសរណគមន៍ស្មើជីវិត ។

ដូច្នេះ សេដ្ឋីជាបិតាព្រះយសនេះជាឧបាសកទី១ ដំបូង បង្អស់ដែលដល់នូវព្រះត្រៃសរណគមន៍ (បើជាទ្វេវាចិកឧបាសក គឺឈ្មួញឈ្មោះភល្លិត និងតបុស្ស:) ។ ឯសេដ្ឋីនីជាមាតា នៃព្រះ យសត្ថេរជាឧបាសិកាមុនគេបង្អស់ក្នុងលោក ។

## ៦. ប្រវត្តិព្រះយសត្ថេរ

ព្រះយសជាបុត្រសេដ្ឋី នៅក្រុងពារាណសី មានត្រីប្រាសាទ ៣ សម្រាប់នៅរដូវទាំង៣ ។ នៅរដូវភ្លៀង យសកុលបុត្របាន ដេកក្នុងប្រាសាទរដូវភ្លៀង លុះក្រោកឡើងក៏ឃើញអាការៈនៃពួក ស្រីរបាំ ដែលដេកលក់ មានអាការៈផ្សេងៗគ្នា ខ្លះស្រោត ខ្លះហៀរ ទឹកមាត់ ខ្លះនិយាយរវើរវាយពេញទាំងផ្ទះ វិស័យដូចសាសព នៅ ក្នុងព្រៃស្មសាន ។

យសកុលបុត្រឃើញដូច្នោះ ក៏នឹកសង្វេគក្នុងចិត្តយ៉ាង ខ្លាំង ថែមទាំងបន្លឺឧទានវាចារថា "ទីនេះវរើកណាស់ៗ" ។ តមកយសកុលបុត្តបានពាក់ស្បែកជើងដើរចេញពីផ្ទះ ដើរសំដៅ ទៅព្រៃឥសិបតនមិគទាយតែម្នាក់ឯង ដោយបានដោះស្បែកជើង ចោលនៅត្រង់ទ្វារចូលព្រៃ ។ ពេលនោះជិតភ្លឺផង ព្រះសាស្តា

www.elibraryofcambodia.org

ដែលគង់ចាំវស្សានៅទីនោះកំពុងយាងចង្ក្រម! ព្រះអង្គក៏ឮវាចាថា ទីនេះវឹកវរណាស់ៗ ដូច្នោះ ក៏ទ្រង់ត្រាស់តបថា "ទីនេះឥតវឹកវរទេ ចូរអ្នកមកអង្គុយជិតចុះ តថាគតនឹងសំដែងធម៌ឱ្យស្តាប់ ។ យសកុលបុត្តឮដូច្នោះ ក៏ចូលទៅជិតព្រះសាស្តា ហើយក្រាបថ្វាយបង្គំអង្គុយក្នុងទីដ៏សមគួរ ។

កាលនោះ ព្រះសម្ពុទ្ធទ្រង់សំដែងអនុបុព្វិកាថា ' ឱ្យយសកុលបុត្តស្តាប់ដោយពិស្តារ។ លុះទ្រង់ជ្រាបថា យសកុលបុត្តយល់ធម៌ហើយ ទ្រង់ក៏សំដែងអំពីអរិយសច្ចធម៌៤ ប្រទានយសកុលបុត្តតទៅទៀត ។ យសបានធម្មចក្ខុក្នុងពេលនោះឯង ។

ចំណែកខាងមាតាយសកុលបុត្ត ព្រឹកឡើងកាលរកកូនមិនឃើញ ក៏ឱ្យគេដើររកគ្រប់ទិសទី ឯខ្លួនគាត់បាននាំស្វាមីដើរសំដៅទៅព្រៃឥសិបតនមិគទាយ ។ លុះដល់ខ្លោងទ្វារចូល សេដ្ឋីនិងភរិយា ក៏បានឃើញស្បែកជើង ដែលយសកុលបុត្តដោះចោល ក៏ចូលទៅ ហើយបានជួបនឹងព្រះសាស្តា ព្រមទាំងយសកុលបុត្តនៅទីនោះ ។ ព្រះសាស្តាទ្រង់ក៏សំដែងអនុបុព្វិកថា និងអរិយសច្ច ៤ ឱ្យជនទាំងពីរនាក់ស្តាប់ ។ សេដ្ឋីប្តីកាលស្តាប់ហើយ កើតចិត្តជ្រះថ្លា ក៏ថ្វាយខ្លួនជាឧបាសក ដល់នូវព្រះត្រៃសរណគមន៍មុនគេក្នុងលោក រួចហើយក៏និមន្តព្រះសាស្តាឱ្យទៅទទួលភត្តឯផ្ទះក្នុងវេលា

www.elibraryofcambodia.org

ព្រឹក ។

ចំណែកព្រះយសកុលបុត្ត កាលមាតាបិតាត្រឡប់ទៅវិញ ក៏បានសូមឧបសម្បទាជាឯហិភិក្ខុ ហើយបានសម្រេចអរហត្តក្នុងពេលនោះ ។ ព្រះអរហន្តក៏មានចំនួន ៧ អង្គក្នុងលោក ។

ព្រឹកឡើងព្រះសាស្តា បានយាងទៅផ្ទះសេដ្ឋីមាតាបិតាព្រះយសជាមួយព្រះយសត្ថេរ ហើយទ្រង់ទទួលភត្តរួច ក៏ទ្រង់សំដែងអនុបុព្វីកថា និងអរិយសច្ច: ឱ្យស្រីជាមាតានិងភរិយាព្រះយសត្ថេរពីដើមស្តាប់ ។ ស្ត្រីទាំងពីរមានចិត្តជ្រះថ្លា ក៏ថ្វាយខ្លួនជាឧបាសិកាដល់នូវព្រះត្រៃសរណគមន៍មុនគេក្នុងលោក ។ ចំណែកព្រះសាស្តា និងព្រះយសត្ថេរ កាលទទួលភត្តាហាររួច ក៏និមន្តទៅព្រៃឥសិបតនមិគទាយវិញ ។

ព្រះយសត្ថេរ បានជាកម្លាំងមួយក្នុងការផ្សាយព្រះពុទ្ធសាសនាក្នុងបឋមពោធិកាល ។ លុះមានព្រះជន្មគ្រប់កំណើតហើយ លោកក៏បរិនិព្វានទៅ ។

ស. ចុះកាលព្រះសាស្តាប្រោសព្រះយសត្ថេរ និងមាតាបិតាព្រមទាំងភរិយាព្រះយសត្ថេរហើយ តើព្រះអង្គបានប្រោសជនណាទៀត ?

ច. ព្រះសាស្តាទ្រង់បានប្រោសសម្លាញ់របស់ព្រះយសត្ថេរ

www.elibraryofcambodia.org

ចំនួន ៤ នាក់ទៀត !

៧- ព្រះវិមលត្ថេរ

៨- ព្រះសុពាហុត្ថេរ

៩- ព្រះបុណ្ណជិត្ថេរ

១០- ព្រះគវម្បតិត្ថេរ

ព្រះថេរទាំង ៤ អង្គនេះ ជាសេដ្ឋីបុត្តនៅក្រុងពារាណសី ហើយជាសម្លាញ់របស់ព្រះយសត្ថេរផង កាលជ្រាបដំណឹងថា ព្រះយសត្ថេរ ចេញបួសបានសម្រេចមគ្គផលហើយ ជនទាំង៤ នាក់នេះ បានចូលទៅរកព្រះយស ហើយប្រាប់នូវគោលបំណង របស់ខ្លួនឱ្យព្រះយសត្ថេរជ្រាប ។ ព្រះយសត្ថេរជ្រាបហើយ ក៏នាំចូលទៅក្រាបថ្វាយបង្គំព្រះសាស្តា ។ ទ្រង់សំដែងអនុបុព្វីកថា និងអរិយសច្ចកថា ឱ្យជនទាំង ៤ នាក់ស្តាប់ ។ កាលចប់ព្រះធម្មទេសនាហើយ ជនទាំង៤ នាក់ក៏បានសម្រេចព្រះអរហត្តផលចូលសូមឧបសម្បទាជាឯហិភិក្ខុ ក្នុងសំណាក់ព្រះសាស្តាអស់ទៅ ។

ព្រះថេរៈទាំង ៤ អង្គនេះ បានជាជំនួយក្នុងការផ្សាយព្រះពុទ្ធសាសនាយ៉ាងមាំ ក្នុងបឋមពោធិកាល លុះគ្រប់អាយុសង្ខារហើយ ក៏បរិនិព្វានទៅ ។

ស. តមក តើព្រះសាស្តាទ្រង់បានប្រោសជនណាទៀត ?

www.elibraryofcambodia.org

ឆ- ព្រះសាស្តាទ្រង់បានប្រោសជន ៥៤ នាក់នោះឱ្យបានស្តាប់ និងសម្រេចអរហត្តផល ។ ពេលនោះ មានព្រះអរហន្តចំនួន ៦១ អង្គក្នុងលោកហើយ ។

ស- កាលមានព្រះអរហន្តច្រើនក្រៃលហើយ តើព្រះសាស្តាទ្រង់ធ្វើយ៉ាងណាទៀត ? ទ្រង់បានប្រោសជនណាជាបន្តបន្ទាប់មក ?

ឆ- កាលចេញព្រះវស្សាហើយ ព្រះសាស្តាបានបញ្ជូនអរហន្តសាវ័កទាំងនោះទៅក្នុងទីផ្សេងៗ ដើម្បីប្រកាសផ្សាយព្រះពុទ្ធសាសនា ឯព្រះសម្ពុទ្ធទ្រង់យាងទៅកាន់ឧរុវេលនិគម ក្នុងដែនមគធៈដោយព្រះអង្គឯង ។ នៅតាមផ្លូវព្រះសាស្តាទ្រង់បានប្រទានធម៌ និងបំបួសជាឯហិភិក្ខុដល់យុវជនចំនួន ៣០ រូប ហៅថា ភទ្ទវគ្គិយកុមារ នៅផងព្រៃកប្បាសមួយ ឱ្យបានសម្រេចអរហត្តផលទាំងអស់ ។ បន្តព្រះដំណើរទៅទៀតដល់ឧរុវេលនិគម ព្រះសាស្តាទ្រង់បានធ្វើបដិហារ្យផ្សេងៗ ចំនួន ១៥០០បែប ដើម្បីផ្ចាញ់ពួកជដិល ជាបងប្អូន ៣ នាក់គឺ :

- ឧរុវេលកស្សបៈ មានបរិវារ ៥០០ នាក់
- នទីកស្សបៈ មានបរិវារ ៣០០ នាក់
- គយាកស្សបៈ មានបរិវារ ២០០ នាក់

www.elibraryofcambodia.org

១១- ប្រវត្តិឧរុវេលកស្សបត្ថេរ

១២- ប្រវត្តិនទីកស្សបត្ថេរ

១៣- ប្រវត្តិគយាកស្សបត្ថេរ

ព្រះថេរទាំង ៣ អង្គនេះ កើតក្នុងត្រកូលព្រាហ្មណ៍កស្សបគោត្រ ហើយជាបងប្អូនគ្នាទាំង ៣ អង្គ បងច្បងនាមថា ឧរុវេលកស្ស, ប្អូនបន្ទាប់មាននាមថា នទីកស្សបៈ, ប្អូនពៅមាននាមថា គយាកស្សបៈ ។ ដែលហៅថា កស្សបៈ គឺហៅឈ្មោះតាមគោត្រ ដែលហៅថា ឧរុវេលៈក្តី , នទីក្តី, គយាក្តី ហៅតាមឈ្មោះតំបន់ដែលលោកទៅតាំងអាស្រមអាស្រ័យ នៅក្នុងពេលបួសជាជដិល លោកទាំង ៣ អង្គនេះមានជាតិភូមិនៅទីតំបន់ណា ព្រះគន្ថរចនាចារ្យមិនបានពោលទុក ។

លោកទាំង ៣ អង្គ កាលនៅវ័យកុមារ បានសិក្សារៀនសូត្រចេះចប់គម្ពីរត្រៃវេទ តាមលទ្ធិព្រាហ្មណ៍ ។ ជនទាំង ៣ ពិចារណាផលនៃការសិក្សា ក្នុងនាលោកិយនេះមិនមានខ្លឹមសារ ទើបប្រាថ្នាក្នុងផ្លូវបរលោកតទៅទៀត ហើយនាំគ្នាចេញទៅបួសជាជដិល គឺជាអ្នកបួសសន្សំជដាព្រមទាំងបរិវារ ។ បងច្បងតាំងអាស្រមនៅតំបន់ឧរុវេលា ទើបមាននាមឆាយាថា ឧរុវេល-កស្សបៈ ។ ប្អូនបន្ទាប់តាំងនៅទន្លេគង្គា ទើបមាននាមឆាយាថា

www.elibraryofcambodia.org

នទីកស្សបៈ ។ ប្អូនពៅ តាំងអាស្រមនៅត្រង់តំបន់គយាសីសៈ ទើបមាននាមឆាយាថា គយាកស្សបៈ ។

ឧរុវេលកស្សបមានជដិល ៥០០ ជាបរិវារ ។ នទីកស្សបៈ មានជដិល ៣០០ ជាបរិវារ ។ គយាកស្សបៈ មានជដិល ២០០ ជាបរិវារ ។ នាយកជដិលទាំង ៣ រូបនេះ នាំគ្នាប្រព្រឹត្តវត្តបូជាភ្លើង ផ្ញើរកិលេសតាមលទ្ធិព្រាហ្មណ៍ ។

កាលព្រះមហាបុរស បានត្រាស់ដឹងហើយ ព្រះអង្គមានព្រះបំណង និងប្រកាសផ្សាយព្រះពុទ្ធសាសនាក្នុងក្រុងរាជគ្រឹះ ទើបស្តេចយាងទៅកាន់អាស្រមឧរុវេលកស្សប ទ្រង់សុំទីស្នាក់អាស្រ័យ ។ លោកឧរុវេលកស្សប ឱ្យព្រះអង្គស្នាក់ក្នុងរោងជាទីបូជាភ្លើង ដែលមាននាគកាចសាហាវតែនាគមិនអាចធ្វើអន្តរាយអ្វីដល់ព្រះអង្គឡើយ ។ តមកទ្រង់សំដែងបាដិហារ្យផ្សេងៗ ច្រើនជាអនេកប្បការ ទ្រង់ផកទិដ្ឋិមានះរឹងរូសរបស់លោកឧរុវេលកស្សប ព្រមទាំងបរិវារឱ្យទន់ខ្សោយចុះទៅ ទ្រង់ទេសនាទូន្មាន ត្រាតែលោកឧរុវេលកស្ស ព្រមទាំងបរិវារកើតប្រាជ្ញាយល់ឃើញច្បាស់ថា លទ្ធិដែលខ្លួនប្រកាន់នោះ មិនមានខ្លឹមសារអ្វីឡើយ កើតសង្វេគស្លុតចិត្ត ទើបនាំគ្នាបណ្តែតបរិក្ខារជដិលចោលទៅក្នុងទន្លេ ហើយក្រាបបង្គំទូលសូមឧបសម្បទ ព្រះអង្គក៏ទ្រង់

www.elibraryofcambodia.org

អនុញ្ញាតឱ្យបានជាភិក្ខុគ្រប់រូបទាំងអស់ ។

ចំណែកឯនទីកស្សបប្អូនបន្ទាប់ តាំងអាស្រមនៅខាងក្រោម បានឃើញបរិក្ខារជដិលបណ្ដែតមកតាមខ្សែទឹក ក៏ស្មានថាកើតអន្តរាយដល់បងរបស់ខ្លួន ព្រមទាំងបរិវារខំស្រូតឡើងទៅស្រាប់តែឃើញជដិលជាបងកាន់ជាភិក្ខុ សាកសួរបានដឹងសេចក្ដីព្រហ្មចារ្យនេះប្រសើរ ហើយទើបបណ្ដែតបរិក្ខារជដិលចោលក្នុងទន្លេ ហើយព្រមទាំងបរិវារក្រាបបង្គំទូលសូមឧបសម្បទ ព្រះអង្គក៏ទ្រង់ប្រទានឧបសម្បទដល់លោកទាំងអស់នោះ ។ ឯគយាកស្សបប្អូនពៅ បានឃើញបរិក្ខារជដិលបណ្ដែតតាមខ្សែទឹកក៏ស្មានថា គង់មានកើតអន្តរាយដល់បងទាំងពីរ ក៏ខំស្រូតតាមទាំងបរិវារ បានឃើញបងទាំងពីរទ្រទ្រង់ភេទជាភិក្ខុ សួរបានដឹងសេចក្ដីសព្វគ្រប់ហើយ ក៏បណ្ដែតបរិក្ខារចោលក្នុងទន្លេ ហើយក្រាបទូលសូមឧបសម្បទ ព្រមទាំងបរិវារ ព្រះអង្គក៏ទ្រង់ប្រទានឧបសម្បទដូចន័យមុននេះដែរ ។

ព្រះបរមសាស្ដា ស្ដេចប្រថាប់ក្នុងតំបន់ឧរុវេលតាមសមគួរហើយ ស្ដេចព្រមដោយភិក្ខុទាំងនោះ យាងទៅកាន់តំបន់គយាសីសប្រទេសជិតទន្លេគយា ទ្រង់ត្រាស់ហៅប្រជុំភិក្ខុទាំងនោះមកជុំហើយ ទ្រង់សំដែងអាទិត្តបរិយាយសូត្រ គឺទ្រង់សំដែងអំពី

www.elibraryofcambodia.org

សភាវៈធម៌ទាំងពួងជារបស់ក្តៅ ដើម្បីឱ្យសមដល់បុព្វចរិយារបស់ពួកបុរាណជដិល ដែលធ្លាប់អប់រំមកក្នុងការបូជាភ្លើង ។ វេលាចប់ព្រះធម្មទេសនា ចិត្តរបស់ភិក្ខុទាំងនោះ ក៏ផុតស្រឡះចាកអាសវក្កិលេសទាំងឡាយ មិនប្រកាន់មាំដោយឧបាទាន (សម្រេចព្រះអរហត្ត) ។

តពីនោះ ព្រះអង្គព្រមដោយភិក្ខុសាវក ១០០៣ អង្គស្តេចត្រេចចលីទៅដោយលំដាប់ ដល់ក្រុងរាជគ្រឹះចូលប្រថាប់ក្នុងសួនត្នោតសាវកដែលហៅថា លដ្ឋិវន ។ ព្រះបាទពិម្ពិសារនៃមគធរដ្ឋទ្រង់ជ្រាបដំណឹង ទើបស្តេចព្រមដោយសេវកាមាត្យរាជបរិវារជាច្រើន ចូលទៅគាល់ព្រះបរមសាស្តា ។ ទ្រង់ទតព្រះនេត្រឃើញរាជបរិវារមានអាការផ្សេងៗ មិនរៀបរយ ។ ទ្រង់មានព្រះពុទ្ធដីកានឹងព្រះឧរុវេលកស្សប ដែលជាទីគោរពរាប់អាននៃជនទាំងនោះ ឱ្យថ្លែងប្រកាសដល់ការមិនមានខ្លឹមនៃលទ្ធិចាស់ ដើម្បីបង្អោនចិត្ត នៃរាជបរិវារឱ្យប្រុងចាំស្តាប់ ព្រះធម្មទេសនារបស់ព្រះអង្គ ទើបទ្រង់ប្រោសសំដែងអនុបុព្វិកថា និងអរិយសច្ចទាំង៤ វេលាចប់ព្រះធម្មទេសនា ព្រះបាទពិម្ពិសារ និងរាជបរិវារបែងជា ១២ ភាគទៀត តាំងនៅក្នុងត្រៃសរណគមន៍ ។

ហេតុដូច្នេះ ទើបឃើញថា ព្រះឧរុវេលកស្សបត្រូវជា

www.elibraryofcambodia.org

កំឡាំងយ៉ាងធំ ក្នុងការជួយប្រកាសព្រះសាសនា ដើម្បីប្រតិស្ឋានព្រះពុទ្ធសាសនាក្នុងក្រុងរាជគ្រឹះ ហើយព្រះថេរអង្គនេះ ជាអ្នកមានបរិស័ទបរិវារច្រើន ដែលជាផលនៃការចេះយកចិត្តបរិស័ទ ចេះសង្គ្រោះដោយអាមិសផង ដោយធម៌ផង ។ ព្រះថេរប្រកបដោយគុណសម្បត្តិបែបនេះ បរិស័ទតែងស្រឡាញ់រាប់អាន ជាគុណដែលគួរគប្បីប្រាថ្នាក្នុងសាវកមណ្ឌល ហេតុនេះបានជាព្រះបរមសាស្តាទ្រង់ដំកើងលោក ក្នុងដំណែងឯតទគ្គៈជាកំពូលនៃភិក្ខុទាំងឡាយ ដែលមានបរិស័ទច្រើន ។

កាលពួកជដិលទាំងនោះបួសហើយ ព្រះសាស្តាទ្រង់សំដែងអាទិត្តបរិយាយសូត្ត ឱ្យភិក្ខុតាំងស្តាប់ ហើយក៏បានសម្រេចអរហត្តផលទាំងអស់អង្គ ។ ពេលនោះព្រះអរហន្តមានចំនួន ១០៦០ អង្គហើយក្នុងលោក ។

ស- កាលព្រះសាស្តាទើបនឹងបានសាងព្រះផ្នួសហើយថ្មីៗ ហើយបានជួបនឹងព្រះបាទពិម្ពិសារ ជាព្រះចៅមគធរដ្ឋ ព្រះអង្គបានប្តេជ្ញាទទួលនិមន្តព្រះរាជាថា ព្រះអង្គនឹងយាងទៅប្រោសព្រះរាជាមុនគេបង្អស់ បើព្រះអង្គបានត្រាស់ដឹងហើយ ចុះហេតុអ្វីក៏ព្រះអង្គបែរជាយាងទៅប្រោសជនដទៃៗមុនទៅវិញ ? ការធ្វើយ៉ាងនេះ តើមានប្រយោជន៍យ៉ាងណា ? ព្រោះហេតុអ្វី ?

www.elibraryofcambodia.org

ច- កាលណោះព្រះពោធិសត្វ ទ្រង់បានទទួលពាក្យប្តេជ្ញា នឹងព្រះចៅមគធៈមែន ប៉ុន្តែពេលនោះក៏ព្រះអង្គនៅជាបុថុជ្ជន ពុំទាន់ជ្រាបនិស្ស័យលក្ខណៈរបស់សត្វឱ្យជាក់ច្បាស់ដែរ។ លុះពេលព្រះអង្គបានត្រាស់ដឹងប្រាជ្ញាសម្មាសម្ពោធិញ្ញាណហើយ ទើបព្រះអង្គជ្រាបនូវនិស្ស័យលក្ខណៈសត្វលោកច្បាស់លាស់ ទើបព្រះអង្គយាងទៅប្រោសសត្វតាមលំដាប់លំដោយរៀងមក ។

ដំបូងព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យចាស់ក្លា របស់បញ្ចវគ្គិយឫសី ទ្រង់ក៏យាងទៅប្រោសបញ្ចវគ្គិយឫសីនោះមុន ព្រោះមានបារមីចាស់ ធ្លាប់បានគិត អប់រំចិត្តក្នុងធម៌មកយូរហើយ តពីនោះមក ព្រះអង្គបានប្រោសយសកុលបុត្រ, មាតាបិតា និងសម្លាញ់របស់យសកុលបុត្រ ព្រោះជនទាំងនោះមាននិស្ស័យចាស់ក្លាផង បានជួបនឹងព្រះសាស្តានៅពេលបន្ទាប់ពីព្រះអង្គបានប្រោសបញ្ចវគ្គិយភិក្ខុផង ។ រីឯពួកជដិលទាំង ៣ និងបរិវារទាំង ១០០០ នាក់វិញ ក៏មាននិស្ស័យគួរនឹងបានត្រាស់ដឹងធម៌តាមផង ជាអ្នកមានកម្លាំងច្រើនក្នុងការផ្សាយព្រះពុទ្ធសាសនា ជាគ្រាដំបូងឱ្យចាក់ឫសគល់មាំទៅក្នុងដែនមគធៈនោះផង ព្រោះជដិលទាំង ៣ មានបរិវារច្រើន ហើយជាមេលទ្ធិដ៏ធំនៅក្នុងទីនោះ មានមនុស្សរាប់អានច្រើន ។ កាលណាព្រះសាស្តាបានយកជដិល

www.elibraryofcambodia.org

ទាំង ៣ ដែលជាមេធំ ធ្វើជាសិស្សគណបានហើយ ការផ្សាយព្រះពុទ្ធសាសនា នៅក្នុងដែនមគធៈនឹងបានប្រព្រឹត្តទៅងាយបំផុត ។ ដូច្នេះបានជាមុននឹងយាងចូលទៅប្រោសព្រះបាទពិម្ពិសារ ព្រះអង្គត្រូវតែប្រោសពួកជដិលជាមេលទ្ធិ ឱ្យបាក់ទិដ្ឋិមានៈសិន ។ ឯព្រះបាទពិម្ពិសារវិញ បើព្រះអង្គយាងចូលទៅប្រោសតែម្តងក៏បាន ព្រោះព្រះអង្គ (សម្មាសម្ពុទ្ធ ) បានប្តេជ្ញានឹងព្រះរាជាស្រេចទៅហើយ បានសេចក្តីថា ព្រះបាទពិម្ពិសាររង់ចាំតែព្រះសម្មាសម្ពុទ្ធគ្រប់ពេលវេលាទាំងរស់ ឱ្យតែព្រះអង្គបានត្រាស់ដឹង ទោះពេលណាក៏ដោយ ឱ្យតែព្រះសាស្តាយាងទៅប្រោស ព្រះរាជានឹងទទួលគ្រប់ពេលវេលា ។ ដូច្នេះដើម្បីនឹងប្រោសព្រះបាទពិម្ពិសារ ព្រះសាស្តា មិនចាំបាច់ធ្វើបដិហារ្យ ឬកលឧបាយណាមួយឡើយ គឺទ្រង់ប្រោសដោយត្រង់ៗ តែម្តង ប៉ុន្តែព្រះរាជបរិពារ និងសេនាបតី សេដ្ឋី គហបតី ព្រាហ្មណ៍បុរោហិតឯទៀត មិនមែនដូចព្រះបាទពិម្ពិសារឡើយ គឺព្រះសាស្តារកមធ្យោបាយផ្សេងៗទៀត ទើបអាចប្រោសបាន ។

ដូច្នេះ ការប្រោសជនឯទៀតៗ មានបញ្ចវគ្គិយភិក្ខុជាដើម ត្រូវបានផលផ្សេង ហើយការប្រោសជដិលទាំង ៣ មុននឹងយាងចូលទៅប្រោសព្រះបាទពិម្ពិសារ មានផលផ្សេង គឺជាការងាយ

www.elibraryofcambodia.org

ស្រួលដល់ព្រះសាស្តា ដើម្បីផ្សាយព្រះពុទ្ធសាសនា ក្នុងគ្រាដំបូងឱ្យបានផ្សព្វផ្សាយទៅយ៉ាងឆាប់រហ័ស ក្នុងដែនមគធៈជាប្រទេសធំ មានប្រជាជនច្រើនជាងរដ្ឋឯទៀត ៗ ។

ស. ព្រះសាស្តាទ្រង់ប្រោសព្រះបាទពិម្ពិសារ និងព្រះរាជបរិពារដោយវិធីណា ? ជនណាបានសម្រេចធម៌អ្វី ? ព្រះរាជាបានថ្វាយអ្វីដល់ព្រះសាស្តា ?

ច. កាលព្រះសាស្តាប្រោសជដិលទាំង ៣ និងបរិវារ ១ ពាន់នាក់ឱ្យបានសម្រេចអរហត្តផលហើយ ព្រះសាស្តាក៏នាំសាវ័កទាំងនោះចូលទៅកាន់ក្រុងរាជគ្រឹះ ។ នៅទីនោះ, កាលព្រះអង្គចូលទៅដល់ជួបព្រះបាទពិម្ពិសារហើយ ព្រះរាជាគ្មានការសង្ស័យអ្វីទេ ប៉ុន្តែមហាជនមានសេចក្តីសង្ស័យថា "ព្រះសិទ្ធត្ថសមណៈគោតម ជាសិស្សរបស់កស្សបទាំង ៣ ឬក៏កស្សបៈទាំង ៣ ជា សិស្សរបស់ព្រះសមណគោតម ? ព្រះសាស្តាជ្រាបចិត្តប្រជាជនហើយ ព្រះអង្គក៏ឱ្យឧរុវេលកស្សបៈហោះឡើង ហើយចុះមកថ្វាយបង្គំព្រះសាស្តាអស់វារៈ ៧ ដង ហើយបន្លឺវាចា "ព្រះពុទ្ធសមណគោតម ជាបរមគ្រូក្នុងលោក ជាគ្រូរបស់ខ្ញុំ ខ្ញុំជា សាវ័ករបស់ព្រះអង្គ " ។ ពួករាជបរិវារឃើញដូច្នោះ ក៏មានចិត្តកោត និងស្ងើចព្រះបរមសាស្តាយ៉ាងខ្លាំង ព្រះសាស្តាក៏

www.elibraryofcambodia.org

ទ្រង់សំដែងមហានារទជាតក ប្រោសព្រះរាជានិងរាជបរិវារ ។ លុះចប់ធម៌ហើយ ព្រះរាជា និងរាជបរិវារ ១១ ម៉ឺននាក់ បាន សម្រេចសោតាបត្តិផល ឯរាជបរិវារ ១ម៉ឺននាក់ទៀត បានដល់ ព្រះត្រៃសរណគមន៍ ។

ព្រះបាទពិម្ពិសារទ្រង់មានសេចក្តីជ្រះថ្លា ក៏វេរឧទ្យានព្រៃ ឫស្សី១ កន្លែងនៅក្នុងក្រុងរាជគ្រឹះ ថ្វាយព្រះសាស្តាដែរធ្វើជាវត្ត អារាមសំរាប់គង់នៅ ។ ព្រះសាស្តាទ្រង់គង់នៅទីនោះហើយដាក់ នាមវត្តនោះថា "វត្តវេឡុវ័ន ឬ វេឡុវនារាម" ជាវត្តទី១ ក្នុងព្រះពុទ្ធសាសនា ។

ស- នៅក្នុងវត្ត វេឡុវ័ននោះ ព្រះសាស្តាទ្រង់បានប្រោស ជនណាខ្លះទៀត ? ជននោះមានលក្ខណៈ និងសារៈសំខាន់យ៉ាង ណា ?

ច- ព្រះសាស្តាបានប្រោសជនជាច្រើន និងបញ្ជូនសាវ័ក សំខាន់ទៅកាន់ទិសទីផ្សេងៗ ដើម្បីផ្សាយព្រះពុទ្ធសាសនា ។ ជន ដែលសំខាន់ហើយមានសារប្រយោជន៍ជាងគេ គឺព្រះសារីបុត្ត (ឧបតិស្សមាណព) និងព្រះមោគ្គល្លាន (កោលិតមាណព) ព្រម ទាំងបរិវារ ២៥០ នាក់ឱ្យបានបួសក្នុងសំណាក់ព្រះអង្គ ។ សាវ័ក ទាំង ២ នេះ តមកក៏បានជាអគ្គសាវ័កស្តាំឆ្វេងរបស់ព្រះអង្គ ។

www.elibraryofcambodia.org

ស. លោកទាំងពីរនេះ មានប្រវត្តិយ៉ាងណា ? ចូរអធិប្បាយពន្យល់ !

## ១៤. ប្រវត្តិព្រះសារីបុត្ត

## ១៥. ប្រវត្តិព្រះមោគ្គល្លាន

**ព្រះសារីបុត្ត** . ព្រះសារីបុត្តត្ថេរនេះ ជាបុត្រព្រាហ្មណ៍មេដំបន់ម្នាក់ឈ្មោះវង្គន្តៈ និងនាងសារី ក្នុងស្រុកនាលកៈ ឬនាលន្ទៈ ជិតក្រុងរាជគ្រឹះ ។ ពីមុនមកលោកឈ្មោះ ឧបតិស្សៈ ហៅឈ្មោះតាមដែលជាបុត្រនាងសារី ថា សារីបុត្រ ។ កាលលោកចូលមកឧបសម្បទក្នុងធម្មវិន័យនេះហើយ ពួកសព្រហ្មចារីភិក្ខុ និយមហៅឈ្មោះលោកថា សារីបុត្រតែឈ្មោះមួយរហូតមក

ព្រះគន្ថរចនាចារ្យបានពោលទុកថា ឧបតិស្សមាណពនេះជាបុរសនៃត្រកូល ដែលបរិបូណ៌ដោយភោគសម្បត្តិ និងបរិវារបានរៀនសូត្រចេះដឹងសិល្បសាស្ត្រស្ទាត់ជំនាញ ហើយមានមិត្តស្និទ្ធស្នាលម្នាក់ឈ្មោះ កោលិតមាណព មោគ្គល្លាន មានអាយុស្រករគ្នា ជាត្រកូលស្តុកស្តម្ភដូចគ្នា ។ សម្លាញ់ទាំងពីរនេះតែងនាំគ្នាទៅមើលមហោស្រព ក្នុងក្រុងរាជគ្រឹះជាមួយគ្នាជារឿយៗ លុះតមកសំឡាញ់ទាំងពីរកំពុងមើលល្បែង នាថ្ងៃមួយដែលគេកំពុងលេងនោះ ស្រាប់តែកើតចិត្តនឿយណាយធុញទ្រាន់មាន

www.elibraryofcambodia.org

តម្រិះស្របតាមគ្នាថា មើលល្បែងឥតប្រយោជន៍គួរស្វែងរកមោក្ខធម៌វិញគាប់ប្រសើរជាង ទើបនាំគ្នាទៅបួសក្នុងសំណាក់សញ្ជ័យបរិព្វាជក ព្រមទាំងបរិវារ ។ លុះសិក្សាលទ្ធិសញ្ជ័យបរិព្វាជកចេះចប់ហើយ ពិចារណាទៅឃើញថា មិនមានខ្លឹមសារអាចនឹងលុះដល់ មោក្ខធម៌ បាន ទើបធ្វើកតិការប្ដេជ្ញាគ្នាថា បើអ្នកណាបានសម្រេច មោក្ខធម៌ មុន ត្រូវសំដែងប្រាប់គ្នានឹងវិញនៅមក ។

ថ្ងៃមួយ ឧបតិស្សបរិព្វាជកបានឃើញព្រះអស្សជិត្ថេរ ដែលព្រះសាស្ដាទ្រង់បញ្ជូន ឱ្យចេញប្រកាសសាសនា បានឃើញអាការលោកគួរឱ្យជ្រះថ្លា ទើបចូលទៅសាកសួរព្រះអស្សជិត្ថេរៗបានសំដែងគោលធម៌យ៉ាងសង្ខេប ឱ្យឧបតិស្សបរិព្វាជកស្ដាប់ ក៏បានសម្រេចសោតាបត្តិផល ទើបសួរព្រះថេរថា ព្រះបរមសាស្ដាស្ដេចគង់នៅទីណា ?

ឧបតិស្សបរិព្វាជកបានដឹងថា ព្រះអង្គគង់នៅវេឡុវន ទើបត្រឡប់ទៅប្រាប់កោលិតបរិព្វាជក ហើយសំដែងធម៌នោះឱ្យស្ដាប់ ។ កោលិតបរិព្វាជកដែលជាគ្រូដើម ហើយសម្លាញ់ទាំងពីរនាំបរិវារចូលទៅគាល់ព្រះបរមសាស្ដា ក្រាបបង្គំទូលសុំឧបសម្បទា ព្រះអង្គក៏ទ្រង់អនុញ្ញាតឱ្យបានសម្រេចជាភិក្ខុទាំងអស់

www.elibraryofcambodia.org

គ្នា ។ ក្នុងចំណោមភិក្ខុទាំងនោះ ពួកភិក្ខុដែលជាបរិវារបាន សម្រេចអរហត្តមុន ។ ព្រះមោគ្គល្លានបានឧបសម្បទហើយ ៧ ថ្ងៃហើយ ទើបបានសម្រេចព្រះអរហត្ត ។

មានរឿងដំណាល អំពីដំណើរដែលលោកសម្រេចអរហត្ត ថា ថ្ងៃមួយព្រះសាស្តាគង់នៅក្នុងគូហាសុករខាតា ភ្នំគិជ្ឈកូដ ដែនក្រុងរាជគ្រឹះ ទ្រង់សំដែងទិដ្ឋិ ៣. ប្រការដល់បរិនិព្វាជកម្នាក់ ឈ្មោះទីឃនខៈអគ្គិវេស្សនគោត្រ ដែលចូលគាល់ក្រាបទូល ប្រាស្រ័យនឹងព្រះអង្គ ។ ខណៈនោះ ព្រះសារីបុត្រ បក់ពាត់ថ្វាយ ព្រះបរមសាស្តា បានពិចារណាធម៌ដែលទ្រង់សំដែងនោះ ចិត្ត របស់លោក ក៏ផុតស្រឡះចាកអាសវៈ មិនប្រកាន់មាំដោយ ឧបាទាន ។ រីឯទីឃនខៈបរិនិព្វាជកបានសម្រេចធម្មចក្ខុ ក្រាប ទូលសរសើរព្រះធម្មទេសនា ហើយថ្វាយខ្លួនជាឧបាសក ។

ព្រះសារីបុត្រនេះ ល្បីល្បាញថា លោកមានសតិបញ្ញា ក្លាហានក្រៃលែងជាងសាវ័កដទៃទៀត ទើបព្រះអង្គទ្រង់សរសើរ ថា ជាឯកទគ្គៈ គឺជាកំពូលនៃភិក្ខុទាំងឡាយដែលមានបញ្ញា អាច សំដែងព្រះធម្មចក្រ និងចតុរារិយសច្ចប្រហែលព្រះអង្គបាន ។ បើ មានពួកភិក្ខុក្រាបទូលលា និងត្រាច់ចារិកទៅកាន់ផ្លូវឆ្ងាយ ព្រះ អង្គច្រើនត្រាស់ឱ្យអស់លោកទាំងនោះ ទៅទូលលាព្រះសារីបុត្រ

www.elibraryofcambodia.org

ជាមុន ដើម្បីឱ្យលោកទូន្មានភិក្ខុទាំងនោះ ។

ព្រះសារីបុត្រនេះ ព្រះបរមសាស្តាទ្រង់តាំងដំកើងជាអគ្គសាវកខាងស្តាំ ជាគូនឹងមោគ្គល្លាន ( ដូចជាអ្នកអនុគ្រោះប្រវត្តិខាងមុខនេះ ) ជាអគ្គសាវកខាងឆ្វេង ជាអ្នកអនុគ្រោះសហធម្មិកផងគ្នា ទ្រង់ប្រៀបព្រះសារីបុត្រដូចជាមាតាដែលបង្កើតកូន អាចណែនាំកុលបុត្រ ឱ្យឋិតនៅក្នុងសោតាបត្តិផល ។ បើលោកយកពុទ្ធភាសិតចេញហើយ ភាសិតរបស់លោក មានច្រើនជាងព្រះសាវកអង្គដទៃទៀត ដូចសមាទិដ្ឋិសូត្រជាដើម ។ លោកមានគុណប្រាកដថា ជាអ្នកមានកតញ្ញូកតវេទីណាស់ សូម្បីគេធ្វើទានលោកដោយបាយ១ វែកក៏មិនភ្លេចដែរ ។ លោកមានជន្មាយុរហូតមកដល់បច្ឆិមពោធិកាល ក្នុងវស្សាទី ៤៥ ។ លុះលោកជិតបរិនិព្វាន មានប្រាថ្នានឹងប្រោសមាតាលោកជាគ្រាចុងក្រោយបង្អស់ ទើបលោកក្រាបទូលលាព្រះដ៏មានគុណ នាំព្រះចុន្ទត្ថេរជាប្អូន ព្រមទាំងបរិវារ និមន្តទៅស្រុកកំណើត ក៏កើតរោគបក្ខន្ទិកាពាធឡើងក្នុងយប់នោះ លោកសំដែងទេសនាប្រោសមាតាលោកទាំងកំពុងអាពាធ គ្រាតែមាតាលោកបានសម្រេចសោតាបត្តិផល លុះពេលបច្ចូសសម័យ ជាថ្ងៃពេញបូរមី ខែកត្តិក ព្រះអគ្គសាវកក៏បរិនិព្វាន ដល់ព្រឹកឡើងព្រះចុន្ទត្ថេរ ក៏ចាត់ចែងធ្វើឈាបនកិច្ចសពលោក

www.elibraryofcambodia.org

រីសុអដ្ឋិធាតុនាំទៅថ្វាយព្រះបរមសាស្ដា ។ ព្រះអង្គទ្រង់ត្រាស់ឱ្យកសាងព្រះបញ្ចវតិយ៍បញ្ចុះអដ្ឋិធាតុលោក ទុកជាទីសក្ការបូជានៃមហាជនក្នុងវត្តជេតពន ក្រុងសាវត្ថី ។

## ព្រះមហាមោគ្គល្លាន

ព្រះមហាមោគ្គល្លានត្ថេរ កើតក្នុងតំបន់ជិតក្រុងរាជគ្រឹះ ជាបុត្រព្រាហ្មណ៍ [illegible] ឈ្មោះកោលិតៈ ម្ដាយលោកឈ្មោះមោគ្គលី ។ គេហៅឈ្មោះលោកតាមគោត្របិតាថា កោលិតៈ ។ គេហៅឈ្មោះលោកម្យ៉ាងទៀត តាមដែលជាបុត្ររបស់នាងមោគ្គលី ។ មោគ្គល្លានៈ លុះលោកចូលបួសក្នុងធម្មវិន័យនេះហើយ ពួកសព្រហ្មចារីហៅឈ្មោះលោកថា មោគ្គល្លានៈ តែឈ្មោះមួយនេះរហូតមក ។ តាំងពីកាលលោកនៅក្នុងវ័យកុមារ ជាមិត្តស្និទ្ធស្នាលនិងសារីបុត្រ មានអាយុស្រករគ្នាបានសិក្សាសិល្បសាស្ត្រជាមួយគ្នា ចូលបួសជាបរិព្វាជកជាមួយគ្នា ហើយចូលឧបសម្ប័ទ ក្នុងធម្មវិន័យនេះជាមួយគ្នា ដូចមានក្នុងប្រវត្តិព្រះសារីបុត្រខាងលើនេះស្រាប់ ។ ក្នុងទីនេះនឹងពោលចំពោះតែប្រវត្តិរបស់លោកដោយរឿងតទៅ :

ចាប់តាំងពីកាលដែលលោកបានចូលមក ឧបសម្ប័ទហើយ ៧ ថ្ងៃ លោកទៅធ្វើសេចក្ដីព្យាយាមបំពេញធម៌ នៅស្រុក

www.elibraryofcambodia.org

កល្យាណបុត្តគ្រាម ខែត្រដែនមគធ ទន់ខ្សោយកម្លាំងចិត្តអង្គុយងោក ។ ព្រះដ៏មានបុណ្យស្តេចយាងទៅកាន់ទីនោះ ទើបទ្រង់ពន្យល់ឧបាយសម្រាប់រម្ងាប់ងងុយងោក ហើយត្រាស់ទូន្មាន មិនប្រកាន់ខ្លួនចូលទៅកាន់ត្រកូលឱ្យនៅក្នុងទីសេនាសនៈស្ងាត់ គួរជាទីស្ងប់អារម្មណ៍តាមសមណៈវិស័យ ។ ព្រះមោគ្គល្លានប្រតិបត្តិតាមពុទ្ធោវាទ ដែលទ្រង់ទូន្មាន ក៏បានសម្រេចអរហត្តក្នុងថ្ងៃនោះឯង ។

ព្រះបរមសាស្តា ទ្រង់សរសើរព្រះមោគ្គល្លានជាគូរនឹងព្រះសារីបុត្រថា ជាអ្នកមានឧបការៈដល់ពួកភិក្ខុឧបសម្បទថ្មី ហើយជាព្រះអគ្គសាវកខាងឆ្វេងជូលពោលមកហើយ ។

ម្យ៉ាងវិញទៀត ទ្រង់ដំកើងលោកក្នុងដំណែងជាឯតទគ្គៈគឺជាកំពូលនៃភិក្ខុទាំងឡាយដែលមានរិទ្ធិ ។ ព្រះបរមសាស្តាបានសាវក ដែលមានបញ្ញាឯក មានរិទ្ធិឯកទាំងពីរអង្គក្នុងដំណែងជាអគ្គសាវក ជាកម្លាំងយ៉ាងធំក្រៃលែងរបស់ព្រះអង្គក្នុងការប្រកាសផ្សាយសាសនា ឱ្យកាន់តែរីកចំរើនឡើងក្នុងទិសទាំងពួង។

ធម្មទេសនារបស់ព្រះមោគ្គល្លាន មិនសូវមានសម្បូរក្នុងគម្ពីរទាំងឡាយ ឃើញមានតែអនុមានសូត្រ ដែលលោកបានឱ្យឱវាទដល់ភិក្ខុសង្ឃ ព្រះធម្មសង្គាហកាចារ្យបានរួបរួមទុកក្នុងគម្ពីរ

www.elibraryofcambodia.org

មជ្ឈិមនិកាយ ។

ព្រះមោគ្គល្លាននេះ ប្រកបដោយរិទ្ធិឈ្លាសខាងការនវកម្ម ទើបទ្រង់ព្រោសជានវកម្មាធិដ្ឋាយិ គឺអ្នកមើលការនវកម្មនៃវិហារបុព្វារាម នៅក្រុងសាវត្ថី ដែលមហាឧបាសិកាវិសាខាបានកសាងឡើង ។

មានសេចក្តីដំណាលមុនលោកបរិនិព្វានថា កាលគ្រាដែលលោកនៅដំបន់កាឡសិលា ដែនមគធរដ្ឋ ពួកអន្យតិរ្ថិយប្រឹក្សាថា ព្រះមោគ្គល្លាននោះ ជាកម្លាំងធំណាស់របស់ព្រះពុទ្ធ អាចនាំដំណឹងពីឋានសួគ៌ និងឋាននរក មកថ្លែកដល់មនុស្សលោក បើយើងកំចាត់ព្រះមោគ្គល្លានចេញទៅបានហើយ លទ្ធិខាងពួកយើងនឹងចំរើនរុងរឿងឡើង ទើបជួលពួកចោរឱ្យទៅលបលួចសម្លាប់លោក ។ ពួកចោរនាំគ្នាចូលស្ទាក់ចាប់សម្លាប់លោកដល់ពីរលើក លោកគេចផុតទាំងពីរលើក ដល់មកលើកទីរប់បី លោកពិចារណាឃើញកម្មចាស់តាមមកទាន់ ទើបលោកមិនគេច ។ ពួកចោរក៏ចាប់លោកវាយដំគ្រាតែល្អិតខ្ទេច ហើយយកសរីរៈលោកទៅលាក់ទុកក្នុងស៊ុមទ្រុបព្រៃមួយអន្លើ ហើយនាំគ្នាគេចរត់ទៅ ។ ព្រះថេរមិនទាន់ដល់មរណៈទេ លោកខំរក្សាព្យាបាលអត្តភាពដោយកម្លាំងឈាននិមន្តទៅគាល់ព្រះបរមសាស្តា ក្រាប

www.elibraryofcambodia.org

ទូលលាសូមបរិនិព្វាន ហើយវិលមកបរិនិព្វាននៅកន្លែងដើមវិញ ក្នុងថ្ងៃ ១៥ រោជ ខែកត្តិក ខាងក្រោយព្រះសារីបុត្របរិនិព្វានទៅកន្លះខែ ព្រះដ៏មានបុណ្យស្តេចទៅធ្វើឈាបនកិច្ចសពលោក រួចមានព្រះពុទ្ធដីកា ឱ្យរើសយកអដ្ឋិធាតុមកទុកក្នុងចេតិយដែលព្រះទុកជិតទ្វារនៃមហាវេឡុវ័ន ។

ស- ព្រះសាស្តាទ្រង់ប្រទានដំណែងជាអគ្គសាវ័កស្តាំ-ឆ្វេង នៅថ្ងៃ ខែ ឆ្នាំណា ? ក្នុងពេលនោះ ព្រះអង្គបានធ្វើអ្វីទៀតដែរ ? មានលក្ខណៈយ៉ាងណា ? ចូរពន្យល់ ៖

ច- ព្រះសាស្តាទ្រង់ប្រទានដំណែងជាអគ្គសាវ័កស្តាំ-ឆ្វេង ដល់ព្រះសារីបុត្រ និងព្រះមោគ្គល្លាន នៅថ្ងៃពេញបូរមី ខែមាឃ ឆ្នាំរកា, នៅថ្ងៃនោះព្រះអង្គទ្រង់ធ្វើមហាសាវ័កសន្និបាត ឬចតុរង្គមហាសាវ័កសន្និបាតផង ។ មហាសន្និបាតនេះ មានលក្ខណៈយ៉ាងនេះគឺ :

១- មាឃនក្ខត្តេន យុត្តោ បុណ្ណមី ឧបោសថទិវសោ.- ប្រជុំនៅថ្ងៃពេញបូរមី ជាថ្ងៃឧបោសថ ប្រកបដោយផ្កាយនក្ខត្តឫក្សប្រចាំខែមាឃ ។

២- ភោនចិ អនាមន្តិតានិ ហុត្វា អត្តនោយេវ ធម្មតាយ សន្និបតិតានិ អឌ្ឍតេរសានិ ភិក្ខុសតានិ.- មានភិក្ខុ

www.elibraryofcambodia.org

សង្ឃ ១២៥០ អង្គ និមន្តមកប្រជុំដោយខ្លួនឯង តាមធម្មតារបស់ខ្លួន ឥតអ្នកណានិមន្តមកឡើយ ។

៣- តេសុ ឯកោ បថុជ្ជនោ វា សោតាបន្នសកិទាកាមិអនាគាមិសុក្ខវិបស្សកអរហន្តេសុ វា អញ្ញតរោ នត្ថិ សព្វេ ឆឡភិញ្ញា.- ភិក្ខុទាំង ១២៥០ អង្គ សូម្បីមានឋានៈត្រឹមតែជាបុថុជ្ជន ឬសោតាបន្នបុគ្គល, ឬសកិទាមិ, អនាគាមិ ឬគ្រាន់តែជាអរហន្ត គ្រាន់តែស្ងួតកិលេស ក៏គ្មានឡើយ គឺសុទ្ធតែជាព្រះអរហន្តបានអភិញ្ញា ៦ គ្រប់រូបទាំងអស់ ។

៤- ឯកោបិ ចេត្ថ សត្ថកេន កេសេ ឆិន្ទិត្វា បព្វជិតោ នាម នត្ថិ សព្វេ ឯហិភិក្ខុកា ។- ភិក្ខុទាំងអស់ គ្មានភិក្ខុរូបណាមួយ កោរសក់ដោយកាំបិតហើយបួសទេ គឺសុទ្ធតែជាឯហិភិក្ខុទាំងអស់ ។

ស. បាតិមោក្ខនេះមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ព្រះពុទ្ធទ្រង់សំដែងបាតិមោក្ខណា ?

ច. បាតិមោក្ខមាន ២ យ៉ាងគឺ ឱវាទបា្បតិមោក្ខ១, អាណាបាតិមោក្ខ១ ។ ព្រះពុទ្ធទ្រង់សំដែង ឱវាទប្បាតិមោក្ខ មានបទថា "សព្វបាបស្សអករណំ" ជាដើម ។

www.elibraryofcambodia.org

ស. ចុះអាណាចាតិមោក្ខ គឺអ្វី ?

ច. អាណាចាតិមោក្ខ គឺបទបញ្ញត្តិដែលទ្រង់ហាមដាច់ខាតសាវ័ក បានដល់សិក្ខាបទ ២២៧ ជាដើម ។

ស. កាលព្រះសាស្តាទ្រង់ប្រោសព្រះសារីបុត្រ និងព្រះមោគ្គល្លានហើយ តើទ្រង់ប្រោសជនណាទៀត ? ជននោះជាអ្វី? ចូរលើកប្រវត្តិមកនិយាយផង !

ច. ព្រះសាស្តាទ្រង់បានប្រោស បិប្ផលិមាណព ទៀត ។ មាណពនេះ កាលបួសហើយក៏បានជាសាវ័កដ៏សំខាន់របស់ព្រះសាស្តានាម មហាកស្សបៈ ។

## ប្រវត្តិព្រះមហាកស្សបៈ

ព្រះមហាកស្សបត្ថេរនេះ ជាកូនព្រាហ្មណ៍ឈ្មោះកបិល-កស្សបគោត្រ កើតនៅស្រុកមហាតិត្ថគ្រាម ក្នុងដែនមគធ នាមដើម "បិប្ផលិ" កាលលោកមានអាយុ២០ ឆ្នាំបានរៀបមង្គលការជាមួយនឹងនាង ភទ្ទកាបិលានី ដែលមានអាយុ ១៦ ឆ្នាំ ហើយជាបុត្រីព្រាហ្មណ៍កោសិយគោត្រ នៅសាគលនគរ ក្នុងដែនមគធៈ ។

វង្សត្រកូលនៃគូស្វាមីភរិយាទាំងពីរនេះ ជាអ្នកមានសម្បត្តិស្តុកស្តម្ភណាស់ ប៉ុន្តែគ្មានកូនប្រុសស្រីតពូជត្រកូលឡើយ។ កាលឪពុកស្លាប់ទៅ បិប្ផលិក៏គ្រប់គ្រងទ្រព្យសម្បត្តិតពូជត្រកូល ប៉ុន្តែ

www.elibraryofcambodia.org

កាលកន្លងតមកបិប្ផលិមានចិត្តនឿយណាយក្នុងឃរាវាស ក៏នាំគ្នាប្តីប្រពន្ធចេញទៅបួស ហើយបានជួបព្រះសាស្តានៅក្រោមដើមជ្រៃ១ ហៅថាពហុបុត្តកនិគ្រោធជាចន្លោះព្រំដែននៃក្រុងរាជគ្រឹះនិងស្រុកនាលន្ទាហើយបានថ្វាយខ្លួនជាសាវ័ក ព្រះសាស្តាប្រទានឱ្យលោក បានជាភិក្ខុក្នុងព្រះពុទ្ធសាសនាដោយឱវាទ ៣ យ៉ាងគឺ :

១. ថា "ម្នាលកស្សបៈ អ្នកគប្បីសិក្សាថា យើងនឹងតាំងនៅក្នុងសេចក្តីអៀនខ្មាស-សេចក្តីកោតក្រែងចំពោះភិក្ខុចាស់ ថ្មីនិងកណ្តាលឱ្យបានម៉ឹងម៉ាត់" ។

២. ថា យើងស្តាប់ធម៌ឯណានីមួយៗ ដែលប្រកបដោយកុសល គប្បីផ្ទៀងត្រចៀកស្តាប់ធម៌នោះ ហើយពិចារណាយកសេចក្តីនៃធម៌នោះ ។

៣. ថា យើងនឹងមិនលះបង់សតិដែលប្រព្រឹត្តនៅក្នុងកាយ គឺពិចារណារាងកាយឱ្យជាអារម្មណ៍ ។

ព្រះកស្សបៈបានទទួលយកឱវាទទាំង៣ ដោយសេចក្តីគោរព ហើយតាំងព្យាយាម មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្តផលក្រោយពេលបួសហើយ ៨ ថ្ងៃ ហើយក៏បានទទួលសេចក្តីសរសើរពីព្រះសាស្តាថា មានព្រហ្មវិហារធម៌ស្មើដោយព្រះអង្គ ។

ព្រះថេរអង្គនេះ គេហៅថា មហាកស្សបត្ថេរ ហើយជា

www.elibraryofcambodia.org

អ្នកធ្លាប់ទទួលយកសំពត់សង្ឃាដិរបស់ព្រះសម្ពុទ្ធមកទ្រទ្រង់ ថែមទាំងព្រះសម្ពុទ្ធក៏ធ្លាប់ទទួលយកសង្ឃាដិ របស់លោកមកទ្រទ្រង់ដែរ ។ ព្រះសម្ពុទ្ធបានសរសើរថា លោកជាអ្នកមានចិត្តសន្តោសប្រាថ្នាតិច ប្រព្រឹត្តខ្លួនជាអ្នកថ្មីជានិច្ច មិនសំដែងស្និទ្ធស្នាល មិនរពិសកាយវាចា មានចិត្តមិនជាប់ជំពាក់ក្នុងត្រកូលផ្សេងៗ ។ ព្រះសាស្តាទ្រង់លើកតំកើងលោកក្នុងដំណែងជាឯតទគ្គ ខាងទ្រទ្រង់ធុតង្គ ៣ គឺទ្រទ្រង់សំពត់បង្សុកូលជាវត្ត១, នៅក្នុងព្រៃជាវត្ត១, ត្រេចបិណ្ឌបាត្រជាវត្ត១ ។

ព្រះមហាកស្សបត្ថេរ ជាព្រះថេរៈសំខាន់បំផុត ហើយមានព្រះជន្មដល់ទៅ ១២០ ឆ្នាំ ។ កាលព្រះសាស្តាបរិនិព្វាន លោកពុំបានគង់នៅទីនោះទេ លុះឮថាព្រះអង្គបរិនិព្វានហើយ ព្រះមហាកស្សបត្ថេរ ក៏នាំបរិវារចូលទៅថ្វាយបង្គំព្រះបរមសព នៅថ្ងៃទី៧ក្រោយពុទ្ធបរិនិព្វាន គឺនៅពេលដែលគេរៀបបូជាព្រះបរមសព។ ពេលនោះភ្លើងមិនអាចឆេះព្រះមឈូសមាសបានឡើយ លុះព្រះមហាកស្សបត្ថេរនិមន្តទៅដល់ ចូលទៅថ្វាយបង្គំព្រះបរមសព ព្រះបាទាទាំងគូនៃព្រះបរមសពក៏លៀនចេញមក ព្រះមហាកស្សបថ្វាយបង្គំព្រះបាទថ្លៃងរៀបរាប់រួច ព្រះបាទាក៏លឹបចូលទៅក្នុងមឈូសមាសរួច ព្រះអគ្គិក៏ឆាបឆេះដោយខ្លួនឯង ។

www.elibraryofcambodia.org

ព្រះមហាកស្សបត្ថេរ ជាមហាសាវ័កសំខាន់បំផុត ដោយលោកបានធ្វើជាប្រធាន ក្នុងការរៀបចំផ្ទៀងផ្ទាត់ធម៌វិន័យ នៅលើកដំបូងហៅថា បឋមសង្គាយនា នៅក្រុងរាជគ្រឹះ ដោយមានព្រះអរហន្ត ៤៩៩ អង្គជាសមាជិក ហើយព្រះមហាកស្សបត្ថេរជាអ្នកចោទសួរវិន័យបិដក ចំពោះព្រះឧបាលិ និងសួរព្រះសុត្តន្តបិដក, អភិធម្មបិដក ចំពោះព្រះមហាអានន្ទ ។ បឋមសង្គាយនានោះ ចាប់ធ្វើក្រោយពុទ្ធបរិនិព្វាន ៣ ខែ ហើយធ្វើ ៧ ខែទើបចប់ដោយប្រារព្ធនូវពាក្យមើលងាយរបស់សុភទ្ទបរិព្វាជក ។

កាលធ្វើបឋមសង្គាយនារួចព្រះមហាកស្សបត្ថេរ បានគង់សម្រេចសម្រាន្តឥរិយាបថនៅក្នុងវត្តវេឡុវ័ន រហូតទល់ព្រះជន្ម ១២០ វស្សា ទើបបរិនិព្វាននៅចន្លោះភ្នំទាំង ៣ ហៅថា "កក្កុដសប្បាតបព៌ត[១]" ។

១. កាលលោកបរិនិព្វានទៅ គេយកព្រះសពលោកទៅបញ្ចុះ ឥតបូជាទេ ។ មឈូសនៃព្រះសពនេះនៅរហូតទល់ព្រះសិរអារ្យមេត្រីបានត្រាស់ ហើយហៀបបរិនិព្វានទៅ ។

សេចក្តីដំណាលថា កាលពីអតីតជាតិព្រះសិរអារ្យបានកើតជាហ្មថាវ ព្រះកស្សបៈកើតជាដំរី ។ ពេល១ ហ្មថាវបានប្រើដំរីឱ្យឱបដែកក្តៅថ្វាយព្រះរាជាទត ។ កម្មពៀរពុំទាន់ស្ងប់នៅឡើយ ។ ដល់ពេលព្រះសិរអារ្យបានត្រាស់ទេសនាប្រោសសត្វគ្រប់ ៥០០០ ឆ្នាំហើយហៀបបរិនិព្វាន មឈូសព្រះសពព្រះមហាកស្សបក៏ផុសពីដីអណ្តែតទៅរកព្រះសិរអារ្យ ១ ទតឃើញក៏យកព្រះហស្តទ្រមឈូស១ ក៏ឆេះលើព្រះហស្តព្រះសិរអារ្យ១ ក៏ចូលបរិនិព្វាននៅពេលនោះឯង ។

www.elibraryofcambodia.org

ស- តមកតើព្រះសាស្តាទ្រង់បានប្រោសជនណាទៀត ? ជននោះជាអ្វី ? មានប្រវត្តិយ៉ាងណា ?

ច- ព្រះសាស្តាទ្រង់បានប្រោសមហាកច្ចាយនៈ ជាបុរោហិតនៃព្រះបាទចណ្ឌប្បជ្ជោតទៀត ។

## ១៧- ប្រវត្តិព្រះមហាកច្ចាយនត្ថេរ

ព្រះមហាកច្ចាយនត្ថេរ ជាបុត្តព្រាហ្មណ៍បុរោហិតកច្ចាយនគោត្រ នៅក្រុងឧជ្ជេនី ឈ្មោះ កញ្ចនៈ។ ធំឡើងបានចេះចប់គម្ពីរត្រៃវេទ ។ លុះបិតាស្លាប់ទៅ កញ្ចនៈក៏បានទទួលងារបុរោហិត ក្នុងរាជ្យព្រះបាទចណ្ឌប្បជោត តមក ។

សម័យនោះ ព្រះបាទចណ្ឌប្បជ្ជោតបានជ្រាបពត៌មានថា ព្រះសម្មាសម្ពុទ្ធ ទ្រង់បានត្រាស់ដឹងក្នុងលោកហើយ ក៏បានចាត់ឱ្យកញ្ចនៈបុរោហិត ទៅក្រាបទូលសុំយោងព្រះសាស្តាឱ្យយាងទៅប្រកាសព្រះពុទ្ធសាសនា ក្នុងក្រុងឧជ្ជេនី ។ កញ្ចនៈបុរោហិតក្រាបទូលសុំបួសផង លុះបានព្រះរាជានុញ្ញាតហើយ លោកក៏នាំបរិវារ ៧ នាក់ចេញពីក្រុងឧជ្ជេនីទៅ ហើយកាលបានជួបព្រះសាស្តា ក៏បានស្តាប់ធម៌បានសម្រេចអរហត្តផលទាំង ៨ នាក់ រួចក៏សុំបព្វជ្ជាឧបសម្បទា ក្នុងសំណាក់ព្រះសាស្តា ។ ទ្រង់អនុញ្ញាតឱ្យបួសជាឯហិភិក្ខុ ។

www.elibraryofcambodia.org

កាលលោកបួសរួចហើយ ក៏ចូលទៅក្រាបសុំយាងព្រះសាស្តាឱ្យទៅឧជ្ជេនី ព្រះសាស្តាទ្រង់ត្រាស់បង្គាប់ឱ្យលោកនិមន្តទៅជាមួយបរិវារ ៧ អង្គទៀត ដើម្បីថ្វាយពរឱ្យមានព្រះមហាក្សត្រព្រមទាំងប្រកាសពុទ្ធសាសនានៅទីនោះ ។ ព្រះមហាកច្ចាយនត្ថេរ បាននិមន្តទៅហើយបានប្រកាសព្រះពុទ្ធសាសនា ដល់អ្នកនគរ និងព្រះមហាក្សត្រក្រុងឧជ្ជេនី ឱ្យជ្រះថ្លាហើយ ក៏ត្រឡប់ទៅថ្វាយបង្គំព្រះសាស្តាវិញ ។

ព្រះមហាកច្ចាយនត្ថេរ ជាព្រះថេរដែលឆ្លាតក្នុងការអធិប្បាយសេចក្តីសង្ខេបឱ្យពិស្តារឡើង ។ កាលព្រះសាស្តាគង់នៅវត្តជេតពន ទ្រង់ប្រារព្ធភទ្ទេករត្តសូត្រ, កច្ចាយនបេយ្យាលសូត្រ, បារាយនសូត្រ និងបកុរសូត្រឱ្យជាឧប្បត្តិហេតុ ហើយក៏តាំងលោកក្នុងដំណែងជាឯតទគ្គ ជាកំពូលនៃភិក្ខុទាំងឡាយ ប៉ែកខាងចែកអត្ថដែលទ្រង់សំដែងដោយសង្ខេបឱ្យពិស្តារឡើង ។ ក្រៅពីនេះ នៅមានធម្មភាសិតដទៃទៀតគឺ មធុបណ្ឌិកសូត្រ, ឧទ្ទេសវិភង្គសូត្រ ក្នុងគម្ពីរមជ្ឈិមនិកាយ ជារបស់ព្រះមហាកច្ចាយនត្ថេរនេះ ។

ព្រះមហាកច្ចាយនត្ថេរ មានរូបល្អ សម្បុរលឿងដូចមាស ដូចមានរឿងនិយាយក្នុងគម្ពីរធម្មបទភាគ ២ ថា សេដ្ឋីបុត្រនៅ

www.elibraryofcambodia.org

ស្រុកសោរេយ្យ បានឃើញលោកហើយក៏នឹកថា បើអញមានភរិយា មានរូបល្អដូចព្រះមហាកច្ចាយនត្ថេរ ជាការប្រសើរណាស់ គ្រាន់តែគិតប៉ុណ្ណោះ ជាបក៏បណ្តាលឱ្យសោរេយ្យក្លាយខ្លួនជាស្ត្រី ហើយរត់ចោលស្រុកទៅយកប្តីបានកូន២ នាក់ទើបមកសូមទោស ចំពោះកច្ចាយនត្ថេរ ក៏បានប្រែភេទមកជាមនុស្សប្រុសវិញ ។

ព្រះមហាកច្ចាយនត្ថេរ តាមក្នុងមធុរសូត្រថា មានព្រះជន្មវែងរហូតក្រោយពុទ្ធបរិនិព្វាន ទើបលោកចូលនិព្វាន ។

ស- ចុះកាលតមក ព្រះសាស្តាទ្រង់បានប្រោសជនណាទៀត សូមពន្យល់ !

ច- ព្រះអង្គទ្រង់បានប្រោសមាណព ១៦ នាក់ ជាសិស្សរបស់គណាចារ្យម្នាក់ ជាតិព្រាហ្មណ៍ឈ្មោះពាវរី ។ មាណពទាំង ១៦ នាក់នោះ មានប្រវត្តិដូចតទៅ ៖

## ១៨- ប្រវត្តិព្រះអជិតត្ថេរ

ព្រះអជិតត្ថេរជាបុត្រព្រាហ្មណ៍ ក្នុងនគរសាវត្ថី កាលចំរើនវ័យដល់ពេលសិក្សាហើយ ទើបមាតាបិតានាំយកទៅផ្ញើនឹងព្រាហ្មណ៍ពាវរីមេគណាចារ្យធំ ។ លុះព្រះពុទ្ធជាម្ចាស់ទ្រង់ឧប្បត្តិឡើងក្នុងលោក មានព្រះគុណល្បីខ្ចរខ្ចាយផ្សាយទៅនានាជនបទ ។ ព្រាហ្មណ៍ពាវរីបានជ្រាបពត៌មានចង់ដឹងសេចក្តីពិត

www.elibraryofcambodia.org

ទើបប្រើមាណព ១៦ នាក់ ដែលជាសិស្សមានអជិតមាណពជាដើម ឱ្យទៅក្រាបបង្គំទូលសួរប្រស្នា ដើម្បីស៊ើបឱ្យដឹងការពិត ទើបឱ្យមាណព ១៦ នាក់នាំបរិវាររៀងៗ ខ្លួនចូលទៅរកព្រះសាស្តា នៅដំបន់បាសាណចេតិយ ក្រាបទូលសុំព្រះឱកាសចូលសួរប្រស្នា កាលព្រះអង្គអនុញ្ញាតហើយ ទើបអជិតមាណពក្រាបទូលសួរប្រស្នា ៤ ខ ដូច្នេះ :

លោកគឺពពួកសត្វ មានអ្វីបិទបាំងបានជាវង្វេងវិលវល់ដូចនៅក្នុងទីងងឹត, ព្រោះអ្វីជាហេតុបើមិនមែនប្រាជ្ញាឃើញប្រាកដ, ព្រះអង្គត្រាស់ថាអ្វីជាគ្រឿងលាបសត្វលោក, ឱ្យជាប់ជំពាក់នៅ, ហើយត្រាស់ថាអ្វីភ័យធំនៃសត្វលោកនោះ ?

ព្រះបរមសាស្តាទ្រង់ព្យាករណ៍ថា លោកជាពពួកសត្វមានអវិជ្ជា (សេចក្តីល្ងង់ខ្លៅ) បិទបាំងទុក ទើបវង្វេងវិលវល់ដូចនៅក្នុងទីងងឹត, ព្រោះសេចក្តីប្រាថ្នាមានប្រការផ្សេងៗ នឹងសេចក្តីប្រមាទធ្វេសប្រហែស ទើបមិនមានប្រាជ្ញាឃើញប្រាកដ, តថាគតពោលថា សេចក្តីប្រាថ្នាជាគ្រឿងលាបរុំសត្វលោកឱ្យជាប់ជំពាក់នៅ, ហើយតថាគតពោលថា សេចក្តីទុក្ខជាភ័យធំនៃសត្វលោកនោះ ។

ចុះអ្វីជាគ្រឿងហាមជាគ្រឿងរាំងរា សេចក្តីប្រាថ្នាបីដូច

www.elibraryofcambodia.org

ខ្សែទឹក តែងហៀរហូរចូលក្នុងអារម្មណ៍ទាំងពួង ចុះសេចក្តីប្រាថ្នានោះ បុគ្គលនឹងលះបង់បានព្រោះធម៌អ្វី ?

- សតិគ្រឿងហាម គ្រឿងរាំងរា សេចក្តីប្រាថ្នាហើយសេចក្តីប្រាថ្នា បុគ្គលនឹងលះចេញបានព្រោះបញ្ញា ។

- បញ្ញា សតិនិងនាមរូបនោះតើរសាត់ទៅក្នុងទីណា ?

- ព្រោះវិញ្ញាណរលត់ទៅមុន ទើបនាមរូបរលត់នៅក្នុងទីនោះឯង ។

- ជនអ្នកមានធម៌បាន់ពិចារណាឃើញហើយ និងជនដែលនៅសិក្សានៅឡើយ ជនពីរជំពូកនេះមាននៅក្នុងលោក, ទូលព្រះបង្គំជាខ្ញុំសូមក្រាបទូលសួរអំពីសេចក្តីប្រព្រឹត្តនៃជនពីរពួកនោះ ?

- ភិក្ខុមានធម៌បានពិចារណាឃើញហើយ និងជនដែលនៅសិក្សានៅឡើយ ត្រូវដកចិត្ត មិនត្រេកត្រអាលក្នុងកាមទាំងឡាយ មានចិត្តមិនរាគ ល្អក់ ឈ្លាសវៃក្នុងធម៌ទាំងពួង មានស្មារតីគ្រប់ឥរិយាបថ ។

ក្នុងវេលាចប់បុញ្ញាព្យាករណ៍ អជិតមាណពបានសម្រេចអរហត្តព្រមដោយចតុប្បដិសម្ភិញាណ ។

លុះព្រះបរមសាស្តា ទ្រង់ដោះស្រាយប្រស្នារបស់មាណព ១៥ នាក់ទៀតចប់ស្រេចហើយ ទើបក្រាបទូលសុំឧបសម្ប័ទ ។

www.elibraryofcambodia.org

ព្រះដ៏មានបុណ្យទ្រង់ប្រទានឯហិភិក្ខុឧបសម្បទា ជាភិក្ខុក្នុងពុទ្ធសាសនា ។ ព្រះអជិតត្ថេរនេះរាប់បញ្ចូលក្នុងពួកអសីតិមហាសាវកព្រះអង្គមួយ មានជន្មាយុសមគួរនឹងពេលកំណត់ហើយ ក៏បរិនិព្វាន ។

## ១៩- ប្រវត្តិព្រះតិស្សមេត្តេយ្យត្ថេរ

ព្រះតិស្សមេត្តេយ្យត្ថេរនេះ ជាបុត្រព្រាហ្មណ៍ម្នាក់នៅក្រុងសាវត្ថី កាលមានវ័យចំរើនឡើង គួរដល់ការសិក្សាហើយបានចេញទៅរៀនលទ្ធិ ក្នុងសំណាក់ព្រាហ្មណ៍ពាវរី ដែលធ្លាប់ធ្វើជាមហាបុរោហិតនៃព្រះបាទកោសលរាជ ហើយតមកសម័យក្រោយ មានសេចក្តីនឿយណាយក្នុងឃរាវាស ទើបក្រាបបង្គំទូលសូមព្រះរាជានុញ្ញាត លាទៅបួសប្រព្រឹត្តវត្តតាមលទ្ធិព្រាហ្មណ៍ តាំងអាស្រមនាឆ្នេរស្ទឹងគោធាវរី ជាទីព្រំប្រទល់នៃស្រុកអស្សកៈនិងអឡក ជាគណាចារ្យធំក្នុងសម័យនោះ ។

លុះព្រះពុទ្ធជាម្ចាស់ទ្រង់ឧប្បត្តិឡើងក្នុងលោកហើយ មានព្រះកិត្តិស័ព្ទល្បីខ្ចរខ្ចាយចេញទៅក្នុងទិសានុទិស ព្រាហ្មណ៍ពាវរីបានជ្រាបពត៌មាន មានសេចក្តីងឿងឆ្ងល់សង្ស័យចង់ដឹងការពិត ទើបចងជាបញ្ហា ១៦ វត្ថុឱ្យមាណព ក៏នៅក្នុងចំនួននេះដែរ នាំគ្នាលាអាចារ្យ នាំបរិវាររៀងខ្លួនចូលទៅក្រាបបង្គំគាល់ព្រះ

www.elibraryofcambodia.org

បរមគ្រូល្បងមើល ។ ឯតិស្សមេត្តេយ្យមាណពក៏នៅក្នុងចំនួននេះដែរ នាំគ្នាតាមអាចារ្យ នាំបរិវាររៀងៗ ខ្លួនចូលទៅក្រាបបង្គំគាល់ព្រះបរមគ្រូ ឯចាសាណាចេតិយដែនមគធរដ្ឋ ក្រាបបង្គំទូលសូមឱ្យឱកាសសួរប្រស្នាម្នាក់ៗមួយវគ្គៗ ។ កាលព្រះបរមគ្រូទ្រង់ព្រះអនុញ្ញាតហើយ ទើបអជិតមាណពក្រាបបង្គំទូលសួរបញ្ហាជាលើកទី១ រួចហើយទើបតិស្សមេត្តយ្យមាណពក្រាបបង្គំទូលសួរប្រស្នាជាគំរប់ទី២ តទៅថា :

បុគ្គលដូចម្តេច ឈ្មោះថាជាអ្នកសន្តោស គឺអ្នកពេញចំណង់ក្នុងលោកនេះ, សេចក្តីប្រាថ្នាដែលជាហេតុអន្ទះអន្ទែងក្រហល់ក្រហាយរបស់ជនណាមិនមានទេ, អ្នកណាដឹងចំណែកខាងក្នុង ទាំងសងខាង (អតីត និងអនាគត) ដោយប្រាជ្ញា, ហើយមិនជាប់នៅត្រង់ចំណែកពាក់កណ្តាល(បច្ចុប្បន្ន) ព្រះអង្គត្រាស់ថាអ្នកណាជាមហាបុរស, អ្នកណាកន្លងផុតចំណងសម្រាប់ចងចិត្តសត្វទុកក្នុងលោក ដូចជាអំបោះសម្រាប់ដេរភ្ជាប់សំពត់ដូច្នោះ ។

ព្រះបរមគ្រូទ្រង់ព្យាករណ៍ថា : ភិក្ខុប្រព្រឹត្តព្រហ្មចរិយាធម៌សង្រួមក្នុងកាយទាំងឡាយ ប្រាសចាកសេចក្តីប្រាថ្នា ហើយមានសតិនឹករឭកឃើញសព្វកាល, ពិចារណាឃើញជាក់ច្បាស់ហើយរំលត់សេចក្តីក្រវល់ក្រវាយបានហើយឈ្មោះថា ជាអ្នក

www.elibraryofcambodia.org

សន្តោស គឺអ្នកពេញចំណោងក្នុងលោកនេះ សេចក្តីប្រាថ្នា ជាហេតុអន្ទះអន្ទែងក្រវល់ក្រវាយរបស់ភិក្ខុនោះ មិនមានទេ. ភិក្ខុនោះឯងដឹងច្បាស់នូវចំណែកខាងចុង ទាំងសងខាង ដោយប្រាជ្ញាហើយ. មិនជាប់ពាក់នៅត្រង់ចំណែកពាក់កណ្តាលតថាគតពោលថា ភិក្ខុនោះឯងជាមហាបុរស. ភិក្ខុនោះឯងកន្លងផុតចំណោង សម្រាប់ចងចិត្តសត្វទុកក្នុងលោក ដូចជាអំពោះសម្រាប់ដេរភ្ជាប់សំពត់ដូច្នោះ ។

នៅទីបំផុតនៃបញ្ហាព្យាករណ៍ តិស្សមេត្តេយ្យមាណពក៏បានសម្រេចអរហត្ត ព្រមដោយចតុប្បដិសម្ភិទាញាណ លុះមាណពដទៃទៀតក្រាបទូលសួរបញ្ហារៀង១ខ្លួន រួចហើយទើបមេត្តេយ្យមាណពព្រមទាំងមាណពជាសមានាចារ្យ នាំគ្នាក្រាបបង្គំទូលសូមបព្វជ្ជា ឧបសម្បទា ព្រះដ៏មានបុណ្យ ក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុ ឧបសម្បទា ។ ព្រះតិស្សមេត្តេយ្យត្ថេរ មានជន្មាយុសមគួរដល់កាលកំណត់ហើយ ក៏រំលត់ខន្ធចូលកាន់បរិនិព្វាន ។

## ២០. ប្រវត្តិព្រះបុណ្ណកត្ថេរ

ព្រះបុណ្ណកត្ថេរ ជាបុត្រព្រាហ្មណ៍ម្នាក់ក្នុងនគរសាវត្ថី កាលមានវ័យចំរើនហើយ ក៏បានទៅសិក្សាលទ្ធិក្នុងសំណាក់

www.elibraryofcambodia.org

ព្រាហ្មណ៍ពាវរី ។ល។

កាលតិស្សមេត្តេយ្យមាណព បានក្រាបទូលសួរប្រស្នាបាន ស្តាប់ព្រះធម្មទេសនាសម្រេចអរហត្តហើយ ទើបបុណ្ណកមាណព ក្រាបទូលសួរប្រស្នាគំរប់ ៣ សេចក្តីថា :

ពពួកមនុស្សក្នុងលោកនេះអាស្រ័យអ្វី ? ទើបនាំគ្នាបូជា យ័ញ្ញបន់ស្រន់ទេព្តា ។

ពពួកមនុស្សទាំងនោះ ប្រសិនបើមិនប្រមាទក្នុងយ័ញ្ញ របស់ខ្លួន តើអាចនឹងឆ្លងជាតិ និងជរាទៅបានឬទេ? ពពួកមនុស្ស ទាំងនោះ ប៉ុនប៉ងចង់បានលាភដែលខ្លួនប្រាថ្នា ទើបពោល សរសើរការបូជាយ័ញ្ញ ពោលដំកើងតែរបស់ខ្លួនប្រាថ្នាដូច្នេះ ក៏ ព្រោះអាស្រ័យលាភ, តថាគតពោលថាអ្នកបូជាយ័ញ្ញទាំងនោះ នៅមានសេចក្តីត្រេកត្រអាល ក្នុងភពនិងឆ្លងឱ្យផុតចាកជាតិជរា ទៅមិនបានឡើយ ។

- ចុះបើអ្នកបូជាយ័ញ្ញទាំងនោះ និងឆ្លងឱ្យផុតចាកជាតិ ជរា ព្រោះយ័ញ្ញរបស់ខ្លួនមិនបានទេ ដូច្នេះតើអ្នកណា ក្នុង ទេវលោក ឬមនុស្សលោកអាចឆ្លងឱ្យផុតចាកជាតិជរានោះទៅ បាន ?

- ចំណង ឬសេចក្តីប្រាថ្នា ដ៏ជាហេតុអន្ទះអន្ទែងក្រហល់

www.elibraryofcambodia.org

ក្រហាយក្នុងលោកណាមួយរបស់បុគ្គលណាមិនខាន ព្រោះបាន ពិចារណាឃើញច្បាស់នូវធម៌តឹង និងធូរក្នុងលោក តថាគត ពោលថា អ្នកនោះឯងជាអ្នកស្ងប់រម្ងាប់ហើយ មិនមែនទុច្ចរិត សេចក្តីប្រព្រឹត្តអាក្រក់ ដែលធ្វើឱ្យសៅហ្មង ដូចផ្សែងភ្លើងចាប់ ខ្មៅមិនមែនកិលេស ប៉ះពាល់ដល់ចិត្តឥតប្រាថ្នាក្រវល់ក្រវាយ. ទើបអាចឆ្លងផុតចាកជាតិជរាទៅបាន ។

កាលបុណ្ណកមាណព បញ្ជូនចិត្តទៅតាមក្រសែព្រះធម្មទេសនា ក៏បានសម្រេចព្រះអរហត្តព្រមទាំងចតុប្បដិសម្ភិទាញាណ ហើយបានក្រាបទូលសូមបព្វជ្ជាឧបសម្បទាជាមួយ នឹងពួកមាណព ជាសមានាចារ្យក្នុងវេលាចប់សោឡសបញ្ហាព្យាករណ៍ ។

ព្រះបរមសាស្តា ក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុដោយឯហិភិក្ខុឧបសម្បទា ព្រះបុណ្ណកត្ថេរ មានជន្មាយុក្នុងព្រះសាសនាតាមសមគួរដល់កាលកំណត់ហើយ ក៏រលត់ខន្ធចូលកាន់បរិនិព្វាន ។

## ២១. ប្រវត្តិព្រះមេត្តគុត្ថេរ

ព្រះមេត្តគុត្ថេរ ជាបុត្រព្រាហ្មណ៍ត្រកូល១ ក្នុងនគរសាវត្ថី កាលមានវ័យធាត់ធំចំរើនឡើង បានទៅនៅសិក្សាលទ្ធិក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

www.elibraryofcambodia.org

កាលបុណ្ណកមាណពក្រាបទូលសួរប្រស្នា បានស្តាប់ព្រះធម្មទេសនាសម្រេចអរហត្តហើយ ទើបមេត្តគូមាណព ក្រាបទូលសួរប្រស្នារជាគំរប់ ៤ តទៅថា :

បពិត្រព្រះអង្គដ៏ចំរើន ទុក្ខក្នុងលោកនេះមានច្រើនប្រការ មិនមែនមានតែ១ ទេ ចុះមានមកពីអ្វីហ្ន ?

ព្រះបរមគ្រូទ្រង់ព្យាករណ៍ថា ទុក្ខក្នុងលោកនេះមានឧបធិគឺកម្មនិងកិលេសជាហេតុ កើតមកអំពីឧបធិជាមុន, ជនណាល្ងង់ខ្លៅមិនដឹងហើយ ធ្វើឧបធិនេះឱ្យកើតឡើង ជននោះឯងតែងបានទទួលទុក្ខរឿយៗ ហេតុនេះកាលបើនឹងឃើញច្បាស់ថា ឧបធិជាដើមចមនៃសេចក្តីទុក្ខ (កុំធ្វើ) ឧបធិឱ្យកើតឡើងឡើយ ។

- អ្នកមានប្រាជ្ញា នឹងឆ្លងអន្លង់សមុទ្រធំ គឺជាតិជរាសោកបរិទេវៈ ឱ្យផុតឱ្យបានដូចម្តេច ? សូមព្រះអង្គទ្រង់សម្តែងខនេះដល់ខ្ញុំព្រះអង្គ ។

- តថាគតនឹងសម្តែងធម៌ ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ក្នុងអត្តភាពនេះ មិនបាច់ជឿងេងងោង ទៅតាមពាក្យនៃអ្នកដទៃថាគឺយ៉ាងនេះៗ ជាអ្នកមានស្មារតី ធ្វើដំណើរឆ្លងសេចក្តីប្រាថ្នា ដែលនាំឱ្យជាប់ជំពាក់ក្នុងលោកចេញដល់អ្នក ។

- ខ្ញុំព្រះអង្គត្រេកអរនឹងធម៌ដ៏ខ្ពង់ខ្ពស់នេះយ៉ាងក្រៃលែង។

www.elibraryofcambodia.org

អ្នកដឹងយ៉ាងណានីមួយ ក្នុងចំណែកខាងលើ (គឺអនាគត) ក្នុងចំណែកពាក់កណ្តាល (គឺបច្ចុប្បន្ន) ចូរបន្ទោរបង់សេចក្តីរីករាយ, សេចក្តីប្រកាន់មាំ, ក្នុងចំណែកអស់នោះចេញ វិញ្ញាណខន្ធរបស់អ្នកនឹងមិនឋិតនៅក្នុងភព, ភិក្ខុអ្នកមានវិហារធម៌យ៉ាងនេះមានសតិមិនធ្វេសប្រហែស, បានដឹងហើយតែងលះបង់នូវសេចក្តីប្រកាន់ថា ជារបស់អញចេញបានហើយ ក៏នឹងលះបង់នូវទុក្ខគឺជាតិ ជរា សោកបរិទេវៈ ក្នុងលោកនេះចេញបាន ។

ខ្ញុំព្រះអង្គគាប់ចិត្តនឹងព្រះវាចា របស់ព្រះអង្គយ៉ាងក្រៃលែង, ធម៌មិនមានឧបធិ ព្រះអង្គទ្រង់សំដែងប្រពៃហើយ, ព្រះអង្គទ្រង់លះបង់នូវទុក្ខបានមែន ព្រោះព្រះអង្គទ្រង់បានជ្រាបនូវធម៌នេះហើយ សូម្បីលោកអ្នកចេះដឹង ដែលព្រះអង្គបានទូន្មានជានិច្ច ក៏គង់លះបង់ទុក្ខនេះបានមែនពិត ហេតុនេះទើបខ្ញុំព្រះអង្គចូលមកក្រាបថ្វាយបង្គំគាល់ ដើម្បីឱ្យទ្រង់ទូន្មានប្រដៅខ្ញុំព្រះអង្គជានិច្ចដូច្នោះផង :

- អ្នកនឹងថា ជនណាជាព្រាហ្មណ៍ ដល់ទីបំផុតចប់ត្រៃវេទមិនមានកិលេសជាគ្រឿងកង្វល់មិនជាប់នៅក្នុងកាមភព អ្នកនោះឯងឆ្លងកន្លងផុតហេតុនៃទុក្ខ ដូចអន្លង់សមុទ្រធំនេះបានហើយលុះឆ្លងដល់ត្រើយជាអ្នកមិនមានកិលេស ជាគ្រឿងរួបរិតចិត្ត.

www.elibraryofcambodia.org

ឥតសេចក្តីសង្ស័យអ្នកនោះលុះចេះចប់ត្រៃវេទ ក្នុងសាសនានេះ ហើយ តែងលះបង់នូវធម៌ ដែលជាហេតុឱ្យជាប់នៅក្នុងភពតូចធំ ចេញបានហើយ ជាអ្នកអស់សេចក្តីប្រាថ្នា មិនមានកិលេសខ្លាំង ខ្ទប់ចិត្ត. ឥតចំណង់អន្ទះអន្ទែង តថាគតពោលថា អ្នកនោះឯង បានឆ្លងផុតជាតិទៅបានហើយ ។

លុះចប់បញ្ហាព្យាករណ៍ មេត្តគូមាណពបានសម្រេច អរហត្ត ព្រមទាំងបដិសម្ភិទាញាណ ទើបក្រាបបង្គំទូលសូម បព្វជ្ជា ឧបសម្បទា ជាមួយមាណពជាសមានាចារ្យ ក្នុងវេលាចប់ បញ្ហាព្យាករណ៍ទាំង ១៦ ។ ឯសម្តេចព្រះសាស្តាចារ្យ ទ្រង់ពុទ្ធា. នុញ្ញាតឱ្យបានជាភិក្ខុឯហិឧបសម្បទា ។

ព្រះមេត្តគុត្ថេរ មានព្រះជន្មដល់កំណត់ហើយ ក៏ចូលកាន់ បរិនិព្វានទៅ ។

## ២៣. ប្រវត្តិព្រះធោតកត្ថេរ

ព្រះធោតកត្ថេរ កើតក្នុងត្រកូលព្រាហ្មណ៍១ នៅក្រុង សាវត្ថី ដែនកោសល បានរៀនសូត្រ ក្នុងសំណាក់ព្រាហ្មណ៍ឈ្មោះ ពាវរី ។ល។

នៅពេលដែលមេត្តគូមាណព ក្រាបទូលសួរប្រស្នា និង បានស្តាប់ធម្មទេសនា បានសម្រេចអរហត្តផលហើយ ធោតក.

www.elibraryofcambodia.org

មាណព ក៏ចូលទៅក្រាបសូរប្រស្នារជាគម្រប់ ៥ នឹងព្រះសាស្តាថា :

"ខ្ញុំព្រះអង្គបានយល់ឃើញថា ព្រះអង្គជាព្រាហ្មណ៍គ្មានកង្វល់ត្រាច់ទៅក្នុងទេវលោក និងមនុស្សលោក សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោស ដោះខ្ញុំព្រះអង្គឱ្យចេញចាកសេចក្តីសង្ស័យផងចុះ ។

ព្រះសាស្តាតបថា "តថាគតនឹងដោះជនណា១ ក្នុងលោកដែលនៅមានសេចក្តីសង្ស័យមិនបានទេ កាលបើអ្នកបានដឹងធម៌ដ៏ប្រសើរដោយខ្លួនឯង ទើបអ្នកអាចនឹងឆ្លងផុតអន្លង់សមុទ្រធំគឺកិលេសចេញបានដោយខ្លួនឯង" ។

មាណពទូលថា "សូមព្រះអង្គទ្រង់ប្រោសសំដែងធម៌ដែលស្ងប់រម្ងាប់ចាកកិលេស ដែលខ្ញុំព្រះអង្គគប្បីដឹងបាន សូមទ្រង់ទូន្មានប្រដៅខ្ញុំព្រះអង្គ ឱ្យទៅជាមនុស្សមិនជាប់ជំពាក់ ជ្រះស្រឡះដូចជាអាកាសរម្ងាប់កិលេសចេញបាន មិនមានអាស្រ័យនឹងអ្វី១" ។

តថាគតនឹងប្រាប់ឧបាយជាគ្រឿងរម្ងាប់កិលេស ដែលមើលឃើញច្បាស់ដោយខ្លួនឯង មិនបាច់ជឿតាមការភ្ញាក់ផ្អើលបានជ្រួតជ្រាប ហើយមានសតិឆ្លងផុតចាកកិលេស ដែលរួបរិត

www.elibraryofcambodia.org

ចិត្តក្នុងលោកដល់អ្នក ។

- ខ្ញុំព្រះអង្គគាប់ចិត្តនឹងឧបាយ ផ្សុះគ្រឿងម្ចាប់ពិសេស ខ្ពង់ខ្ពស់យ៉ាងនេះក្រៃលែង ។

- បើអ្នកដឹងថា សេចក្តីប្រាថ្នាអន្ទះអន្ទែងទាំងខាងក្រោម ទាំងកណ្តាល ជាហេតុនាំឱ្យជាប់នៅក្នុងលោក អ្នកកុំធ្វើសេចក្តីប្រាថ្នាអន្ទះអន្ទែង ដើម្បីទៅកើតក្នុងភពតូច-ធំទៀតឡើយ ។

កាលចប់ប្រស្នានេះហើយ ធោតកមាណពបានសម្រេចព្រះអរហត្ត ព្រមទាំងចតុប្បដិសម្ភិទាញាណ ហើយក្រាបបង្គំទូលសូមឧបសម្ប័ទ ព្រះសាស្តាក៏ទ្រង់ពុទ្ធានុញ្ញាតឱ្យបានជាភិក្ខុដោយឯហិភិក្ខុឧបសម្បទា ជាមួយនឹងមាណពផ្សេងទៀត វេលាចប់ប្រស្នាទាំង ១៦ ព្រះថេរៈអង្គនេះមានព្រះជន្មជរាហើយ ក៏បរិនិព្វានទៅ ។

## ២៣- ប្រវត្តិព្រះឧបសីវត្ថេរ

ព្រះឧបសីវត្ថេរ កើតក្នុងត្រកូលព្រាហ្មណ៍១ នានគរសាវត្ថី ក្នុងកោសលជនបទ កាលចំរើនវ័យធំឡើង បានទៅសិក្សាលទ្ធិក្នុងសំណាក់ពាវរី ។ល។

កាលធោតកមាណពក្រាបទូលសួរប្រស្នា បានស្តាប់ព្រះធម្មទេសនាសម្រេចព្រះអរហត្តហើយ ទើបឧបសីវមាណព ក្រាប

www.elibraryofcambodia.org

ទូលសួរប្រស្នារជាគំរប់ ៦ តទៅទៀត :

ទំនើងខ្ញុំព្រះអង្គម្នាក់ឯង មិនបានអាស្រ័យអ្វីទេ មិនអាចឆ្លងអន្លង់សមុទ្រធំ គឺកិលេសបានឡើយ. សូមព្រះអង្គត្រាស់ប្រាប់អារម្មណ៍សម្រាប់ចាប់តោង ដែលខ្ញុំព្រះអង្គអាចអាស្រ័យឆ្លងអន្លង់នេះទៅបានដល់ខ្ញុំព្រះអង្គ ។

ព្រះសម្ពុទ្ធទ្រង់ព្យាករណ៍ថា ចូរអ្នកមានសតិពិនិត្យអាកិញ្ចញ្ញាយតនជ្ឈាន អាស្រ័យអារម្មណ៍ថា មិនមានអ្វីៗ ដូច្នេះឆ្លងអន្លង់ទៅ. ចូរអ្នកលះកាមទាំងឡាយចេញ ជាអ្នកវៀចាកសេចក្ដីសង្ស័យ. ឃើញធម៌ជាទីអស់នៃតណ្ហាឱ្យប្រាកដច្បាស់ទាំងយប់ទាំងថ្ងៃ ។

ជនណា ប្រាសចាកតម្រេកក្នុងកាមទាំងឡាយហើយកន្លងឈានដទៃបានហើយ. អាស្រ័យអាកិញ្ចញ្ញាយតនជ្ឈាន (គឺការពិនិត្យសំឡឹងខាងផ្លូវចិត្តថា "មិនមានអ្វី" ជាអារម្មណ៍) បង្អោនចិត្តទៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ដែលជាធម៌សម្រាប់ដកចេញនូវសញ្ញាយ៉ាងប្រសើរ. តើអ្នកនោះនឹងឋិតនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះមិនសាបសូន្យទេឬ ។

- អ្នកនោះនឹងឋិតនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាន មិនសាបសូន្យទេ ។

www.elibraryofcambodia.org

. បើអ្នកនោះនឹងឋិតនៅក្នុងអាកិញ្ចញ្ញាយតនជ្ឈាន អស់ឆ្នាំដ៏ច្រើនបុគ្គលនោះ ជាអ្នកខ្ជាប់ខ្ជួនក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ ឬមួយនឹងរំលត់ខន្ធបរិនិព្វានទៅ តើវិញ្ញាណរបស់អ្នកនោះនឹងទៅជាដូចម្ដេចវិញ ?

. អណ្ដាតភ្លើងដែលត្រូវខ្យល់បក់ហើយរលត់ទៅ មិនគួររាប់ថាបានទៅហើយក្នុងទិសតំបន់ណា មានឧបមាយ៉ាងណា. វិញ្ញូជនដែលផុតទៅហើយចាកកងនាមរូប. រមែងរលត់ទៅមិនមែនសេសសល់ (គឺរលត់ព្រមទាំងកិលេសទាំងខន្ធ ) មិនគួររាប់ថា បានទៅកើតជាអ្វីមានឧបមេយ្យដូច្នោះដែរ ។

. តើបុគ្គលនោះរលត់ទៅហើយ ឬគ្រាន់តែមិនមានរូប ឬជាអ្នកឋិតនៅខ្ជាប់ខ្ជួនមិនមានអន្តរាយ. សូមព្រះអង្គទ្រង់ព្យាករណ៍សេចក្ដីនេះដល់ខ្ញុំព្រះអង្គ ព្រោះថាធម៌នេះសូមព្រះអង្គទ្រង់ជ្រាបច្បាស់ហើយ ?

ប្រមាណនៃបញ្ចក្ខន្ធ របស់អ្នករំលត់ខន្ធ ចូលទៅកាន់បរិនិព្វានទៅហើយ មិនមានកិលេសដែលជាហេតុពោលអំពីអ្នកនោះថា ទៅកើតជាអ្វី. កាលបើធម៌ទាំងឡាយ (មានខន្ធជាដើម) ដែលបុគ្គលនោះកំចាត់ចេញរស់ហើយ ក៏ឈ្មោះថាផ្ដាច់សំដីដែលត្រូវនិយាយដល់អ្នកនោះថាជាអ្វីទាំងអស់ ។

www.elibraryofcambodia.org

វេលាចប់បញ្ហាព្យាករណ៍ ឧបសីវមាណពនៅក្នុងអរហត្ត ផលហើយ ក្រាបបង្គំទូលសូមឧបសម្ប័ទព្រះអង្គទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទាជាមួយនឹងពួកមាណពទាំងនោះ ក្នុងកាលចាប់សោឡសបញ្ហាព្យាករណ៍ ។ ព្រះឧបសីវត្ថេរមានជន្មាយុក្នុងព្រះសាសនាសមគួរ ដល់ការកំណត់ហើយក៏បរិនិព្វាន ។

## ២៤. ប្រវត្តិព្រះនន្ទកត្ថេរ

ព្រះនន្ទកត្ថេរជាបុត្រព្រាហ្មណ៍ ក្នុងសំណាក់ពាវរី ។ល។

កាលឧបសីវមាណព ក្រាបទូលសួរប្រស្នាបានស្ដាប់ព្រះធម្មទេសនាសម្រេចអរហត្តហើយ ទើបនន្ទមាណពក្រាបទូលសួរប្រស្នាជាគំរប់ ៧ តទៅថា :

ជនទាំងឡាយពោលថា"មុនី" មាននៅក្នុងលោកដូចម្ដេច ៗ នេះ តើដូចម្ដេច, គេហៅថា មនុស្សប្រកបព្រមដោយញាណ, ឬប្រកបដោយការចិញ្ចឹមជីវិតបានជាមុនី ?

ព្រះសយម្ភូ ទ្រង់ព្យាករណ៍ថា អ្នកឃ្លាតក្នុងលោកនេះមិនបានពោលមនុស្សដែលមុនី ដោយយោបល់យល់ឃើញ, ដោយឱ្យស្ដាប់ ឬដោយចំណេះចេះដឹងនោះទេ តថាគតពោលថា ជនណាធ្វើខ្លួនឱ្យប្រាសចាកកងកិលេស, ជាអ្នកឥតកិលេស, មិនមាន

www.elibraryofcambodia.org

តណ្ហា គឺសេចក្តីប្រាថ្នាអន្ទះអន្ទែង, ជននោះឯងឈ្មោះថាមុនី ។

- សមណព្រាហ្មណ៍ឯណាៗ ពោលសេចក្តីបរិសុទ្ធដោយការយល់ ដោយការស្តាប់, ដោយសីលនឹងវត្ត និងដោយវិធីដទៃទៀតជាច្រើន, តើសមណព្រាហ្មណ៍ទាំងនោះប្រព្រឹត្តតាមវិធីទាំងនោះ ដែលខ្លួនយល់ថាជាគ្រឿងបរិសុទ្ធ អាចឆ្លងជាតិជរាបានខ្លះដែរឬទេ ? ខ្ញុំព្រះអង្គសូមក្រាបទូលសួរ សូមព្រះត្រាស់សំដែងសេចក្តីនេះដល់ខ្ញុំព្រះអង្គ ។

- សមណព្រាហ្មណ៍ទាំងនោះ ទោះបីបានប្រព្រឹត្តដូច្នោះក៏ដោយ តថាគតពោលថាឆ្លងឱ្យផុតជាតិជរាទៅមិនបានឡើយ ។

- ប្រសិនបើព្រះអង្គត្រាស់ថា សមណព្រាហ្មណ៍ទាំងនោះឆ្លងអន្លង់ទៅមិនបានទេ, បើដូច្នេះតើនរណាវិញក្នុងមនុស្សលោកឬក្នុងទេវលោកអាចឆ្លងឱ្យផុតជាតិជរាទៅបាន ?

តថាគតមិនពោលថា សមណព្រាហ្មណ៍ទាំងឡាយមានជាតិជរាគ្របសង្កត់ហើយគ្រប់ៗ គ្នាទេ, ប៉ុន្តែតថាគតពោលថា ពួកសមណព្រាហ្មណ៍ណាក្នុងលោកនេះបានលះបង់អារម្មណ៍ដែលខ្លួនបានឃើញ បានស្តាប់បានដឹង និងសីលវត្តព្រមទាំងវិធីជាច្រើនចេញអស់ហើយ, កំណត់ដឹងនូវតណ្ហា ថាជាទោសគួរលះបង់បានហើយ ជាអ្នកមិនមានអាសវៈ, សមណព្រាហ្មណ៍ទាំង

www.elibraryofcambodia.org

នោះឆ្លងផុតបានហើយ ។

ខ្ញុំព្រះអង្គគាប់ចិត្តនឹងព្រះវាចារបស់ព្រះអង្គពេកណាស់. សូមព្រះអង្គទ្រង់សំដែងធម៌ដែលមិនមានឧបធិ (កិលេស) ប្រពៃហើយ. សូម្បីខ្ញុំព្រះអង្គក៏ពោលថា សមណព្រាហ្មណ៍ទាំងនោះជាអ្នកឆ្លងអន្លង់ផុតទៅហើយ ដូចព្រះអង្គត្រាស់ដែរ ។

វេលាចប់បញ្ហាព្យាករណ៍នន្ទកមាណព បានសម្រេចអរហត្ត ព្រមដោយចតុប្បដិសម្ភិទាញាណ ទើបក្រាបបង្គំទូលសូមបព្វជ្ជាឧបសម្បទា។ សម្តេចព្រះបរមសាស្តា ក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទា ជាមួយនឹងមាណព ជាសមានាចារ្យក្នុងទីបំផុតនៃសោឡសបញ្ហាព្យាករណ៍ ។ ព្រះនន្ទកត្ថេរ មានជន្មាយុក្នុងព្រះសាសនាតាមសមគួរ ដល់កាលកំណត់ហើយទើបរំលត់ខន្ធចូលកាន់បរិនិព្វាន ។

## ២៥- ប្រវត្តិព្រះហេមកត្ថេរ

ព្រះហេមកត្ថេរ ជាបុត្រព្រាហ្មណ៍ត្រកូលមួយ នៅក្នុងសាវត្ថី កាលចំរើនវ័យធំឡើង បានចេញទៅសិក្សាលទ្ធិក្នុងសំណាក់ពាវរី ។ល។

កាលនន្ទកមាណព បានក្រាបបង្គំទូលសួរប្រស្នា បានស្តាប់ព្រះធម្មទេសនា សម្រេចព្រះអរហត្តហើយ ទើបហេមក-

www.elibraryofcambodia.org

មាណព ក្រាបទូលសួរប្រស្នាជាគំរប់ ៨ សេចក្តីថា :

ក្នុងសម័យមុនព្រះសាសនារបស់ព្រះអង្គ អាចារ្យទាំងឡាយបានពោលរ៉ាប់រងថា យ៉ាងនោះធ្លាប់មានមកហើយ. យ៉ាងនេះនឹងមានតទៅខាងមុខ. ពាក្យនេះសុទ្ធតែជាយ៉ាងនេះៗ សម្រាប់តែធ្វើសេចក្តីត្រិះរិះឱ្យរាយមាយច្រើនឡើង. ខ្ញុំព្រះអង្គមិនគាប់ចិត្តនឹងពាក្យនេះឡើយ. សូមព្រះអង្គទ្រង់សំដែងធម៌ដែលជាហេតុដកតណ្ហាចេញ ដែលខ្ញុំព្រះអង្គបានដឹងហើយ គប្បីជាអ្នកមានសតិឆ្លងតណ្ហា ក៏ជាប់ស្អិតនៅក្នុងលោកនេះ ដល់ខ្ញុំព្រះអង្គ ?

ព្រះដ៏មានបុណ្យទ្រង់ព្យាករណ៍ថា ជនពួកណោះបានដឹងថា និព្វានជាទីបន្ទោរបង់នូវតម្រេកក្នុងអារម្មណ៍ ជាទីស្រឡាញ់. ដែលខ្លួនបានឃើញហើយ. បានស្តាប់ហើយ. បានហិតហើយ. បានភ្លក់ហើយ. បានពាល់ត្រូវហើយ. បានដឹងហើយដោយចិត្ត. ជាធម៌មិនប្រែប្រួល ដូច្នេះហើយជាអ្នកមានស្មារតី. មានធម៌បានឃើញហើយរំលត់កិលេសបានហើយ. ជនណាស្ងប់រម្ងាប់កិលេសបានហើយនោះឯង តែឆ្លងគន្លងតណ្ហា ដែលនាំឱ្យជាប់នៅក្នុងលោកបានហើយ ។

ក្នុងទីបំផុតនៃបញ្ហាព្យាករណ៍ ហេមកមាណព ក៏បាន

www.elibraryofcambodia.org

សម្រេចព្រះអរហត្ត ព្រមដោយចតុប្បដិសម្ភិទាញាណ ហើយក្រាបទូលសូមបព្វជ្ជាឧបសម្បទា ។ ព្រះបរមគ្រូក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទាជាមួយនឹងពួកជាសមានាចារ្យ ក្នុងគ្រាសោឡសបញ្ហាព្យាករណ៍ ។ ព្រះហេមកត្ថេរមានជន្មាយុក្នុងព្រះសាសនា ដោយសមគួរដល់កាលកំណត់ហើយ ទើបបរិនិព្វាន ។

## ២៦. ប្រវត្តិព្រះតោទេយ្យត្ថេរ

ព្រះតោទេយ្យត្ថេរ ជាបុត្រព្រាហ្មណ៍ត្រកូលមួយ ក្នុងក្រុងសាវត្ថី កាលមានវ័យចំរើនធំឡើង បានទៅនៅសិក្សាលទ្ធិក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

កាលហេមកមាណព ក្រាបទូលសួរប្រស្នា បានស្តាប់ធម្មទេសនាជាគម្រប់ ៩ តទៅថា :

កាមទាំងឡាយមិនបានឋិតនៅក្នុងបុគ្គលណា, តណ្ហារបស់ណាមិនមាន, ហើយបុគ្គលណាឆ្លងកន្លងផុត សេចក្តីសង្ស័យបានហើយ ការផុតរហូតរបស់បុគ្គលនោះតើដូចម្តេច ?

ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ព្យាករណ៍ថា ការផុតរហូតរបស់បុគ្គលនោះ នឹងក្លាយទៅជាយ៉ាងដទៃទៀត មិនមានឡើយ (អធិប្បាយថា : បុគ្គលនោះផុតចាកកាម, ចាកតណ្ហា ចាកសេចក្តី

www.elibraryofcambodia.org

សង្ស័យក្តី អាចនឹងត្រឡប់កើតឡើងវិញ ហើយអ្នកនោះត្រូវព្យាយាមធ្វើឱ្យផុតរបូត របស់បុគ្គលនោះខ្ជាប់ខ្ជួនមិនមានប្រែប្រួលឡើយ ។

បុគ្គលនោះ ជាអ្នកមានចំណងឬគ្មានទេ, ជាអ្នកមានបញ្ញាមែនពិត ឬគ្រាន់ជាអ្នកបង្កតណ្ហា និងទិដ្ឋិឱ្យកើតឡើងដោយបញ្ញា, តើខ្ញុំព្រះអង្គនឹងស្គាល់មុនីនោះដូចម្តេច សូមព្រះអង្គត្រាស់ប្រាប់ដល់ខ្ញុំព្រះអង្គ ។

- បុគ្គលនោះឥតចំណងរន្ធះអន្ទែង, ជាអ្នកមានបញ្ញាមែន, មិនមែនជាអ្នកបង្កទិដ្ឋិ និងតណ្ហាឱ្យកើតឡើងដោយបញ្ញាទេ, ចូរអ្នកស្គាល់មុនីនោះថា ជាអ្នកឥតកង្វល់ មិនជាប់ជំពាក់នៅក្នុងកាមភពដូច្នេះចុះ ។

ក្នុងទីបំផុតនៃបញ្ហាព្យាករណ៍ តោទេយ្យមាណពបានសម្រេចអរហត្ត ព្រមទាំងចតុប្បដិសម្ភិទាញាណ ទើបក្រាបបង្គំទូលសូមឧបសម្បទក្នុងព្រះធម្មវិន័យ ។ សម្តេចព្រះសុគតទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុដោយឯហិភិក្ខុឧបសម្បទា ព្រមជាមួយនិងពួកមាណពទាំងនោះ ក្នុងវេលាចប់សោឡសបញ្ហាព្យាករណ៍ ។ ព្រះតោទេយ្យត្ថេរ មានជន្មាយុក្នុងព្រះសាសនាដោយសមគួរដល់កាលកំណត់ហើយ ក៏រំលត់ខន្ធបរិនិព្វាន ។

www.elibraryofcambodia.org

# ២៧- ប្រវត្តិព្រះកប្បត្ថេរ

ព្រះកប្បត្ថេរជាបុត្រព្រាហ្មណ៍ម្នាក់នៅក្នុងក្រុងសាវត្ថីកាលចំរើនវ័យឡើង បានទៅសិក្សាក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

កាលតោទេយ្យមាណព ក្រាបទូលប្រស្នាបានស្តាប់ព្រះធម្មទេសនា សម្រេចអរហត្តហើយ ទើបកប្បមាណពបានឱកាសក្រាបទូលសួរប្រស្នាគំរប់ ១០ ដូចតទៅថា :

សូមព្រះអង្គត្រាស់ប្រាប់ធម៌ ដែលជាទីពឹងពំនាក់នៃជនដែលមានជរា និងមរណៈមកដល់ជុំវិញដូចជាកោះជាទីស្នាក់អាស្រ័យ នៃជនអ្នកឋិតនៅនាកណ្តាលសាគរ ដែលមានរលកគគ្រាំគគ្រេងគួរស្ញែងខ្លាច ដល់ខ្ញុំព្រះអង្គ កុំឱ្យទុក្ខនេះកើតឡើងទៀតបាន ។

ព្រះឈ្មោះមារទ្រង់ព្យាករណ៍ថា តថាគតពោលថានិព្វានគ្មានកិលេសគ្រឿងកង្វល់, មិនមានតណ្ហាជាគ្រឿងប្រកាន់មាំ, ជាទីអស់ទៅនៃជរា និងមរណៈនេះឯង បីដូចជាកោះមិនមែនធម៌ដទៃផ្សេងៗ ទេ, ជនពួកណាស្គាល់និព្វាននោះហើយ, ជាអ្នកមានសតិ, មានធម៌បានឃើញហើយ, រំលត់កិលេសបានហើយ ជនពួកនោះមិនបានធ្លាក់ទៅក្នុងអំណាចនៃមារ, មិនបាច់ដើរក្នុងផ្លូវនៃមារឡើយ ។

www.elibraryofcambodia.org

វេលាចប់បញ្ហាព្យាករណ៍ កប្បមាណពបានសម្រេចអរហត្ត ព្រមទាំងចតុប្បដិសម្ភិទាញាណ ទើបក្រាបថ្វាយបង្គំសូមឧបសម្ប័ទ ។ ព្រះដ៏មានបុណ្យក៏អនុញ្ញាតឱ្យបានជាភិក្ខុដោយឯហិភិក្ខុឧបសម្ប័ទ ព្រមជាមួយនិងពួកមាណពទាំងនោះ ក្នុងខណៈចប់សោឡសបញ្ហាព្យាករណ៍ ។ ព្រះកប្បត្ថេរ មានជន្មាយុក្នុងព្រះសាសនាដល់សមគួរ ដល់កាលកំណត់ហើយ ក៏រំលត់ខន្ធចូលកាន់បរិនិព្វាន ។

## ២៨- ប្រវត្តិព្រះជតុកណ្ណិត្ថេរ

ព្រះជតុកណ្ណិត្ថេរ ជាបុត្រព្រាហ្មណ៍ត្រកូលមួយក្នុងនគរសាវត្ថី មានឈ្មោះថាជតុកណ្ណិមាណពបានទៅសិក្សាលទ្ធិ ក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

កាលកប្បមាណពក្រាបទូលសួរប្រស្នា បានស្តាប់ព្រះធម៌ទេសនាសម្រេចអរហត្តហើយ ទើបជតុកណ្ណិមាណពបានឱកាសក្រាបទូលសួរប្រស្នាជា [illegible]

ខ្ញុំព្រះអង្គបាន [illegible] ព្រះអង្គ [illegible] មិនជាអ្នកប្រាថ្នាកាម ឆ្លងអន្លង់កិលេស [illegible] ហើយ ទើបខ្ញុំមកក្រាបថ្វាយបង្គំគាល់ទូលសួរព្រះអង្គ [illegible] សូមព្រះដ៏មានជោគមានបញ្ញា [illegible] ចក្ខុកើតឡើងព្រមទាំងសេចក្តីត្រាស់ដឹង, សូម

www.elibraryofcambodia.org

ព្រះអង្គទ្រង់សំដែងធម៌ជាគ្រឿងរម្ងាប់កិលេស ដល់ខ្ញុំព្រះអង្គ. ព្រោះហេតុថាព្រះអង្គទ្រង់ផ្ចាញ់កិលេសកាម ឱ្យស្ងួតស្ងប់ទៅ ហាក់ដូចដួងអាទិត្យកំដៅផែនដីឱ្យហែងហួងទៅដោយស្មើ. សូមព្រះអង្គដ៏មានបញ្ញាធំទូលាយដូចផែនដី ទ្រង់ព្រះមេត្តាប្រោសសំដែងធម៌ ជាគ្រឿងលះបង់នូវជាតិជរា ក្នុងអត្តភាពដែលព្រះអង្គចេះគួរដឹងដល់ខ្ញុំព្រះអង្គមានបញ្ញាតិផងចុះ ?

ព្រះបរមសាស្ដាទ្រង់ព្យាករណ៍ថា ចូរអ្នកនាំយកតម្រេកក្នុងកាមចេញឱ្យអស់ ហើយឃើញការចេញចាកកាមជាសភាវៈក្សេមក្សាន្តចុះ. កិលេសជាគ្រឿងកង្វល់ ដែលអ្នកធ្លាប់តោងស្អិតដោយតណ្ហា និងទិដ្ឋិ ដែលបានលះបង់ចេញ កុំឱ្យចាកដោតដោយចិត្តរបស់អ្នក. កង្វល់ឯណាធ្លាប់មានមកហើយក្នុងកាលមុន. ចូរអ្នកញុំាងកង្វល់នោះឱ្យហែងហួតស្ងួតទៅ. កង្វល់ជាខាងក្រោយកុំមានដល់មកទៀត. បើអ្នកមិនប្រកាន់យកនូវកង្វល់កណ្ដាលទេ. អ្នកនឹងបានជាអ្នកស្ងប់ស្ងាត់កង្វល់ត្រេចទៅ. អាសវក្កិលេសដែលជាហេតុឱ្យលុះក្នុងអំណាចមច្ចុរាជ របស់ជនអ្នកប្រាសចាកតម្រេក ក្នុងនាមរូបដោយអាការៈទាំងពួង មិនគប្បីមានឡើយ ។

ក្នុងឱកាសចប់បញ្ហាព្យាករណ៍ ជតុកណ្ណិមាណពក៏បានសម្រេចអរហត្តផល ព្រមទាំងចតុប្បដិសម្ភិទាញាណ ទើបក្រាប

www.elibraryofcambodia.org

បង្គំទូលសូមឧបសម្បទ ។ ព្រះបរមគ្រូក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទា ព្រមទាំងពួកមាណពទាំងនោះក្នុងវេលាចប់សោឡសបញ្ហាព្យាករណ៍ ។

ព្រះជតុកណ្ណិកត្ថេរ មានជីវិតក្នុងព្រះសាសនាត្រាតែសមគួរដល់កំណត់អាយុសង្ខារ ហើយទើបបរិនិព្វាន ។

## ២៩. ប្រវត្តិព្រះភទ្រាវុធត្ថេរ

ព្រះភទ្រាវុធត្ថេរ កើតក្នុងត្រកូលព្រាហ្មណ៍មួយ នាក្រុងសាវត្ថី កាលមានវ័យចំរើនឡើង បានទៅសិក្សាចំណេះវិជ្ជាក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

កាលព្រះបរមគ្រូទ្រង់ដោះស្រាយប្រស្នា របស់ជតុកណ្ណិមាណពរួចហើយ, ទើបភទ្រាវុធមាណពបានឱកាសក្រាបទូលសួរប្រស្នាជាគំរប់ ១២ តទៅថា :

ខ្ញុំព្រះអង្គសូមក្រាបទូល អារាធនាព្រះអង្គ ទ្រង់លះបង់អាល័យកាត់ផ្ដាច់នូវតណ្ហាបានហើយ, មិនទ្រង់ញាប់ញ័រ ( ព្រោះលោកធម៌ ) លះបង់សេចក្ដីរីករាយចេញហើយ ទ្រង់លះបង់ធម៌ជាគ្រឿងត្រិះរិះ (ផ្សេងៗ) គឺ តណ្ហានិងទិដ្ឋិហើយ មានព្រះប្រាជ្ញាញាណដ៏ថ្លៃថ្លា ជន នៅជនបទផ្សេងៗ បានស្ដាប់សព្ទព្រះវាចារបស់ព្រះអង្គហើយ និងត្រឡប់ចេញទៅអំពីទីនេះ សូមព្រះអង្គ

www.elibraryofcambodia.org

ទ្រង់ដោះស្រាយប្រស្នា ដើម្បីជនទាំងនោះ ព្រោះថាធម៌នោះព្រះអង្គទ្រង់ជ្រាបបានហើយ ?

ព្រះបរមសាស្តាទ្រង់ព្យាករណ៍ថា ពពួកជនទាំងនោះគួរនាំចេញនូវតណ្ហា ដែលជាហេតុប្រកាន់មាំទាំងខាងលើ ទាំងខាងក្រោម និងចំណែកកណ្តាលឱ្យអស់ទៅ ព្រោះបុគ្គលប្រកាន់មាំនូវរបស់អ្វីៗ ក្នុងលោក, មាររមែងត្រាច់ទៅតាមបុគ្គលនោះដោយសាររបស់នោះ ហេតុនេះ កាលបើភិក្ខុបានដឹង ឃើញពពួកសត្វដែលជាប់នៅក្នុងវដ្ត ជាទីអាស្រ័យនៃមារថា ការជាប់ជំពាក់ព្រោះអាស្រ័យសេចក្តីប្រកាន់មាំដូច្នេះ គប្បីជាអ្នកមានសតិមិនប្រកាន់មាំឥតកង្វល់ក្នុងលោកទាំងពួង ។

ក្នុងទីបំផុតនៃព្យាករណ៍ ភទ្រាវុធមាណពបានសម្រេចអរហត្ត ព្រមទាំងចតុប្បដិសម្ភិទាញាណ ទើបក្រាបបង្គំទូលសូមឧបសម្បទ ។ ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទា ព្រមជាមួយនិងពួកមាណពទាំងនោះក្នុងទីបំផុតនៃសោឡសបញ្ហាព្យាករណ៍ ។

ព្រះភទ្រាវុធត្ថេរ ឋិតនៅក្នុងព្រះសាសនា ត្រាតែដល់កំណត់អាយុសង្ខារ ហើយក៏រំលត់ខន្ធចូលបរិនិព្វាន ។

www.elibraryofcambodia.org

## ៣០- ប្រវត្តិព្រះឧទយត្ថេរ

ព្រះឧទយត្ថេរ ជាបុត្រព្រាហ្មណ៍នៅក្រុងសាវត្ថី កាលមានវ័យចំរើនឡើង បានចេញទៅរៀនសូត្រក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

លុះភទ្រាវុធមាណព ក្រាបទូលសួរប្រស្នា បានស្តាប់ព្រះធម្មទេសនាសម្រេចព្រះអរហត្តហើយ ទើបឧទយមាណពបានឱកាសក្រាបបង្គំទូលសួរប្រស្នាជាគំរប់ ១៣ សេចក្តីថា :

ខ្ញុំព្រះអង្គមានបំណងនិងក្រាបទូលសួរប្រស្នា ទើបចូលមកថ្វាយបង្គំគាល់ព្រះអង្គទ្រង់គង់បំពេញឈាន, មានព្រះសន្តានប្រាសចាកកិលេសធូលី, គ្មានអាសវៈ, ទ្រង់ធ្វើកិច្ចដែលត្រូវធ្វើរួចហើយ, ទ្រង់ដល់នូវត្រើយនៃធម៌ទាំងពួង, សូមព្រះអង្គទ្រង់សំដែងធម៌ជាគ្រឿងផុត (ចាកកិលេស) ដែលគួរដឹងទូទៅ ជាគ្រឿងរំលាយបង់នូវអវិជ្ជាគឺសេចក្តីល្ងង់ខ្លៅ មិនដឹងច្បាស់តាមពិតនោះ ?

ព្រះបរមគ្រូទ្រង់ព្យាករណ៍ថា តថាគតពោលនូវធម៌ជាគ្រឿងលះបង់នូវសេចក្តីត្រេកអរក្នុងកាម និងទោមនស្សទាំងពីរយ៉ាង, ជាគ្រឿងបន្ទោរបង់នូវងងុយងោក, ជាគ្រឿងរាំងរានូវសេចក្តីរំខាន, មានឧបេក្ខា និងសតិជាធម៌បរិសុទ្ធ, មានសេចក្តី

www.elibraryofcambodia.org

ត្រិះរិះប្រកបដោយធម៌ថាជាធម៌បំផុត (ចាកកិលេស) ដែលគួរដឹងទូទៅ, ជាគ្រឿងរំលាយបង់នូវអវិជ្ជា សេចក្ដីល្ងង់ខ្លៅមិនដឹងច្បាស់ ។

. លោកមានអ្វីចងទុក, អ្វីជាគ្រឿងត្រាច់ទៅរបស់លោកនេះ, ដែលលោកពោលថា និព្វានៗ ដូច្នេះព្រោះលះអ្វីចេញបាន?

. លោកមានការរីករាយភ្លើតភ្លើនចងទុក, សេចក្ដីត្រិះរិះជាគ្រឿងត្រាច់ទៅនៃលោកនេះ, លោកពោលថា និព្វានៗ ដូច្នេះព្រោះលះតណ្ហាចេញបាន ។

. កាលបុគ្គលមានសតិនឹករឭកដូចម្ដេច ទើបវិញ្ញាណរលត់ទៅ ខ្ញុំព្រះអង្គទាំងឡាយនាំគ្នាចូលមកគាល់ព្រះអង្គ ដើម្បីទូលសួរព្រះអង្គ ,,សូមឱ្យខ្ញុំព្រះអង្គ បានស្ដាប់ព្រះវាចារបស់ព្រះអង្គ ។

. កាលបុគ្គលមិនរីករាយ និងវេទនាទាំងខាងក្នុងទាំងខាងក្រៅ មានសតិយ៉ាងនេះ ទើបវិញ្ញាណរបស់គេរលត់ទៅ ។

. វេលាចប់បញ្ហាព្យាករណ៍ ឧទយមាណព បានសម្រេចអរហត្ត ព្រមទាំងចតុប្បដិសម្ភិទាញាណ ទើបក្រាបបង្គំទូលសូមឧបសម្បទ ក្នុងព្រះសាសនា ។ ព្រះបរមសាស្ដាទ្រង់អនុញ្ញាត ឱ្យបានជាភិក្ខុដោយឯហិភិក្ខុឧបសម្បទា ជាមួយនិងពួកមាណព ជា

www.elibraryofcambodia.org

សមានាចារ្យក្នុងវេលាចប់សោឡសបញ្ហាព្យាករណ៍ ។ ព្រះឧទយត្ថេរមានជីវិត នៅក្នុងសាសនាត្រាតែដល់កំណត់អាយុសង្ខារ ទើបលោករំលត់ខន្ធចូលកាន់បរិនិព្វាន ។

## ៣១. ប្រវត្តិព្រះបោសាលត្ថេរ

ព្រះបោសាលត្ថេរ ជាបុត្រព្រាហ្មណ៍នៅក្រុងសាវត្ថី មាននាមថា បោសាលមាណព បានចំរើនវ័យឡើងបានទៅនៅសិក្សាលទ្ធិក្នុងសំណាក់ព្រាហ្មណ៍ពាវរី ។ល។

កាលឧទយមាណព ក្រាបទូលសួរប្រស្នា បានស្តាប់ព្រះធម្មទេសនាសម្រេចអរហត្តហើយ ទើបបោសាលមាណព បានឱកាសក្រាបទូលសួរប្រស្នាជាគំរប់ ១៤ តទៅថា :

ខ្ញុំព្រះអង្គមានបំណងនឹងទូលសួរប្រស្នា ទើបចូលមកគាល់ព្រះអង្គជាអ្នកទ្រង់សំដែងនូវព្រះប្រាជ្ញាញាណ ក្នុងអតីតកាល, មិនទ្រង់រំភើប (ដោយសុខទុក្ខ) ទ្រង់បានកាត់ផ្តាច់សេចក្តីសង្ស័យហើយ, ទ្រង់ដល់ត្រើយនៃធម៌ទាំងពួងហើយ, ខ្ញុំព្រះអង្គសូមទូលសួរ អំពីញាណរបស់បុគ្គលអ្នកមានតម្រេកសំគាល់ក្នុងរូបជាក់ច្បាស់ (គឺបានឈានហើយលះរូបារម្មណ៍ទាំងពួងបានហើយ គឺកន្លងផុតរូបជ្ឈានហើយ) មើលឃើញទាំងខាងក្នុងទាំងខាងក្រៅថា មិនមានអ្វីបន្តិចបន្តួច (គឺលុះដល់រូបជ្ឈាន ដែល

www.elibraryofcambodia.org

ហៅថា អាកិញ្ចញ្ញាយតនជ្ឈាន) តើបុគ្គលដូច្នេះ គួរនឹងណែនាំទូន្មាន ឱ្យធ្វើដូចម្ដេចតទៅទៀត ?

ព្រះបរមសាស្ដាទ្រង់ព្យាករណ៍ថា តថាគតទ្រង់ជ្រាបភូមិជាទីតាំងនៃវិញ្ញាណទាំងអស់ ទើបទ្រង់ជ្រាបបុគ្គលដូច្នេះ ទោះបីឋិតនៅក្នុងលោកនេះ ថាមានអាធ្យាស្រ័យបង្អោនទៅក្នុងអាកិញ្ចញ្ញាយតនភព មានអាកិញ្ចញ្ញាយតនភពជាទីប្រព្រឹត្តទៅខាងមុខ. បុគ្គលដូច្នោះនឹងថាកម្មជាហេតុឱ្យកើត ក្នុងអាកិញ្ចញ្ញាយតនភព មានសេចក្ដីត្រេកអរីករីករាយ ជាគ្រឿងប្រកបដូច្នេះហើយ. លំដាប់នោះឯង តែពិចារណាឃើញសហជាតិធម៌ក្នុងអាកិញ្ចញ្ញាយតនជ្ឈាននោះ (គឺធម៌ដែលកើតព្រមគ្នា និងលោកនេះនឹងជាក់ច្បាស់ដោយលក្ខណៈទាំង ៣ (គឺមិនទៀង ជាទុក្ខ. មិនមែនខ្លួន) ខនេះជាញាណដ៏ពិតប្រាកដរបស់ព្រាហ្មណ៍នោះ អ្នកមានព្រហ្មចរិយធម៌បានប្រព្រឹត្តចប់ហើយ ។

ក្នុងទីបំផុតនៃបញ្ហាព្យាករណ៍ បោសាលមាណពសម្រេចអរហត្ត ព្រមទាំងចតុប្បដិសម្ភិទាញាណ ទើបក្រាបទូលសូមឧបសម្បទ ។

ព្រះដ៏មានបុណ្យទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុដូចន័យមុន ។ ព្រះបាសាលត្ថេរ គង់នៅក្នុងព្រះសាសនា ត្រាតែសមគួរដល់

www.elibraryofcambodia.org

កំណត់អាយុសង្ខា ទើបលោករំលត់ខន្ធចូលកាន់និព្វាន ។

## ៣២. ប្រវត្តិព្រះមោឃរាជត្ថេរ

(ទ្រទ្រង់ ចីវរសៅហ្មង)

ព្រះមោឃរាជត្ថេរ ជាបុត្រព្រាហ្មណ៍ត្រកូល១ ក្នុងក្រុងសាវត្ថី មាននាមថាមោឃរាជមាណព កាលមានវ័យចំរើនឡើងបានធ្វើខ្លួនជាសិស្ស ក្នុងសំណាក់ព្រាហ្មណ៍ពាវរី ដ៏ជាមហាបុរោហិតនៃព្រះបាទកោសលរាជ។ អំណើះកាលតមក ព្រាហ្មណ៍ពាវរីមានសេចក្តីនឿយណាយខាងផ្លូវឃរាវាស ទើបក្រាបទូលលាព្រះមហាក្សត្រ ចេញពីដំណែងបុរោហិត ហើយទៅបួសជាជដិល តាំងអាស្រមនៅនាឆ្នេរស្ទឹងគោធាវរី។ ព្រំប្រទល់ដែននៃស្រុកអស្សកៈ និងស្រុកអាលកៈ ។

មោឃរាជមាណព ព្រមទាំងពួកសិស្សជាសមានាចារ្យ ក៏នាំគ្នាទៅបួសតាមអាចារ្យ ។

លុះព្រះពុទ្ធជាម្ចាស់ ទ្រង់ឧប្បត្តិឡើងក្នុងលោក មានព្រះកិត្តិគុណល្បីខ្ចរខ្ចាយសាយចេញទៅក្នុងទិសតំបន់ផ្សេងៗ ។ ព្រាហ្មណ៍បានជ្រាបកិត្តិស័ព្ទ ក៏នឹកងឿងឆ្ងល់មានបំណងចង់ស៊ើបឱ្យដឹងការពិត ទើបចងជាប្រស្នាឱ្យមាណពជាសិស្ស ១៦ នាក់ មានអជិតមាណពជាប្រធាន ក្នុងម្នាក់មួយវគ្គៗ ឱ្យនាំយកទៅ

www.elibraryofcambodia.org

ក្រាបទូលសួរល្បងមើល មោឃរាជមាណពក៏នៅក្នុងចំនួននេះដែរ បាននាំគ្នាព្រមទាំងបរិវារ ចូលទៅគាល់ព្រះបរមសាស្ដាឯបាសាណចេតិយ ដែនមគធៈរដ្ឋ ក្រាបទូលសូមព្រះឱកាសសួរប្រស្នាម្នាក់ម្ដង១ កាលព្រះដ៏មានបុណ្យទ្រង់អនុញ្ញាតហើយ បានដោះស្រាយប្រស្នារបស់អជិតមាណព ជាលើកដំបូងចប់ហើយ មោឃរាជមាណព ប្រារព្ធ និងទូលសួរប្រស្នាជាលំដាប់តទៅ ។ មានសេចក្ដីដំណាលថា មោឃរាជមាណពនេះ ប្រកាន់ខ្លួនថាជាអ្នកមានប្រាជ្ញាឆើតជាងគេ គិតចង់ទូលសួរមុន ប៉ុន្តែនឹកក្រែងចិត្តអជិតមាណពដែលជាធំជាង ទើបបណ្ដោយអជិតមាណពទូលសួរមុន ។ ព្រះបរមគ្រូទ្រង់ទតឃើញអាការៈដូច្នេះ ទើបត្រាស់ឃាត់មោឃមាណពឱ្យបង្អង់សិន ។ លុះមាណពដទៃទៀតនាំគ្នាក្រាបទូលសួរប្រស្នាទៅដោយលំដាប់លំដោយដល់ ៨ នាក់ហើយ មោឃរាជមាណពប្រារព្ធនឹងទូលសួរទៀត ព្រះអង្គក៏ត្រាស់ហាមឃាត់ឱ្យបង្អង់សិនទៀត ។ កាលមាណពទាំងឡាយក្រាបទូលសួរហួសទៅ ៦ នាក់ទៀតហើយ ទើបមោឃរាជមាណពបានឱកាសទូលសួរប្រស្នារគំរប់ ១៥ សេចក្ដីថា :

ខ្ញុំព្រះអង្គនឹងពិចារណាឃើញ លោកដូចម្ដេចទើបស្ដេចមច្ចុរាជមើលគឺថាតាមមិនទាន់ ?

www.elibraryofcambodia.org

ព្រះពិជិតមារទ្រង់ព្យាករណ៍ថា ម្នាលមោឃរាជ, ចូរអ្នកមានសតិពិចារណាឃើញលោកថា ជាសភាវៈសាបសូន្យទទេ ដកអត្តានុទិដ្ឋិចេញគ្រប់ខណៈចុះ, អ្នកនឹងឆ្លងកន្លងមច្ចុរាជចេញទៅបានដោយឧបាយយ៉ាងនេះ, បើពិចារណាឃើញលោកយ៉ាងនេះ ទើបមច្ចុរាជមើលមិនឃើញ ។

ក្នុងវេលាចប់បញ្ហាព្យាករណ៍ មោឃរាជមាណពបានសម្រេចអរហត្ត ព្រមទាំងបរិវារ ហើយក្រាបបង្គំទូល សូមឧបសម្បទ ក្នុងព្រះសាសនា ។ ព្រះបរមសាស្តាទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុដូចន័យមុន ។

ព្រះមោឃរាជត្ថេរនេះ ចាប់តាំងពីបានឧបសម្បទមក លោកតែងទ្រទ្រង់ចីវរប្រកបដោយសៅហ្មង ៣ យ៉ាង គឺសំពត់សៅហ្មង, ដេរក៏សៅហ្មងជ្រលក់ក៏សៅហ្មង ហេតុនេះទើបព្រះបរមគ្រូ កាលទ្រង់ប្រថាប់ក្នុងព្រះជេតវនមហាវិហារ បានទ្រង់តាំងមោឃរាជត្ថេរ ក្នុងឯតទគ្គៈគឺជាកំពូលនៃភិក្ខុទាំងឡាយដែលទ្រង់ចីវរសៅហ្មង ។ លោកគង់នៅក្នុងសាសនា សមគួរដល់កំណត់អាយុហើយ ក៏រំលត់ខន្ធបរិនិព្វាន ។

www.elibraryofcambodia.org

# ៣៣- ប្រវត្តិព្រះបិង្គិយត្ថេរ

ព្រះបិង្គិយត្ថេរ កើតក្នុងត្រកូលព្រាហ្មណ៍មួយក្នុងក្រុងសាវត្ថី ត្រូវជាក្មួយរបស់ព្រាហ្មណ៍ពាវរី កាលចំរើនវ័យឡើងបានសិក្សាសិល្ប៍សាស្ត្រក្នុងសំណាក់ឪពុកធំ ។ មានសេចក្តីដំណាលថា ព្រាហ្មណ៍ពាវរីនេះ ធ្វើជាបុរោហិតនៃព្រះបាទកោសលរាជ ។ តមកសម័យក្រោយ ព្រាហ្មណ៍ពាវរី បានក្រាបទូលលាព្រះមហាក្សត្រចេញទៅបួសតាមលទ្ធិព្រាហ្មណ៍ តាំងអាស្រមនៅឆ្នេរស្ទឹងគោធាវរី នាទីព្រំប្រទល់ស្រុកអស្សកៈ និងស្រុកកាលកៈ ។ល។

មោឃរាជមាណពក្រាបទូលសួរប្រស្នា បានស្តាប់ព្រះធម្មទេសនាសម្រេចអរហត្តហើយ ទើបបិង្គិយមាណពក្រាបទូលសួរប្រស្នាជាគំរប់ ១៦ តទៅថា :

ខ្ញុំព្រះអង្គជាមនុស្សចាស់ហើយ មិនមានកម្លាំងអស់សម្បុរផូរផង់ហើយ, ភ្នែករបស់ខ្ញុំព្រះអង្គក៏មើលមិនឃើញច្បាស់, ត្រចៀកក៏ស្តាប់មិនបានស្រួល, សូមកុំឱ្យព្រះអង្គសាបសូន្យក្នុងចន្លោះឡើយ សូមព្រះអង្គត្រាស់សំដែងធម៌ដែលខ្ញុំព្រះអង្គគួរចេះដឹង ជាគ្រឿងលះបង់នូវជាតិជរាក្នុងអត្តភាពនេះ ។

ព្រះបរមសាស្តាទ្រង់ព្យាករណ៍ថា អ្នកឃើញថាជនទាំងឡាយប្រមាទហើយ រមែងក្តៅក្រហាយព្រោះរូបជាហេតុ ហេតុ

www.elibraryofcambodia.org

នេះចូរអ្នកកុំបីប្រមាទលះបង់សេចក្តីគាប់ចិត្តក្នុងរូបចេញ ទើបមិនបាច់កើតទៀត ។

ទិសធំបួន ទិសតូចបួនជាដប់ទាំងទិសខាងលើ ខាងក្រោម ដែលព្រះអង្គមិនបានឃើញហើយ មិនបានឮហើយ មិនបានជ្រាបហើយ, សូម្បីតែបន្តិចបន្តួចក៏មិនមានក្នុងលោក, សូមព្រះអង្គត្រាស់ប្រាប់ធម៌ដែលខ្ញុំព្រះអង្គគួរចេះដឹង ជាគ្រឿងលះជាតិជរាក្នុងអត្តភាពនេះ ?

កាលបើអ្នក[illegible] [illegible]ណ្ហាគ្របសង្កត់ហើយ, មានសេចក្តី[illegible] មានជរាចោមរោមហើយ, ហេតុនោះ[illegible] [illegible]ញ្ញាពេញអ្នកនឹងមិនបាច់កើតទៀត ។

វេលាចប់បញ្ហា[illegible] [illegible]សម្រេចធម្មចក្ខុថ្នាក់សោតាបត្តិផល ហេតុដែលបិង្គិយមាណពមិនបានសម្រេចអរហត្ត ក្នុងខណៈនោះ ព្រោះមានគំនិតគិតដល់ព្រាហ្មណ៍ពាវរីជាអាចារ្យ ក្នុងខណៈស្តាប់ធម្មទេសនា ដោយនឹកស្តាយថាឳពុកធំពុំបានស្តាប់ព្រះធម្មទេស[illegible]ពិរោះយើងនេះសោះ ។ អាស្រ័យទោសដែលកើតចិត្តរា[illegible]ដូច្នេះ ទើបមិនអាចធ្វើចិត្តឱ្យផុតចាកអាសវៈទៅបាន ។ លំដាប់នោះបិង្គិយមាណពក៏បានក្រាប

www.elibraryofcambodia.org

ទូលសូមឧបសម្បទ ។ ព្រះបរមគ្រូក៏ទ្រង់អនុញ្ញាតឱ្យបានជាភិក្ខុ ដោយឯហិភិក្ខុឧបសម្បទា ជាមួយនិងមាណព ១៥ នាក់ទៀត ។

លោកបិង្គិយភិក្ខុ បានក្រាបថ្វាយបង្គំលាព្រះបរមគ្រូ ត្រឡប់ទៅថ្លែងពត៌មានដល់ព្រាហ្មណ៍ពាវរីជាអាចារ្យ ។ សម័យក្រោយមក លោកបានស្តាប់ព្រះបរមពុទ្ធោវាទ ទើបធ្វើចិត្តឱ្យផុតចាកអាសវក្កិលេសទាំងពួង ។ ចំណែកឯព្រាហ្មណ៍ពាវរីបានលុះធម្មាភិសម័យត្រឹមថ្នាក់សេខភូមិ ។ ព្រះបិង្គិយត្ថេរមានជន្មាយុក្នុងព្រះសាសនា គួរដល់កាលកំណត់ហើយក៏បរិនិព្វាន ។

ស-·តមកតើព្រះសាស្តាទ្រង់ប្រោសជនណាទៀត ? នៅឯណា ?

ច- បន្ទាប់ពីនោះមក ព្រះបរមសាស្តាទ្រង់បានប្រោសរាធព្រាហ្មណ៍ នៅក្នុងនគររាជគ្រឹះទៀត ។

## ៣៤- ប្រវត្តិរបស់រាធត្ថេរ

(បដិភាណមានញាណភ្លឺច្បាស់ក្នុងធម្មទេសនា)

រាធត្ថេរ ជាបុត្រនៃព្រាហ្មណ៍ម្នាក់ក្នុងក្រុងរាជគ្រឹះ ដែនមគធៈ ។ កាលរាធនេះចាស់ជរាហើយ ៗ ដោយគ្មានកូនប្រពន្ធនឹងបិញ្ជីម ក៏ចូលទៅនៅអាស្រ័យនឹងព្រះសង្ឃក្នុងវត្តវេឡុវ័នហើយក៏មានបំណងបួសក្នុងសំណាក់ព្រះពុទ្ធសាសនា តែពួកភិក្ខុ

www.elibraryofcambodia.org

ទាំងឡាយមិនព្រមឱ្យបួសទេ ព្រោះយល់ថារាធនេះមិនអាចនឹងប្រព្រឹត្តវត្តប្រតិបត្តិ ក្នុងព្រះពុទ្ធសាសនាតទៅបាន ។ ម្ល៉ោះហើយរាធព្រាហ្មណ៍ ក៏មានទុក្ខរហូតទល់ស្គមស្គាំងរាងកាយអស់ ។

តមក រាធព្រាហ្មណ៍ដោយចង់បួសពេក ក៏ចូលទៅក្រាបថ្វាយបង្គំទូលព្រះសាស្តា ហើយថ្លែងប្រាប់គោលបំណងរបស់ខ្លួនក្នុងការចង់បួស ព្រះសាស្តាទ្រង់ទតឃើញឧបនិស្ស័យរាធព្រាហ្មណ៍ ក៏ទ្រង់អនុញ្ញាតឱ្យបួសក្នុងសំណាក់ព្រះសារីបុត្ត ។ ព្រះសាស្តាទ្រង់ក៏បញ្ញត្តិមិនឱ្យភិក្ខុបំបួសកុលបុត្រ ដោយត្រៃសរណគមនូបសម្បទា ហើយទ្រង់អនុញ្ញាតដោយវិធីញត្តិចតុត្ថកម្មវាចាវិញ ។ រាធៈបានបួសដោយវិធីនេះជាដំបូងបំផុត ។

ពេលមួយ រាធភិក្ខុបានចូលទៅគាល់ព្រះមានព្រះភាគ ហើយក្រាបទូលព្រះអង្គថា សូមព្រះអង្គទ្រង់សំដែងធម៌ដល់ខ្ញុំព្រះអង្គយ៉ាងសង្ខេបចុះ ខ្ញុំព្រះអង្គនឹងបានស្តាប់រួចនឹងចៀសចេញចាកពួកគណៈ ទៅនៅតែម្នាក់ឯង ហើយនិងលះបង់សេចក្តីប្រមាទចោល ដោយការតាំងនៅក្នុងភាវនា ។ ព្រះសាស្តាទ្រង់ទូន្មានថា ម្នាលរាធៈ របស់ឯណាជាមារ ចូរអ្នកលះសេចក្តីត្រេកត្រអាលពេញចិត្តក្នុងរបស់នោះចេញ. ចុះអ្វីទៅជាមារ ? រូបវេទនា. សញ្ញាសង្ខារ. វិញ្ញាណ ដែលមិនទៀងជាទុក្ខ មិនមែន

www.elibraryofcambodia.org

ជារបស់ខ្លួនតែអស់សាបសូន្យទៅ នឹងកើតឡើងរួចទៅជាធម្មតា ឈ្មោះថាមារ, ម្នាលរាធៈ ចូរអ្នកលះសេចក្ដីគាប់ចិត្តក្នុងរូប, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណនោះចោលចេញ ។

រាធត្ថេរ បានទទួលព្រះពុទ្ធោវាទនោះហើយ ក៏ត្រាច់តាមព្រះសារីបុត្តទៅកាន់ទីផ្សេងៗ រួចខំចំរើនធម៌រហូតបានសម្រេចព្រះអរហត្តផល ទើបព្រះសារីបុត្តនាំចូលទៅគាល់ព្រះសាស្ដា ។ ទ្រង់ត្រាស់សួរថា សទ្ធិវិហារិករបស់អ្នក មានលក្ខណៈដូចម្ដេចខ្លះ ? ព្រះសារីបុត្តបានក្រាបទូលសរសើររាធត្ថេរថា ជាមនុស្សងាយប្រដៅណាស់ បើណែនាំទូន្មានថា ការនេះគួរធ្វើ ការនោះមិនគួរធ្វើ ចូរអ្នកធ្វើការនេះ កុំធ្វើការនោះជាដើម ក៏មិនដែលខឹងឡើយ ។ ព្រះសាស្ដាក៏ទ្រង់ទូន្មានពួកភិក្ខុទាំងឡាយឱ្យប្រកាន់យកជាគំរូតួយ៉ាងថា អ្នកទាំងឡាយចូរធ្វើខ្លួនឱ្យជាអ្នកប្រដៅងាយដូចរាធៈនេះចុះ បើព្រះឧបជ្ឈាយ៍បានចង្អុលប្រាប់ទោស ទូន្មានអ្នកៗកុំខឹង គួរគប់បណ្ឌិតដែលខ្លួនសំគាល់ឃើញថាជាអ្នកបង្ហាញទោសពោលសង្កត់សង្កិន ហាក់ដូចជាចង្អុលប្រាប់កំណប់ទ្រព្យឱ្យព្រោះការគប់នឹងជនជាបណ្ឌិតដូច្នេះ មានតែគុណគាប់ប្រសើរគ្មានទោសឡើយ ។

ដោយហេតុថា រាធត្ថេរជាអ្នកប្រដៅងាយយ៉ាងក្រៃលែង

www.elibraryofcambodia.org

ទើបពេលក្រោយមក លោកបានទទួលសេចក្ដីសរសើរអំពីព្រះសាស្ដាថា ជាអ្នកប្រសើរលើសភិក្ខុទាំងឡាយ ប៉ែកខាងបដិភាណ គឺមានញាណភ្លឺច្បាស់ក្នុងព្រះធម្មទេសនា អាចសំដែងធម៌ដែលព្រះសាស្ដាទ្រង់សំដែងហើយនោះបានយ៉ាងពិស្ដារ ។

ព្រះរាធត្ថេរ មានព្រះជន្មក្នុងព្រះពុទ្ធសាសនាដល់គំណត់ហើយ ក៏រំលត់ខន្ធចូលកាន់បរិនិព្វានទៅ ។

ស- តមក តើព្រះសាស្ដាបានប្រោសសាវ័កណាទៀត ? នៅទីណា ? មានប្រវត្តិយ៉ាងណាដែរ ?

ច- ព្រះសាស្ដាបានប្រោសបុណ្ណៈជាកូននាង មន្តានីព្រាហ្មណី នៅស្រុក១ ឈ្មោះទោណវត្ថុ ជិតក្រុងកបិលព័ស្ដុទៀត បុណ្ណៈនេះបានមកជួបព្រះសាស្ដាឯនគររាជគ្រឹះ ។

## ៣៥- ប្រវត្តិព្រះបុណ្ណមន្តានីបុត្តត្ថេរ

(ធម្មកថិក)

ព្រះបុណ្ណៈនេះ កើតក្នុងត្រកូលព្រាហ្មណ៍មហាសាល ក្នុងស្រុកព្រាហ្មណ៍ឈ្មោះទោណព័ស្ដុ ជិតក្រុងកបិលព័ស្ដុ ជាបុត្តនាងព្រាហ្មណីឈ្មោះមន្តានី ដែលជាប្អូនស្រីនៃព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ។

មានសេចក្ដីដំណាលថា កាលព្រះអញ្ញាកោណ្ឌញ្ញត្ថេរជា

www.elibraryofcambodia.org

ឪពុកធំនិមន្តទៅកាន់ក្រុងកបិលព័ស្តុ ដើម្បីសាកសួរសុខទុក្ខក្រុមគ្រួសាររបស់លោកនោះ លោកក៏បាននាំក្មួយ១ ឈ្មោះបុណ្ណៈជាកូននៃប្អូនស្រីឈ្មោះនាងមន្តានី ឱ្យចូលបួសក្នុងព្រះពុទ្ធសាសនា រួចបុណ្ណភិក្ខុ ក៏និមន្តទៅក្នុងប្រទេសមួយឈ្មោះជាតិភូមិ នៅតាំងចំរើនធម៌ មិនយូរប៉ុន្មានក៏បានសម្រេចព្រះអរហត្តផល ព្រមទាំងបដិសម្ភិទាញាណ ហើយលោកក៏តែងតាំងនៅក្នុងគុណធម៌ ១០ ប្រការជានិច្ច គឺប្រាថ្នាតិច១, សន្តោស១, ពេញចិត្តនឹងទីស្ងាត់ដោយការមិននៅច្រឡូកច្របល់នឹងពួកគណៈ១, ប្រារព្ធសេចក្តីព្យាយាម១, បរិបូណ៌ដោយសីល១, សមាធិ១, បញ្ញា១, វិមុត្តិ១, វិមុត្តិញ្ញាណ១ ។ បើលោកមានបរិស័ទ ក៏លោកតែងទូន្មានឱ្យស្ថិតនៅធម៌ ១០ យ៉ាងនេះដែរ ក្នុងជាតិភូមិនោះ លោកបានធ្វើជាឧបជ្ឈាយ៍បំបួសកុលបុត្តប្រហែល ៥០០ នាក់ ហើយទូន្មានដឹកនាំភិក្ខុទាំងនោះ ឱ្យស្ថិតនៅក្នុងគុណធម៌ ១០ ប្រការនេះជានិច្ច ។

នៅពេល១ ព្រះបរមគ្រូទ្រង់យាងចេញពីនគររាជគ្រឹះទៅនគរសាវត្ថី ព្រះបុណ្ណមន្តានីបុត្តត្ថេរ បានជ្រាបដំណឹង ក៏ចូលទៅក្រាបបង្គំស្តាប់ធម្មទេសនា ហើយក៏ថ្វាយបង្គំលាទៅគង់ឯព្រៃស្ងាត់ ដើម្បីសំរាកក្នុងពេលថ្ងៃ ។ ព្រះសារីបុត្តបានជ្រាបដំណឹងហើយ ក៏ចូលទៅរកព្រះបុណ្ណៈរួចបានធ្វើការរាក់ទាក់ទៅវិញទៅ

www.elibraryofcambodia.org

មក ហើយក៏បានសួរអំពីវិសុទ្ធិ ៧ ប្រការចំពោះបុណ្ណត្ថេរ ។ បាន ឆ្លើយដោយប្រៀបធៀបទៅនឹងរាជរថ ឥតមានជាប់ជំពាក់ឡើយ

ព្រះបុណ្ណមន្តានីបុត្តត្ថេរនេះ ដំកល់ខ្លួននៅក្នុងគុណធម៌ដូចម្តេច ក៏លោកទូន្មានអ្នកដទៃឱ្យតាំងនៅក្នុងគុណធម៌ដូច្នោះដែរ ។ ដូច្នេះហើយបានជាព្រះសាស្តាទ្រង់តាំងដំកើងព្រះបុណ្ណត្ថេរក្នុងដំណែងឯតទគ្គៈគឺជាកំពូលនៃភិក្ខុទាំងឡាយខាងធម្មថិក។

ព្រះបុណ្ណមន្តានីបុត្តត្ថេរ កាលមានព្រះជន្មដល់កំណត់ ហើយក៏ចូលបរិនិព្វានទៅ ។

៥. កាលព្រះសាស្តាគង់នៅរាជគ្រឹះនោះ ព្រះអង្គបាន ប្រោសជនណាដែលជាសហជាតិជាមួយព្រះអង្គដែរ ? មានប្រវត្តិ យ៉ាងណា ?

ច. ព្រះអង្គបានប្រោសកាឡុទាយីអាមាត្យ ដែលបានកើត ក្នុងថ្ងៃជាមួយនឹងព្រះអង្គ ហើយជាអាមាត្យទី ១០ ដែលព្រះបាទ សិរីសុទ្ធោទនៈ ពុទ្ធបិតាទ្រង់បញ្ជូនទៅឱ្យនិមន្តព្រះសាស្តា ។

## ៣៦. ប្រវត្តិកាឡុទាយិត្ថេរ

(អ្នកញុំាងត្រកូល ដែលមិនទាន់ជ្រះថ្លា ឱ្យជ្រះថ្លា)

កាឡុទាយិត្ថេរ ជាបុត្តនៃអាមាត្យនៅក្រុងកបិលព័ស្តុ លោកកើតក្នុងថ្ងៃជាមួយគ្នា នឹងព្រះសិទ្ធត្ថពោធិសត្វ គឺជាសហ-

www.elibraryofcambodia.org

ជាតិរបស់ព្រះសាស្តា ។

កាឡុទាយី កាលដើមឈ្មោះឧទាយី ព្រោះជាទីរីករាយនៃអ្នកស្រុក តមកមានឈ្មោះថា កាឡុទាយី ព្រោះលោកមានសម្បុរខ្មៅ ។ កាលចំរើនវ័យហើយ លោកក៏បានថ្វាយខ្លួនជាមហាតលិករបស់ព្រះពោធិសត្វជាមួយឆន្នៈ ដែលជាសហជាតិដែរ ។

នៅពេលដែលព្រះសាស្តា បានត្រាស់ដឹងជាព្រះពុទ្ធ គង់នៅក្រុងរាជគ្រឹះនោះ ព្រះបាទសិរីសុទ្ធោទនៈ ពុទ្ធបិតាទ្រង់ជ្រាបដំណឹង ក៏បញ្ជូនអាមាត្យម្តងមួយៗ អស់ ៩ ដង ដោយម្នាក់ៗមានបរិវារមួយពាន់ ។ ទៅកាន់រាជគ្រឹះ ដើម្បីនិមន្តសាស្តាឱ្យយាងទៅកាន់ក្រុងកបិលព័ស្តុ តែមិនបានសម្រេច ព្រោះលោកទាំងនោះបានបួសហើយភ្លេចភ្លាំងកិច្ចការរបស់ខ្លួនអស់ លុះដល់លើកទី១០ ព្រះរាជាបានបញ្ជូនកាឡុទាយីអាមាត្យ ដែលជានាយសារថី មានការស្និទ្ធស្នាលនឹងព្រះ ឱ្យនាំបរិវារ ១ ពាន់នាក់ទៀតទៅនិមន្តព្រះសាស្តា ។កាឡុទាយី បានក្រាបទូលសូមបួសផង លុះព្រះរាជាទ្រង់អនុញ្ញាតហើយ កាឡុទាយី ក៏ក្រាបថ្វាយបង្គំលាទៅ ។ កាលលោកទៅដល់បានជួបព្រះសាស្តាហើយបានស្តាប់ធម៌ បានសំរេចអរហត្តផលហើយ ក៏ចូលសូមបួសជាឯហិភិក្ខុក្នុងព្រះពុទ្ធសាសនានោះ ។ លុះដល់រដូវប្រាំង (ខែផល្គុណ) កាឡុទាយីត្ថេរបានចូល

www.elibraryofcambodia.org

ទៅក្រាបថ្វាយបង្គំនិមន្តព្រះសាស្តា ដើម្បីស្តេចយាងទៅកាន់ក្រុងកបិលព័ស្តុ តាមបណ្តាំព្រះបិតា ។ កាលព្រះសាស្តាទ្រង់យល់ព្រមហើយ កាឡុទាយិត្ថេរ ក៏និមន្តទៅមុន ដើម្បីថ្វាយពត៌មានចំពោះព្រះបាទសុទ្ធោទនៈ និងព្រះរាជវង្សានុវង្ស ។

កាលជ្រាបមិនដឹងថា លោកនិមន្តមកហើយ ពួកអ្នកនគរមានចិត្តរីករាយណាស់ នាំគ្នាទទួលយ៉ាងឧឡារិក ហើយកាឡុទាយិត្ថេរ ក៏ដឹកនាំសាក្យវង្សឱ្យជ្រះថ្លាក្នុងពុទ្ធសាសនា ។ ព្រះសាស្តាទ្រង់ប្រារព្ធដល់គុណសម្បត្តិនេះ ក៏តាំងលោកក្នុងដំណែងថាជាអ្នកប្រសើរលើសភិក្ខុទាំងឡាយ ប៉ែកខាងញ៉ាំងត្រកូលមិនទាន់ជ្រះថ្លា ឱ្យជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ។

កាឡុទាយិត្ថេរ កាលមានព្រះជន្មសមគួរហើយ ក៏ចូលនិព្វានទៅ ។

www.elibraryofcambodia.org

# ភាគទី ១០

## ព្រះពុទ្ធដំណើរទៅកាន់ក្រុងកបិលពស្តុ ជាលើកដំបូង និងការប្រោសពួកសាក្យរាជ

ស- ព្រះសម្ពុទ្ធទ្រង់មានព្រះបំណងធំយ៉ាងណា បានជាមិនយាងទៅប្រោសព្រះពុទ្ធបិតា និងញាតិវង្សមុន ហើយបែរជាទ្រង់គង់នៅតែក្នុងដែនមគធៈយ៉ាងយូរម្ល៉េះ ? តើការគង់នៅនេះមានសារសំខាន់យ៉ាងណាខ្លះ ?

ច- ព្រះសម្ពុទ្ធបរមគ្រូ កាលទ្រង់បានត្រាស់ដឹងហើយទ្រង់មិនទាន់យាងទៅប្រោសពុទ្ធបិតា និងព្រះញាតិវង្សដែលមានព្រះជន្មនៅឯមាតុភូមិនៅឡើយភ្លាមៗទេ ។ ការធ្វើយ៉ាងនេះ គឺព្រះអង្គមានព្រះបំណងច្រើនប្រការដូចតទៅនេះ :

១- ទ្រង់ប្រោសសត្វទៅតាមឧបនិស្ស័យចាស់ខ្ចីហួរហែដូចជាកាលទ្រង់ដាក់ភារៈក្នុងព្រះទ័យថា នឹងប្រោសសត្វក្រោយពេលធ្វើពុទ្ធសកម្មភាពចំនួន ៤៩ ថ្ងៃ ក្នុងទី ៧ កន្លែងចប់ហើយទ្រង់ក៏ចាប់ប្រមើលមើលឧបនិស្ស័យសត្វ ហើយទ្រង់ឃើញតាបសពីរជាមុន បន្ទាប់មកទ្រង់ទតឃើញបញ្ចវគ្គិយភិក្ខុ នៅឯព្រៃឥសិបតនមិគទាយឯណោះ ហើយសូម្បីទីនោះឆ្ងាយដល់ទៅ ១៨ យោជន៍ ( ប្រហែល ១៥០ គីឡូម៉ែត្រពីទីត្រាស់ដឹង ) ក៏ដោយ

www.elibraryofcambodia.org

ក៏ព្រះអង្គប្រឹងយាងទៅប្រោសបញ្ចវគ្គិយភិក្ខុទាំងនោះ មុនគេដែរ

២. តមកទ្រង់យាងមកប្រោសព្រះបាទពិម្ពិសារ និងដើម្បីដោះសារពាក្យប្ដេជ្ញាជាមួយព្រះមហាក្សត្រអង្គនេះផង ។ តាមពិត ការយាងត្រឡប់មកកាន់ដែនមគធៈ ដើម្បីប្រោសព្រះបាទពិម្ពិសារនេះ ទ្រង់មានបំណងក្នុងព្រះទ័យយ៉ាងធំជាច្រើនទៀតគឺ

ក. ដោយព្រះអង្គទ្រង់យាងមកគង់ រកការត្រាស់ដឹងឃើញនៅក្នុងដែនមគធៈនេះ ហើយជាទី១ សម្បូរទៅដោយពួកព្រាហ្មណ៍ គហបតីសេដ្ឋី ដែលប្រកាន់ទិដ្ឋិមានៈរឹងត្អឹងណាស់ ថែមទាំងចេះសិល្បសាស្ត្រ យុទ្ធសាស្ត្រយ៉ាងខ្លាំងពូកែផង មិនតែប៉ុណ្ណោះសោត ជម្ពូទ្វីបភាគខាងជើង ត្រូវនៅក្រោមការត្រួតត្រារបស់ដែនមគធៈនេះទាំងអស់. ព្រះបាទពិម្ពិសារជាក្សត្រាធិរាជមានប្រទេសចំណុះច្រើនណាស់ សូម្បីតែដែនសក្កៈ ក្រុងកបិលព័ស្តុ ដែលជាជាតិភូមិនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ ក៏នៅក្រោមអំណាចចក្ររបស់ដែនមគធៈដែរ ពោលគឺព្រះបាទសុទ្ធោទនៈពុទ្ធបិតាជាសាមន្តរាជ របស់ព្រះបាទពិម្ពិសារនេះឯង ។ ដូច្នេះបើព្រះអង្គបានផ្សាយព្រះពុទ្ធសាសនា ឱ្យចាក់ឫសគល់ជ្រួតជ្រាបទូទៅ នៅក្នុងដែនមគធ និងលើប្រជាជនក្នុងដែននេះហើយ ក៏នឹងបានងាយស្រួលជាខាងក្រោយយ៉ាងច្រើន ព្រោះពួកក្សត្រ និង

www.elibraryofcambodia.org

ព្រាហ្មណ៍គហបតី បានបាក់ទិដ្ឋិមានះចុះចូលអស់ទៅហើយ ផងឯទៀតៗ នៅក្រោមអំណាចក៏នឹងខ្លាចទៅឯងៗ ដែលជាការងាយស្រួលបំផុត ។

ខ. ដោយដែនមគធៈនេះ ជាដែនដីទូលាយ មានមនុស្សកុះករ បរិបូណ៌ដោយស្បៀងអាហារ សូម្បីក្រោយពុទ្ធបរិនិព្វានហើយ ៣ ខែពួកសាវ័កនានា មានមហាកស្សបត្ថេរជាប្រធាន ក៏បានរៀបចំធ្វើបឋមសង្គាយនា នៅក្នុងដែនដីនេះដែរ ។ ព្រះពុទ្ធជាម្ចាស់ទ្រង់បានប្រកាសផ្សាយព្រះពុទ្ធសាសនា ឱ្យជ្រួតជ្រាបក្នុងទីដ៏ធំមានឥទ្ធានុភាពខ្លាំង មានស្បៀងអាហារច្រើន មានមនុស្សសំខាន់ៗ ដូចជាព្រះបាទពិម្ពិសារជាដើមផង ។

គ. ពុទ្ធបំណងដ៏ធំលើសនេះ គឺការប្រតិស្ឋានអារាម១ ដ៏សំខាន់គឺវត្តវេឡុវ័ន នៅជិតក្រុងរាជគ្រឹះ ការតែងតាំងអគ្គសាវ័កស្តាំ-ឆ្វេង បានដល់ព្រះសារីបុត្ត និងព្រះមោគ្គល្លាន ព្រមទាំងការប្រជុំធ្វើចតុរង្គមហាសាវ័កសន្និបាតនោះឯង ។

ដូច្នេះបានជាកាលទ្រង់បានត្រាស់ហើយ ទ្រង់ធ្វើពុទ្ធសកម្មអស់ ៩ ខែ (ពីថ្ងៃពេញបូរមី ខែពិសាខ រហូតទល់ថ្ងៃពេញបូរមីខែមាឃ) នៅតែក្នុងដែនមគធៈនោះ ពុទ្ធបំណងនេះបានសម្រេចតាមប្រាថ្នាមែន គឺបានត្រៀកជដិល ១០០៣ នាក់, ព្រះ

www.elibraryofcambodia.org

បាទពិម្ពិសារ (ជាជនសំខាន់ណាស់) តែងតាំងអគ្គសាវ័ក និង ប្រតិស្ឋានវត្តវេឡុវ័ន ដែលជាវត្តទី១ ក្នុងព្រះពុទ្ធសាសនា ឱ្យបាន ផ្សព្វផ្សាយទូទៅយ៉ាងឆាប់រហ័ស ព្រោះប្រទេសដ៏ធំ មហាក្សត្រ ដ៏មានឫទ្ធានុភាពខ្លាំងក្លា បានទទួលស្គាល់គោរពបូជាព្រះពុទ្ធ និង ព្រះពុទ្ធសាសនាទៅហើយ ប្រទេសតូច ក្សត្រឬប្រមុខរដ្ឋ មាន កម្លាំងតិច ក៏នឹងទទួលស្គាល់ជាខាងក្រោយមិនខាន ។

ស- ចុះព្រះសាស្ដាទ្រង់យាងទៅកាន់ក្រុងកបិលព័ស្ដុ ជា ជាតិភូមិព្រះអង្គ ដើម្បីប្រោសពុទ្ធបិតា និងញាតិវង្សនៅពេលណា ដោយមានអ្នកណាអារាធនាដែរ ឬទៅដោយព្រះអង្គឯង ?

ច- ព្រះសម្ពុទ្ធទ្រង់យាងទៅកាន់ក្រុងកបិលព័ស្ដុ ដើម្បី ប្រោសពុទ្ធបិតា និងព្រះញាតិវង្សដែរតីយាងទៅនៅថ្ងៃពេញបូរមី ខែផល្គុន ។ ការយាងទៅនេះ តាមសេចក្ដីដំណាលថា ដោយព្រះ បាទសិរីសុទ្ធោទនៈ ជាពុទ្ធបិតា បានឱ្យអាមាត្យទៅអារាធនានិមន្ត ដំបូងទ្រង់ចាត់ឱ្យអាមាត្យម្នាក់ នាំបរិវារ ១ ពាន់នាក់ទៅនិមន្ត ព្រះសាស្ដា អាមាត្យបាននាំបរិវារទៅ បានជួបនឹងព្រះសាស្ដា ក៏ នាំគ្នាបួស ហើយភ្លេចព្រះរាជបណ្ដាំអស់រលីង ។ ព្រះបាទសុទ្ធោ ទនៈ ទ្រង់បញ្ជូនអាមាត្យ ៨ នាក់ឱ្យទៅបន្ត១គ្នាទៀត អាមាត្យ ទាំង ៩ នាក់នាំបរិវារទៅ ៩ ពាន់ ក៏ទៅបួសហើយភ្លេចបណ្ដាំ

www.elibraryofcambodia.org

ទាំងអស់គ្នា ។ នៅលើកទី ១០ ព្រះបាទសុទ្ធោទនៈ ទ្រង់បញ្ជូនកាឡុទាយី (ជាអាមាត្យ ដែលកើតជំណាលគ្នានឹងព្រះសម្ពុទ្ធ) នាំបរិវារ ១ ពាន់នាក់ទៅទៀត ដើម្បីទូលអារាធនាព្រះអង្គឱ្យយាងទៅកាន់ក្រុងកបិលព័ស្តុ ។ កាឡុទាយីអាមាត្យ បាននាំបរិវារទៅដល់ក៏សុំបួសទៀត ប៉ុន្តែកាលបួសនេះហើយ ក៏នឹកឃើញព្រះរាជបណ្តាំ ទើបចូលទៅទូលអារាធនាសុំឱ្យព្រះអង្គយាងទៅកាន់ក្រុងកបិលព័ស្តុ ។

ស. កាលព្រះសាស្តាទ្រង់យាងទៅកាន់ក្រុងកបិលព័ស្តុនោះ ទ្រង់យាងទៅតែ១ ព្រះអង្គឯងទេ ឬយ៉ាងណា ? ទ្រង់ទៅគង់នៅទីណា ? ទ្រង់ធ្វើយ៉ាងណាខ្លះ ?

ច. ព្រះសាស្តាទ្រង់យាងទៅកាន់ក្រុងកបិលព័ស្តុ ជាលើកដំបូងនេះ គឺយាងទៅជាមួយព្រះអរហន្ត ២ ម៉ឺនអង្គជាបរិវារ ទ្រង់យាងទៅគង់នៅក្នុងឧទ្យាន១ ឈ្មោះនិគ្រោធ ។ ពេលនោះព្រះពុទ្ធបិតាក្តី ញាតិវង្សក្តី ឥតបានថ្វាយបង្គំព្រះអង្គទេ ព្រោះយល់ថាព្រះអង្គក្មេងជាង ។ ព្រះសាស្តាជ្រាបដូច្នោះ ក៏ធ្វើយមកប្បាដិហារ្យនិម្មិតទីចង្ក្រម ហើយនិម្មិតព្រះពុទ្ធរូប ១ ព្រះអង្គឱ្យធ្វើជាអ្នកឆ្លើយបញ្ហារបស់ព្រះអង្គ ព្រះបិតា និងពួកញាតិវង្សឃើញដូច្នោះ ក៏ថ្វាយបង្គំព្រះសាស្តា ។ ទ្រង់យាងចុះពីពុទ្ធាសនៈ ភ្លៀង

www.elibraryofcambodia.org

បោក្ខរពសី ក៏បង្អុរចុះយ៉ាងខ្លាំងលើទីប្រជុំនៃពពួកញាតិ ។ ភ្លៀងនោះ បើអ្នកណាចង់ឱ្យទទឹកក៏ទទឹកដែរ ដូចទឹកធ្លាក់លើស្លឹកឈូក ព្រះសាស្ដាទ្រង់ប្រារព្ធភ្លៀងនោះ ហើយទ្រង់សំដែងមហាវេស្សន្តរជាតក ប្រោសពពួកញាតិ ។

ស. ចុះកាលពេលព្រឹកឡើង និងថ្ងៃបន្តបន្ទាប់ទៅ តើព្រះសាស្ដាទ្រង់ប្រោសជនណាទៀត ចូរលើកប្រវត្តិនៃសាវ័កទាំងនោះផង ។

ច. ព្រឹកឡើងព្រះសាស្ដា ទ្រង់ត្រាច់បិណ្ឌបាត្រជាមួយសាវ័កក្នុងនគរ ព្រះបិតាឃើញដូច្នោះ នឹករៀនខ្មាសក៏ទ្រង់ឃាត់ "សូមព្រះអង្គកុំធ្វើដូច្នោះ ព្រោះពូជត្រកូលយើងមិនដែលធ្វើដូច្នោះទេ" ព្រះសាស្ដាទ្រង់ត្រាស់ថា "ការត្រាច់បិណ្ឌបាត្រនេះជាកិច្ចរបស់ព្រះពុទ្ធគ្រប់ព្រះអង្គ មិនមែនជាកិច្ចរបស់វង្សក្សត្រទេ" ព្រះបិតាកាលស្ដាប់ហើយ ក៏បានសម្រេចសោតាបត្តិផល ។

នៅថ្ងៃទី ៣ ព្រះអង្គទ្រង់ប្រោសនាងបជាបតិគោតមី ជាព្រះមាតាមីង ហើយដែលបានចិញ្ចឹមព្រះសាស្ដាកាលពីព្រះកុមារឱ្យស្ថិតនៅក្នុងសោតាបត្តិផល ឯព្រះបាទសុទ្ធោទនៈ ក៏ស្ថិតនៅក្នុងសកិទាគាមិផល ។

ថ្ងៃទី ៤ ពេលព្រឹកទ្រង់សំដែងធម្មបាលជាតកថ្វាយព្រះ

www.elibraryofcambodia.org

បិតា ៗ ក៏បានសម្រេចអនាគាមិផល តមកទ្រង់យាងទៅប្រោស នាងពិម្ពា ជាមួយនឹងពុទ្ធបិតា និងសាវ័ក ហើយសំដែងកិច្ចរី ជាតកប្រោសនាងពិម្ពា ៗ ក៏បានសម្រេចសោតាបត្តិផល ។

នៅថ្ងៃទី៥ ព្រះសាស្តាទ្រង់ប្រោសនន្ទជាអនុជរួមបិតាក្នុង ពេលដែលនន្ទនេះ កំពុងរៀបការជាមួយនាងជនបទកល្យាណី ។ ប្រវត្តិនន្ទនេះមានដូចតទៅ :

## ៣៧- ប្រវត្តិព្រះនន្ទត្ថេរ

(សង្រួមឥន្ទ្រីយ៍ទាំង ៦)

នន្ទត្ថេរ ជារាជឱរសនៃព្រះបាទសុទ្ធោទនៈពុទ្ធបិតា និង នាងគោតមី ជាអនុរួមបិតានិងព្រះសម្ពុទ្ធ មានព្រះជន្មតិចជាង ព្រះសម្ពុទ្ធតែ ២-៣ ថ្ងៃប៉ុណ្ណោះ កាលនៅក្នុងផ្ទៃព្រះមាតា ពួក ញាតិ[illegible]ត្តិរីករាយចង់ឃើញណាស់ ដូច្នេះបានជាកាលប្រសូត ហើយ ព្រះញាតិថ្វាយនាមថា នន្ទកុមារ ។

កាលព្រះសាស្តាទ្រង់យាងទៅក្រុងកបិលព័ស្តុ ជាលើក ដំបូង ហើយនៅថ្ងៃទី ៥ ពេលដែលនន្ទកំពុងរៀបមង្គលការ ជាមួយនាងជនបទកល្យាណី ព្រះសម្ពុទ្ធទ្រង់យាងទៅសោយភត្តា ក្នុងតំណាក់ព្រះនន្ទកុមារ លុះធ្វើភត្តានុមោទនារួចហើយ [illegible] [illegible]ទៅវិញ ទ្រង់ហុចបាត្រទៅនន្ទកុមារ ៗ ទទួលយក

www.elibraryofcambodia.org

ហើយ កាន់បាត្រនោះតាមព្រះអង្គទៅ ដោយគិតថា បើព្រះសម្ពុទ្ធទ្រង់ទទួលយកបាត្រក្នុងទីណាហើយ ខ្លួននឹងត្រឡប់មកពីទីណាក់វិញ ។ ឯនាងជនបទកល្យាណីបានឃើញដូច្នោះ ក៏ទូលផ្ដាំថា សូមព្រះអយ្យបុត្តប្រញាប់វិលមកវិញ ។

កាលព្រះសាស្ដាយាងទៅដល់និគ្រោធារាមហើយ ក៏សួរថា នន្ទឯងចង់បួសឬទេ ? នន្ទកុមារ ទោះបីមិនចង់បួសក៏ដោយ តែដោយមានសេចក្ដីគោរពព្រះសាស្ដាពេក ក៏ក្រាបទូលថាបួស។ ព្រះសាស្ដាក៏ឱ្យបំបួសនន្ទកុមារនោះទៅ ។

កាលនន្ទត្ថេរបួសហើយ លោកមានព្រះទ័យនឹករលឹកដល់នាងទេវី ដែលបានផ្ដាំមកនោះខ្លាំងណាស់ ក៏កើតចិត្តអផ្សុកនឿយណាយចង់សឹកទៅវិញ ។ ចំណែកព្រះសាស្ដាទ្រង់ជ្រាបរឿងនោះ ក៏នាំនន្ទភិក្ខុត្រាច់ទៅកាន់ចារិក ។ ហើយទៅឱ្យនន្ទភិក្ខុបានឃើញស្រ្តីមានរូបឆោមល្អជាងនាងទេវីនោះ ធ្វើឱ្យនន្ទកុមារលះបង់សេចក្ដីស្រឡាញ់ចំពោះនាងទេវីចេញ ហើយកើតចិត្តចង់បានស្រីល្អ ធើត១ តទៅទៀត រហូតទល់តែមានប្រាជ្ញាយល់ពិតថា ចំណង់ពុំមានទីបំផុតទេ ។ នន្ទភិក្ខុប្រឹងបន្ទោរបង់សេចក្ដីស្រឡាញ់ចេញ ហើយបំពេញសេចក្ដីព្យាយាម ដោយមិនប្រហែសធ្វេសរហូតបានសម្រេចអរហត្តផល ។

www.elibraryofcambodia.org

ព្រះសាស្តាឃើញដូច្នោះ ក៏បានលើកតម្កើងសរសើរនន្ទត្ថេរថា ជាអ្នកប្រសើរលើសភិក្ខុទាំងឡាយ ខាងសង្រួមរក្សាឥន្ទ្រីយ៍ទាំង ៦ មិនឱ្យមានសេចក្តីត្រេកអរ ឬទោមនស្សកើតឡើងដោយអំណាចលោកធម៌ហើយ ជាអ្នកប្រកបដោយបដិភាណផង ។

ព្រះនន្ទត្ថេរ លុះមានព្រះជន្មដល់កំណត់ហើយ ក៏បរិនិព្វានទៅ ដោយអនុបាទិសេសនិព្វានធាតុ ។

ស-ចុះដល់ថ្ងៃណាទើបព្រះអង្គទ្រង់ប្រោសជនណាទៀត? ចូរលើកប្រវត្តិជននោះផង !

ច- នៅថ្ងៃទី ៧ ព្រះសាស្តាទ្រង់បានបញ្ជាឱ្យសារីបុត្តត្ថេរបំបួសរាហុលកុមារ ជាបុត្ររបស់ព្រះអង្គឱ្យទៅជាសាមណេរ ដែលមានព្រះជន្មទើបបាន ៧ ឆ្នាំហើយនៅពេលដែលនាងពិម្ពាបញ្ជូនឱ្យទៅសុំកំណប់ទ្រព្យអំពីព្រះអង្គជាព្រះបិតា ។

## ៣៨- ប្រវត្តិព្រះរាហុលត្ថេរ

(អ្នកប្រាថ្នាក្នុងការសិក្សាធម្មវិន័យ)

ព្រះរាហុលជាបុត្រព្រះសម្ពុទ្ធ និងនាងពិម្ពា កាលនៅជាឃរាវាស ហើយរាហុលនេះទ្រង់ប្រសូត្រពីថ្ងៃ ពេលអាត្រាតុព្រះបិតាទ្រង់យាងចេញទៅសាងព្រះផ្នួស ។

www.elibraryofcambodia.org

នៅថ្ងៃទី ៧ ពេលដែលព្រះអង្គគង់នៅនិគ្រោធារាម ព្រះនាងពិម្ពាបានបញ្ជូនរាហុលកុមារ ឱ្យទៅសុំកំណប់ទ្រព្យពីព្រះសម្ពុទ្ធជាបិតា ។ ព្រះសាស្តាទ្រង់មានព្រះតម្រិះថា ទ្រព្យធនជារបស់គ្មានខ្លឹមសារឱ្យរឹងប៉ឹងឡើយ មានតែអរិយទ្រព្យទេ ទើបប្រសើរថ្លៃថ្លា។ ទ្រង់ព្រះតម្រិះរួចក៏សំដែងអរិយទ្រព្យ ៧ ប្រការឱ្យ រាហុលកុមារស្តាប់ ហើយឱ្យព្រះសារីបុត្តបំបួសរាហុលជាសាមណេរព្រោះលោកទើបនឹងមានព្រះជន្ម ៧ វស្សាប៉ុណ្ណោះ ។ រាហុលនេះហើយ ជាសាមណេរដំបូងបង្អស់ក្នុងព្រះពុទ្ធសាសនា

កាលបានបួសជាសាមណេរហើយ រាហុលមានការពេញចិត្តនឹងសិក្សាធម្មវិន័យ ហើយអត់ធន់ចំពោះពាក្យប្រៀនប្រដៅណាស់ ។ លុះព្រះជន្មបាន ១៨ ព្រះវស្សា មានឥន្ទ្រីយចាស់ហើយក៏បានស្តាប់ធម្មទេសនា អំពីរាហុលោវាទសូត្រ ពីសំណាក់ព្រះសាស្តា ។ លោកតែងត្រាច់តាមព្រះសាស្តា និងព្រះសារីបុត្តជានិច្ច លុះព្រះជន្ម ២០ វស្សាហើយ ក៏បានទទួលឧបសម្បទាជាភិក្ខុ ។

ថ្ងៃមួយ រាហុលត្ថេរ គង់នៅព្រៃស្វាយ១ ជិតក្រុងរាជគ្រឹះពេលនោះព្រះសាស្តាទ្រង់យាងទៅដល់ ព្រះរាហុលក៏យកភាជនៈទឹកទៅលាងព្រះបាទព្រះសាស្តា១ ទ្រង់លើកភាជនៈទឹកឡើង

www.elibraryofcambodia.org

ហើយត្រាស់សួរថា ម្នាលរាហុល បាបានឃើញភាជនៈនេះគ្មានទឹកទេ រាហុលទូលថា សូមទ្រង់មេត្តាប្រោស គ្មានទឹកទេ ព្រះសាស្តាត្រាស់ថា ភាជនៈនេះមានលក្ខណៈសភាពយ៉ាងណា សមណគុណរបស់ជនគ្មានខ្មាស់ ក្នុងការថ្លែងពោលពាក្យភូតភរ ក៏មានសភាពសោះទទេយ៉ាងនោះដែរ ។ អ្នកណាគ្មានខ្មាសក្នុងការថ្លែងពោលពាក្យកុហក អ្នកនោះមិនដែលមិនធ្វើអាក្រក់ណា១ឡើយ ។ ដូច្នេះ ចូរបាសិក្សាថា អញនឹងមិននិយាយកុហកឡើយ។ ម្នាលរាហុល ចុះកញ្ចក់មានប្រយោជន៍ដូចម្តេច ? ក្រាបទូលមានប្រយោជន៍សម្រាប់ឆ្លុះ ! - អើ ! កញ្ចក់នេះ មានប្រយោជន៍យ៉ាងណា ប្រាជ្ញាក៏មានប្រយោជន៍ចំរាប់ឆ្លុះយ៉ាងនោះដែរ ។ល។

ថ្ងៃមួយព្រះរាហុល បានចូលទៅគាល់ព្រះសាស្តា១ ទ្រង់ទូន្មានក្នុងរូបកម្មដ្ឋានគឺ ទឹក, ដី, ភ្លើង, ខ្យល់, អាកាសធាតុថា របស់ទាំងនេះ មានទាំងខាងក្នុងខាងក្រៅ ។ របស់ឯណាប្រព្រឹត្តទៅចំពោះខ្លួន ដែលបុគ្គលចាត់ទុកថាជារបស់ខ្លួន របស់នោះហៅថាធាតុខាងក្នុង ។ ធាតុទាំង ៥ ខាងក្នុងក្តី ខាងក្រៅក្តី ក៏គ្រាន់តែជាធាតុម្យ៉ាង១ ប៉ុណ្ណោះ ។ល។

តមកព្រះសាស្តាទ្រង់ត្រាស់ទូន្មាន ក្នុងរូបកម្មដ្ឋានយ៉ាងនេះហើយ ក៏ត្រាស់ទូន្មានក្នុងព្រហ្មវិហារ និងកម្មដ្ឋានដទៃទៀត

www.elibraryofcambodia.org

ថា ម្នាលរាហុល ចារថ្មរចំរើនភាវនាគឺ មេត្តា, ករុណា, មុទិតា, ឧបេក្ខា ហើយលះសេចក្ដីព្យាបាទអ្នកដទៃបានដោយមេត្តា, លះ ផស្សក្រ គឺរឺសោ...មិនត្រេកអរដោយមុទិតា, លះសេចក្ដីគាប់ចិត្ត នឹងរើ...ចិត្តដោយចំរើនឧបេក្ខា, លះតម្រេកត្រេកត្រអាលក្នុង ...ទិ...ដៃ ដោយការចំរើនអសុភ, លះមានះ គឺសេចក្ដី ...ដោយចំរើនអនិច្ចសញ្ញា ។ល។

...ហើយ ព្រះរាហុលភិក្ខុក៏មានចិត្តត្រេកអរ ទទួលព្រះបរមពុទ្ធោវាទនោះហើយ ក្រោយមកលោកបានស្ដាប់ ឱវាទដែលទ្រង់ទូន្មានខាងវិបស្សនា ដែលទ្រង់លើកយកអាយតនៈ ខាងក្រៅ និងខាងក្នុងមកសំដែងថា ជារបស់អនត្តា ។ល។ ព្រះ រាហុលបានស្ដាប់ហើយ បញ្ជូនចិត្តទៅតាមក្រសែធម៌នោះ ហើយ ក៏បានសម្រេចអរហត្តផល ។

ព្រះសាស្ដាដោយទតឃើញរាហុលត្ថេរ ថាជាអ្នកពេញចិត្ត ក្នុងការសិក្សាធម្មវិន័យ តាំង...ជាសាមណេរមក ដូច្នេះក៏បាន លើកតម្កើងថា ជាឯតទគ្គៈ ខាងការប្រាថ្នាសិក្សាធម្មវិន័យ ។ លុះ មានព្រះជន្មចាស់ជរាហើយ ក៏បរិនិព្វានក្នុងស្ថានតាវត្តិង្ស ។

៩៨. កាលតៗ មក ...សាស្ដាបានប្រោសសាវ័ក សំខាន់ៗណាទៀត នៅទីណា? ជននោះត្រូវជាអ្វីនឹងព្រះសាស្ដា?

www.elibraryofcambodia.org

ចូរលើកប្រវត្តិសាវ័កទាំងនោះផង ។

ច- ក្នុងកាលជាខាងក្រោយមក ព្រះសាស្តាទ្រង់គង់នៅក្នុងអនុបិយម្ពវ័ន ទ្រង់បានប្រោសក្សត្រ ៦ អង្គគឺ ភទ្ទិយ១, អនុរុទ្ធ១, ភគុ១, កិមិល១, អានន្ទ១, ទេវទត្ត១, ដែលជាព្រះញាតិរបស់ព្រះអង្គ ព្រមទាំងខ្មាន់ព្រះកេសម្នាក់ឈ្មោះ ឧបាលី ផង ។ ដោយក្សត្រទាំង ៦ អង្គនេះមានមានៈខ្លាំង ក៏បានបញ្ជូន ឧបាលិ ជាខ្មាន់ព្រះកេស គឺជាជាងកាត់សក់ ឱ្យទៅបួសមុន ។

## ៣៩- ប្រវត្តិព្រះឧបាលិត្ថេរ

(ទ្រទ្រង់ព្រះវិន័យបិដក)

ព្រះឧបាលិត្ថេរ ជាកូនជាងកាត់សក់ កើតក្នុងក្រុងកបិល-ព័ស្តុ ។ កាលធំពេញវ័យហើយ ក៏បានជាទីសព្វព្រះទ័យនៃពួកក្សត្រសាក្យវង្សណាស់ ហើយបានទទួលមុខងារជាអ្នកសំអិតសំអាងកាយ នៃរាជវង្សសាក្យតមក ។

កាលព្រះសាស្តាគង់នៅក្នុងអនុបិយម្ពវ័ន ពួកសាក្យៈទាំង ៦ អង្គ បាននាំគ្នាទៅបួស ឯឧបាលិក៏ទៅជាមួយដែរ ប៉ុន្តែដោយពួកក្សត្រមានមានៈច្រើន ក៏ឱ្យបាលិទៅបួសមុនក្សត្រ ៦ អង្គ លុះបានបួសហើយ លោកក៏ប្រឹងចំរើនវិបស្សនាកម្មដ្ឋាន រហូតទល់បានសម្រេចអរហត្តផល មានប្រាជ្ញាបែកធ្លុះធ្លាយក្នុងព្រះវិន័យ

www.elibraryofcambodia.org

បិដក ។ ពេលខាងក្រោយមក ព្រះឧបាលិត្ថេរ បានទទួលមុខងារ ជាអ្នកជម្រះវត្ថុ ៣ ប្រការគឺ ភារុកច្ឆកវត្ថុ ១, អជ្ជុកវត្ថុ១ និង កុមារកស្សបវត្ថុ១ នឹងព្រះបរមសាស្តា ៗ ទ្រង់វិនិច្ឆ័យវត្ថុទាំង ៣ ប្រការនេះឱ្យជា[illegible] ហើយបានតាំងព្រះឧបាលិត្ថេរជាឯតទគ្គ ប៉ែកខាងទ្រទ្រង់វិន័យបិដក ។

នៅពេលព្រះសាស្តាបរិនិព្វានទៅបាន ៣ ខែ សង្ឃបាន ប្រជុំគ្នា ធ្វើបឋមសង្គាយនានៅក្រុងរាជគ្រឹះ ការកសង្ឃក៏បាន ប្រគេននាទីទៅព្រះឧបាលិត្ថេរឱ្យជាអ្នកឆ្លើយវិន័យបិដក ។

កាលលោកមានព្រះជន្មជរាហើយ ក៏បរិនិព្វានទៅដោយ អនុបាទិសេសនិព្វានធាតុ ។

## ៤០- ប្រវត្តិព្រះភទ្ទិយត្ថេរសាក្យរាជ

(មានត្រកូលខ្ពង់ខ្ពស់)

ព្រះភទ្ទិយ ជារាជបុត្តព្រះនាង កាឡិគោធាសាក្យកញ្ញា ក្នុងត្រកូលក្សត្រ ក្រុងកបិលព័ស្តុ ។ កាលលោកមានវ័យល្មម ហើយក៏បានទទួលរាជាភិសេកក្នុងរាជសម្បត្តិ លុះតមកព្រះអនុរុទ្ធ ជាសម្លាញ់ ក៏ដឹកនាំឱ្យទៅបួសក្នុងសំណាក់ព្រះពុទ្ធសាសនា ជាមួយក្សត្រ ៥ អង្គទៀតគឺ អនុរុទ្ធ, កិមិល, អានន្ទ, ទេវទត្ត, ភគុ ក្នុងពេលដែលព្រះសាស្តាគង់នៅ អនុបិយម្ពវ័នក្នុងដែនមល្ល: ។

www.elibraryofcambodia.org

កាលបានទទួលឧបសម្បទាហើយភទ្ទិយភិក្ខុ ក៏ប្រឹងព្យាយាមចំរើនធម៌ រហូតបានសម្រេចអរហត្តក្នុងវស្សា ដែលទ្រង់សាងផ្នួសនោះ ។ កាលលោកបានសម្រេចធម៌យ៉ាងនេះហើយ ទោះបីលោកនៅក្នុងទីណាក៏ដោយ' ក៏លោកតែងបន្លឺឧទានវាចាថា សុខណាស់ហ្ន ៗ ជារឿយ ។ ពួកភិក្ខុទាំងឡាយឮហើយ ក៏យកពាក្យនោះទៅទូលព្រះដ៏មានព្រះភាគ ៗ ទ្រង់ត្រាស់ហៅភទ្ទិយត្ថេរមកសួរ ភទ្ទិយបានបន្លឺវាចាដូច្នោះមែនឬ ? ព្រះភទ្ទិយបានទូលព្រះសាស្តាថា ទូលព្រះបង្គំបានបន្លឺយ៉ាងនេះមែន ។ ព្រះសាស្តាត្រាស់សួរថាហេតុដូចម្តេច បានជាលោកបន្លឺវាចាយ៉ាងនេះ ? - បានជាខ្ញុំព្រះអង្គបន្លឺព្រះវាចាយ៉ាងនេះ ព្រោះកាលខ្ញុំព្រះអង្គនៅជាក្សត្រគ្រងរាជ្យ ទោះបានចាត់ការឱ្យការពារយ៉ាងណា៎ ក៏នៅតែភ័យខ្លាចជានិច្ច លុះឥឡូវ ទោះខ្ញុំព្រះអង្គនៅទីណាក៏ឥតភ័យតក់ស្លុតឡើយ ព្រះសាស្តាទ្រង់ប្រទានពរថា ល្អហើយល្អហើយ លុះដល់ពេល១ ព្រះសាស្តាទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ក៏ប្រទានឋានៈដល់ព្រះភទ្ទិយត្ថេរថា ជាអ្នកមានត្រកូលខ្ពស់ ព្រោះលោកបានប្រាថ្នាដំណែងនេះ តាំងពីអតីតកាលយូរយារណាស់មកហើយ បានជាព្រះអង្គទ្រង់ប្រទានយ៉ាងនេះ ។

ព្រះភទ្ទិយត្ថេរ កាលមានព្រះជន្មល្មមក្នុងព្រះពុទ្ធសាសនា

www.elibraryofcambodia.org

ហើយ ក៏បរិនិព្វានទៅ ។

## ៤១. ប្រវត្តិព្រះអនុរុទ្ធត្ថេរ

( មានទិព្វចក្ខុ )

ព្រះអនុរុទ្ធ ជាបុត្រព្រះអមិតោទន អនុជព្រះបាទសុទ្ធោទន ពុទ្ធបិតា ។ លោកមានព្រះរៀមនាម មហានាម និងប្អូនស្រី១ ឈ្មោះនាងរោហិណី ហើយត្រូវជាអនុជជីដូន១ នឹងព្រះសាស្តា។ លោកជាអ្នកប្រកបដោយសុខុមាលភាពយ៉ាងក្រៃលែង សូម្បីតែពាក្យថា "គ្មាន" ក៏លោកមិនដែលឮឡើយ ។

ព្រះអនុរុទ្ធ កាលបានបួសហើយក៏រៀនព្រះកម្មដ្ឋានក្នុងសំណាក់ព្រះសារីបុត្ត ហើយក៏និមន្តទៅកាន់បាចីនវង្សមិគទាយវ័ន ហើយខំចំរើនសមណធម៌ ព្រមទាំងបានស្តាប់ព្រះឱវាទព្រះដ៏មានបុណ្យ ក៏បានសម្រេចព្រះអរហត្តផល។ មានសេចក្តីដំណាលថា ថ្ងៃមួយពួកភិក្ខុទាំងឡាយ បានចូលទៅរកលោក ហើយបានសួរថាលោកដ៏មានអាយុ បានដល់ភាវៈ ព្រោះបានចំរើនធម៌អ្វី ? ព្រះអនុរុទ្ធឆ្លើយថា ខ្ញុំបានចំរើនសតិបដ្ឋាន ៤ រួចលោកពោលសរសើរអ្នកដែលចំរើនសតិបដ្ឋាន ៤ ឱ្យភិក្ខុទាំងឡាយស្តាប់ ដោយឧបមាដូចទន្លេគង្គា ដែលហូរទៅទិសខាងកើត ពួកជនតែងនាំគ្នាមកដោយសេចក្តីសង្ឃឹមថា នឹងទប់ឱ្យត្រឡប់ហូរទៅ

www.elibraryofcambodia.org

ក្រោយវិញ តើអ្នកទាំងឡាយសំគាល់សេចក្តីនេះដូចម្តេច តើនឹងធ្វើដូច្នោះបានឬទេ ? គេធ្វើមិនកើតឡើយ ព្រោះទន្លេគង្គា ដែលហូរទៅទិសខាងកើតនោះ នឹងមិនហូរត្រឡប់វិញឡើយ ឯមហាជនគ្រាន់តែនឿយហត់ប៉ុណ្ណោះ សេចក្តីនេះយ៉ាងណា ភិក្ខុចំរើនសតិបដ្ឋាន ៤ ក៏ដូច្នោះដែរ បើមានជនណាមកលួងលោមដោយភោគសម្បត្តិថា អ្នកស្លៀកសំពត់ទឹកអម្ចត់ធ្វើអ្វី ចូរអ្នកសឹកមកបរិភោគទ្រព្យធ្វើបុណ្យវិញទៅ ភិក្ខុនោះមិនអាចលាចាកតាមពាក្យនោះឡើយ ព្រោះខ្លួនមានចិត្តបង្អោនទៅកាន់វិវេកយូរហើយ ។

ព្រះអនុរុទ្ធថេរ ក្រោយពីពេលឆាន់ចង្ហាន់ហើយ លោកតែងប្រមើលមើលលោកធាតុដោយទិព្វចក្ខុញាណ ហើយជាអ្នកជំនាញក្នុងទិព្វចក្ខុ ដោយផលានិសង្សនៃការបូជាប្រទីបក្នុងជាតិមុន ។ ដូច្នេះបានជាព្រះបរមសាស្តា ទ្រង់សរសើរថាជាកំពូលលើសភិក្ខុទាំងឡាយខាងទិព្វចក្ខុ ។

ព្រះអនុរុទ្ធ បានជាសាវ័ក១ដ៏សំខាន់ក្នុងពេលពុទ្ធបរិនិព្វាន ហើយជាអ្នកចាត់ចែងការក្នុងពេលបូជាសព ។ លុះពេលធ្វើបឋមសង្គាយនា លោកក៏បានជាអ្នកចាត់ការក្នុងពិធីសង្គាយនានោះទៀត ។ លោកមានព្រះជន្មដល់កំណត់ហើយ ក៏បរិនិព្វានក្រោយ

www.elibraryofcambodia.org

ពុទ្ធបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ។

## ៤២. ប្រវត្តិព្រះអានន្ទត្ថេរ

(ពុទ្ធុបដ្ឋាក, ជាពហុស្សុត, មានសតិ, មានព្យាយាម, និងមានគតិ)

ព្រះអានន្ទ ជាឱរសព្រះសុក្កោទន ក្នុងសាក្យត្រកូលដែលជាអនុជព្រះសុទ្ធោទន ហើយព្រះអានន្ទជាអនុជជីដូន១ នឹងព្រះសាស្ដា ព្រមទាំងប្រសូត្រដំណាលគ្នានឹងព្រះសាស្ដាទៀត ។ ញោមស្រីព្រះនាម កីសាគោតមី ។

ព្រះអានន្ទបានចូលទៅសាងព្រះផ្នួស ជាមួយក្សត្រសាក្យ ៦ អង្គទៀត ក្នុងសំណាក់ព្រះសាស្ដានៅអនុបិយម្ពវ័ន ។ កាលបួសហើយបានស្ដាប់ឱវាទព្រះបុណ្ណត្ថេរមន្តានីបុត្រ ក៏បានសំរេចសោតាបត្តិផល ។ នៅពេលដែលមេឃិយត្ថេរ បានលាព្រះសាស្ដាចេញទៅប្រព្រឹត្តធម៌ គ្មានអ្នកណានៅបំរើព្រះសាស្ដា សង្ឃបានរើសព្រះអានន្ទថ្វាយព្រះសាស្ដា ប៉ុន្តែលោកជាអ្នកធ្ងន់ក្នុងហេតុមានការត្រិះរិះល្អិតល្អន់ លោកមិនព្រមទទួលភ្លាមទេ ដោយលោកបានក្រាបទូលសូមពរ៨ ប្រការជាមុនសិន កាលព្រះសាស្ដាទ្រង់អនុញ្ញាតហើយ ទើបព្រះអានន្ទព្រមចូលខ្លួនធ្វើជាពុទ្ធុបដ្ឋាកតទៅ ។ ពរ ៨ ប្រការនោះគឺ :

១. សូមព្រះអង្គកុំប្រទានចីវរដ៏ប្រណីតដល់ខ្ញុំអានន្ទ ។

www.elibraryofcambodia.org

២- សូមព្រះអង្គកុំប្រទានបិណ្ឌបាត្រដ៏ប្រណិតដល់ខ្ញុំអានន្ទ ។

៣- សូមព្រះអង្គកុំឱ្យខ្ញុំអានន្ទ នៅក្នុងទីប្រថាប់ជាមួយព្រះអង្គ ។

៤- សូមព្រះអង្គកុំនាំខ្ញុំអានន្ទទៅកាន់ទីនិមន្តជាមួយព្រះអង្គ ។

៥- សូមព្រះអង្គស្តេចយាងទៅកាន់ទីនិមន្ត ដែលខ្ញុំព្រះអង្គបានទទួលគេទុកហើយ ។

៦- សូមឱ្យខ្ញុំព្រះអង្គនាំបរិស័ទ ដែលមកពីចម្ងាយចូលគាល់ព្រះអង្គបានក្នុងខណៈ ដែលគេមកដល់ហើយ ។

៧- បើមានសេចក្តីសង្ស័យកើតឡើងក្នុងវេលាណា សូមឱ្យខ្ញុំព្រះអង្គ ចូលគាល់សួរបានក្នុងវេលានោះ ។

៨- បើព្រះអង្គទៅទេសនារឿងអ្វីក្នុងទីណា ដែលខ្ញុំព្រះអង្គមិនទាន់បានស្តាប់ សូមព្រះអង្គត្រាស់សំដែងរឿងនោះដល់ខ្ញុំព្រះអង្គ ។

ហេតុដែលព្រះអានន្ទបានសូមពរទាំង៨ នេះ ព្រោះលោកយល់ឃើញហេតុ ៣ យ៉ាងគឺ :

ពរ ៤ ខាងដើម គឺដើម្បីចៀសវាងពាក្យនិន្ទាថា អានន្ទធ្វើ

www.elibraryofcambodia.org

ពុទ្ធុប្បដ្ឋាន ដើម្បីប្រាថ្នាលាភ ។

ពរ ៣ បន្ទាប់មក ដើម្បីការពារពាក្យនិន្ទាថា អានន្ទប្រឹង បំរើព្រះសាស្ដាធ្វើអ្វី បើគ្រាន់តែមានការពឹងពាក់បន្តិចបន្តួច ក៏ធ្វើមិនកើតដែរ ។

ពរខាងចុងបង្អស់ ដោយលោកមានបំណងថា បើមានគេសួរថា ព្រះអង្គទេសរឿងអ្វី ? សំដែងនៅទីណា ? ក៏អាចប្រាប់គេបានកុំឱ្យគេរិះគន់ថា នៅជាប់នឹងព្រះសាស្ដាជានិច្ចតែមិនដឹងអ្វី ។

ព្រះអានន្ទមានព្រះទ័យស្មោះត្រង់ នឹងព្រះសាស្ដាណាស់ រហូតដល់ទៅហ៊ានលះបង់ជីវិតថ្វាយព្រះសាស្ដា ដូចកាលលោកទៅឈរពាំងដំរីនាឡាគិរី ការពារព្រះសាស្ដាជាដើម។ ព្រះអានន្ទត្ថេរ ជាសាវ័កមានស្មារតីរឹងប៉ឹង ចេះចាំព្រះធម៌ទាំងអស់ ហើយឈ្លាសវៃក្នុងធម្មទេសនាណាស់ ដូច្នេះបានជាព្រះបរមសាស្ដាទ្រង់លើកតំកើងថា ជាកំពូលនៃភិក្ខុទាំងឡាយ ខាងពហុស្សូត១ មានសតិ១ មានគតិ១ មានព្យាយាម១ និងថាឧបដ្ឋាក១ ។

កាលព្រះបរមសាស្ដាបរិនិព្វាន ព្រះអានន្ទមិនទាន់បានសម្រេចអរហត្តផលនៅឡើយ លុះ ៣ ខែកន្លងមកមុននឹងធ្វើបឋមសង្គាយនាតែ ២-៣ ម៉ោងប៉ុណ្ណោះ ទើបលោកបានសម្រេច

www.elibraryofcambodia.org

អរហត្តផល ក្នុងចន្លោះឥរិយាបថទាំង ៤ ហើយតមកសង្ឃក៏បាន សម្រេចរើសលោកបញ្ចូលក្នុងជំនុំសង្ឃជាគំរប់ ៥០០ អង្គ ហើយ លោកទទួលនាទីជាអ្នកដោះស្រាយព្រះសូត្រ និងព្រះអភិធម្ម បិដក ក្នុងបឋមសង្គាយនារហូតទល់ចប់ ។

កាលក្រោយពុទ្ធបរិនិព្វាន ព្រះមហាអានន្ទ បាននិមន្តទៅ ទេសនាប្រោសសត្វ ដូចព្រះសម្ពុទ្ធដែរ លោកមានព្រះជន្មវែង ណាស់ គឺព្រះជន្មដល់ទៅ ១២០ ឆ្នាំ ។ លុះពុទ្ធបរិនិព្វានបាន ៤០ ឆ្នាំ ទើបព្រះអានន្ទបរិនិព្វាន ។ មានសេចក្ដីដំណាលថា កាល លោកហៀបនឹងបរិនិព្វាន ទ្រង់ទេសនាប្រោសពួកញាតិបាន សម្រេចមគ្គផលរួច ក៏ធ្វើបដិហារ្យផ្សេងៗ ហើយអធិដ្ឋានថា កាលអាត្មាអញបរិនិព្វានហើយ សូមឱ្យចំណែកអដ្ឋិធាតុបែកចេញ ជាពីរចំណែក មួយចំណែកបានទៅពួកសាក្យ មួយចំណែកបាន ទៅពួកកោលិយៈ ដើម្បីកុំឱ្យពួកញាតិទាស់ទែងគ្នា ។ តមកលោក ក៏ហោះឡើងក្នុងផ្ទៃអាកាស រួចបរិនិព្វាននៅលើស្ទឹងរោហិណី ចន្លោះនគរកបិលព័ស្តុ និងកោលិយៈ ភ្លើងក៏ឆេះព្រះកាយរួចខ្យល់ បក់ព្រះធាតុបែកជា ២ ចំណែកមែន ។

ស- រឿងសាវ័កដ៏សំខាន់ៗ ទាំងនេះ យើងឈប់ស្លេះសិន ហើយយើងចង់ដឹងថា ក្រៅពីវត្តវេឡុវ័ន តើមានវត្តណាសំខាន់ៗ

www.elibraryofcambodia.org

ទៀតដែរ ? ជនណាបានកសាងថ្វាយ ? ចូរពន្យល់ !

ច. មានវត្តសំខាន់ៗ ទៀតគឺ :

១. វត្តជេតពន់ នៅជិតក្រុងសាវត្ថី ក្នុងដែនកោសល ជាវត្តដែលសេដ្ឋីឈ្មោះ អនាថបិណ្ឌិកបានកសាងថ្វាយព្រះសាស្តា ។ សេដ្ឋីនេះ ជាមហាឧបាសកក្នុងព្រះពុទ្ធសាសនា បានទិញដីព្រៃមួយកន្លែងរបស់ព្រះអង្គម្ចាស់នាម ជេត ហើយកសាងវត្តជេតពននេះថ្វាយព្រះពុទ្ធជាម្ចាស់អស់ប្រាក់ចំនួន៥៤ កោដិ(ចតុប្បញ្ញាស) កហាបណៈ ។ តាមសេចក្ដីដំណាលថា សេដ្ឋីអនាថបិណ្ឌិក (អ្នកឱ្យបាយដល់ជនគ្មានទីពឹង) ជាអ្នកទំនុកបំរុងព្រះពុទ្ធសាសនា ព្រះភិក្ខុសង្ឃជានិច្ច មានការស្និទ្ធស្នាលនឹងព្រះសម្ពុទ្ធ ព្រមទាំងភិក្ខុសង្ឃណាស់ ពេលចូលទៅវត្តម្ដងៗ គាត់មិនដែលទៅដោយដៃទទេឡើយ ឯភិក្ខុសង្ឃកាលឃើញសេដ្ឋីនេះចូលទៅកាន់វត្ត ពេលណា ក៏តែងនាំគ្នាមើលដៃសេដ្ឋីដោយក្ដីសង្ឃឹមថា សេដ្ឋីអនាថ-បិណ្ឌិក នឹងយកភត្ត. ភេសជ្ជមកប្រគេនខ្លួនមិនខាន ។ សេដ្ឋីនេះចំណាយទ្រព្យខ្លួនទាល់តែអស់ពីឃ្លាំង រហូតទល់បរិភោគខ្លួនឯងតែបាយចុងអង្ករ និងជ្រក់ ទោះបីទេពតាដែលជាមិច្ឆាទិដ្ឋិមកប្រាប់គាត់ថា ឱ្យឈប់ទំនុកបំរុងព្រះពុទ្ធ និងភិក្ខុសង្ឃទៅក៏ដោយក៏គាត់មិនព្រមស្ដាប់ ហើយបណ្ដេញទេពតាឱ្យឈប់ នៅលើ

www.elibraryofcambodia.org

ខ្លោងទ្វារចូលទៅផ្ទះគាត់ទៀត ។

២- វត្តបុព្វារាម វត្តនេះនៅក្នុងដែនកោសលដែរ ប៉ុន្តែនៅជិតក្រុងសាកេត ។ វត្តនេះនាងវិសាខា (ជាស្ត្រីប្រកបដោយបញ្ចពិធកល្យាណី) បានចំណាយទ្រព្យសាងថ្វាយព្រះសាស្តាអស់ចំនួន ២៧ កោដិ (សត្តវីសតិ) កហាបណៈ ។ នាងវិសាខានេះជាមហាឧបាសិកា ក្នុងព្រះពុទ្ធសាសនា ទំនុកបំរុងព្រះពុទ្ធ និងព្រះសង្ឃយ៉ាងមុតមាំ ។ តាមសេចក្តីដំណាលថា នាងវិសាខាជាស្ត្រីមានរូបល្អណាស់. សេដ្ឋីឈ្មោះធនញ្ជ័យជាបិតាបានសាងគ្រឿងពាក់កាយម្យ៉ាងឈ្មោះ បសាធន ! សុទ្ធតែមានមាស និងពេជ្រអស់តម្លៃ ២៧ កោដិកហាបណៈ ។ នាងវិសាខាជាស្ត្រីមង្គល ពេកមានរវល់អ្វីៗ នៅទីណា គេតែងអញ្ជើញនាងទៅជាអធិបតីជានិច្ចពេល១ នាងបានពាក់គ្រឿងបសាធនៈនោះទៅក្នុងពិធីមង្គល ១ លុះត្រឡប់មកវិញ ក៏ចូលទៅក្នុងវត្តជេតពន ដើម្បីស្តាប់ព្រះធម៌ទេសនា នៅក្នុងសំណាក់ព្រះសាស្តា ។ កាលស្តាប់ធម៌រួច នាងវិសាខា និងបរិវារបានត្រឡប់ទៅផ្ទះវិញ ដោយភ្លេចបន្ទិចគ្រឿងបសាធនៈនោះ វេចទុកនៅកន្លែងស្តាប់ធម៌ ។

គ្រានោះព្រះមហាអានន្ទពុទ្ធុបដ្ឋាក កាលព្រះសាស្តាសំដែងធម៌ចប់ ហើយឧបាសក-សិកា ត្រឡប់ទៅផ្ទះអស់ លោក

www.elibraryofcambodia.org

ក៏និមន្តពេញតែទីវត្ត ដើម្បីមើលកិច្ចការខុសត្រូវផ្សេងៗ ឬមួយមានជនណាភ្លេចជ្រុះអ្វីក្នុងទីវត្ត លោកក៏តែងរើសទុកដាក់ឱ្យជានិច្ច ។ កាលណោះលោកក៏ឃើញបង្ខិចគ្រឿងបសាធនៈដូច្នេះ លោកក៏រើសយកទៅព្យួរនឹងមែកឈើ១ យ៉ាងស្រួល ។ ក្រោយបន្តិចមក អ្នកបំរើនាងវិសាខា នឹកឃើញហើយក៏ត្រឡប់មកយកបង្ខិចនោះវិញ ព្រះអានន្ទក៏យកបង្ខិចនោះទៅប្រទានឱ្យស្ត្រីបំរើនោះភ្លាម បានហើយស្ត្រីបំរើក៏ត្រឡប់វិញ. កាលទៅដល់នាងវិសាខា សួរស្ត្រីបំរើថា មានលោកសង្ឃណា កាន់ពាល់ត្រូវបង្ខិចនេះឬទេ ? ស្ត្រីបំរើឆ្លើយថា ព្រះអានន្ទបានយកទុក ។ ដោយនាងវិសាខានេះ បានកាន់ប្រពៃណី១ ថា គ្រឿងបសាធនៈនោះកាលណាមានសមណៈអង្គណា កាន់ពាល់ត្រូវហើយ នឹងទៅជារបស់សៅហ្មង ហើយនាងត្រូវតែលក់របស់នោះចេញ រួចនាងក៏ប្រកាសលក់គ្រឿងបសាធនៈនោះ មានតម្លៃ ២៧ កោដិកហាបណៈដដែល ប៉ុន្តែគ្មានអ្នកណាហ៊ានទិញឡើយ ។ កាលបើដូច្នោះ នាងវិសាខាក៏ចំណាយទ្រព្យ ២៧ កោដិកហាបណៈចេញទិញគ្រឿងបសាធនៈនោះមកវិញ ដោយបានយកប្រាក់នោះទៅកសាងវត្តបុព្វារាម១ ថ្វាយព្រះសាស្តា ។ វត្តនេះមានប្រាសាទធំៗមានកំពូលដល់ទៅ ៥០០ ហើយក្នុងការកសាងវត្តនោះបានព្រះ

www.elibraryofcambodia.org

មហាមោគ្គល្លាន ជាអ្នកជួយជញ្ជូនថ្មពីទីផ្សេងៗ ដោយឫទ្ធិផង ។

៣. វត្តឃោសសិតារាម វត្តនេះនៅក្នុងដែនវង្ស ជិតក្រុងកោសម្ពី ដែលឃោសិតសេដ្ឋី បានសាងថ្វាយព្រះសាស្ដា ។ វត្តនេះមិនដឹងជាមានប្រវត្តិនិយាយយ៉ាងណាដែរ គឺយើងគ្រាន់តែស្គាល់ឈ្មោះវត្ត និងឈ្មោះអ្នកកសាងតែប៉ុណ្ណោះ ។

ស. ព្រះសាស្ដា ទ្រង់ដែលយាងទៅគង់នៅវត្តជេតពននោះញឹកញាប់ឬទេ ? ព្រោះអ្វី ?

ច. ទ្រង់យាងទៅញឹក ព្រោះជាវត្តដែលស្ថិតនៅលើរដ្ឋនិងក្រុងដ៏ធំមានប្រជាជនច្រើន ស្មើគ្នានឹងមគធរដ្ឋដែរ ម្យ៉ាងទៀត តាមសូត្រនានាក៏មានជាញឹកដែរ " .. ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្សអារាម" ព្រះសាស្ដាទ្រង់គង់ចាំវស្សាទី ១ និងទី ២១ ដល់ ២៩ ហើយនិងពីវស្សាទី ៣៦ ដល់ផុតវស្សាទី ៤៤ ឃើញថាបានទាំងអស់ចំនួន ២០ វស្សា គឺច្រើនជាងទីឯទៀត ។

ស. ព្រះសាស្ដាទ្រង់ដែលគង់ចាំវស្សា នៅវត្តបុព្វារាមបានប៉ុន្មានវស្សាដែរ ? ពីវស្សាទីប៉ុន្មានដល់ទីប៉ុន្មាន ?

ច. បាន ៦ វស្សាគឺពីវស្សាទី ៣០ ដល់ចប់វស្សាទី ៣៥ ។

ស. នៅក្រុងកបិលព័ស្ដុ ព្រះសាស្ដាដែលទ្រង់គង់ចាំវស្សា

www.elibraryofcambodia.org

ដែរឬទេ ? អ្នកណាសង់ថ្វាយ ?

ច. ទ្រង់ដែលគង់ចាំវស្សានៅវត្ត និងនិគ្រោធារាម ជិតទីក្រុងតែ១ វស្សាគត់គឺនៅវស្សាទី១៥ ដើម្បីប្រោសពួកព្រះញាតិ ។ វត្តនេះពួកសាក្យវង្សបានសាងថ្វាយព្រះអង្គ ។

ស. កាលព្រះសាស្តាទ្រង់យាងទៅកាន់ក្រុងកបិលព័ស្តុជាលើកទី ២ ទ្រង់បានប្រោសអ្នកណាខ្លះ ?

ច. កាលទ្រង់យាងទៅកាន់ក្រុងកបិលព័ស្តុជាលើកទី ២ ទ្រង់ពុំបានប្រោសជនណាឱ្យពិតប្រាកដទេ ក៏ប៉ុន្តែពេលនោះ នាងបជាបតិគោតមី ជាម្តាយមីងព្រះអង្គ បានយកសំពត់សាដកពីរផ្ទាំងគឺ មួយផ្ទាំង១ មានបណ្តោយ ១៤ ហត្ថ ទទឹង ៥ ហត្ថ ដែលនាងធ្វើដោយខ្លួននាងផ្ទាល់ ទៅថ្វាយព្រះសាស្តា ដើម្បីឱ្យព្រះអង្គប្រោសទទួល តែព្រះសាស្តាពុំព្រមទទួលទេ ទោះជានាងអង្វរយ៉ាងណាក៏ដោយ ។ ព្រះអង្គបានសំដែងអំពីបាដិបុគ្គលិកទាន និងសង្ឃទានឱ្យនាងគោតមីស្តាប់ នាងក៏ប្រគេនទៅព្រះមហាថេរនានា តែលោកពុំព្រមទទួលសោះ លុះដល់ភិក្ខុទើបនឹងបួសថ្មីមួយរូបនាម អជិត ជារាជបុត្រព្រះបាទអជាតសត្រូវ[១] និងនាងកញ្ចនា លោកក៏ព្រមទទួលយក តែនាងគោតមីកើតទោមនស្សខ្លាំងណាស់ ព្រោះពុំសមតាមប្រាថ្នា ប៉ុន្តែព្រះសាស្តាកាលទ្រង់

www.elibraryofcambodia.org

ជ្រាប ក៏ទ្រង់បោះបាត្រទៅក្នុងអាកាស ឱ្យសាវ័កទាំងអស់រក តែគ្មានសាវ័កណាអាចរកឃើញ លុះអជិតភិក្ខុទៅរក ក៏បានឃើញ ។

---

១. ព្រះបាទអជាតសត្រូវ ជាបុត្រព្រះបាទពិម្ពិសារ និងនាងវេទេហិ មហាក្សត្រ នៅមគធៈរដ្ឋ ក្រុងរាជគ្រឹះ ។ កាលព្រះកុមារនៅក្នុងផ្ទៃព្រះមាតា ។ ទ្រង់ឃ្លានតែឈាមដើមព្រះហស្តព្រះស្វាមី(ពិម្ពិសារ)រហូតទល់ស្លន់ស្លោ លុះព្រះបាទពិម្ពិសារសួរយូរៗទៅ នាងក៏ប្រាប់ត្រង់ ព្រះរាជាទ្រង់វះដើមដៃយកឈាមឱ្យព្រះនាងសោយ. ទើបព្រះនាងបានស្បើយ ។ ហោរាទាយថា ព្រះកុមារនេះ នឹងសម្លាប់ព្រះបិតាយករាជ្យសោយ. ព្រះនាងវេទេហី ក៏រំលូតទារកចោលតែមិនរលូត ។ កាលរាជកុមារប្រសូត្រហើយ គេក៏យកទៅលាក់រហូតទល់ធំ ទើបព្រះនាងជាមាតាឃើញ ក៏ស្រឡាញ់បុត្រណាស់ ។ កាលព្រះកុមារពេញវ័យ ក៏ចូលដៃជាមួយទេវទត្ត ហើយចាប់ព្រះបាទពិម្ពិសារជាបិតាយកទៅដាក់គុករហូតទល់សុគត ហើយយករាជ្យសម្បត្តិសោយនៅឆ្នាំទី ៣៧ នៃពុទ្ធកាល ។ ៨ ឆ្នាំក្រោយមក ទើបព្រះពុទ្ធបរិនិព្វាន ។ តាំងពីសម្លាប់បិតាហើយ។ ទេវទត្តក៏ត្រូវព្រះធរណីស្រូបទៅ ព្រះបាទអជាតសត្រូវទ្រង់ខ្មាសខ្លួនយ៉ាងខ្លាំងចំពោះអំពើ ដែលខ្លួនបានធ្វើគត់បិតាក៏បានទៅសុំទោសចំពោះព្រះសាស្តា ។ កាលព្រះពុទ្ធបរិនិព្វានទៅបាន ៣ខែ ព្រះរាជាអង្គនេះទ្រង់ឧបត្ថម្ភពិធីធ្វើបឋមសង្គាយនាអស់ ៧ ខែ ។ ព្រះបាទអជាតសត្រូវសោយរាជ្យបាន៣២ ឆ្នាំ គឺក្នុងពុទ្ធកាលបាន៨ ឆ្នាំ លុះព្រះពុទ្ធបរិនិព្វាន ហើយសោយរាជ្យបាន២២ ឆ្នាំទៀត ទើបសុគតទៅកើតក្នុងលោកុម្ភិនរក ដោយត្រូវព្រះរាជបុត្រព្រះនាម ឧទយភទ្ទ ធ្វើគត់ព្រះអង្គ ហើយសោយរាជ្យបាន១៦ ឆ្នាំត្រូវព្រះកុមារនាមអនុរុទ្ធជារាជបុត្រធ្វើគតយករាជ្យសោយទៀត ។ ព្រះមុណ្ឌក ជាបុត្រអនុរុទ្ធ ធ្វើគត់អនុរុទ្ធជាបិតាយករាជ្យសោយទៀតបាន៨ ឆ្នាំ ក៏ត្រូវព្រះកុមារនាគទស្សកៈជារាជបុត្រធ្វើគត់ព្រះមុណ្ឌកជាបិតា យករាជ្យសោយបាន២៤ ឆ្នាំទើបអ្នកនគរធ្វើឃាតព្រះនាគទស្សកៈ និងរាជ្យវង្សអស់ហើយថ្វាយរាជ្យទៅសុសុនាគកុមារ។ ដូច្នេះរាជវង្សព្រះបាទពិម្ពិសារ-អជាតសត្រូវ សុទ្ធតែធ្វើគត់បិតាខ្លួនយករាជ្យសោយទាំងអស់ចំនួន ៨០ ឆ្នាំ ។

www.elibraryofcambodia.org

ព្រះសាស្តាទ្រង់បានប្រកាសគុណសម្បត្តិរបស់ភិក្ខុនោះថា "ភិក្ខុនេះនឹងបានត្រាស់ជាព្រះពុទ្ធមួយអង្គនាម មេត្តេយ្យ ក្នុងអនាគតកាលនេះ នាងគោតមីឃើញ និងឮដូច្នេះក៏មានសេចក្តីត្រេកអរយ៉ាងក្រៃលែង ។

ព្រះសាស្តាទ្រង់ធ្វើយ៉ាងនេះ ក៏ដើម្បីប្រោសនាងគោតមី១ផ្នែក និងដើម្បីបង្ហាញនូវអជិតភិក្ខុថាជាតួអង្គពោធិសត្វ១ ផ្នែក ។

ស- នៅក្នុងពុទ្ធចរិយា មានចរិយាមួយ គឺញាតិត្ថចរិយា ការប្រព្រឹត្តិធ្វើប្រយោជន៍ចំពោះញាតិ ។ ក្នុងរឿងនេះ តើព្រះអង្គបានធ្វើប្រយោជន៍ចំពោះញាតិ ឱ្យច្រើនជាងមហាជននានា ក្រៅពីព្រះញាតិ ឬតិចជាង ?

ច- នៅក្នុងរឿងដែលព្រះអង្គធ្វើប្រយោជន៍ចំពោះញាតិ យើងអាចឆ្លើយបានតាមហេតុពីរយ៉ាងគឺ :

១- ទ្រង់អនុញ្ញាតិដោយពិសេស ចំពោះញាតិទាំងឡាយក្នុងសាក្យវង្ស ដែលចូលក្នុងពួកតិរ្ថិយហើយ បើចង់ចូលមកសុំបួសក្នុងព្រះពុទ្ធសាសនាវិញ ក៏ចូលបានភ្លាម មិនបាននៅជាតិរ្ថិយបរិវាស ៤ ខែមុនដូចពួកតិរ្ថិយផ្សេងៗនោះឡើយ ។ ម្យ៉ាងទៀតទ្រង់ការពារញាតិរបស់ព្រះអង្គ ក្នុងកាលខ្លះដែរ ដូចកាលទ្រង់ជ្រាបថា ព្រះបាទអជាតសត្រូវលើកទ័ពទៅវាយក្រុងកបិលពស្តុ

www.elibraryofcambodia.org

ប្រមើលមើលឃើញដល់កម្មដ៏ខ្លាំង របស់ព្រះញាតិវង្សពីជាតិមុន ទ្រង់ក៏ឈប់លែងនៅវង់ចាំការពារទៀត ។ ព្រះសាស្តាទ្រង់យាង ទៅក្រុងកបិលព័ស្តុជាញឹកញាប់ ដើម្បីប្រោសព្រះញាតិវង្ស តែ ទ្រង់គង់ចាំវស្សា នៅក្នុងវត្តនិគ្រោធារាមតែ ១ វស្សាគត់គឺនៅ វស្សាទី ១៥ ក្រៅពីនេះទ្រង់គង់ក្នុងទីដទៃៗ ទាំងអស់ ។ សេចក្តី ខាងលើនេះបញ្ជាក់ឱ្យឃើញថា ព្រះអង្គមិនមែនធ្វើប្រយោជន៍ឱ្យ ពួកញាតិច្រើនជាងមហាជននោះទេ ។

www.elibraryofcambodia.org

ប្រមើលមើលឃើញផលកម្មដ៏ខ្លាំង របស់ព្រះញាតិវង្សពីជាតិមុន ទ្រង់ក៏លែងប៉ងនៅវង់ចាំការពារទៀត ។ ព្រះសាស្ដាទ្រង់យាង ទៅក្រុងកបិលពស្ដុជាញឹកញាប់ ដើម្បីប្រោសព្រះញាតិវង្ស តែទ្រង់គង់ចាំវស្សា នៅក្នុងវត្តនិគ្រោធារាមតែ ១ វស្សាគត់គឺនៅវស្សាទី ១៥ ក្រៅពីនេះទ្រង់គង់ក្នុងទីដទៃ១ ទាំងអស់ ។ សេចក្ដីខាងលើនេះបញ្ជាក់ឱ្យឃើញថា ព្រះអង្គមិនមែនធ្វើប្រយោជន៍ឱ្យពួកញាតិច្រើនជាងមហាជននោះទេ ។

www.elibraryofcambodia.org

# ភាគទី ១១

## បរិនិព្វានននៃពុទ្ធបិតា

## និង ការប្រោសពុទ្ធមាតា

ស- ព្រះពុទ្ធបិតា ទ្រង់បរិនិព្វាននៅពេលណា ? ព្រះពុទ្ធជាម្ចាស់ទ្រង់បានត្រាស់ដឹងហើយប៉ុន្មានឆ្នាំ ? ដោយព្រះជម្ងឺអ្វីដែរ ? ក្នុងព្រះជន្មប៉ុន្មាន ? មុនពេលបរិនិព្វាន តើព្រះអង្គបានសម្រេចធម៌អ្វីដែរ ? ចូររៀបរាប់រឿងនោះមើល !

ច- ព្រះពុទ្ធបិតាសុទ្ធោទនៈ ទ្រង់បរិនិព្វាននៅពេលក្រោយព្រះពុទ្ធបានត្រាស់ដឹងហើយ៥ ព្រះវស្សា ដោយអាពាធជរាធម្មតាក្នុងព្រះជន្ម៩៧ ឆ្នាំ គឺនៅឆ្នាំខាល មុននឹងបរិនិព្វាននេះ ព្រះរាជាទ្រង់បានសម្រេចព្រះអរហត្តផល ។

មានសេចក្ដីដំណាលថា "កាលបើព្រះអង្គទ្រង់គង់នៅក្នុងកូដាគារសាលានាម នគរវេសាលី, ព្រះបាទសុទ្ធោទនៈ (បានសម្រេចអនាគាមិផលហើយ) ទ្រង់ប្រឈួនយ៉ាងខ្លាំង ពេទ្យហ្មក៏ពុំអាចរំងាប់ជម្ងឺបានឡើយ ព្រះអង្គទ្រង់នឹកដល់ព្រះពុទ្ធជាម្ចាស់យ៉ាងខ្លាំង ទ្រង់នឹកថា "បើបានព្រះពុទ្ធអង្គមកស្ទាបព្រះសិរ, ព្រះអានន្ទមកស្ទាបព្រះកាយ, ព្រះរាហុលជាចៅមកស្ទាបខ្នង ជម្ងឺរបស់អាត្មាអញមុខជានឹងបានសះស្បើយមិនខាន" ។ ព្រះសាស្ដា

www.elibraryofcambodia.org

ទ្រង់ជ្រាបហើយ ទ្រង់នាំភិក្ខុ ៥០០ អង្គហោះឆ្ពោះទៅកាន់កបិលព័ស្តុបុរី ហើយចូលទៅស្ទាបព្រះសិរសា ព្រះរោគរបស់ព្រះបិតាក៏បានសះស្បើយភ្លាម ហើយព្រះពុទ្ធទ្រង់ពិចារណាទៅ ក៏ឃើញថា នៅតែ៧ ថ្ងៃទៀត ព្រះបិតានឹងបរិនិព្វានហើយ ទ្រង់ក៏សម្តែងព្រះត្រៃលក្ខណ៍ គឺ អនិច្ចំ ទុក្ខំ អនត្តា ថ្វាយព្រះបិតាស្តាប់ កាលចប់ហើយ ព្រះរាជាក៏បានសម្រេចអរហត្តផល ។ លុះដល់ថ្ងៃទី៧ ព្រះអង្គទ្រង់សុំខមាទោសចំពោះព្រះសាស្តាជាបុត្រ រួចបរិនិព្វានទៅ ។

ព្រះសម្ពុទ្ធទ្រង់បង្គាប់ឱ្យព្រះមហាកស្សបត្ថេររៀបជើងថ្ករដើម្បីថ្វាយព្រះភ្លើងព្រះបិតា រួចព្រះអង្គទ្រង់លើកព្រះសពស្រោចសុគន្ធវារី ហើយទ្រង់ថ្វាយព្រះភ្លើងដោយព្រះអង្គឯង ។

ស. កាលព្រះបាទសុទ្ធោទនៈទ្រង់បរិនិព្វានហើយ តើព្រះនាងបជាបតិគោតមី ទ្រង់មានស្វាមីទៀត ឬទៅជាយ៉ាងណា ?

ច. ព្រះនាងឥតមានស្វាមីទេ ទ្រង់ចូលទៅសុំសាងព្រះផ្នួសក្នុងសំណាក់ព្រះសាស្តា ដែលគង់នៅក្នុងវត្តនិគ្រោធារាម តែព្រះអង្គពុំបានអនុញ្ញាតឡើយ លុះព្រះសាស្តាយាងទៅកាន់កូដាគារសាលាវិញ ព្រះនាងក៏យាងទៅសុំបព្វជ្ជា ដោយមានព្រះអានន្ទជួយអង្វរផង តែព្រះសាស្តានៅតែមិនអនុញ្ញាត លុះដល់

www.elibraryofcambodia.org

ពេលដែលព្រះសាស្តាទ្រង់គង់នៅវត្តជេតពនមហាវិហារ ព្រះនាងបាននាំខត្តិយកញ្ញា ៥០០ នាក់ ទៅសូមបព្វជ្ជាទៀត ព្រះអានន្ទជួយអង្វរ ព្រះសាស្តាទ្រង់អនុញ្ញាតឲ្យបួសដោយគរុធម៌ ៨ ប្រការ ។

ព្រះនាងបជាតិគោតមី ក៏បានបួសជាភិក្ខុនីជាមួយខត្តិយកញ្ញាទាំង ៥០០ នាក់ ហើយព្រះនាងបជាបតិគោតមីនេះហើយ ជាដើមនៃភិក្ខុនីបរិស័ទ ។

ស- ព្រះនន្ទ ជាបុត្រនៃនាងបជាបតិគោតមី ទ្រង់បានបួសហើយបានសម្រេចអរហត្តផលរួចហើយ, ព្រះនាងគោតមី ក៏បានបួសក្នុងពេលនោះដែរ ចុះនាងរូបនន្ទាជាបុត្រព្រះនាងគោតមីនោះ បានបួសនឹងគេដែរ ?

ច- នាងបានបួសដែរ គឺបួសក្រោយមាតានាង ។

ស- នាងបានសម្រេចធម៌អ្វីដែរ ព្រោះហេតុអ្វី ?

ច- នាងបានអរហត្តផលដែរ ព្រោះបានស្តាប់ព្រះគាថា ១ ជា : អដ្ឋីនំ នគរំ កតំ ។ល។ មានោ មក្ខោ ច ឱហិតោ ហើយនាងក៏មាននាមថា "រូបនន្ទាថេរី" ព្រោះព្រះនាងជាស្ត្រីដែលមានរូបល្អណាស់ នៅក្នុងសម័យនោះ ។

ស-ព្រះញាតិវង្សក្តី ព្រះបិតាក្តីសុទ្ធតែព្រះអង្គបានទេសនា

www.elibraryofcambodia.org

ប្រោសបានសម្រេចផលតាមសមគួរអស់ហើយ ចុះព្រះនាងសិរិមហាមាយា ដែលទៅកើតនៅស្ថានតាវត្តិង្សនោះ ព្រះពុទ្ធទ្រង់បានទៅប្រោសហើយឬនៅ ?

ច. ទ្រង់ពុំទាន់បានទៅប្រោសនៅឡើយ ។

ស. តើព្រះអង្គទ្រង់យាងទៅប្រោសឬទេ ? មុននឹងយាងទៅ ទ្រង់បានធ្វើអ្វីនៅស្ថានមនុស្សលោកដែរ ? ទ្រង់ប្រោសព្រះពុទ្ធមាតាដោយធម៌អ្វី ? ទ្រង់សំដែងអស់វេលាប៉ុន្មានទើបចប់ ? នៅវស្សាទីប៉ុន្មាន ? ព្រះមាតាបានសម្រេចអ្វីដែរ ?

ច. ទ្រង់យាងទៅប្រោសដែរ ប៉ុន្តែមុននឹងយាងទៅ ទ្រង់បានធ្វើយមកបាដិហារ្យផ្ចាញ់ពួកគ្រូអន្យតិរ្ថិយ គ្រូទាំង ៦ នាក់គឺ បូរណកស្សបៈ១, មក្ខលិគោសាល១, និគ្គណ្ឋនាដបុត្រ១, សញ្ជយវេលដ្ឋបុត្រ១, បកុធកច្ចាយន១, អជិតកេសកម្ពល១ ។ កាលគ្រូទាំង ៦ នោះបានចាក់បបខ្ចបខ្ចាច ហើយទ្រង់យាងទៅស្ថានតាវត្តិង្ស រួចសំដែងព្រះអភិធម្ម៧ គម្ពីរប្រោសព្រះពុទ្ធមាតាអស់វេលា ៣ ខែចប់ ព្រះនាងសិរិមហាមាយាបានស្តាប់ហើយ ក៏បានសម្រេចសោតាបត្តិផល ។ ទ្រង់សំដែងធម៌នេះនៅវស្សាទី ៧ គឺទ្រង់គង់ចាំវស្សានៅទីនោះឯង ។

ស. ទ្រង់យាងចុះពីស្ថានតាវត្តិង្សវិញនៅថ្ងៃណា ? ដោយ

www.elibraryofcambodia.org

សារអ្វី ? មកគង់នៅទីណា ?

ច. ទ្រង់យាងមកវិញនៅថ្ងៃ ១ រោជ ខែអស្សុជ ដោយជណ្ដើរកែវ ហើយមកគង់នៅត្រង់ទ្វារនៃនគរសង្កស្សៈ ។

ស. ព្រះសត្ថុប្បករណាភិធម្ម ព្រះពុទ្ធទ្រង់សំដែងប្រោសពុទ្ធមាតាឯស្ថានតាវត្តឹង្សឯណោះ ហេតុដូចម្ដេចក៏សាវ័កនៅមនុស្សលោកឯណោះបានចេះដឹងដែរ ?

ច. បានជាមានសាវ័កចេះដឹងដែរ ព្រោះពេលដែលព្រះអង្គទ្រង់យាងចុះមកវិញ ទ្រង់បានសំដែងឱ្យព្រះសារីបុត្តស្ដាប់ ព្រះសារីបុត្តក៏យកទៅសំដែងឱ្យភិក្ខុ ៥០០ រូបនៅក្នុងគុហា ១ ស្ដាប់តទៅទៀត ។

www.elibraryofcambodia.org

# ភាគទី ១២

## ពុទ្ធកិច្ច
## និងពុទ្ធបរិនិព្វាន

ស- ចាប់តាំងពីព្រះសាស្តាប្រសូត្រមកទល់បរិនិព្វាន តើមានរយៈពេលប៉ុន្មានឆ្នាំ ? បើរាប់ពីពេលចេញបួសមក តើមានវេលាប៉ុន្មានឆ្នាំដែរ ?

ច- បើរាប់ពីពេលទ្រង់ប្រសូត្រមកបាន ៨០ ឆ្នាំហើយៗ បើរាប់ពីពេលចេញបួសមក មានរយៈវេលា ៥១ ឆ្នាំ ។

ស- ចុះតាំងពីពេលដែលព្រះពុទ្ធត្រង់ត្រាស់ដឹងហើយទល់បរិនិព្វាន មានវេលាប៉ុន្មានវស្សា ? ពីឆ្នាំណាដល់ឆ្នាំណា ?

ច- មានរយៈ ៤៥ វស្សា គឺពីឆ្នាំរកា ដល់ឆ្នាំម្សាញ់ ។

ស- ក្នុងរយៈវេលាប៉ុណ្ណេះឆ្នាំ តើព្រះសាស្តាទ្រង់បានធ្វើកិច្ចការអ្វីខ្លះ ដែលទៀងទាត់ជាងគេ ? មានប៉ុន្មានយ៉ាងអ្វីខ្លះ ? ចូរពន្យល់ !

ច- ព្រះសាស្តាទ្រង់យាងប្រោសសត្វគ្រប់ទីកន្លែង ហើយព្រះកិច្ចទាំងនោះ បើនិយាយរួមមកហៅថា ពុទ្ធកិច្ច មាន៥យ៉ាង គឺ :

www.elibraryofcambodia.org

១- បុព្វណ្ហេ បិណ្ឌបាតញ្ច.- ពេលព្រឹកព្រះសាស្ដាទ្រង់យាងបិណ្ឌបាតគ្រប់ស្រុកស្រែ ទោះផ្ទះណា ត្រកូលណាក៏ព្រះអង្គទ្រង់យាងទៅ ហើយទោះអ្នកណាឱ្យគ្រឿងល្អក្ដី អន់ក្ដី ក៏ព្រះអង្គទទួលយកដែរ ។

២- សាយណ្ហេ ធម្មទេសនំ.- ពេលរសៀលទ្រង់សំដែងធម៌ទេសនាប្រោសសត្វលោក ឱ្យបានចេះបានយល់ និងបានសម្រេចធម៌តាមនិស្ស័យខ្លួន ។

៣- បទោសេ ភិក្ខុឱវាទំ.- ពេលព្រលប់ទ្រង់ប្រទានឱវាទដល់ពួកភិក្ខុបរិស័ទតែមួយផ្នែក ។

៤- អឌ្ឍរត្តេ ទេវបញ្ហានំ .- ពេលអាធ្រាត្រទ្រង់ដោះប្រស្នារបស់ពួកទេវតា ។

៥- បច្ចូសេវគតេ កាលេ ភព្វាភព្វេ វិលោកនំ.- ពេលទៀបភ្លឺទ្រង់ប្រមើលមើលឧបនិស្ស័យសត្វលោក ដែលគួរព្រះអង្គយាងទៅប្រោស ឬមិនគួរយាងទៅប្រោស ។

ស- សត្វលោកដែលគួរប្រោសដឹកនាំមានប៉ុន្មានពួក ? ហៅថាអ្វី ?

ច- មាន ៣ ពួកដែលហៅថា វេនេយ្យសត្វ គឺ :

www.elibraryofcambodia.org

១- ពុទ្ធវេនេយ្យ.- សត្វខ្លះមាននិស្ស័យនឹងព្រះពុទ្ធ។ ក៏ទ្រង់យាងទៅព្រោសដោយព្រះអង្គឯង ។

២- សាវកវេនេយ្យ.- សត្វខ្លះមាននិស្ស័យនឹងសាវ័ករបស់ព្រះអង្គ។ ក៏ប្រើសាវ័កខ្លះ។ ដូចជាព្រះសារីបុត្ត, មោគ្គល្លានព្រមហាកស្សប ជាដើមឱ្យទៅដឹកនាំ ។ សត្វជំពូកនេះបើព្រះពុទ្ធជាម្ចាស់ទ្រង់យាងទៅទូន្មានដឹកនាំដោយព្រះអង្គឯង ខ្លះក៏ងាយពេក ខ្លះលំបាកពេក, មិនចួនល្មមដល់ពុទ្ធវិស័យ មានតែសាវ័កប៉ុណ្ណោះ ទើបដឹកនាំតាមវិស័យបាន ។

៣- ធាតុវេនេយ្យ.- សត្វខ្លះ មាននិស្ស័យនឹងព្រះធាតុរបស់ព្រះសម្ពុទ្ធ គឺកាលឃើញហើយ ក៏កើតសេចក្ដីសង្វេគ, កើតចិត្តជ្រះថ្លាហើយក៏ជឿ, ប្រតិបត្តិតាមពុទ្ធោវាទ ។

ស. ឱវាទដែលព្រះពុទ្ធបរមគ្រូ ទ្រង់ប្រទានដល់បព្វជិតនិងគ្រហស្ថដូចគ្នា ឬផ្សេង។ គ្នា ? ចូរបង្ហាញ !

ច. ផ្សេងគ្នា គឺបើបរិស័ទជាបព្វជិតទ្រង់ប្រទាននូវសីល, សមាធិបញ្ញា ។ បើបរិស័ទជាគ្រហស្ថទ្រង់ប្រទាននូវប្រយោជន៍បច្ចុប្បន្ន ៤ គឺ :

១- ឧដ្ឋានវគា = ការប្រកបការងារ,

២- សតីមវគា = ថែរក្សា និងចាយវាយទ្រព្យដែលរក

www.elibraryofcambodia.org

បានហើយ.

៣- សមជីវិតា = ចេះចិញ្ចឹមជីវិតតាមគួរ.

៤- កល្យាណមិត្ត = ចេះសេពគប់មិត្តល្អ. និង ប្រយោជន៍ក្នុងលោកខាងមុខ ៤ យ៉ាងគឺ សទ្ធា = ការជឿ. សីល = ការរក្សារបៀបរៀបរយ. ចាគ = ការចំណាយទ្រព្យឱ្យទាន. បញ្ញា = ការចេះគិតគូរ ។

ស- ក្នុងរយៈវេលាទាំង ៤៥ វស្សានោះ ព្រះពុទ្ធបរមគ្រូទ្រង់គង់ចាំវស្សានៅទីណាខ្លះ ?

ច- កន្លែងដែលធ្លាប់ចាំវស្សាមាន ១៨ គឺ :

១- វស្សាទី១ ទ្រង់គង់នៅព្រៃឥសិបតនមិគទាយ ដើម្បីប្រោសបញ្ចវគ្គិយភិក្ខុ ។

២- វស្សាទី២ ៣-៤ ទ្រង់គង់នៅវត្តវេឡុវ័ន ជិតក្រុងរាជគ្រឹះ មគធរដ្ឋ ។

៣- វស្សាទី៥ ទ្រង់គង់នៅកូដាគារសាលា ជិតក្រុងវេសាលី វជ្ជីរដ្ឋ ។

៤- វស្សាទី៦ ទ្រង់គង់នៅមកុឡបព៌តក្នុងមគធរដ្ឋ ។

៥- វស្សាទី៧ ទ្រង់គង់នៅស្ថានតាវត្តិង្ស ដើម្បីសម្តែងអភិធម្ម ប្រោសពុទ្ធមាតា ។

www.elibraryofcambodia.org

៦. វស្សាទី៨ ទ្រង់គង់នៅក្នុងភេសកលាវ័នតត្តភជជនបទ

៧. វស្សាទី៩ ទ្រង់គង់ក្នុងព្រៃបាលិលេយ្យក[1] ជិតក្រុងកោសម្ពីវង្សរដ្ឋ ។

៨. វស្សាទី១០-១១ ទ្រង់គង់ក្នុងដងព្រៃ ជិតស្រុកព្រាហ្មណ៍ឈ្មោះសាលេយ្យកៈ ។

៩. វស្សាទី១២ ទ្រង់គង់ក្រោមដើមស្ដៅ ដើម្បីប្រោសនឡេរុយក្ស ។

១០. វស្សាទី១៣ ទ្រង់គង់ចាំវស្សានៅភ្នំចាលិលេយ្យក ។

១១. វស្សាទី១៤ ទ្រង់គង់ចាំវស្សានៅវត្តជេតពន ទៀបក្រុងសាវត្ថី កោសលរដ្ឋ ។

១២. វស្សាទី១៥ ទ្រង់គង់នៅវត្តនិគ្រោធារាម ជិតក្រុងកបិលព័ស្តុ សក្កជនបទ ដើម្បីប្រោសព្រះញាតិ ។

១៣. វស្សាទី១៦ ទ្រង់ចាំវស្សាក្នុងស្រុកអាឡវី ដើម្បីប្រោសពួកអាឡវកយក្ស ។

១៤. វស្សាទី១៧-១៨-១៩ ទ្រង់មកគង់ចាំវស្សាក្នុងវត្តវេឡុវ័នវិញ ។

---

១. បានជាគង់នៅទីនោះ ព្រោះមានភិក្ខុជាវិនយធរ និងធម្មកថិកឈ្មោះគ្នា នៅឃោសិតារាម ។

www.elibraryofcambodia.org

១៥. វស្សាទី២០.២១.២២.២៣.២៤.២៥.២៦.២៧.២៨ និងទី២៩ ទ្រង់គង់ក្នុងវត្តជេតពនវិញ ។

១៦. វស្សាទី៣០.៣១.៣២.៣៣.៣៤ និងទី៣៥ ទ្រង់គង់ចាំវស្សាក្នុងវត្តបុព្វារាម ដែលនាងវិសាខាសាងថ្វាយ ។

១៧. វស្សាទី៣៦.៣៧.៣៨.៣៩.៤០.៤១.៤២.៤៣ និងទី៤៤ ទ្រង់គង់នៅវត្តជេតពនវិញ ។

១៨. វស្សាទី៤៥ ទ្រង់គង់នៅវេឡុគ្រាម ។

ដូច្នេះកន្លែងដែលទ្រង់គង់ច្រើនជាងគេគឺ :

វត្តវេឡុវ័ន មាន ៦ វស្សា

វត្តជេតពន មាន ២០ វស្សា[១]

វត្តបុព្វារាម មាន ៦ វស្សា ។

ស. ក្នុងវេលារយៈ ៤៥ វស្សានេះ តើព្រះអង្គយាងទៅកាន់នគរណាខ្លះ ?

ច. ព្រះអង្គបានយាងទៅកាន់នគរ :

១. ពារាណសី          រដ្ឋកាសី

២. រាជគ្រឹះ          រដ្ឋមគធៈ

---

១. ក្នុងគាថាថា "ឯកូនវីសតិ" . ១៩ ទេវិញ ។

www.elibraryofcambodia.org

៣. សាវត្ថី រដ្ឋកោសល

៤. កបិលព័ស្តុ សក្កជនបទ

៥. វេសាលី រដ្ឋវជ្ជី

៦. បាតលិបុត្ត រដ្ឋមគធៈ

៧. កោសម្ពី រដ្ឋវង្សៈ

៨. វេរញ្ញា (មិនប្រាកដ)

៩. កុសិនារា រដ្ឋមល្លៈ

១០. បាវា រដ្ឋមល្ល[១]

១១. សាកេត (រដ្ឋកោសល)

១២. ចម្បា រដ្ឋអង្គៈ

១៣. វេឡុទីបកៈ (រដ្ឋមិនប្រាកដ)

១៤. អល្លកប្បៈ រដ្ឋពូលិ

១៥. មោរិយៈ ព្រៃបិប្ផលិ

ទ្រង់ដែលយាងទៅក្នុងរដ្ឋឯទៀត តែមិនមានឈ្មោះប្រាកដ ។

ទ្រង់ដែលយាងទៅលង្កាទ្វីប ៣ ដងគឺ ម្តងពេលត្រាស់ដឹង

---

១. រដ្ឋមល្លៈមានក្រុង១ ឈ្មោះ កុសាវតី ក្រោយមកក៏បែកជាពីរគឺ កុសិនារានិងបាវា ។

www.elibraryofcambodia.org

ហើយបាន ៩ ខែ ទ្រង់និមន្តទៅកោះនោះតែ១ ព្រះអង្គឯង ទ្រង់ប្រថាប់កណ្តាលអាកាស កណ្តាលទីប្រជុំពួកយក្ស (កាលនោះលង្កាទ្វីបគ្មានមនុស្សនៅទេ មានសុទ្ធតែពួកយក្សបិសាចនៅ) ។ ទ្រង់បណ្តាលឱ្យភ្លៀងធ្លាក់ ឱ្យពួកយក្សរងាហើយចុះចាញ់ ព្រមទាំងប្រគេនទ្វីបនេះដល់ព្រះអង្គ។ ទ្រង់ហោះវៀល ៣ ជុំ ហើយប្រទានព្រះកេសធាតុដល់ពួកយក្សបិសាច ។

លើកទី២ ក្នុងពេលត្រាស់ហើយបាន ៥ ឆ្នាំ ទ្រង់យាងទៅតែ១ ព្រះអង្គឯង ដើម្បីសម្រុះសម្រួលនាគឈ្មោះចូឡោទរ និងមហោទរ ជាមានិងក្មួយដែលទាស់ទែងគ្នាព្រោះរឿងបល្ល័ង្កកែវ។

លើកទី៣ ពេលទ្រង់បានត្រាស់ហើយបាន ៨ ឆ្នាំ ទ្រង់និមន្តទៅកោះនេះ ជាមួយភិក្ខុសាវ័ក៥០០ រូបដោយមណិអក្ខីនាគរាជអារាធនានិមន្ត។ ទ្រង់ស្នាមព្រះបាទនៅលើភ្នំសុមនក្ខូដហើយយាងត្រឡប់មកវិញ ។ ទ្រង់ពុំដែលគង់ចាំវស្សានៅទីនោះទេ ។

ស- កាលចេញព្រះវស្សាទី ៤៥ ហើយ តើព្រះសាស្តាទ្រង់យាងទៅកាន់ទីណាទៀត ? ទ្រង់បានធ្វើអ្វីខ្លះ ? នៅថ្ងៃខែឆ្នាំណា ?

ច- ព្រះសាស្តាទ្រង់យាងចេញពីស្រុកវេឡុវ (វជ្ជីវង្ស ) ហើយទ្រង់យាងព្រោសសត្វជាលំដាប់លំដោយរហូតដល់ថ្ងៃពេញ

www.elibraryofcambodia.org

បូរមី ខែមាឃ ឆ្នាំរោង[1] ទើបយាងទៅគង់នៅចាបាលចេតិយ ។ នៅទីនោះ មារចូលទៅអារាធនាព្រះអង្គឱ្យបរិនិព្វាន ព្រះអង្គក៏មានព្រះពុទ្ធដីការដាក់អាយុសង្ខារថា "កន្លងទៅ ៣ ខែទៀត តថាគតនឹងបរិនិព្វានហើយ" ។ ពេលនោះក្រឡាមហាប្រឹថពីក៏កម្រើកញាប់ញ័រ ពួកសាវ័កក៏កើតសេចក្តីសង្វេគគ្រប់អង្គ ។

ស. ព្រះសម្ពុទ្ធទ្រង់យាងទៅកាន់ទីណាទៀត បន្ទាប់ពីនោះទៅ ?

ច. ទ្រង់យាងទៅបិណ្ឌបាត្រក្នុងក្រុងវេសាលីហើយ ទ្រង់មានបន្ទូលនឹងព្រះអានន្ទថា "តថាគតឃើញក្រុងវេសាលី[2] លើកនេះជាលើកចុងក្រោយបង្អស់ហើយ" រួចទ្រង់ត្រាស់ថា "ក្រុងវេសាលីមានសោភ័ណភាពល្អស្មើនឹងស្ថានទេពតាឈ្មោះចាតុម្មហារាជិកា បើភិក្ខុទាំងឡាយមិនដែលឃើញស្ថាននោះចូលមើលក្រុងវេសាលីនេះចុះ ។

---

១. ខ្លះថាឆ្នាំម្សាញ់ ។ បើគិតតាមខ្មែរយើងមិនមែនឆ្នាំម្សាញ់ទេ គឺខែមាឃ [illegible] ពីបូរមី ខែមាឃទៅដល់ខែពិសាខពេញបូរមី មានត្រឹម ៨៨ ថ្ងៃ គិតតាម[illegible] ៤ លុះដល់ខែពិសាខ ទើបចូលមកឆ្នាំម្សាញ់ ។ ដូច្នេះបានជាយើងថាឆ្នាំរោងវិញ ដែរព្រះអង្គទ្រង់ដាក់អាយុសង្ខារ លុះចូលឆ្នាំម្សាញ់ពេញបូរមី ខែពិសាខទើបបរិនិព្វាន ។

www.elibraryofcambodia.org

ស. កាលទ្រង់យាងចេញពីក្រុងវេសាលី តើព្រះអង្គទ្រង់យាងទៅទីណាទៀត ?

ច. ព្រះសាស្ដាទ្រង់យាងទៅកាន់ភណ្ឌគ្រាមទៀតហើយ ទ្រង់យាងទៅប្រោសសត្វ តាមលំដាប់លំដោយរហូតទល់ ដែនមល្លៈ ហើយយាងទៅកាន់សាលវ័នរបស់ក្សត្រមល្ល ជិតក្រុងកុសិនារា រួចទ្រង់ប្រាប់ព្រះអានន្ទឱ្យរៀបចំគ្រែនៅក្រោមដើមសាលព្រឹក្សទាំងគូ ដើម្បីព្រះអង្គចូលបរិនិព្វាន ព្រមទាំងឱ្យព្រះអានន្ទ ចូលទៅថ្វាយពត៌មានដល់មល្លក្សត្រ នៅក្រុងកុសិនារាថា ព្រះអង្គនឹងបរិនិព្វានក្នុងថ្ងៃអង្គារ ពេញបូរមី ខែពិសាខ ឆ្នាំម្សាញ់ នេះផង ។

---

២. ក្រុងវេសាលី ស្ថិតនៅក្នុងដែនវជ្ជី ជាប្រទេសសហរដ្ឋ មានជនជាតិ ៨ ត្រកូលរួមគ្នា ត្រកូលធំជាងគេមានពីរគឺ ត្រកូលលិច្ឆវី តាំងរាជធានីឈ្មោះវេសាលី សព្វថ្ងៃហៅថា ពេសារហ៍ (Bésarh) ចម្ងាយ ៤៤ គ.ម. ពីក្រុងបត្នៈ ( បាតលីបុត្ត ) តាំងនៅលើត្រើយស្ទឹងគន្ធកៈ និងត្រកូលវិទេហៈ តាំងរាជធានីឈ្មោះ មិថិលា ។

លោកអ្នកម៉ាស ថាក្រុងវេសាលីចំរើនជាងក្រុងឯទៀតៗ ក្នុងសម័យជាមួយគ្នា មានកំពែង ៣ ជាន់ ឆ្ងាយពីគ្នា ១ គាវុត (១ សម្រែកគោ) ពីក្រោយក្រុង មានព្រៃធំ ១ ឈ្មោះមហាវ័ន [illegible] ត្រកូលលិច្ឆវី បានសាងកូដាគារសាលាថ្វាយព្រះពុទ្ធ និង [illegible] ។ [illegible] មានកើតអាសន្នរោគជាញឹក

www.elibraryofcambodia.org

ផ្ទះក្នុងធម៌បណិធានគោ ក៏មាននិយាយអំពីរឿងព្រះអង្គប្រើមហានន្ទ ឱ្យទៅរម្ងាប់រោគនិងទុរ្ភិក្សភ័យក្នុងដែននេះដែរ ។ ព្រះពុទ្ធទ្រង់បញ្ញត្តិសាវ័កមិនឱ្យឆាន់ទឹកដោយមិនចាងក្រងនោះទេ ។ គ្រូពេទ្យឈ្មោះជីវកកោមារភច្ច ដែលមានឈ្មោះល្បីល្បាញក្នុងសម័យពុទ្ធកាល ធ្លាប់ព្យាបាលព្រះរោគព្រះអង្គ និងសាវ័កក៏មានកំណើតនៅក្រុងវេសាលីនេះដែរ ។

ព្រះសម្មាសម្ពុទ្ធទ្រង់សព្វព្រះទ័យគង់នៅក្រុងវេសាលីញឹក ហើយកាលមុនបរិនិព្វាន ទ្រង់កង្វល់នឹងទីនេះយ៉ាងខ្លាំង ព្រោះទ្រង់ជ្រាបថា ព្រះបាទអជាតសត្រូវប៉ុងចូលវាយយកក្រុងវេសាលីនេះ ព្រះអង្គក៏នៅគង់ប្រថាប់នៅជិតក្រុងវេសាលីនេះ ១ ឆ្នាំគត់ ។ ព្រះមហានន្ទ ក៏សព្វព្រះទ័យនឹងក្រុងនេះណាស់ដែរ ទ្រង់ព្យាយាមនិមន្តទៅនិព្វាននៅក្រុងនេះ តែកាលដល់លើស្ទឹង ជាព្រំដែនមគធៈនិងវជ្ជី ក៏ពិចារណាថា កុំឱ្យអ្នកដែនមគធៈតូចចិត្ត លោកក៏និព្វានលើអាកាសពីលើស្ទឹងនោះទៅ ។

ដែនវជ្ជី (ក្រុងវេសាលីនិងមិថិលា)មានការគ្រប់គ្រងប្រទេសល្អណាស់ គឺគ្រប់គ្រងជាខត្តិយាធិបតេយ្យ ដោយគ្មានមហាក្សត្រទេ តែមានក្សត្រជាច្រើនផ្តុំគ្នាប្រកបដោយសភាជាទីប្រជុំ១សម្រាប់វិនិច្ឆ័យសេចក្តីផ្សេងៗ តាមមតិភាគច្រើន ។ ព្រះពុទ្ធបានសំដែងអបរិហានិយធម៌ ៧ ប្រការ ជាប្រយោជន៍ដល់ស្តេចលិច្ឆវីនេះដែរ ។ វិធីគ្រប់គ្រងដែននេះមានលក្ខណៈល្អណាស់ ទោះប្រទេសខ្លួនតូចក៏ដោយ ក៏អាចការពាររុកទន្ទ្រានពីប្រទេសធំ ៗ បានដែរ ប៉ុន្តែជាអកុសល ពេលក្រោយព្រះពុទ្ធបរិនិព្វាន ព្រះបាទអជាតសត្រូវ បានប្រើសេនានុភាពចូលវាយ ក៏ប្រើកលល្បិចឱ្យព្រាហ្មណ៍ឈ្មោះវស្សការ ទៅញុះញង់បំបែកសាមគ្គីជនជាតិលិច្ឆវី ទាល់តែបែកបាក់ខ្ទេចខ្ទីអស់ ទើបចូលវាយទន្ទ្រានបានក្នុងកាលជាខាងក្រោយ ។

លោកមៃលចវ័នឡ និយាយថា ក្សត្រលិច្ឆវី ជាសាខាសាក្យវង្សដែរ តែជាសាក្យវង្សវាសិដ្ឋគោត្រ មិនមែនសាក្យវង្ស គោតមគោត្រទេ ពេលដែលព្រះសម្ពុទ្ធទ្រង់ត្រាស់ជាមួយក្សត្រលិច្ឆវី ទ្រង់ហៅថា វាសិដ្ឋ ៗ ។

www.elibraryofcambodia.org

ស. ហេតុដូចម្ដេចបានជាព្រះអង្គទៅបរិនិព្វាននៅទីនោះទៅវិញ ម្ដេចក៏មិនយាងទៅបរិនិព្វាននៅទីឯទៀតៗ ដែលមានទីក្រុងធំ ឬទៅបរិនិព្វានឯក្រុងកបិលព័ស្ដុ ដែលជាជាតិភូមិរបស់ព្រះអង្គវិញ ? ទ្រង់មានតម្រិះយ៉ាងណា ? ព្រះអង្គបានប្រឹក្សានឹងព្រះអានន្ទដូចម្ដេចខ្លះ ?

ច. ហេតុបានជាទ្រង់ចូលទៅបរិនិព្វាននៅទីនោះ ព្រោះក្រុងកុសិនារា[១] នេះកាលពីដើមឈ្មោះថាក្រុង កុសាវតី ។ មានសេចក្ដីដំណាលថា "មុនបរិនិព្វាននោះ ព្រះសាស្ដាទ្រង់ប្រឹក្សារើសទីកន្លែងសម្រាប់បរិនិព្វាននឹងព្រះអានន្ទៗ ក្រាបទូលព្រះអង្គថា "មិនគួរព្រះអង្គយាងមកបរិនិព្វានក្នុងទីក្រុងកុសិនារា ជាក្រុង

---

១. ក្រុងកុសិនារានេះ ស្ថិតនៅក្នុងដែនមល្លៈ ។ ដែនមល្លៈនៅខាងជើងដែនវជ្ជី និង ខាងកើតដែនសក្កៈ ។ ពួកមល្លៈជាត្រកូល១មកពីដែនបាវា និងកុសិនគររាជធានីឈ្មោះ កុសិនគរ ឬកុសិនារា តាំងនៅទីប្រជុំស្ទឹងរប្តំ និងគន្ធកៈ នៅក្នុងដែននេប៉ាល់សព្វថ្ងៃ ។ ដែនមល្លៈនេះ កាលពីដើមមានរាជធានីឈ្មោះកុសាវតី តែក្រោយមកចែកជា ២ គឺរាជ ធានីកុសិនារា និងបាវា ។ កុសិនារា សព្វថ្ងៃហៅថាកាស្យា (Kacia) ឯក្រុងបាវាហៅថា បដ្រវូនៈ ។

លោករីស ដាវិត សរសេរថា រាជធានីនៃពួកមល្លៈមានពីរគឺ កុសិនារា, បាវា ហើយផ្លាស់ប្ដូរទីប្រជុំម្ដងម្នាក់ៗ និងមានរបៀបគ្រប់គ្រងរដ្ឋដូចដែនវជ្ជី ឬលិច្ឆវី និង

www.elibraryofcambodia.org

តូចដូច្នេះទេ" ហើយព្រះអានន្ទបានថ្វាយយោបល់ចំពោះព្រះអង្គថា គួរព្រះអង្គយាងទៅបរិនិព្វាននៅក្រុងធំៗទាំង ៦ ក្រុងណាមួយក៏បានដែរគឺ :

១. ក្រុងចម្បា ដែន អង្គៈ

២. រាជគ្រឹះ ដែន មគធៈ

៣. សាវត្ថិ ដែន កោសល

៤. សាកេត ដែន កោសល

---

វិទេហៈដែរ ។ នៅវេលាចែកព្រះបរមសារីរិកធាតុ ដែនមល្លៈបានពីរចំណែកគឺ ក្រុងកុសិនារា ១ ចំណែក បាវា ១ចំណែក ។

លោកវិមលចរ័នឡ សរសេរថា ដែនមល្លៈមានរាជធានីចំនួនពីរគឺ រាជធានីកុសិនារា១ បាវា១ ហើយមានក្រុងធំដទៃពីរកន្លែងទៀតគឺ អនុមិយា១. នរុវេលកប្ប១ ហើយក្សត្រមល្លៈ ក៏ជាវាសិដ្ឋគោត្រដូចពួកលិច្ឆវីដែរ ព្រោះកាលព្រះអានន្ទទៅថ្វាយពត៌មានអំពីពុទ្ធបរិនិព្វាននោះ លោកក៏ប្រើពាក្យហៅមល្លក្សត្រថា វាសិដ្ឋ ។ ព្រះពុទ្ធបរិនិព្វាននៅមល្ល ខាងក្រុងកុសិនារា មិនមែនមល្លខាងក្រុងបាវាទេ ។

លោកវិមលរ័នឡ អាងដល់គម្ពីរមហាវង្ស និងកុសិជាតកថា ក្រុងកុសាវតីជាឈ្មោះក្រុងដែលព្រះបាទនិក្ខាគរាជជើមវង្សសាក្យៈ គ្រប់គ្រងរាជសម្បត្តិតាំងពីអតីតកាលមក ។ កាលមានរឿងរាជសម្បត្តិកើតស្មុគស្មាញ ព្រះអង្គក៏បញ្ជូនរាជបុត្រ-ធីតា ៩ អង្គឱ្យចេញសាងនគរថ្មីទៀត ។ ដូច្នេះបានជាក្នុងគម្ពីរជីកាថា សក្កជនបទចែកជា ៣ នគរគឺ នគរដើមរបស់ព្រះបាទនិក្ខាគរាជ១ នគរកបិលព័ស្តុ១ នគរទេវទហៈ១ ។

www.elibraryofcambodia.org

៥. កោសម្ពី ដែន វង្សៈ

៦. ពារាណសី ដែន កាសី

ដែលជាក្រុងធំៗ មានមហាជនច្រើននោះវិញ ដែលព្រះអង្គគួរបរិនិព្វាន ប៉ុន្តែព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា "ក្រុងកុសិនារានេះ កាលពីដើមជាក្រុងធំណាស់ឈ្មោះកុសាវតី មានស្ដេចចក្រពត្តិសោយរាជ្យនាមព្រះបាទសុខស្សនៈ ដូច្នេះបានជាតថាគតមកបរិនិព្វាននៅទីនេះ ។

មួយវិញទៀត តាមសេចក្ដីដំណាលថា បានជាទ្រង់មកបរិនិព្វាននៅទីនោះ ព្រោះក្រុងកុសិនារានេះមានអាចារ្យម្នាក់ឈ្មោះទោណព្រាហ្មណ៍ ដែលមានឈ្មោះល្បីល្បាញ មានសមត្ថភាពអាចចែកព្រះបរមសារីរិកធាតុបាន ។ ដូច្នេះហើយបានជាពេលបូជាសពព្រះអង្គរួច មានកើតជម្លោះរហូតទល់ជិតច្បាំងគ្នា តែបាននោះទោណព្រាហ្មណ៍ដោះស្រាយចែកព្រះសារីរិកធាតុឱ្យស្រួលរឿងនោះក៏ស្ងប់ទៅវិញ ។

សួរ៖ មុននឹងបរិនិព្វានព្រះអង្គបានមានព្រះពុទ្ធដីកានឹងព្រះអានន្ទយ៉ាងណាខ្លះ ? ព្រះអានន្ទអាចដោះស្រាយរួចឬទេ ?

ឆ្លើយ៖ ទ្រង់សួរព្រះអានន្ទដោយន័យផ្សេងៗ អំពីឥទ្ធិបាទធម៌ ៤ ក៏ប៉ុន្តែព្រះអានន្ទពុំយល់ ទើបព្រះអង្គពន្យល់ដោយសព្វគ្រប់

www.elibraryofcambodia.org

រួចត្រាស់ថា "តថាគតនឹងបរិនិព្វានក្នុងថ្ងៃនេះ" ។ ព្រះអានន្ទទ្រង់ចេញទៅគង់យំ នៅក្បែរទ្វារនគរយ៉ាងខ្លាំង ទើបព្រះអង្គត្រាស់ហៅព្រះអានន្ទមកហើយ ត្រាស់សរសើរព្រះអានន្ទថា ជាអ្នកមានគុណសម្បត្តិយ៉ាងច្រើនរួចទ្រង់ឱ្យព្រះអានន្ទ ទៅថ្វាយដំណឹងដល់មល្លក្សត្រ ។

( រឿងនេះ កាលការកសង្ឃធ្វើបឋមសង្គាយនា (ការប្រជុំរៀបចំធម៌វិន័យ ជាលើកដំបូងនៅក្រុងរាជគ្រឹះនារដូវភ្លៀង) រួចហើយព្រះមហាកស្សបត្ថេរ ទ្រង់ចោទទោសព្រះអានន្ទថា "ព្រះអានន្ទមិនបានទូលសុំឱ្យព្រះពុទ្ធបរមគ្រូ គង់បន្តព្រះជន្មាទៅទៀតនៅពេលដែលព្រះអង្គទ្រង់ឱ្យន័យ ដល់ព្រះអានន្ទ" ) ។

ស- កាលមុនបរិនិព្វាន ព្រះសាស្ដាទ្រង់ហៅអានន្ទមកសរសើរហើយ តើទ្រង់ទូន្មានផ្ដាំព្រះឱវាទចុងក្រោយបង្អស់យ៉ាងណាដែរ ?

ច- ទ្រង់ផ្ដាំព្រះអានន្ទថា "ម្នាលអានន្ទ ! ធម៌និងវិន័យទាំងឡាយដែលតថាគត បានសម្ដែង[illegible]ប្រាមរួចហើយ នឹងបានជាគ្រូបាអាចារ្យ របស់អ្នកនៅពេលអស់ពីតថាគតទៅ, ជនណា, អ្នកណា ដែលបានបូជាដល់តថាគតដោយគ្រឿងអាមិស ជននោះមិនឈ្មោះថា ជាអ្នកស្រឡាញ់រាប់អានបូជាតថាគតទេ លុះតែជន

www.elibraryofcambodia.org

នោះបានប្រតិបត្តិឱ្យពិតដល់តាមធម៌វិន័យ ដែលតថាគតបានហាមប្រាមសំដែងហើយទើបឈ្មោះថា ជាអ្នកគោរពស្រឡាញ់រាប់អានបូជាដល់តថាគតយ៉ាងពិតប្រាកដ ដូច្នេះចូរអ្នកទាំងឡាយ ប្រឹងប្រែងធ្វើប្រយោជន៍របស់ខ្លួននឹងអ្នកដទៃ ឱ្យសម្រេចដោយសេចក្តីមិនប្រមាថចុះ នេះជាឱវាទចុងក្រោយបង្អស់ ឬឱវាទពៅរបស់តថាគត ។

ស- ក្រៅពីនេះ តើអ្នកមានអ្នកណាចូលទៅសួរទាក់ទងពីរឿងអ្វីនឹងព្រះអង្គទៀតដែរ ?

ច- មានសុភទ្ទបរិព្វាជក បានចូលទៅសួរប្រស្នាព្រះអង្គ១ ប្រទានធម៌ចប់ សុភទ្ទបរិព្វាជក ក៏បានសម្រេចព្រះអរហត្តផល បានជាសាវ័កពៅបង្អស់របស់ព្រះអង្គ (សាវ័កច្បងគឺព្រះកោណ្ឌញ្ញត្ថេរ) ។

ស- ព្រះសម្មាសម្ពុទ្ធជាបរមគ្រូ ទ្រង់ចូលបរិនិព្វានដោយអាការដូចម្តេច ? មានហេតុចម្លែកយ៉ាងណាទេ ?

ច- ព្រះអង្គទ្រង់ផ្ទំផ្អៀងទៅខាងស្តាំ បែរព្រះសិរទៅខាងជើង ព្រះភក្ត្រទៅលិចនៅចន្លោះដើមរាំងទាំងគូ ។

មុនបរិនិព្វានទ្រង់ចូលបឋមជ្ឈាន, ទុតិយជ្ឈាន, តតិយ-ជ្ឈាន, ចតុត្ថជ្ឈាន រួចចូលអាកាសានញ្ចាយតនសមាបត្តិ វិញ្ញាណ

www.elibraryofcambodia.org

ញ្ញាយតនសមាបត្តិអភិញ្ញាយតនសមាបត្តិ. នេវសញ្ញានាសញ្ញាយតនសមាបត្តិ. សញ្ញាវេទយិតនិរោធ រួចចេញពីសញ្ញាវេទយិតនិរោធ មកកាន់អភិញ្ញាយតនសមាបត្តិ (វៀលងនេវសញ្ញានាសញ្ញាយតនសមាបត្តិ)។ ច្រាសរហូតដល់បឋមជ្ឈាន ហើយចូលបណ្តោយទៅវិញដល់ចតុត្ថជ្ឈាន. រួចចេញពីចតុត្ថជ្ឈាន ក៏ទ្រង់ចូលបរិនិព្វាន់នៅពេលនោះ ព្រះធរណីក៏កក្រើករំពើកយ៉ាងខ្លាំង

ស. មុនពេលទ្រង់បរិនិព្វាន ព្រះអង្គទ្រង់ប្រឈួនដែរ ឬគ្មានទេ ?

ច. ទ្រង់ប្រឈួនដែរ ។

ស. ទ្រង់ប្រឈួនដោយរោគអ្វី ?

ច. ទ្រង់ប្រឈួនដោយរោគធ្លាក់ឈាម ។

ស. រោគធ្លាក់ឈាមនោះជារោគធម្មតាទេ ឬដោយមានហេតុយ៉ាងណាដែរ ?

ច. ដោយមកពីព្រះអង្គមានពៀរពីអតីតជាតិ ។ មានសេចក្តីដំណាលថា "កាលពីអតីតជាតិយូរលង់ណាស់មកហើយ ទ្រង់កើតជាឈ្មួញរទេះ បានបរគោរទេះទៅដល់ស្ទឹងមួយ គោក៏ស្រេកទឹកទាញរទេះទៅរកទឹកផឹក តែព្រះអង្គទ្រង់ក្រោធក៏ទាញគោបង្អត់ទឹក ។ លុះព្រះអង្គរៀបចូលបរិនិព្វាន ទ្រង់ស្រេកទឹក

www.elibraryofcambodia.org

ណាស់ បានប្រើអានន្ទឱ្យទៅដងទឹកយកមកសោយ ព្រះអានន្ទរកទឹកល្អពុំបាន ព្រោះទឹកស្ទឹងជិតនោះល្អក់ទាំងអស់ ដោយមានឈ្មួញរទេះ ៥០០ ទើបនឹងបររទេះទៅថ្មី ៗ. ទៅត្រង់ណាក៏ល្អក់ទាំងអស់ ព្រះអានន្ទមកទូលព្រះអង្គថា : គ្មានទឹកល្អទេ ព្រះអង្គទ្រង់ធ្លាក់ឈាមហើយស្រេកទឹកខ្លាំង ក៏បង្គាប់អានន្ទថាទឹកនោះមិនល្អក់ទេ ចូរអានន្ទដងមកចុះ ព្រះអានន្ទក៏ដងតាមព្រះពុទ្ធដីកាយកមកថ្វាយព្រះអង្គ ទឹកក៏ថ្លាវិញ ហើយព្រះអង្គទ្រង់សោយទៅ

ស. ព្រះបរមសាស្តាចារ្យទ្រង់បរិនិព្វាន ទៅថ្ងៃខែឆ្នាំណារដូវណា ? នៅទីណា ? ក្នុងព្រះជន្មប៉ុន្មាន ? ក្រោយពេលបានដឹងហើយប៉ុន្មានឆ្នាំ ?

ច. ទ្រង់បរិនិព្វាន នៅថ្ងៃអង្គារ ១៥ កើត ខែពិសាខ ឆ្នាំម្សាញ់នាគិម្ហរដូវ នៅក្រោមដើមសាលព្រឹក្សទាំងគូ [១] លើផ្ទាំងថ្មក្នុងសាលវ័ន ជិតក្រុងកុសិនារារបស់ពួកមល្លក្សត្រ ក្នុងដែនមល្ល:

---

១. ធ្លាប់ឮមកថា ដើមសាលព្រឹក្សទាំងគូនិងផែនថ្មនេះ កើតយូរហើយនៅត្រង់កន្លែងនេះ គឺកាលពីពេលកន្លងយូរណាស់មកហើយ ក្មេងគង្វាលគោ (ប្រហែលជាព្រះពោធិសត្វនៃយើង) បាននាំគោទៅឃ្វាលនៅទីនោះ។ កាលក្មេងចុះក្នុងទឹកឈើងក៏ទាមជាប់ ហើយចាប់ឈើងនោះយកមែកសាលព្រឹក្សពីរដោតសន្ទឹងទៅជើងទៅត្បូង ។ ឈើងក៏ក្លាយជាផែនថ្ម ឯមែកសាលព្រឹក្សក៏ដុះធំឡើង ហើយនៅរហូតទល់ព្រះពុទ្ធ បរិនិព្វាន ។ នេះជារឿងព្រេងដូចរឿងភ្នំនាងកង្រីខ្មែរយើងនៅខេត្តកំពង់ឆ្នាំងដែរមើលទៅ ។

www.elibraryofcambodia.org

នៅព្រះជន្ម៨០ ឆ្នាំគត់ក្រោយពេលបានត្រាស់ដឹងហើយ៤៥ ឆ្នាំ ។

ស-ព្រះបរមសពនៃព្រះសម្ពុទ្ធ គេដំកល់ទុក ឬបូជាភ្លាម?

ច- គេដំកល់ទុកចំនួន ៧ ថ្ងៃ ។

ស- គេដំកល់ទុកនៅទីណា ? បានធ្វើអ្វីខ្លះដល់ព្រះសព ? អ្នកណាជាអ្នកចាត់ការ ?

ច- គេដំកល់ទុកនៅ មកុដពន្ធនចេតិយ ត្រង់ទិសបូព៌ នៃទីក្រុង ហើយមល្លក្សត្រ និងទេពតាព្រមទាំងមហាជន បានធ្វើសក្ការបូជាដោយរបាំតន្ត្រី គ្រឿងក្រអូបអស់រយៈវេលា ៦ ខែ ។ អ្នកចាត់ការផ្នែកសាវ័កមានព្រះអនុរុទ្ធ និងព្រះអានន្ទជាប្រធាន ព្រមទាំងពួកគ្រហស្ថ មានពួកមល្លក្សត្រ ៨ អង្គជាសមាជិក ។

ស- គេធ្វើពិធីថ្វាយព្រះភ្លើងនៅថ្ងៃណា ? នៅទីណា ? មានហេតុចំឡែកអស្ចារ្យអ្វីដែរឬទេ ? ព្រោះហេតុអ្វី ?

ច- គេធ្វើពិធីថ្វាយព្រះភ្លើងនៅថ្ងៃអង្គារ៧រោជ ខែពិសាខ នៅមកុដពន្ធនចេតិយ ខាងកើតក្រុង ។ មានសេចក្តីដំណាលថា "កាលពួកមល្លក្សត្រទាំង៨ អង្គដែលជាអ្នកចាត់ការបុណ្យបានគិតរំកិលព្រះសពដង្ហែចេញទៅទិសខាងត្បូងហើយ នឹងថ្វាយព្រះភ្លើង នៅខាងត្បូងព្រះរាជវាំង លុះគិតរួចហើយ ក៏រំកិលព្រះសព តែពុំរួចសោះ។ មល្លក្សត្រសួរព្រះអនុរុទ្ធ ១ ថ្វាយពត៌មានថាមកពី

www.elibraryofcambodia.org

ខុសបំណងទេពតា ។ តមកមល្លក្សត្រព្រមព្រៀងគ្នាថា នឹងរំកិល ព្រះសពដង្ហែចេញទៅទិសខាងជើង បត់ទៅលិច រួចចូលទៅកាន់ក្រុងតាមទ្វារខាងជើង កាត់ទីក្រុងរួចចេញតាមទ្វារខាងកើត ហើយតំកល់ព្រះសពនៅមកុដពន្ធនៈ ចេតិយដដែល រួចថ្វាយព្រះភ្លើង។ គិតរួចក៏រំកិលព្រះសពបានកម្រើកដោយស្រួល រួចធ្វើតាមដំណើរនោះ ។ នៅពេលបូជាព្រះភ្លើង១ពុំឆេះឡើយ មល្លក្សត្រសង្ស័យក៏ទូលសួរព្រះអនុរុទ្ធ ១ ថ្វាយពតីមានថា ព្រះមហាកស្សបត្ថេរ (១) ពុំទាន់និមន្តមកដល់ ។

---

១. ព្រះមហាកស្សបត្ថេរនេះ មានព្រះវ័យចាស់ជាងព្រះអង្គ ហើយជាទំនុកទុកព្រះទ័យរបស់ព្រះអង្គណាស់ ។ ព្រះអង្គកាលគង់ព្រះជន្មនៅ ធ្លាប់ផ្លាស់ប្តូរប្រទានចីវរជាមួយព្រះកស្សបៈប្រើប្រាស់ ។ លោកជាប្រធានសង្ឃក្នុងបឋមសង្គាយនា ជាអ្នកចោទសួរបិដកទាំង ៣ ចំពោះព្រះឧបាលី និងព្រះអានន្ទ ។ កាលលោកបរិនិព្វានទៅ គេយកព្រះសពលោកទៅបញ្ចុះឥតបូជាទេ ។ មឈូសនៃព្រះសពនេះនៅរហូតទល់ព្រះសិអារ្យមេត្រី បានត្រាស់ហើយហៀបបរិនិព្វានទៅវិញ ។

សេចក្តីដំណាលថា កាលពីអតីតជាតិ ព្រះសិអារ្យមេត្រីបានកើតជាហ្មថាវ ព្រះកស្សបៈកើតជាដំរី ។ ពេលមួយហ្មថាវបានប្រើដំរីឱ្យឱបដែកក្តៅថ្វាយព្រះរាជាទតកម្មពៀរក៏ពុំទាន់ស្ងប់នៅឡើយ ។ ដល់ពេលព្រះសិអារ្យបានត្រាស់ទេសនាប្រោសសត្វគ្រប់ ៥០០០ ឆ្នាំហើយហៀបបរិនិព្វាន មឈូសព្រះសពព្រះមហាកស្សបៈក៏ផុសពីដីអណ្តែតទៅរកព្រះសិអារ្យ១ទតឃើញ ក៏យកព្រះហស្តទ្រមឈូស១ ក៏ឆេះលើព្រះហស្តព្រះសិអារ្យ ១ ក៏ចូលបរិនិព្វាននៅពេលនោះឯង ។ នេះមកពីកម្មពៀរកាលហ្មថាវប្រើដំរីឱ្យឱបដែកក្តៅពីមុននោះ ។

www.elibraryofcambodia.org

កាលលោកនិមន្តមកដល់ ព្រះបាទទាំងគូររបស់ព្រះសពក៏លៀន ចេញពីមឈូសមាស ព្រះមហាកស្សបះបានថ្វាយបង្គំរួច ព្រះអគ្គី ក៏ឆេះឯងភ្លាម ។

ស- ព្រះបរមសព បានឆេះអស់ ឬនៅសល់អ្វីដែរ ?

ច- នៅសល់ព្រះអដ្ឋិធាតុទាំងអស់ឥតឆេះទេ ។

ស- ព្រះអដ្ឋិធាតុដែលនៅសល់នោះ មានលក្ខណៈយ៉ាង ណាខ្លះ ? ប៉ុន្មានណា ?

ច- ព្រះអដ្ឋិធាតុដែលនៅនោះមានពីរចំណែកគឺ ព្រះអដ្ឋិ ធាតុដែលនៅល្អ មិនបាក់បែក ១ ផ្នែក. ព្រះអដ្ឋិធាតុដែលបាក់ បែក ១ ផ្នែក ។

ព្រះធាតុដែលមិនបាក់បែកមាន ៧ ព្រះអង្គគឺ : ឆ្អឹងថ្ងាស (ព្រះឧណ្ហីសធាតុ )១. ព្រះចង្កូមកែវ (ព្រះទាឋាធាតុ) ទាំង៤ និង ឆ្អឹងដងកាំបិតព្រះអក្ខកធាតុទាំង ២ ។

ព្រះធាតុក្រៅពីនេះ សុទ្ធតែបែកបាក់ជាបំណែកធំខ្លះតូច ខ្លះ គឺ :

ព្រះធាតុខ្នាតធំបំផុត មានទំហំប៉ុនមួយកំណាត់គ្រាប់ សណ្តែកបាយ មានពណ៌ដូចមាសហើយមានទម្ងន់ ៥ នាឡិ ។

ព្រះធាតុខ្នាតកណ្តាលមានទំហំប៉ុនមួយកំណាត់គ្រាប់អង្ករ

www.elibraryofcambodia.org

មានពណ៌ដូចកែវផ្លេក ហើយមានទម្ងន់ ៦ នាឡិ ។

ព្រះធាតុខ្នាតតូចមានទំហំប៉ុនគ្រាប់ស្ពៃ មានពណ៌ដូចផ្កាថ្កុល មានទម្ងន់ ៥ នាឡិ ។

ស- កាលគេបូជាហើយ តើគេយកព្រះធាតុទៅដំកល់ទុកនៅទីណា ?

ឆ- ពួកមល្លក្សត្របានរើសព្រះបរមសារីរិកធាតុដង្ហែយកទៅដំកល់ទុកនៅក្នុងព្រះរាជវាំង ហើយធ្វើសក្ការបូជាអស់ ៧ ថ្ងៃទៀត ។

ស- ព្រះសារីរិកធាតុទាំងអស់ តើគេដំកល់ទុកតែ ១ កន្លែង ឬ ចែកទៅនគរផ្សេងទៀតដែរ ?

ឆ- គេចែកទៅតាមនគរចំនួន ៨ គឺ :

| | |
|---|---|
| ១- នគររាជគ្រឹះ | មគធរដ្ឋ |
| ២- នគរវេសាលី | វជ្ជីរដ្ឋ |
| ៣- នគរកបិលព័ស្តុ | សក្កជនបទ |
| ៤- នគរអល្លកប្បៈ | ពូលិរដ្ឋ |
| ៥- នគររាមគ្រាម | កោលិយរដ្ឋ |
| ៦- ពួកព្រាហ្មណ៍ | នៅវេដ្ឋទីបករដ្ឋ |
| ៧- នគរបាវា | មល្លរដ្ឋ |

www.elibraryofcambodia.org

៨. នគរកុសិនារា មល្លរដ្ឋ

នគរទាំង ៨ នេះបានចំណែកនៃព្រះបរមគ្រូសារីរិកធាតុស្មើ ៗ គ្នា គឺ នគរមួយបានពីរនាឡិ១ ។

នៅពេលគេចែកព្រះសារីរិកធាតុរួច ក្សត្រមោរិយៈ ពួកអ្នកក្រុងបិប្ផលិវ័ន បានបញ្ជូនទូតទៅដែរ តែមិនបានទាន់នឹងគេទេ ពួកមល្លក្សត្របានឱ្យតែព្រះអង្គារ (ធ្យូង) ដល់ពួកទូតមោរិយៈ១ ក៏ព្រមយក ។

ស. អ្នកណាជាអ្នកចែកព្រះបរមសារីរិកធាតុ. បើគ្មានអ្នកនោះទេ តើគេអាចចែកបានទេ ?

ច. អាចារ្យឈ្មោះទោណព្រាហ្មណ៍ជាអ្នកចែក ។ បើគ្មានទោណព្រាហ្មណ៍នេះទេ នឹងកើតចម្បាំងយ៉ាងខ្លាំងមិនខាន ។

ស. អាចារ្យទោណព្រាហ្មណ៍ជាមេចំណែក បានចំណែកព្រះសារីរិកធាតុនឹងគេទេ ?

ច. ឥតបានទេ បានតែតុម្ពសម្រាប់វាល់ព្រះបរមសារីរិកធាតុប៉ុណ្ណោះ ហើយគាត់ក៏យកតុម្ពនោះទៅធ្វើចេតិយបញ្ចុះក្នុងក្រុងកុសិនារាដែរ[១] ។

---

១. ពួកមកថា ទោណព្រាហ្មណ៍បានយកព្រះចង្កូមកែវ១ ទៅលាក់នៅផ្នួងសក់ តែទេវតាបានយកទៅទៀត ហើយយកទៅបញ្ចុះនៅចូឡាមណិចេតិយនៅស្ថានតាវត្តិង្ស ។

www.elibraryofcambodia.org

ក្សត្រទាំង ៨ នគរ និងនគរបិប្ផលិវ័ន ១ ទៀតជា ៩ បាន យកព្រះបរមសារីរិកធាតុ ទៅធ្វើជាស្តូបបញ្ចុះនៅក្នុងក្រុងរបស់ខ្លួនរៀងរាល់អង្គ ។ រាប់ទាំងព្រះស្តូបដែលបញ្ចុះព្រះតុម្ពរបស់ទោណព្រាហ្មណ៍ ១ ផងទៀតព្រះស្តូបមាន ១០ ដែលស្ថិតនៅក្នុងជម្ពូទ្វីបនេះ ។

ស. ព្រះធាតុដែលបាក់សុទ្ធតែបានចែកទៅតាមនគររៀងរាល់ទៅហើយ ចុះព្រះធាតុដែលមិនបាក់បែក តើបានទៅណាខ្លះ ?

ច. ព្រះធាតុទាំងនេះ បានទៅប្រតិស្ឋានក្នុងកន្លែងទាំងនេះគឺ :

ព្រះចង្កូមកែវស្តាំលើ ប្រតិស្ឋាននៅ ស្ថានត្រៃត្រឹង្ស

ព្រះចង្កូមកែវស្តាំក្រោម ប្រតិស្ឋាននៅ សីហឡទ្វីប

ព្រះចង្កូមកែវឆ្វេងលើ ប្រតិស្ឋាននៅ ដែនគន្ធារៈ

ព្រះចង្កូមឆ្វេងក្រោម ប្រតិស្ឋាននៅ នៅពិភពនាគ

ឆ្អឹងដងកាំឆ្វេងទាំងបីអង្គ ប្រតិស្ឋាននៅព្រហ្មលោក ឯឆ្អឹងដងកាំបិតស្តាំ មិនប្រាកដថាប្រតិស្ឋាននៅទីណា ឯព្រះឧណ្ហីសធាតុ ( ឆ្អឹងថ្ងាស ) ក៏មិនឮថាប្រតិស្ឋាននៅទីណាដែរ ។

បំណែកខាងព្រះកេសធាតុ, ព្រះទន្តធាតុ ៤០, ព្រះលោមធាតុ ( រោម ) ព្រះនខធាតុ ( ក្រចក ) ពួកទេពតានាំយកមួយអង្គ ១

www.elibraryofcambodia.org

ទៅចក្រវាឡដទៃទាំងអស់ ។

ស. ចុះព្រះពុទ្ធបរិក្ខារតើមានប៉ុន្មាន? កាលព្រះអង្គបរិនិព្វានទៅគេយកពុទ្ធបរិក្ខាទាំងនោះ ទៅបញ្ចុះទុកក្នុងទីណា ?

ឆ. ពុទ្ធបរិក្ខារមាន ១០ យ៉ាង ។ កាលព្រះអង្គបរិនិព្វានទៅគេយកពុទ្ធបរិក្ខារទាំងនោះទៅក្នុងទីផ្សេងៗគឺ :

១. ត្រៃចីវរ បានទៅប្រទេស ភទ្ទ

២. សំពត់ឧទកសាដក បានទៅប្រទេស បញ្ចាលរាជ

៣. សំពត់ចម្មក្ខន្ធ បានទៅប្រទេស កោសល

៤. កាយពន្ធ និងបាត្រ បានទៅប្រទេស បាតលិបុត្ត

៥. ទ្រនាប់ព្រះបាទនិងស្បោកបាត្រ បានទៅប្រទេសស្រុកឧសិព្រាហ្មណ៍

៦. គ្រឿងកម្រាល បានទៅប្រទេស នគរមកុដ

៧. និសីទនសន្ថត បានទៅប្រទេស កុរុរដ្ឋ

៨. កាំបិតកោរនិងបំពង់ម្ជុល បានទៅប្រទេស ឥន្ទបត្ត

៩. សំពត់តម្រងទឹក បានទៅប្រទេស វិទេហរដ្ឋ

១០. ឈើស្ទន់ បានទៅប្រទេស មិថិលា ។

ស. កាលមុនព្រះសាស្ដាទ្រង់ចូលបរិនិព្វាន តើព្រះអង្គបានតាំងព្រះមហាថេរអង្គណាជាសង្ឃនាយក ( អ្នកគ្រប់គ្រងសង្ឃ )

www.elibraryofcambodia.org

ដែរ ? ព្រោះហេតុអ្វី ?

ច- ទ្រង់ពុំបានតាំងព្រះមហាថេរអង្គណាជាសង្ឃការីទេ ព្រោះទ្រង់ក្រែងសង្ឃការីនោះ ពុំបានធ្វើកិច្ចការផ្សេងៗ ឱ្យបានដូចព្រះអង្គផង ហើយពុំមានសមត្ថភាពឱ្យស្មើនឹងព្រះអង្គផង ម្យ៉ាងទៀតព្រះអង្គគ្រាន់តែទ្រង់ផ្តាំផ្ញើនូវបច្ឆិមពុទ្ធវចនៈ ចំពោះព្រះអានន្ទប៉ុណ្ណោះ ហើយក្រោយបឋមសង្គាយនា ព្រះអានន្ទក៏បាននិមន្តទៅទេសនាប្រោសមហាជន ប្រហាក់ប្រហែលនឹងព្រះអង្គដែរ ។ ដូច្នេះព្រះមហាអានន្ទដែលជាពុទ្ធុបដ្ឋាករបស់ព្រះអង្គនេះក៏ទុកស្មើនិងសង្ឃការីដែរ ។ មួយចំណែកពិសេសទៅទៀតព្រះពុទ្ធសាសនាយើង បើយោងទៅតាមព្រះបរមពុទ្ធោវាទជាបច្ឆិមពុទ្ធវចនៈ ក៏យើងអាចយល់បានថា មិនបាច់មានសង្ឃការីក៏បានដែរ ឱ្យតែអ្នកណាបានប្រតិបត្តិត្រឹមត្រូវតាមធម៌ ដែលព្រះអង្គទ្រង់បញ្ញត្តិសំដែងហើយ ក៏ឈ្មោះថា គោរពព្រះសាស្តាហើយ អាចធ្វើឱ្យពុទ្ធសាសនារុងរឿងបានដែរ ។ ឯព្រះធម៌ទាំង៨៤០០០ ព្រះធម្មក្ខន្ធនេះឯង ក៏គឺតួអង្គព្រះសម្មាសម្ពុទ្ធហ្នឹងឯង ។ ដោយហេតុនេះហើយ បានជាពេលមុនបរិនិព្វាន ព្រះសាស្តាទ្រង់ពុំបានតាំងព្រះមហាថេរអង្គណាជា សង្ឃការី គឺជាអ្នកកាន់កាប់ថែរក្សាព្រះសង្ឃជំនួសព្រះអង្គតមកដូចសាសនាឯទៀតៗ ឡើយ គឺគ្រាន់

www.elibraryofcambodia.org

តែផ្ដាំនឹងព្រះអានន្ទជាព្រះបណ្ដាំពៅបង្ហស់ថា "ធម៌ណា វិន័យណា ដែលតថាគតបានសំដែងហើយ ហាមប្រាមហើយ នឹងបានជាគ្រូបារបស់អ្នករាល់គ្នា" តែប៉ុណ្ណោះ ។

ចំពោះព្រះមហាអានន្ទ ដែលជាអ្នកគាល់បំរើព្រះសាស្ដា (ពុទ្ធុបដ្ឋាក) ដែលចេះចាំធម៌វិន័យទាំងអស់ពីព្រះពុទ្ធអង្គ ក៏ព្រះអង្គពុំបានតាំងជាអ្វីដែរ ព្រោះអានន្ទពេលនោះទើបនឹងបានសម្រេចត្រឹមសោតាបត្តិផលតែប៉ុណ្ណោះ ។

ស. ព្រះសម្ពុទ្ធទ្រង់ប្រតិស្ឋានព្រះសាសនារបស់ព្រះអង្គប៉ុន្មានឆ្នាំទៅអនាគតដែរ ? ព្រះពុទ្ធសាសនានេះនឹងគ្រប់នៅឆ្នាំណា ?

ច. ព្រះសមណគោតមសម្មាសម្ពុទ្ធ ទ្រង់ប្រតិស្ឋានព្រះពុទ្ធសាសនាចំនួន ៥០០០ ឆ្នាំ ហើយព្រះពុទ្ធសាសនានឹងគ្រប់ ៥០០០ វស្សានៅឆ្នាំផុត ។

ស. កាលព្រះពុទ្ធបរិនិព្វានទៅ តើមានអ្វីជាតំណាងដែរ? មានប៉ុន្មានយ៉ាង អ្វីខ្លះ ?

ច. មាន ៥ យ៉ាងគឺ ១.ព្រះបដិមាករ, ២.ពោធិព្រឹក្ស, ៣.ព្រះស្ដូប, ៤.ព្រះសារីរិកធាតុ, ៥.ព្រះធម៌ទាំង ៨ ម៉ឺន ៤ពាន់ព្រះធម្មក្ខន្ធ ។

www.elibraryofcambodia.org

ស- ព្រះពុទ្ធសាសនារុងរឿងដោយហេតុប៉ុន្មានយ៉ាង ? អ្វីខ្លះ ?

ច- ព្រះពុទ្ធសាសនារុងរឿងដោយហេតុ ៥ យ៉ាងគឺ :

**១- សក្កច្ចំ ធម្មំ សុណន្តិ** ស្តាប់ធម៌ដោយគោរព

**២- សក្កច្ចំ ធម្មំ បរិយាបុណន្តិ** រៀនធម៌ដោយគោរព

**៣- សក្កច្ចំ ធម្មំ ធារេន្តិ** ទ្រទ្រង់ធម៌ដោយគោរព

**៤- សក្កច្ចំ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ** ពិចារណានូវសេចក្តីនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ដោយគោរព ។

**៥- សក្កច្ចំ អត្ថមញ្ញាយ បដិបជ្ជន្តិ** ដឹងសេចក្តីហើយប្រតិបត្តិធ្វើតាមដោយគោរព ។

ការបានត្រាស់ដឹងជាព្រះពុទ្ធ. ការយាងប្រោសសត្វជាពុទ្ធសកម្មនៅគ្រប់ទីកន្លែងច្រកល្ហក បាននាំមកនូវផលប្រយោជន៍ដ៏សំខាន់ពីរយ៉ាង ម្យ៉ាងប្រយោជន៍នៅក្នុងបច្ចុប្បន្ន គឺដឹកនាំសត្វលោកឱ្យមានសណ្តាប់ធ្នាប់ ប្រកបដោយរបៀបរៀបរយដ៏ល្អ ដែលជាហេតុនាំឱ្យបានសន្តិសុខសន្តិភាព មានវិន័យថ្លៃថ្នូរប្រកបដោយមនុស្សធម៌ដ៏ខ្ជាប់ខ្ជួន ម្យ៉ាងទៀតគឺនាំសត្វលោកឱ្យបាននូវសម្បត្តិដ៏ពិសេស 'គឺលោកុត្តរសម្បត្តិមានមគ្គផល រហូតដល់ព្រះនិព្វាន ជាស្ថានក្សេមផុតចាកទុក្ខទាំងពួង ហើយមិនត្រឡប់ប្រែ

www.elibraryofcambodia.org

ជាមានទុក្ខសោកវិញឡើយ សត្វលោកសឹងបានសម្រេចកុសល សម្បត្តិនេះជាច្រើន ។ ផលនេះសុទ្ធតែកើតពីព្រះបរមពុទ្ធោវាទទាំងអស់ ។ ព្រះបរមពុទ្ធោវាទទាំង ៨៤ ០០០ ព្រះធម្មក្ខន្ធ ដែលព្រះអង្គទ្រង់សំដែងហើយអស់រយៈពេល ៤៥ ឆ្នាំ បើរួមមកមានតែ ៣ យ៉ាងគឺ :

១- សព្វបាបស្សអករណំ = ការមិនធ្វើអំពើបាបគ្រប់យ៉ាង បានដល់ព្រះវិន័យបិដក ។

២- កុសលស្សូបសម្បទា = ការបំពេញធ្វើអំពើជាកុសល បានដល់ព្រះសុត្តន្តបិតក ។

៣- សចិត្តបរិយោទបនំ = ការញ៉ាំងចិត្តឱ្យផូរផង់គឺការជម្រះចិត្តឱ្យស្អាតចាកគ្រឿងសៅហ្មង បានដល់អភិធម្មបិដក។

ដូច្នេះព្រះពុទ្ធសកម្មទានា ដែលទ្រង់បានបំពេញរួចហើយ គឺជាទឹកព្រះទ័យដ៏ស្អាតបរិសុទ្ធ ឬ ជាពុទ្ធហឫទ័យដែលព្រះអង្គបានលាតត្រដាងគ្របដណ្តប់ចំពោះសត្វលោក ដោយមេត្តាករុណារកសាស្តាណាមកប្រដូចឱ្យស្មើគ្នាឡើយ ។

✧

✧ ✧

www.elibraryofcambodia.org

## ភាគអវសាន

ពុទ្ធប្រវត្តិដែលខ្ញុំព្រះករុណាខ្ញុំបាទបានសរសេរមកនេះ បានចប់ដោយសង្ខេបតែប៉ុណ្ណេះ គឺតាំងពីអតីតកាលដែលហៅថា ទូរេនិទាន រហូតទល់ពេលព្រះអង្គចូលបរិនិព្វាន និងការបូជាសព ព្រមទាំងការចែកព្រះបរមសារីរិកធាតុរបស់ព្រះអង្គ នៅគ្រប់ទិសទី ដោយសព្វគ្រប់ ។ ប៉ុណ្ណេះឃើញថាអាចនាំឱ្យព្រះសង្ឃ គ្រហស្ថជាពុទ្ធបរិស័ទ យកទៅអានសិក្សាបានល្មមដែរហើយ ប៉ុន្តែ ខាងផ្នែកអនុពុទ្ធប្រវត្តិរបស់សាវ័កសំខាន់ៗ ចំនួន ៨០ អង្គ នោះពុំទាន់ចប់នៅឡើយ ។ ប្រវត្តិសាវ័កសំខាន់ៗ ដែលខ្ញុំព្រះករុណាខ្ញុំបាទបានសរសេរក្នុងសៀវភៅនេះ បានតែ ៤២ អង្គ ប៉ុណ្ណោះ នៅសល់ ៣៨ អង្គទៀត ព្រមទាំងសាវិកា គឺភិក្ខុនីសំខាន់ៗ ដូចនាងបជាបតិគោតមី. ខុជ្ជុត្តរាជាដើម ដែលមិនទាន់បានសរសេរ ដោយហេតុថា កុំឱ្យសៀវភៅនេះមានកម្រាសច្រើនហួសប្រមាណពេក ។ ឯសាវ័កចំនួន ៣៨ អង្គទៀតនោះគឺ :

៤៣. ព្រះសោណកោឡិវិត្ថេរ ( ប្រារព្ធសេចក្តីព្យាយាម )

៤៤. ព្រះរដ្ឋបាលត្ថេរ ( អ្នកចេញបួសដោយសទ្ធា )

៤៥. ព្រះបិណ្ឌោលភារទ្វាជ ( បន្លឺសីហនាទ )

៤៦. ព្រះមហាបន្ថកត្ថេរ ( ចំរើនបញ្ញាភាវនា )

៤៧. ព្រះចុល្លបន្ថកត្ថេរ (ស្ទាត់ជំនាញក្នុងមនោមយិទ្ធិវិជ្ជា)

www.elibraryofcambodia.org

៤៨- ព្រះសោណកុដិកណ្ណត្ថេរ (សំដែងធម្មទេសនាដោយវាចាពិរោះ)

៤៩- ព្រះវក្កលិត្ថេរ ( សទ្ធាវិមុត្តិ )

៥០- ព្រះវង្គីសត្ថេរ ( មានបញ្ញាបដិភាណ ឆ្លាតចងបទគាថា )

៥១- ព្រះកុមារកស្សបត្ថេរ ( ចិត្តកថា )

៥២- ព្រះមហាកោដ្ឋិតត្ថេរ ( បែកធ្លុះធ្លាយក្នុងបដិសម្ភិទាញាណទាំង ៤ )

៥៣- ព្រះសោភិតត្ថេរ ( បុព្វេនិវាសញ្ញា )

៥៤- ព្រះនន្ទកត្ថេរ ( ឱ្យឱវាទដល់នាងភិក្ខុនី )

៥៥- ព្រះមហាកប្បិនត្ថេរ ( ឱ្យឱវាទដល់ភិក្ខុ )

៥៦- ព្រះសាគតត្ថេរ (ឈ្លាសវៃក្នុងការចូលតេជោកសិណសមាបត្តិ )

៥៧- ព្រះឧបសេនត្ថេរ ( នាំមកនូវសេចក្តីជ្រះថ្លា )

៥៨- ព្រះរេវតខទិរវនិយត្ថេរ ( ស្ថិតនៅក្នុងព្រៃ )

៥៩- ព្រះសីវលិត្ថេរ ( មានលាភច្រើន )

៦០- ព្រះពាហិទារុចិយត្ថេរ ( ខិប្បាភិញ្ញា )

៦១- ព្រះពាកុលត្ថេរ ( មានអាពាធតិច )

www.elibraryofcambodia.org

៦២. ព្រះទព្វមល្លបុត្តត្ថេរ ( រៀបចំក្រាលអាសនៈ )

៦៣. ព្រះសុភូតតិត្ថេរ ( អរណវិហារនិងជាទក្ខិណេយ្យបុគ្គល )

៦៤. ព្រះកង្ខារេវតត្ថេរ ( ត្រេកអរក្នុងឈានសមាបត្តិ )

៦៥. នាលកត្ថេរ ( បំពេញមោនេយ្យបដិបត្តិ )

៦៦. ព្រះអង្គុលិមាលត្ថេរ ( សាមិបរិភោគ )

៦៧. ព្រះភគុត្ថេរ

៦៨. ព្រះកិម្ពិលត្ថេរ

៦៩. ព្រះលកុណ្ឌកភទ្ទិយត្ថេរ ( វាចាពិរោះ )

៧០. ព្រះកុណ្ឌធានត្ថេរ ( ចាប់ស្លាកជាលើកដំបូង )

៧១. បិលិន្ទវច្ឆត្ថេរ ( បានជាទីស្រឡាញ់ពេញចិត្តរបស់ពួកទេវតា )

៧២. ព្រះឧទាយិត្ថេរ

៧៣. ព្រះឱបវាណត្ថេរ

៧៤. ព្រះមេឃិយត្ថេរ

៧៥. ព្រះនាគិតត្ថេរ

៧៦. [illegible]ត្ថេរ

៧៧. ព្រះយសោជត្ថេរ

www.elibraryofcambodia.org

៧៨- ព្រះសុភិយត្ថេរ

៧៩- ព្រះសេលត្ថេរ

៨០- ព្រះមហាបន្ថកត្ថេរ ។

ប្រវត្តិព្រះសាវ័កទាំង ៣៨ អង្គក្រោយនេះសូមព្រះករុណា និងលោកអ្នកនាងទាំងឡាយ រកមើលក្នុងអនុពុទ្ធប្រវត្តិ ឬទិទាន មហាសាវ័កផងចុះ ។

នៅទីបំផុតនេះ ខ្ញុំព្រះករុណាខ្ញុំបាទ សូមលើកកុសលរាសី ថ្វាយប្រគេនជូនចែក ចំពោះពុទ្ធបរិស័ទទាំងឡាយក្នុងកម្ពុជរដ្ឋ សូមបានសេចក្តីសុខសន្តិភាពតរៀងទៅ តាមសេចក្តីប្រាថ្នា ។

សូមព្រះពុទ្ធសាសនាបានរុងរឿងជានិច្ចនិរន្តរ៍តទៅ រហូតគ្រប់ ៥ ពាន់ព្រះវស្សា ។

ភ្នំពេញ ថ្ងៃទី ៣ កក្កដា ១៩៦៩

**សែម-សូរ**

សញ្ញាប័ត្រពុទ្ធិកឧត្តមសិក្សា ១៩៦៣

បរិញ្ញាប័ត្រអក្សរសាស្ត្រ ១៩៦៩

www.elibraryofcambodia.org

**មានជាវដុំ និង ជាវរាយ**

នូវសៀវភៅធម៌គ្រប់មុខគ្រប់ប្រភេទ នៅ

" **បណ្ណាគារត្រៃរតន៍** " ផ្ទះលេខ ១៣៦ អឺ០

វិថីខេមរភូមិន្ទ រាជធានីភ្នំពេញ

ទូរស័ព្ទលេខ : ០១២ ៧០៦ ៥៨១

សូមនិមន្ត និង អញ្ជើញដោយមេត្រីភាព ។

www.elibraryofcambodia.org